ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# ភាសាខ្មែរ

៨



គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា

# ភាសាខ្មែរ

## ថ្នាក់ទី ៨

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៥៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

**គណៈកម្មការនិពន្ធ** លោក យិន ធី លោក ព្រៃ សំបូរ
លោកស្រី ម៉ៅ តាន់ណារី លោក យ៉ង់ កំស៊ាន

**អ្នកវាយអត្ថបទ** លោក សេង តុងបុត្តា

**វិចិត្រករ** លោក យុន សុវណ្ណរិទ្ធី

**អ្នករៀបរៀង** លោកជំទាវ ទន់ សាអ៊ីម

**អ្នករចនាទំព័រ** លោក គង់ ចិត្រា

**គណៈកម្មការពិនិត្យ** លោក នៅ ស៊ុន លោកស្រី គាត ស៊ីជឿន

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី **ក្រសួងអប់រំ យុវជន និងកីឡា** តាមប្រកាសលេខ ២២២៩ អយក.ប្រក. ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០១០ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ ២០១៦

ISBN 9-789-995-001-216

# អារម្ភកថា

សៀវភៅភាសាខ្មែរថ្នាក់ទី ៨នេះ បាននិពន្ធឡើងតាមកម្មវិធីសិក្សាថ្មីរបស់ក្រសួង អប់រំ យុវជន និងកីឡា ។ សៀវភៅនេះបន្តពង្រឹងនិងពង្រីកសមត្ថភាពអាន និយាយ ស្តាប់ និងសរសេរ ពីថ្នាក់ទី ៧នៃមធ្យមសិក្សាបឋមភូមិ ឱ្យកាន់តែប្រសើរឡើងថែមទៀត ។

សៀវភៅនេះបង្ហាញអំពីប្រធានបទសំខាន់ៗស្តីពី មោទនភាពជាតិ អត្តសញ្ញាណជាតិ ការគោរពបូជា ការទទួលស្គាល់ការពិត ភាពជាពលរដ្ឋល្អ ។ល ។ ដើម្បីរួមចំណែកអភិវឌ្ឍគំនិត ប្រាជ្ញា ស្មារតី និងការទទួលខុសត្រូវរបស់កុលបុត្រ កុលធីតាខ្មែរចំពោះជាតិមាតុភូមិ ។ មេរៀន នៅក្នុងសៀវភៅនេះនឹងជួយអ្នកសិក្សាឱ្យទទួលបានចំណេះដឹងនិងបំណិនកាន់តែជ្រាលជ្រៅនិង ច្បាស់លាស់ តាមរយៈអត្ថបទអក្សរសិល្ប៍ប្រជាប្រិយ អក្សរសិល្ប៍បុរាណ អក្សរសិល្ប៍ទំនើប អត្ថបទអត្ថាធិប្បាយ ល្ខោន ចម្រៀងរបាំ វេយ្យាករណ៍ និងគំរូសំណេរផ្សេងៗដូចជា បំពេញ ទម្រង់បែបបទផ្សេងៗ តាក់តែងរឿង តែងសេចក្តី អត្ថបទព័ត៌មាន វិភាគអត្ថបទជាដើម ។

ជារួមខ្លឹមសារ បំណិន សំណួរ លំហាត់ ការសិក្សាពាក្យគន្លឹះ នៅក្នុងសៀវភៅនេះ នឹង ជំរុញឱ្យអ្នកមានការអភិវឌ្ឍផ្នែកបំណិន ចំណេះដឹងកាន់តែល្អប្រសើរថែមទៀតលើការសិក្សា ភាសាខ្មែរ ដើម្បីតម្រង់ទិសការសិក្សាអក្សរសិល្ប៍ អក្សរសាស្ត្រ និងវប្បធម៌អរិយធម៌ខ្មែរនៅថ្នាក់ បន្តទៀត ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅភាសាខ្មែរថ្នាក់ទី ៨ ថ្មីនេះនឹងក្លាយជាមិត្តដ៏ល្អរបស់ អ្នកជាពុំខាន ។

សូមឱ្យការសិក្សារបស់អ្នកទទួលបានជោគជ័យជានិច្ច ។

គណៈកម្មការនិពន្ធ

# បញ្ជីអត្ថបទ

ទំព័រ


១. មោទនភាព ............................................................ ១

២. ភាពស្មោះត្រង់ ........................................................ ២៧

៣. អធ្យាស្រ័យ ........................................................ ៥៣

៤. មិត្តភាព ............................................................ ៧៧

៥. ការគោរពខ្លួនឯង .................................................... ៩៧

៦. ការគោរពច្បាប់ .................................................... ១១៩

៧. ការទទួលខុសត្រូវ .................................................. ១៤១

៨. ការជឿជាក់ .......................................................... ១៦៥

៩. សេចក្ដីថ្លៃថ្នូរ ........................................................ ១៩១

១០. ឧត្តមភាព .......................................................... ២១១

មេរៀនទី
១

# មោទនភាព



ជនជាតិខ្មែរជាជាតិសាសន៍មួយសម្បូរទៅដោយកំណប់មហាសាលនៃសម្បត្តិវប្បធម៌និងសម្បត្តិធម្មជាតិដែលបន្សល់ទុកដោយបុព្វបុរសខ្លួន។ ចំពោះសម្បត្តិវប្បធម៌ បុព្វបុរសខ្មែរមានចំណេះវិជ្ជានិងទេពកោសល្យដ៏ប៉ិនប្រសប់គួរឱ្យស្ញប់ស្ញែង។ លោកបានកសាងប្រាង្គប្រាសាទប្រកបដោយក្បូរក្បាច់រចនាល្អប្រណីតឆ្លាក់ផ្ចិតផ្ចង់ជាប់លើផ្ទាំងថ្មនិងបង្កើតវត្តអារាម គម្ពីរក្បួនខ្នាត អក្សរសាស្ត្រ កំណាព្យ កាព្យឃ្លោង ទំនៀមទម្លាប់ប្រពៃណី ឧបករណ៍តន្ត្រី សិល្បៈ ព្រមទាំងសម្ភារៈប្រើប្រាស់គ្រប់យ៉ាង។ មរតកទាំងនោះសុទ្ធតែបានបង្កប់នូវមោទនភាពជាតិនិយមទុកឱ្យកូនខ្មែរជំនាន់ក្រោយខិតខំការពារនិងថែរក្សាឱ្យគង់វង្សស្ថិតស្ថេរ នោះទើបសក្តិសមជាកុលបុត្រកុលធីតាខ្មែរពិតប្រាកដ។

ដើម្បីឆ្លើយតបទៅនឹងមោទនភាពជាតិដូចខាងលើនេះ អ្នកនឹងបានសិក្សាពីការពិតឬការណ៍ មតិឬគំនិត តម្លៃអប់រំ របាយការណ៍សម្ភាសន៍ និងសញ្ញាដំលើ (ˆ)។

# ពិតកថា

នៅក្នុងសង្គមមនុស្សមានរឿងរ៉ាវជាច្រើន ដែលកើតមានជាបន្តបន្ទាប់តាមសភាពធម្មជាតិ ឬតាមបរិយាកាសនៃសង្គមណាមួយ ។ រឿងរ៉ាវទាំងនោះត្រូវបានគេលើកយកមកបរិយាយជាបន្តបន្ទាប់ ដែលជួនកាលអាចឃ្លាតចាកពីការពិតទៀតផង ។ ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអំពីពិតកថា ដែលជាការលើកឡើងពីហេតុការណ៍ពិតៗ ហើយត្រូវបានស្មេររៀបរៀងនិងចងក្រងដោយឥតបំភ្លៃ ដើម្បីជាប្រយោជន៍ដល់អ្នកជំនាន់ក្រោយសិក្សាស្រាវជ្រាវ ។

ពិតកថាមានច្រើនប្រភេទ ដូចជា ជីវប្រវត្តិកថា ស្វ័យជីវប្រវត្តិកថា បទសាកល្បង (ឧស្សាហកថា) ប្រវត្តិសាស្ត្រ របាយការណ៍ កំណត់ហេតុ ព្រឹត្តិការណ៍ជាក់ស្តែងជាដើម ។

ចូរអ្នកអានឧទាហរណ៍ខាងក្រោមនេះ ដែលជាអត្ថបទមួយនៃពិតកថា :

លោកតាភិរម្យង៉ុយមាននាមដើម អ៊ុក អ៊ូ តែមាតាបិតាលោកហៅក្រៅថា ង៉ុយ ក៏ជាប់នាមនេះរហូតមក ។ ឪពុកលោកនាម អ៊ុក ធ្វើមេឃុំនៅឃុំកំបូលស្រុកភ្នំពេញ (សព្វថ្ងៃជាស្រុកអង្គស្នួល) ខេត្តកណ្តាល ។ មាតាលោកជាកូនរបស់ចៅពញាម៉ុក មេឃុំស្ពានថ្ម នៅស្រុកនិងខេត្តជាមួយគ្នា ។ កាលពីកុមារ ឪពុកលោកបាននាំលោកទៅរៀនអក្សរសាស្ត្រក្នុងសំណាក់លោកគ្រូចៅអធិការវត្តអង្គបឹងចក នៅស្រុកកំណើតរបស់លោក ។ បន្ទាប់មកលោកបានបួសជាសាមណេររួចរៀនប្រែគម្ពីរបាលី ។ អាយុ ២១ឆ្នាំ លោកបានបំពេញឧបសម្បទាភិក្ខុ ហើយរៀនប្រែព្រះត្រៃបិដកនិងរៀនវិបស្សនាកម្មដ្ឋានទៀតផង ។ ក្រោយពេលលាចាកសិក្ខាបទ លោកបានរៀបអាពាហ៍ពិពាហ៍នៅឃុំបែកចាន ស្រុកភ្នំពេញរួចប្រកបរបរជាអ្នកស្រែធម្មតា ។ ទោះជាគ្រហស្ថក៏ដោយ លោកតែងទទួលការអញ្ជើញពីអ្នកស្រុកឱ្យទៅទេសនាក្នុងពិធីបុណ្យផ្សេងៗ ដូចព្រះសង្ឃដែរ ។ ដោយលោកពូកែខាងលើកកំណាព្យនិងមានវោហារប៉ិនប្រសប់ លោកក៏ក្លាយទៅជាអ្នកចម្រៀងសាដៀវមួយរូបដែលប្រជាពលរដ្ឋនិយមចូលចិត្ត ។ ចម្រៀងរបស់លោកត្រូវបានអ្នកស្រាវជ្រាវជនជាតិបារាំងចម្លងយកទៅបោះពុម្ពចំនួនបួនច្បាប់គឺ ច្បាប់ល្បើកថ្មី សេចក្តីរំលឹកដាស់តឿន ច្បាប់កេរកាលថ្មី និងច្បាប់ទូន្មានជនប្រុសស្រី ។ លោកទទួលអនិច្ចកម្ម នៅខែមិគសិរ គ.ស. ១៩៣៦ ក្នុងជន្មាយុ ៧១ឆ្នាំ ។ មរណភាពរបស់លោកធ្វើឱ្យអ្នកស្រុកជិតឆ្ងាយមានសេចក្តីសោកស្តាយយ៉ាងក្រៃលែង ។

*(ដកស្រង់ចេញពីអ្នកនិពន្ធខ្មែរភិរម្យ ង៉ុយ ឆ្នាំ ១៩៦៦)*

អត្ថបទខាងលើនេះជាប្រភេទជីវប្រវត្តិកថា ព្រោះអ្នកនិពន្ធបានសរសេររៀបរាប់អំពីជីវិតពិតរបស់លោកតាភិរម្យង៉ុយ មាននាមដើម អ៊ុក អ៊ូ។ ខាងក្រោមនេះជាជីវប្រវត្តិសង្ខេប :

- មាតាលោកតាភិរម្យង៉ុយជាកូនរបស់ចៅពញា ម៉ុក មេឃុំស្ពានថ្ម នៅស្រុកភ្នំពេញខេត្តជាមួយគ្នា។
- កាលពីកុមារ ឪពុកលោកបាននាំលោកទៅរៀនអក្សរសាស្ត្រក្នុងសំណាក់លោកគ្រូចៅអធិការវត្តអង្គបឹងចកនៅស្រុកកំណើតរបស់លោក ។
- លោកបានបួសជាសាមណេររួចរៀនប្រែគម្ពីរបាលី ។
- អាយុ ២១ឆ្នាំ លោកបំពេញឧបសម្បទាភិក្ខុរៀនប្រែព្រះត្រៃបិដកនិងរៀនវិបស្សនាកម្មដ្ឋាន ។
- ក្រោយពេលបានចាកសិក្ខាបទហើយ លោកបានរៀបអាពាហ៍ពិពាហ៍នៅឃុំបែកចាន ស្រុកភ្នំពេញ ប្រកបរបរជាអ្នកស្រែចម្ការ ។
- ទោះនៅជាគ្រហស្ថ លោកតែងទទួលការអញ្ជើញពីអ្នកស្រុកឱ្យទៅទេសនាក្នុងពិធីបុណ្យផ្សេងៗ ។
- លោកពូកែខាងលើកកំណាព្យភ្លាមៗនិងមានវោហារប៉ិនប្រសប់ លោកក៏ក្លាយជាអ្នកចម្រៀងសាដៀវ ។
- ចម្រៀងរបស់លោកត្រូវបានអ្នកស្រាវជ្រាវជនជាតិបារាំងម្នាក់ថតសំឡេងចម្លងយកទៅបោះពុម្ពចំនួនបួនច្បាប់ គឺច្បាប់ល្បើកថ្មី សេចក្តីរំលឹកដាស់តឿន ច្បាប់កេរកាលថ្មី និងច្បាប់ទូន្មានជនប្រុសស្រី ។
- លោកទទួលអនិច្ចកម្មនៅខែមិគសិរ គ.ស. ១៩៣៦ ក្នុងជន្មាយុ ៧១ឆ្នាំ ។

*ពិតកថា (ជីវប្រវត្តិ) ជាប្រភេទរឿងពិតដែលបង្ហាញពី :*

- *ស្ថានភាពជីវិតពិតរបស់បុគ្គលនិងស្នាដៃ*
- *កាលបរិច្ឆេទពិតដែលទាក់ទងទៅនឹងការរស់នៅជាក់ស្តែង*
- *ស្ថានភាពគ្រួសារពិតឆ្លងកាត់ដំណាក់កាលនីមួយៗ*
- *ឈ្មោះពិតរបស់បុគ្គលផ្ទាល់ គ្រួសារ និងញាតិសន្តាន*
- *ប្រវត្តិនៃការងារ មានកាលបរិច្ឆេទពិតប្រាកដ កន្លែងពិតជាក់ស្តែង*
- *កាលបរិច្ឆេទនៃថ្ងៃកើត ថ្ងៃស្លាប់ សុទ្ធតែពិតប្រាកដទាំងអស់ ។*

## លំហាត់

ចូរអ្នកអានអត្ថបទខាងក្រោមនេះ ហើយកំណត់អត្ថបទណាមួយជាជីវប្រវត្តិកថា ៖

ក. ព្រះអង្គប្រសូតនៅថ្ងៃអាទិត្យ ១៥កើត ខែបុស្ស ឆ្នាំរោង ចត្វាស័ក ព.ស. ២៤៣៥ គ.ស. ១៨៩២ នៅភូមិឧដុង្គ ខេត្តកំពង់ស្ពឺ។ បិតានាម ហុក សេង ហៅហួត មាតានាម ង៉ែត។ ព្រះជន្មបាន ៧ឆ្នាំទៅរៀនអក្សរសាស្ត្រ លេខនព្វន្តក្នុងសំណាក់ព្រះធម្មឃោសាចារ្យ មាស។ ព្រះជន្ម ១៣ឆ្នាំបួសជាសាមណេរនៅក្នុងសំណាក់ព្រះធម្មលិខិត ស៊ូ។ ព្រះជន្ម២១វស្សា នៅឆ្នាំជូត ព.ស. ២៤៥៦ គ.ស. ១៩១២ បានឧបសម្បទាក្នុងពុទ្ធសីមាវត្តឧណ្ណាលោម ក្នុងសំណាក់សម្ដេចព្រះសង្ឃរាជព្រះនាម និល ទៀងជាព្រះឧបជ្ឈាយ៍។ ព្រះជន្មាយុបាន ៥៧វស្សា នៅឆ្នាំជូត ព.ស. ២៤៩២ គ.ស. ១៩៤៨ ព្រះអង្គបានទទួលសមណសក្តិជាព្រះពោធិវង្ស។ ព្រះជន្មាយុបាន ៧៣វស្សា នៅឆ្នាំរោង ព.ស. ២៥០៨ គ.ស. ១៩៦៩ ព្រះអង្គបានទទួលសមណសក្តិជាសម្ដេចព្រះពោធិវង្សតាមព្រះរាជក្រឹត្យលេខ២៤ រ.វ ចុះថ្ងៃទី ២៤ កក្កដា ១៩៦៤។ ព្រះជន្មាយុ ៧៨វស្សា នៅឆ្នាំរកា ព.ស. ២៥១៣ គ.ស. ១៩៦៩ ព្រះអង្គបានទទួលសមណសក្តិជាសម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជគណៈមហានិកាយ ពីប្រធានសភាជាតិ។ ក្នុងឆ្នាំថោះ ព.ស. ២៥១៩ គ.ស. ១៩៧៥ ព្រះអង្គបានចូលទិវង្គតក្នុងព្រះជន្មាយុ ៨៤វស្សា។

*(ដកស្រង់ចេញពីព្រះរាជប្រវត្តិសម្ដេចព្រះសង្ឃរាជ រៀបរៀងដោយភិក្ខុបញ្ញាវិមលោ លឹម វាសនា ២០០៤)*

ខ. កាលពីព្រេងនាយ មានបុរសម្នាក់ចង់បានប្រពន្ធក៏ទៅដណ្ដឹងកូនគេម្នាក់។ ម្ដាយឪពុកខាងស្រីបង្គាប់ "បើចង់បានកូនយើងជាប្រពន្ធ យើងចងអ្នកត្រាំទឹកបីយប់ បើទ្រាំបាន ទើបយើងឱ្យកូនយើង"។ បុរសនោះក៏ឱ្យគេចងត្រាំទឹក។ លុះត្រាំទឹកបានពីរយប់ បុរសនោះឃើញភ្លើងឆេះលើកំពូលភ្នំ។ គាត់ក៏លើកដៃឡើងដូចអាំងភ្លើង។ គេមកមើលឃើញបុរសនោះ លើកដៃអាំងភ្លើងក៏យកលេសមិនលើកកូនគេជាប្រពន្ធឡើយ។ បុរសនោះខឹងណាស់ទៅប្ដឹងចៅក្រម។ ចៅក្រមឱ្យកោះម្ដាយឪពុកនោះជំនុំជម្រះ។ ចៅក្រមទទួលយកសំណូកក៏កាត់សេចក្ដីថា "ចៅឯងត្រូវចាញ់គេ ហើយមិនត្រូវបានកូនក្រមុំនេះទេ បើដូច្នេះចៅឯងទៅរៀបបាយមកឱ្យយើងស៊ី"។ ឯចៅនោះឮគេថាមិនត្រូវបានកូនក្រមុំជាប្រពន្ធទេ ហើយត្រូវគេប្រើទៅរៀបបាយមកឱ្យគេដូច្នេះ ក៏តូចចិត្តណាស់ដើរបណ្ដើរយំបណ្ដើរទៅប្រទះសុភាទន្សាយ។ សុភាទន្សាយសួរ "ហេតុអ្វីបានជាបងយំ ?"។ បុរសនោះប្រាប់រឿងរ៉ាវតាមដំណើរសព្វគ្រប់ប្រការ។ សុភាទន្សាយសួរទៀត "គេឱ្យបងឯងទៅណា ?" បុរសនិយាយ "ឥឡូវគេប្រើឱ្យទៅរៀបបាយ"។ សុភាទន្សាយ "អើ! បងឯងរៀបរួចមកយកអញទៅផង អញទៅជួយជុំនុំជម្រះឱ្យ ប៉ុន្តែបើបងឯងរៀបបាយមក ស្លកុំដាក់អំបិលប្រហុក។ ប្រហុកដាក់តែក្បែរខាងនោះ ស្លតែត្រីនិងបន្លែបានហើយ"។ បុរសនោះឮសុភាទន្សាយប្រាប់ដូច្នេះអរណាស់ ខំទៅរៀបបាយដូចបង្គាប់របស់សុភាទន្សាយ។ ចៅក្រមឃើញសុភាទន្សាយមកក៏សួរ "បងទន្សាយមករកអ្វី ?"។ [...]

*(ដកស្រង់ និងកែសម្រួលចេញពីរឿងព្រេងខ្មែរភាគ ១)*



# សម្តេចសង្ឃរាជជួនណាត



ព្រះសង្ឃរាជជួនណាត

## ក. សិក្សាពាក្យគន្លឹះ

- វែកពុន (កិ) : ទទួលរ៉ាប់រងការងារ ឬទទួលបន្ទុកការងារណាមួយដ៏ធ្ងន់ធ្ងរ ។
- ឆ្លូកឆ្លាក់ (កិ) : ខ្មីឃ្មាត ប្រឹងប្រែងបំពេញកិច្ចការណាមួយ ។
- បារាំងសែស (គុ) : ដែលជាជាតិបារាំង ។
- ហ្លួង (ន) : ព្រះរាជា ។
- ចូកចាំង (កិ) : ពង្រាប ឬចូកឆាយ ឈូសឆាយឱ្យស្មើ ។
- ប្រសូត (កិ) : សម្រាលកូន ។
- ព្រះជន្មាយុ (ន) : អាយុ ជីវិត ឆ្នាំ ។
- ព្រះពុទ្ធឃោសាចារ្យ (ន) : គ្រូអាចារ្យដែលបានបង្ហាត់បង្រៀនសិស្ស ។
- ឧបសម្បទា (ន) : ការបំបួសសាមណេរឱ្យបានជាភិក្ខុ ។
- គន្ថធុរៈ (ន) : ធុរៈផ្នែកខាងគម្ពីរបាលី កិច្ចការរៀនសូត្រខាងបរិយត្តិជាគូនឹងវិបស្សនាធុរៈ ។

- ព្រះសង្ឃរាជ (ន) : សម្ដេចសង្ឃ ។
- ប្រាស្រ័យ (ន) : ការស្រឡាញ់រាប់អាន សេចក្ដីគោរព ដំណើរអធ្យាស្រ័យ ។
- សាមណេរ (ន) : បព្វជិត ពុទ្ធសាសនិកអ្នកកាន់សីល ១០ លោកនេន ។

## ខ. អភិវឌ្ឍន៍បំណិន

ស្គាល់ពីបទកំណាព្យនិងសេចក្ដីលំអិតក្នុងអត្ថបទ យល់ពីខ្លឹមសារនៃអត្ថបទកាព្យ យល់ពីប្រភេទនៃរឿងពិត ឬរឿងប្រឌិត ចេះស្វែងយល់ពីលក្ខណសម្បត្តិនៃវរជន ស្គាល់ពីបំណងរបស់អ្នកនិពន្ធដែលបានចងក្រងជីវប្រវត្តិវរជនណាមួយ ។

## គ. អត្ថបទ

សម្ដេចព្រះសង្ឃរាជទ្រង់ប្រសូតនៅថ្ងៃអង្គារ ១១រោច ខែផល្គុន ឆ្នាំវក ឆស័ក ព.ស.២៤២៧ ត្រូវនឹងថ្ងៃទី ១១ ខែមីនា គ.ស.១៨៨៣នៅភូមិកំរៀង សង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ សម្ដេចមានព្រះជាតិក្នុងត្រកូលកសិករ ព្រះមាតាសម្ដេចនាមយក់ ព្រះបិតានាមព្រហ្មជួន ។ គ្រួសារនេះមានបុត្រតែពីរនាក់ គឺអង្គសម្ដេចព្រះសង្ឃរាជនិងលោកអ្នកឧកញ៉ាសោភណមន្ត្រីជួននុតជាព្រះអនុជនៃសម្ដេចព្រះសង្ឃរាជ ។ កាលសម្ដេចនៅកុមារភាពមានព្រះជន្មាយុរវាង ១២វស្សា ព្រះមាតាបិតាបាននាំយកទៅផ្ញើផ្ដាក់ឱ្យរៀនសូត្រអក្សរសាស្ត្ររបស់ជាតិក្នុងសំណាក់លោកគ្រូសូត្រស្ដាំនាម កែវ ម៉ន វត្តពោធិព្រឹក្ស ហៅពោលឿ សង្កាត់រលាំងកែន ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។

លុះមានព្រះជន្មាយុ១៤វស្សា សម្ដេចបានបួសជាសាមណេរក្នុងថ្ងៃ១៥កើត ខែពិសាខ ឆ្នាំច សំរិទ្ធស័ក ព.ស.២៤៤១ គ.ស.១៨៩៧ នៅបំពេញកិច្ចសិក្សានាវត្តពោធិព្រឹក្សអស់រយៈកាល ២ ឆ្នាំ ទើបចេញពីវត្តពោធិព្រឹក្សទៅរៀនសូត្រព្រះបរិយត្តិធម៌ ឯវត្តឧណ្ណាលោមក្រុងភ្នំពេញក្នុងសំណាក់ព្រះគ្រូទេពសោ នាកុដិថែវប្រែបកំពែងខាងជើង ក្នុងព.ស. ២៤៤៣ គ.ស. ១៨៩៩ ។ លុះបានព្រះជន្មាយុគម្រប់ ២១វស្សា សម្ដេចបានទ្រង់និមន្តត្រឡប់ទៅសូមឧបសម្បទាជាភិក្ខុក្នុងវត្តពោធិព្រឹក្សដែលជាវត្តដើមវិញ ដោយមានព្រះតេជព្រះគុណព្រះពុទ្ធឃោសាចារ្យម៉ាកេត សុវណ្ណប្បញ្ញោជាព្រះឧបជ្ឈាយ៍ កាលលោកនៅជាចៅអធិការវត្តពោធិព្រឹក្សមានព្រះតេជព្រះគុណ កែម៉ន មិស្សនាគោ ជាគ្រូសូត្រស្ដាំនិងព្រះតេជគុណ អ៊ុមខឹម តិក្ខប្បញ្ញោ ជាគ្រូសូត្រឆ្វេងសូត្របំពេញកិច្ចឧបសម្បទា នៅថ្ងៃ ១៥កើត ខែជេស្ឋ ឆ្នាំរោងឆស័ក ព.ស. ២៤៤៨ គ.ស. ១៩០៤ ។ សម្ដេចទ្រង់ទទួលព្រះនាមបញ្ញត្តិថា ជោតញ្ញាណោ លុះទ្រង់បំពេញឧបសម្បទាជាភិក្ខុភាពរួចហើយ ទ្រង់ក៏និមន្តត្រឡប់មកគង់នៅវត្តឧណ្ណាលោមទទួលការសិក្សាគន្ថធុរៈបន្តទៀត ។

សម្ដេចព្រះសង្ឃរាជមានសេចក្ដីព្យាយាមប្រកបដោយថាមពលដ៏ក្លៀវក្លាក្នុងការសិក្សាទាំងផ្នែកភាសាបាលីទាំងផ្នែកភាសាឯទៀត មានភាសាបារាំងជាដើម ។ ការសិក្សារបស់ព្រះសង្ឃរាជ មានជោគជ័យប្រសើរណាស់ បណ្ដាលោកអ្នកសិក្សាក្នុងសម័យនោះជំនាន់ជាមួយគ្នានឹងសម្ដេចព្រះសង្ឃរាជ ឃើញតែសម្ដេចព្រះសង្ឃរាជទេ ដែលរៀនចម្រើនលូតលាស់មានល្បឿនឈ្នះលោកឯទៀត ។ សម្ដេចចាប់រៀនដំបូងមេសូត្រប្រែមូលកច្ចាយនៈនិងគម្ពីរធម្មបទពីព្រះពុទ្ធឃោសាចារ្យព្រះនាមម៉ាកេត ដែលជាព្រះឧបជ្ឈាយ៍នៃសម្ដេចព្រះសង្ឃរាជ ។ សម្ដេចព្រះសង្ឃរាជពេលដែលទ្រង់រៀនវិជ្ជាណាមួយមានបាលីជាដើម គឺរៀនដោយយកព្រះទ័យទុកដាក់ ខំប្រឹងប្រែងឥតមានបន្ធូរបន្ថយក្នុងការសិក្សានោះឡើយ ។

សម្ដេចទ្រង់ទទួលការសិក្សាដោយឆន្ទៈដ៏មានកម្លាំងមែនទែន ពុំសិក្សាវិជ្ជាណាមួយដោយលេងៗទេ ។ វិជ្ជាខាងភាសាបាលី ភាសាសំស្ក្រឹត និងភាសាបារាំងសុទ្ធតែវិជ្ជាប្រកបដោយវេយ្យាករណ៍ហ្មត់ចត់ជ្រាលជ្រៅ លំបាករៀនលំបាកយល់ណាស់ ប៉ុន្តែសម្ដេចអាចរៀនអាចយល់ច្បាស់លាស់ដោយឆាប់រហ័សគួរឱ្យកោតសរសើរពន់ពេកណាស់ ។ ព្រះអង្គទ្រង់ចេះដឹងយល់ធ្លុះធ្លាយពីវេយ្យាករណ៍គ្រប់ភាសា ដែលមានវេយ្យាករណ៍បាលីសំស្ក្រឹតជាដើម ។ ទាំងអក្សរសាស្ត្ររបស់ជាតិ ទាំងពាក្យពេចន៍ក្នុងផ្នែកវប្បធម៌បុរាណក៏សម្ដេចចេះចាំយល់ហេតុផលជាច្រើន ។ សម្ដេចបានរៀនភាសាសៀម ភាសាលាវ និងភាសាបារាំង ហើយអាចនិយាយប្រាស័យទាក់ទងនឹងជាតិសៀមជាតិលាវនិងជាតិបារាំងបាន ។ សម្ដេចឈ្លាសវៃប្រសប់ត្រាប់តាមសំឡេងភាសាដទៃៗឱ្យស្រដៀង ឬដូចភាសាជាតិដទៃទៀតបាន ។ ភាសាអង់គ្លេសនិងភាសាវៀតណាមក៏សម្ដេចបានរៀនអាចមើលសរសេរ និយាយប្រាស្រ័យបានច្រើនដែរ ។ ក្នុងកំលុងពេលដែលសម្ដេចកំពុងសិក្សាវិជ្ជាខាងបាលីក្នុងរវាង គ.ស. ១៩១០ ឃើញថាសម្ដេចមានព្រះកិត្តិសព្ទល្បីថា ព្រះថេរៈស្ទាត់ជំនាញពូកែខាងភាសាបាលី អាចនិយាយភាសាបាលីបានច្រើនជាងភិក្ខុសាមណេរឯទៀតដែលរៀនជាមួយគ្នាក្នុងសម័យនោះ ។

នៅព.ស.២៤៥៧ គ.ស.១៩១៣ សម្ដេចទ្រង់បានចូលប្រឡងដេញប្រយោគក្នុងព្រះឧបោសថរតនារាមវិហារព្រះកែវមរកត ចំពោះព្រះភ័ក្ត្រព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិបាន៤ប្រយោគ ដែលជាប្រយោគជាន់ខ្ពស់បំផុតក្នុងសម័យនោះ ។ ព.ស.២៤៥៩ គ.ស.១៩១៥សម្ដេចទ្រង់បានប្រឡងជាប់លេខ ២ ដោយបានទទួលការតែងតាំងជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ដែលសព្វថ្ងៃមានឈ្មោះថា ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ។ ក្រៅពីភាសាខ្មែរដែលសម្ដេចទ្រង់បានស្រាវជ្រាវយល់ឫសគល់ពិតប្រាកដ សម្ដេចបានសិក្សាភាសាបាលីអាចអានឬសន្ទនាតាមសំនៀងជាតិបរទេសបានទាំងអស់

គឺសំនៀងលង្កា ភូមា មន សៀម និងលាវ ឥតមានទើសទាក់ភ្លាំងភ្លាត់ឡើយ ។ នៅព.ស. ២៤៦៦ ត្រូវនឹង គ.ស. ១៩២៣ សម្ដេចកាលនៅជាព្រះគ្រូសង្ឃសត្ថាជាមួយនឹងសម្ដេចព្រះពោធិវង្ស ហួត តាតវជិរប្បញ្ញោកាលនៅជាព្រះគ្រូសង្ឃវិជ្ជាបានធ្វើជាសមណនិស្សិតនិមន្តទៅបំពេញវិជ្ជាខាងភាសាសំស្រ្កឹតនិងអក្សរសិលាចារឹកជាដើម នៅសាលាបារាំងសែសចុងបូព៌ាប្រទេសនាក្រុងហាណូយ វៀតណាមខាងជើង ក្នុងសំណាក់លោក លីហ្វីណូត៍ ជាតិបារាំងសែស ជាចាងហ្វាងសាលានេះ ។ នៅ ព.ស.២៤៦៣ គ.ស.១៩១៩ សម្ដេចទ្រង់បានធ្វើជាសមាជិកនៃក្រុមជំនុំតែងវចនានុក្រមខ្មែរ ដែលទ្រង់ជាលេខាធិការកាន់កិច្ចការផ្ទាល់លុះត្រាបានចប់ចុងចប់ដើម ។ នៅព.ស. ២៤៦៩ គ.ស. ១៩២៥ សម្ដេចបានធ្វើជាសមាជិកនៃក្រុមជំនុំពិនិត្យអក្ខរាវិរុទ្ធនៃសៀវភៅនានាដែលសាលាបាលីជាន់ខ្ពស់បោះពុម្ពផ្សាយ ។ ព.ស. ២៤៧០ គ.ស.១៩២៦ តមកជាច្រើនឆ្នាំ សម្ដេចទ្រង់បានទទួលការតែងតាំងនាមប្រយោគក្នុងការប្រឡងយកវិញ្ញាបនបត្របឋមសិក្សាខ្មែរនិងការប្រឡងយកសញ្ញាបត្របឋមសិក្សាជាន់ខ្ពស់បារាំងខ្មែរនៅក្រុងភ្នំពេញ ។ ព.ស. ២៤៧៤ គ.ស. ១៩២៧ សម្ដេចទ្រង់បានទទួលការតែងតាំងជាសមាជិកក្រុមជំនុំផ្ទៀងសម្រេចខាងវចនានុក្រមខ្មែរ ហើយសម្ដេចទ្រង់បានទទួលភារៈធ្វើវចនានុក្រមតែមួយព្រះអង្គឯងដរាបបានចប់សព្វគ្រប់បានបោះពុម្ពផ្សាយទាំងភាគ១ ភាគ ២ បាន ៥ គ្រាហើយ ។ ក្នុងឆ្នាំនោះ សម្ដេចបានទទួលការតែងតាំងជាសមាជិកនៃក្រុមអភិបាលជំនុំផ្ដាច់ឆ្នាំសម្រាប់បណ្ណាល័យកម្ពុជា ដែលសព្វថ្ងៃហៅថាវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ។ ក្នុងព.ស.២៤៧៤ គ.ស.១៩៣០ សម្ដេចទ្រង់បានទទួលការតែងតាំងក្នុងមុខតំណែងជាចាងហ្វាងរងនៃសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញ ។ ក្នុងឆ្នាំដដែលនោះ សម្ដេចបានទទួលការតែងតាំងជាសមាជិកជំនួយនៃក្រុមជំនុំខាងស្រាវជ្រាវជ្រើសរើសពាក្យពេចន៍ក្នុងផ្នែកនៃកវីនិពន្ធខ្មែរបុរាណ ដើម្បីប្រមូលបញ្ចូលពាក្យទាំងនេះទៅក្នុងវចនានុក្រមខ្មែរ ។ ព.ស. ២៤៧៧ គ.ស. ១៩៣៣ សម្ដេចទ្រង់បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំពិនិត្យសៀវភៅដែលក្រសួងសិក្សាធិការជាតិបោះពុម្ពផ្សាយ ។ ព.ស. ២៤៧៨ គ.ស. ១៩៣៤សម្ដេចទ្រង់បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំជ្រើសរើសពាក្យខ្មែរប្រៀបធៀបនឹងពាក្យបារាំងសម្រាប់ប្រើក្នុងការងាររាជការ ។ ក្នុងព.ស. ២៤៧៩ គ.ស. ១៩៣៥ សម្ដេចទ្រង់បានទទួលការតែងតាំងជាសាស្រ្តាចារ្យបង្រៀនភាសាបាលីសំស្រ្កឹតខ្មែរនិងលាវប្រចាំថ្នាក់ទីបញ្ចប់នៃមធ្យមសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិក្រុងភ្នំពេញ ។

លុះមកដល់ព.ស. ២៥៨៦ គ.ស. ១៩៤២ សម្ដេចទ្រង់បានទទួលឋានន្តរៈជាចាងហ្វាងសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញដែលសព្វថ្ងៃកែឈ្មោះជាពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។ នៅព.ស. ២៤៨៨

គ.ស. ១៩៤៤ សម្ដេចទ្រង់បានទទួលតំណែងជាចៅអធិការវត្តឧណ្ណាលោម ។ ព.ស.១៩៤៥ សម្ដេចទ្រង់បានទទួលនាទីជាអធិបតីនៃថេរសភា គឺក្រុមជំនុំជាន់ខ្ពស់របស់សង្ឃ ហើយព.ស. ២៤៩១ គ.ស. ១៩៤៧សម្ដេចទ្រង់បានទទួលនាទីជាអនុប្រធានគណៈកម្មការវប្បធម៌ផ្នែកអក្សរ "ក" នៃគណៈកម្មការធម្មវិន័យពិនិត្យការផ្សាយសៀវភៅសម្រាប់សាលាធម្មវិន័យក្នុងព្រះរាជាណាចក្រ ។ គ.ស. ១៩៦១ រហូតមកសម្ដេច ទ្រង់ប្រោសមេត្តាទទួលនិមន្តរបស់សមាគមខ្មែរ ធ្វើជាព្រះប្រធាន ក្នុងការសម្ភាសអក្សរសាស្ត្រដែលផ្សាយតាមវិទ្យុជាតិរៀងរាល់ថ្ងៃសុក្រ ។ នៅគ.ស. ១៩៦៨ ទ្រង់ទទួលឋានៈជាព្រះប្រធានគណៈកម្មការពិនិត្យអត្ថបទផ្សាយជារឿងខាងប្រវត្តិសាស្ត្រខ្មែរ ។ ក្នុងគ.ស. ១៩៦៩ ព្រះអង្គទទួលការតែងតាំងជាប្រធានគណៈកម្មការពិនិត្យនិងកំណត់អំពីន័យរបស់ទង់ជាតិខ្មែរ ។ [...]

*(ដកស្រង់ចេញពីព្រះរាជជីវប្រវត្តិសម្ដេចព្រះសង្ឃរាជ រៀបរៀងដោយភិក្ខុបញ្ញាវិមលោ លឹម វាសនា ២០០៤)*

## សំណួរ

១. តើសម្ដេចព្រះសង្ឃរាជ ប្រសូតនៅថ្ងៃណា ? ខែណា ? ឆ្នាំណា ? ហើយមានទីកន្លែងកំណើតនៅឯណា ? មានគោរមងារយ៉ាងដូចម្ដេច ?

២. តើស្នាដៃរបស់ព្រះអង្គណាមួយដែលមានប្រជាប្រិយភាពជាងគេនៅក្នុងសំណាក់អ្នកសិក្សារហូតមកដល់សព្វថ្ងៃនេះ ? ហេតុដូចម្ដេចបានជាអ្នកយល់យ៉ាងនេះ ?

៣. តើអត្ថបទដកស្រង់នេះ ជាប្រភេទអត្ថបទរឿងពិត ឬជារឿងប្រឌិត ? ហេតុអ្វី ?

៤. តើព្រះអង្គមានគុណសម្បត្តិអ្វីខ្លះ ចំពោះភាសាជាតិ ? ហេតុអ្វី ?

៥. តើកត្តាអ្វី ដែលនាំឱ្យព្រះអង្គមានស្មារតីពុះពារក្នុងការកសាងវចនានុក្រមខ្មែរ ?

៦. តាមរយៈសកម្មភាពព្យាយាមរបស់ព្រះអង្គ តើអ្នកមានអារម្មណ៍យ៉ាងដូចម្ដេចចំពោះបុព្វបុរសជាតិ ?

៧. ហេតុដូចម្ដេចបានជាអ្នកនិពន្ធចងក្រងជីវប្រវត្តិនេះឡើង ?

# សញ្ញាដំលើ ( ំ )

អ្នកធ្លាប់បានសិក្សាជាច្រើននូវសញ្ញាពិសេសក្នុងភាសាខ្មែរ ។ តទៅនេះ អ្នកនឹងបានសិក្សាសញ្ញាពិសេសមួយទៀតដែលខ្មែរយើងហៅថា សញ្ញាដំលើ ហើយបើតាមវចនានុក្រមរបស់សម្តេចសង្ឃរាជជួន ណាត ហៅថា " និគ្គហិត " ។

ចូរអ្នកសង្កេតឧទាហរណ៍ខាងក្រោមនេះ ៖

| ឧទាហរណ៍ | ស្រៈប្រកប | | ព្យញ្ជនៈប្រកប |
|---|---|---|---|
| | សញ្ញា | សូរ | |
| ចំ | | [ អ់ ] | ម > ◌ំ |
| កុំ | ◌ុ | [ អុ ] | ម > ◌ំ |
| កាំ | ◌ា | [ អា់ ] | ម > ◌ំ |
| ជុំ | ◌ុ | [ អ៊ុ ] | ម > ◌ំ |
| ទំ | | [ អ៊់ ] | ម > ◌ំ |

ឧទាហរណ៍ខាងលើនេះបានបញ្ជាក់ថា សញ្ញាដំលើប្រើជំនួស "ម" ប្រកបនឹងស្រៈខ្លី ។ គេអាចប្រើសញ្ញានេះ នៅលើស្រៈប្រកបគឺ

- ស្រៈកប់តួ
  - ស្រៈខ្លី [ អ់ ] ÷ ដំ | dɒm | ចំ | cɒm | ហំ | hɒm | ខំ | khɒm | ។
  - ស្រៈខ្លី [ អ៊់ ] ÷ ទំ | təm | ជំ | cəm | រំ | rəm | យំ | jəm | ។
- ស្រៈភ្ជាប់តួ
  - ស្រៈខ្លី [ អា់ ] ÷ ដាំ | dam | ចាំ | cam | ខាំ | kam | សាំ | sam | ។
  - ស្រៈខ្លី [ អុ ] ÷ ដុំ | dọm.| កុំ | kọm | សុំ | sọm | ខ្ញុំ | kɲọm | ។
  - ស្រៈខ្លី [ អ៊ុ ] ÷ ទុំ | tum | ជុំ | cum | ពុំ | pum |ឃុំ | khum | ។

ម្យ៉ាងវិញទៀតចំពោះសញ្ញានេះគេអាច ៖

## ក. ប្រកបនឹងស្រៈ [ អ៊ី ] → អ៊ាំ

*ឧទាហរណ៍ :* ជាំ | coa:m | មាំ | moa:m | រាំ | roa:m |

## ១. ចំពោះពាក្យក្លាយពីបាលីសំស្ក្រឹត [ ំ ]

- [ អាំង ] : + សំយោគ [ សាំងយោគ ] [ saŋ jok ] ។
- [ អាំង ] : + សំស្ក្រឹត [ សាំងស្ក្រឹត ] [ saŋ sak ] [ krœt ] ។
- [ អំម ] : + សំរិទ្ធី [ សំម រិត ធី ] [ sam rit ] [ thi: ] ។
- [ អំម ] : + សំស្ការ [ សំម ស្កា ] [ sam ska: ] ។

ដូចនេះ សញ្ញាដំលើ គេអាចប្រើ :

- លើស្រៈប្រកប គឺស្រៈកប់តួ និងស្រៈភ្ជាប់តួមានស្រៈ "អ់" ខ្លី [ ɒ ] ស្រៈ "អា់" ខ្លី [ a ] ស្រៈ "អ៊ា់" ខ្លី [ iə ] ស្រៈ "អ៊ី់" ខ្លី [ ə ] ស្រៈ "អ៊ុ" ខ្លី [ u ] ស្រៈ "អ៊ំ" ខ្លី [ oa ] ស្រៈ "អុ" ខ្លី [ o̞ ] ។
- ប្រកបនឹងស្រៈ [អ៊ំ] ។
- កត់សូរក្នុងពាក្យក្លាយពីបាលីសំស្ក្រឹត ។

## លំហាត់

ចូរអ្នកដកស្រង់ពាក្យក្នុងវគ្គនេះ ដែលមានសញ្ញាដំលើប្រើនៅលើស្រៈប្រកបគឺ

- ស្រៈកប់តួនិងស្រៈភ្ជាប់តួ
- អាចប្រកបនឹងស្រៈ [អ៊ំ]
- អាចកត់សូរក្នុងពាក្យក្លាយពីបាលីសំស្ក្រឹត ។

[...] ក្នុងឆ្នាំដដែលនោះ សម្តេចបានទទួលការតែងតាំងជាសមាជិកជំនួយនៃក្រុមជំនុំខាងការស្រាវជ្រាវជ្រើសរើសពាក្យពេចន៍ក្នុងផ្នែកនៃកវីនិពន្ធខ្មែរបុរាណ ដើម្បីប្រមូលបញ្ចូលពាក្យទាំងនេះទៅក្នុងវចនានុក្រមខ្មែរ ។ ព.ស. ២៤៧៧ គ.ស. ១៩៣៣ សម្តេចទ្រង់បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំពិនិត្យសៀវភៅ ដែលក្រសួងសិក្សាធិការជាតិបោះពុម្ពផ្សាយ ។ ព.ស. ២៤៧៨ គ.ស. ១៩៣៤ សម្តេចទ្រង់បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំជ្រើសរើសពាក្យខ្មែរប្រៀបធៀបនឹងពាក្យបារាំងសម្រាប់ប្រើក្នុងការងាររាជការ ។ ព.ស.២៤៧៩ គ.ស.១៩៣៥ សម្តេចទ្រង់បានទទួលការតែងតាំងជាសាស្ត្រាចារ្យបង្រៀនភាសាបាលីសំស្ក្រឹតខ្មែរនិងលាវប្រចាំថ្នាក់ទីបញ្ចប់នៃមធ្យមនៅវិទ្យាល័យព្រះស៊ីសុវត្ថិក្រុងភ្នំពេញ ។ [...]

# ជីវប្រវត្តិឧកញ៉ាសុត្តន្តប្រីជាឥន្ទមុក



## ក. សិក្សាពាក្យគន្លឹះ

- កវីនិពន្ធ (ន) : កវីជាអ្នកនិពន្ធ អ្នកនិពន្ធខាងកំណាព្យកាព្យឃ្លោង ។
- កាលមរណៈ (ន) : កាលកំណត់ដែលត្រូវស្លាប់ ពេលស្លាប់ ស្លាប់ ។
- លាយលក្ខណ៍អក្សរ (ន) : ស្នាមលក្ខណៈជាអក្សរ ។
- កលិយុគ (ន) : កាលសម័យដែលប្រកបដោយទោស ដោយវិបត្តិផ្សេងៗ ។
- ប្រគេន (ន) : ឱ្យ លើកឱ្យដល់ដៃក្នុងហត្ថបាស ប្រគេនចង្ហាន់លោក ។
- ស្នាមអុត (ន) : ស្នាមឈ្មោះរោគមួយពួក មានបីប្រភេទ ។ អុតក្តាម កើតនៅស្បែកមនុស្សចេញក្រហមផេរស្រដៀងនឹងកញ្ជ្រឹលនិងអុតស្វាយ អុតធំ ។
- ចាកសិក្ខាបទ (កិ) : វៀរលែងជាបព្វជិត សឹកមកជាមនុស្សសាមញ្ញលែងបួសតទៅទៀត ។
- ក្រុមអាល័ក្ស (ន) : ឈ្មោះក្រុមរាជការមួយក្រុមក្នុងបរមរាជវាំងមានមុខការជាអ្នកកត់ត្រាប្រាក់ព្រះរាជទ្រព្យផ្សេងៗ ។
- ឋានន្តរសក្តិ (ន) : លំដាប់នៃទី មុខងារ ងារ ថ្នាក់ងារ ថ្នាក់ស័ក្តិយស ។

- គោរមងារ (ន) : ពាក្យដ៏ឧត្តមបន្ថែមពីលើងារជាពាក្យសរសើរងារសម្រាប់ប្រើសរសេរចំពោះតែការចេញសំបុត្រដីកាធំៗ ។
- រាជានុញ្ញាត (កិ) : យល់ព្រម បើកឱកាសឱ្យ(រាជស័ព្ទ) ។
- ផ្ទឹតផ្ទឹង (កិ.វិ) : ខ្ទឹម ដែលបះអើតក្រអឺតឡើង ខ្ទឹតឡើងត្រង់កន្ទុយ ។
- អប្បលក្ខណ៍ (និ) : ដែលប្រាសចាកយសគឺដែលខូចឈ្មោះ ដែលឥតគេរាប់ ដែលអាប់មុខ ។
- រជ្ជកាល (ន) : កាលឬសម័យដែលក្សត្រអង្គនីមួយៗទ្រង់សោយរាជ្យ ។
- ឈ្លើយ (គុ) : ដែលមានអាការៈព្រៃ ។
- បព្វជិត (ន) : អ្នកបួស ។
- គ្រហស្ថ (ន) : អ្នកផ្ទះ អ្នកគ្រប់គ្រងផ្ទះ គឺអ្នកមានគ្រួសារ ។
- កម្មដ្ឋាន (ន) : ហេតុជាទីតម្កល់នៃបរិកម្ម ចម្រើនកម្មដ្ឋាន ។
- ពង្សាវតារ (ន) : រឿងរ៉ាវតាមលំដាប់នៃវង្សត្រកូល ប្រវត្តិដែលឆ្លងពីសង្កាត់មួយមកសង្កាត់មួយ ដំណើរសេចក្តីសំដែងអំពីតំណនៃវង្សត្រកូល ។
- អនិច្ចកម្ម (ន) : សេចក្តីស្លាប់ ។

## ខ. អភិវឌ្ឍន៍បំណិន

ក្នុងការសិក្សាអត្ថបទអំណាននេះ អ្នកនឹងបានស្តាប់អត្ថបទកំណាព្យនិងសេចក្តីលំអិតក្នុងអត្ថបទ យល់ខ្លឹមសារនៃអត្ថបទកាព្យ ស្គាល់រឿងពិត ឬប្រឌិត ស្វែងយល់ពីឥរិយាបថរបស់តួអង្គនិងតម្លៃអប់រំ ព្រមទាំងស្គាល់ឥរិយាបថរបស់អ្នកនិពន្ធ ។

## គ. អត្ថបទ

ការស្រាវជ្រាវរកកវីនិពន្ធខ្មែរនីមួយៗ ជាការលំបាកណាស់ដែរ ព្រោះអ្នកទាំងនោះ ពេលធ្វើកាលមរណៈទៅមិនបានទុកជីវប្រវត្តិរបស់លោកជាលាយលក្ខណ៍អក្សរ ល្មមឱ្យយើងអាចរកឃើញសោះទេ ។ ប៉ុន្តែទោះបីយ៉ាងដូច្នេះក៏ដោយ យើងក៏អាចរកឃើញបានខ្លះដែរនូវជីវប្រវត្តិដែលយើងល្មមទុកដាក់ថាជាគោលៗបាន ។

យើងដឹងថាចំពោះលោកឧកញ៉ាសន្ធរម៉ុក ជាកវីនិពន្ធមួយរូបក្នុងរាជព្រះបាទសម្តេចព្រះនរោត្តម (ព្រះករុណាសុវណ្ណកោដ្ឋ)។ លោកកើតនៅក្រុងឧដុង្គ ក្នុងគ.ស. ១៨៤៦។ បិតារបស់លោកធ្វើជាមន្ត្រីក្នុងបរមរាជវាំងក្នុងរាជ្យព្រះបាទសម្តេចអង្គឌួង។ សម័យនោះជាកលិយុគដែលប្រទេសយើងពើបប្រទះនឹងសង្គ្រាមជាមួយនឹងប្រទេសជិតខាងជាច្រើនឆ្នាំ។ ដូច្នេះបិតារបស់លោកព្រមទាំងគ្រួសារត្រូវទ័ពយួនកៀរយកទៅបាត់ ហើយខ្លួនលោកក៏ដល់នូវភាវៈជាកុមារកំព្រាមាតាបិតាតាំងពីអាយុ ១១ឆ្នាំមក។ កុមារម៉ុកក្នុងរយៈពេលនោះមានសំណាងធំ ដោយបានព្រះតេជគុណព្រះនាមអន ចៅអធិការវត្តគុករើសយកទៅរក្សា និងឱ្យរៀនសូត្រក្នុងវត្តនោះរៀងមក។ កុមារនេះឧស្សាហ៍រៀនសូត្រណាស់។ គេតំណាលថា ថ្វីបើពេលនោះគ្រឿងសម្ភារៈសម្រាប់រៀនសូត្រមិនបរិបូណ៌ក៏កុមារម៉ុកនៅតែរកគ្រឿងប្រដាប់រៀនបានដែរ ដោយគាត់យកធ្យូងប្រើជំនួសដីស យកភ្លើងចង្ក្រានដែលដាំចម្អិនអាហារ ឬចង្ហាន់ប្រគេនលោកគ្រូធ្វើជាគ្រឿងបំភ្លឺ។ល។

ឯរូបសម្បត្តិរបស់លោកវិញ គេតំណាលថា លោកមានរូបអាក្រក់ ស្បែកមុខសុសដោយស្នាមអុត មានដៃក្រវែង ប៉ុន្តែមានសំឡេងពីរោះ ថាលោកចេះអានសាស្ត្រាកាព្យដោយបែបបទគួរជាទីពេញចិត្តនៃអ្នកស្តាប់យ៉ាងក្រៃលែង។ លំដាប់ក្រោយមកកុមារម៉ុកបានបួសជាសាមណេរ រួចជាភិក្ខុភាវៈ បន្ទាប់ពីភិក្ខុម៉ុកចាកសិក្ខាបទមក លោកគ្រូព្រះនាមអនបាននាំលោកទៅថ្វាយព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ទុកជាបម្រើក្រោមល្អងធូលីព្រះបាទតរៀងមក។ ព្រះករុណាទ្រង់សព្វព្រះរាជហឫទ័យប្រោសប្រទានឱ្យធ្វើការក្នុងក្រុមអាល័ក្ស (ប៉ែកខាងបោះពុម្ព)។ លោកអាល័ក្សម៉ុកបានយកចិត្តទុកដាក់បម្រើកិច្ចការរាជការព្រះបាទករុណា ហើយបានទទួលព្រះរាជទានឋានន្តរសក្តិជាលំដាប់រហូតដល់បានគោរម្យងារជាឧកញ៉ាសន្ធរវោហារ។ នៅទីបំផុតលោកបានទទួលព្រះរាជទានគោរម្យងារ ជាអម្រឹតក្សត្រីទៀត។ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសព្វព្រះរាជហឫទ័យនឹងលោកណាស់។ ទ្រង់មានព្រះតម្រាស់ហៅឧកញ៉ាម៉ុកតែ "ម៉ែងៗ" ហើយព្រះរាជានុញ្ញាតឱ្យទូលឆ្លើយថា "ក្រង៉ុកៗ"ទៅវិញ។ ភរិយារបស់លោកនាម ជំទាវ "សម"។ លោកទទួលមរណភាពនៅក្រុងភ្នំពេញគ.ស. ១៩០៨ ក្នុងជន្មាយុ ៦២ ឆ្នាំ។ ក្នុងឋានៈជាវណ្ណការីលោកសន្ធរវោហារម៉ុកល្បីឈ្មោះខាងលើកកំណាព្យកាព្យឃ្លោង។ លោកពូកែបំផុតខាងតែងកំណាព្យបានភ្លាមៗ ហើយសមតាមលក្ខណៈដំណើររឿង។ ចុងចួនទៀតសោតក៏រណ្តំគ្នាដូចជាស្នូររនាត។ យើងសូមជូនកំណាព្យពីរបីគាថាតាមការចាំមាត់តៗគ្នាមក :

ក. ផ្កែឆ្កួតបោលផ្កឹតកន្ទុយផ្កឹង ពាំផ្លឹងមាន់ឆ្កាងទៅស៊ីឆ្កុយ ... ។

ខ. រ៉ឺយអាចឹកឱ្យសាច់មួយកាក់ អាចឹកកន្ត្រាក់បានសាច់ខ្វៃ
អារខ្វាច់ហាន់ខ្វាប់សាប់ញាប់ដៃ រ៉ឺយលៃឱ្យឆាប់ប្រញាប់ឆាន់ ។

គ. បារាំងបារ៉ោចោរអបលក្ខណ៍ ហ៊ានលើកជើងធាក់អាល័ក្សហ្លួងលេង ... ។

[...]លោកឧកញ៉ាសន្ធរវោហារម៉ុកកាលនៅជានាហ្មឺនក្រុមព្រះអាល័ក្សនៅឡើយបានទៅដណ្ដឹងធីតាម្នាក់ឈ្មោះនាងសុខ ។ មាតាបិតានៃនាងនេះបានព្រមព្រៀងលើកនាងឱ្យទៅលោកហើយ ប៉ុន្តែនាងសុខប្រកែកមិនព្រមស្រឡាញ់លោកអាល័ក្សម៉ុក ព្រោះលោកមានរូបអាក្រក់ហើយដៃក្រវែងទៀតផង ។ មាតាបិតានៃនាងសុខដោយមិនអាចបង្ខំចិត្តកូនបាន ហើយដោយអាណិតស្រឡាញ់កំលោះម៉ុកនេះផងក៏លើកនាងសម ជាបងសុខឱ្យទៅលោកអាល័ក្ស ហើយផ្សំផ្គុំគ្នាឱ្យបានជាស្វាមីភរិយាតាមប្រពៃណីរបស់ខ្មែរ ។ អ្នកឧកញ៉ាសន្ធរវោហារម៉ុកបង្កើតបានបុត្រាបួននាក់និងបុត្រីម្នាក់ ។ បុត្រានាមម៉ិល១ ត្រចាត់១ សំឌិក១ សំអែល១ បុត្រីនាមនាងរំដេញ ។ បណ្ដាបុត្ររបស់លោកនោះលោកម៉ិលនិងលោកត្រចាត់បានទៅរៀននៅប្រទេសបារាំងជាច្រើនឆ្នាំ ។ លុះត្រឡប់មកវិញ លោកម៉ិលបានធ្វើការបម្រើប្រទេសជាតិយើងក្នុងឋានៈជាចៅហ្វាយស្រុក ឯលោកត្រចាត់បានទៅធ្វើការនៅប្រទេសលាវហើយបានទទួលមរណភាពនៅទីនោះ ។ ឯលោកសំអែល លោកសំឌិក និងអ្នករំដេញបានរៀននៅក្នុងប្រទេសខ្មែរ ។ លោកសំឌិក លោកសំអែលបានធ្វើជាគ្រូបង្រៀន ។ ឯអ្នករំដេញ បានទៅជាអ្នកម្នាងរបស់ព្រះអង្គម្ចាស់នរោត្តមឌួងច័ក្រ ។ ក្នុងកិច្ចសង្គ្រោះបុត្រធីតា លោកឧកញ៉ាសន្ធរវោហារគួរគេចាត់ទុកថាជាឪពុកវាងវៃម្នាក់ ដែលមើលអនាគតឃើញវែងឆ្ងាយ ដោយលោកមានគំនិតបញ្ជូនកូនឱ្យទៅរៀននៅបរទេសមុនអ្នកឯទៀត ។ មិនតែប៉ុណ្ណោះ លោកបានទម្លុះទម្លាយមុនគេនូវទម្លាប់ដែលបំបាត់សិទ្ធិកូនស្រីមិនឱ្យរៀនសូត្រ ដោយឱ្យកូនស្រីតែមួយរបស់លោករៀនសូត្ររហូតដល់ចេះមើលនិងសរសេរបានតាមសេចក្ដីត្រូវការ ។ ក្នុងជីវប្រវត្តិអ្នកឧកញ៉ាសន្ធរវោហារម៉ុកនេះ យើងគួរកត់សម្គាល់ថា លោកជាអ្នកផ្ដើមបង្កើតវង់ភ្លេងខ្សែដែលពីដើមគេហៅថាភ្លេងចិននោះមុនគេ ជាហេតុឱ្យវង់ភ្លេងប្រភេទនេះកកើតមានជាប់រហូតមក ។ បានជាយើងហ៊ានអះអាងថា លោកឧកញ៉ាសន្ធរវោហារម៉ុកជាអ្នកបង្កើតវង់ភ្លេងខ្សែមុនគេ ព្រោះថាក្នុងរជ្ជកាលនៃព្រះករុណាព្រះបាទនរោត្តមនាហ្មឺន មុខមន្ត្រីក្នុងព្រះបរមរាជវាំងដែលមានភ្លេងសម្រាប់បំពេញព្រះរាជហឫទ័យព្រះមហាក្សត្រនោះ មានត្រឹមតែភ្លេងពិណពាទ្យនិងមហោរីប៉ុណ្ណោះទេ ឯវង់ភ្លេងខ្សែមានតែឧកញ៉ាសន្ធរវោហារម្នាក់ឯងគត់ ។

[...] ក្នុងនៅគ.ស. ១៨៥៩ នៅក្រុងឧដុង្គសម្តេចព្រះរាជជននី បានបញ្ជាឱ្យអម្រឹតក្សត្រីម៉ុកបកប្រែរឿងទេវន្ទបាលីទាញចេញពីគម្ពីរបញ្ញាសជាតក (៥០ជាតក) មកជាភាសាខ្មែរ។ លោកអម្រឹតក្សត្រីម៉ុកបានយកមកលើកជាកំណាព្យរឿងទេវន្ទនេះដោយមានចៅពញាសុន្ទអក្ខរាជាស្មេរជួយសរសេរចម្លងផងនៅថ្ងៃព្រហស្បតិ៍ ៣កើត ខែអស្សុជ ឆ្នាំមមែ ព.ស. ២៤០២ (គឺត្រូវនឹងគ.ស. ១៨៥៩)។ នៅព.ស. ២៤០៦ (គ.ស. ១៨៦៣) សម្តេចព្រះវររាជជនីគង់ធ្វើកម្មដ្ឋានលើភ្នំព្រះរាជទ្រព្យបានបញ្ជាម្តងទៀតឱ្យលោកអម្រឹតក្សត្រីម៉ុក ប្រែរឿងព្រះសិង្ហនាទ ពីភាសាបាលីទាញចេញពីគម្ពីរបញ្ញាសជាតកនិងចងក្រងជាកំណាព្យ។ រវាងគ.ស. ១៨៦៦ ក្រោយមរណកាលព្រះមាតាស្តេចអង្គឌួង ម៉ុកបានមកនៅភ្នំពេញបម្រើហ្លួងនរោត្តមជារាជកវីបណ្ឌិតជំនិតនឹងព្រះអង្គបានតែងពាក្យខ្លីៗជាច្រើនសម្រាប់ស្តេចក្រសាល ដូចមានចែងដោយអ្នកស្រាវជ្រាវនានាដែលយើងស្រង់ចុះខាងលើស្តីពីសំនួនវោហារលោកម៉ុក។ នៅចុងសតវត្សទី ១៩ គឺរវាងគ.ស. ១៨៩០-១៨៩៣ ហ្លួងនរោត្តមបានបញ្ជាឱ្យក្រុមរាជបណ្ឌិតតាក់តែងព្រះរាជពង្សាវតារក្រុងកម្ពុជាឡើងវិញ គឺមានមហាសង្ឃរាជព្រះនាមទៀង (សុគតក្នុងជន្មាយុ ៩១ព្រះវស្សា ក្នុងគ.ស. ១៩១៣) ព្រះសុគន្ធព្រះនាម ប៉ាន (សុគតក្នុងគ.ស.១៨៩៤)និងអ្នកចងក្រងនិពន្ធគឺលោកឧកញ៉ាសន្ធរវោហារម៉ុក។ ឯកសារចម្លងដៃដែលសន្ធរវោហារម៉ុកបានសរសេរនេះមានតម្កល់មួយច្បាប់ក្នុងសាលាចុងបូព៌ាប្រទេសនៅក្រុងប៉ារីស ហើយមួយច្បាប់ទៀតដែលលោកអាដេម៉ារឡឺក្លែរ (Adhemard Leclere) បានយកមកហើយសរសេរសៀវភៅប្រវត្តិ សាស្ត្រកម្ពុជាមានតម្កល់នៅបណ្ណាល័យនាក្រុងអាឡង់សុង (Alen Son)។ ឯកសារចុងក្រោយនេះលោកម៉ីសែលត្រាណេបានយកទៅបោះពុម្ពផ្សាយនៅគ.ស. ១៩៨៧។

ក្រោយមក លោកបានទទួលចំណេះដឹងនិងឥទ្ធិពលអក្សរសិល្ប៍បារាំងសែស បន្ទាប់ពីបុត្រាលោកពីរនាក់ម៉ិល និងត្រចាត់ត្រឡប់ពីប្រទេសបារាំងវិញ លោកបាននិពន្ធល្បើក "រៃនិងស្រមោច" ជាដើម។ តាមអ្នកស្រាវជ្រាវបារាំងខ្លះសរសេរថា លោកសន្ធរម៉ុកបានទទួលគោរមងាររហូតដល់ឧកញ៉ាចៅហ្វាំង ហើយបានចូលមរណកាលរវាងគ.ស. ១៨៩៤ តែតាមព្រះអង្គម្ចាស់នរោត្តមម៉ុងតាណាជាថៅទូតបញ្ជាក់ថា លោកសន្ធរម៉ុកបានអនិច្ចកម្មនៅរវាងឆ្នាំ ១៩០៨។

*(ដកស្រង់ចេញពីអក្សរសិល្ប៍ខ្មែរសតវត្សទី ១៩ "ឃឹង ហុកឌី" ២០០៣)*

# សំណួរ

១. តើមានកត្តាសំខាន់អ្វី ដែលនាំឱ្យព្រះរាជាសព្វព្រះទ័យតែងតាំ ន្ទរម៉ុកជាចាងហ្វាងក្រុមព្រះអាល័ក្ស ? តើព័ត៌មានក្នុងអត្ថបទនេះ ជាការពិត ាតុអ្វី ?

២. ហេតុដូចម្តេចបានជាយុវជនម៉ុកមានគំនិតស្វែងរកចំណេ ឥរិយាបថនេះបានបង្ហាញពីលោកសន្ទរម៉ុកជាបុគ្គលបែបណា ?

៣. បើយោលតាមស្នាដៃរបស់លោកសន្ទរម៉ុក តើអ្នកទទួលបានតម្លៃអប់រំយ៉ាងណាខ្លះ ?

៤. តាមរយៈជីវប្រវត្តិខាងលើ តើអ្នកយល់ឃើញយ៉ាងដូចម្តេចពីសម័យកាលនោះ ?

៥. តើបទពិសោធនៃជីវិតលោកសន្ទរម៉ុកអាចធ្វើជាគំរូសម្រាប់ជីវិតអ្នកបានដែរ ឬទេ ? ព្រោះអ្វី ?

៦. ចូរអ្នកស្រង់ចំណុចសំខាន់ៗនៃជីវប្រវត្តិសង្ខេប របស់លោកឧកញ៉ាសន្ធរវោហារ "ម៉ុក" ។

៧. ចូរអ្នកបង្ហាញពីឥរិយាបថរបស់អ្នកនិពន្ធក្នុងការចងក្រងជីវប្រវត្តិលោកឧកញ៉ាសន្ធរវោហារ "ម៉ុក" ។

៨. ចូរអ្នកបង្ហាញឱ្យឃើញពីខ្លឹមសារនិងទឹកដមនៃស្នាដៃរបស់កវីដែលមានក្នុងឧទាហរណ៍ ក, ខ, គ ខាងក្រោម :

ក. ឆ្កែឆ្កួតបោលឆ្កឹតកន្ទុយឆ្កឹង ពាំឆ្អឹងមាន់ឆ្កាងទៅស៊ីឆ្កុយ ... ។

ខ. វ៉ីយអាចឹកឱ្យសាច់មួយកាក់ អាចឹកកន្ត្រាក់បានសាច់ខ្វៃ
អារខ្វាច់ហាន់ខ្វាប់សាប់ញាប់ដៃ វ៉ីយលៃឱ្យឆាប់ប្រញាប់ឆាន់ ។

គ. បារាំងបារ៉ោចោរអបលក្ខណ៍ ហ៊ានលើកជើងធាក់អាល័ក្សហ្លួង ... ។

# ជីវិតលើនាវា



អ្នកធ្លាប់បានស្តាប់អត្ថបទជាច្រើន ដែលជាអត្ថបទប្រភេទអក្សរសិល្ប៍និងអត្ថបទអត្ថាធិប្បាយ ។ អត្ថបទទាំងនោះសុទ្ធតែបង្កប់នូវគំនិតអប់រំនិងបណ្តុះស្មារតីស្នេហាជាតិ ស្នេហាប្រជាជនជាដើម ។ ពេលនេះអ្នកនឹងបានស្តាប់អត្ថបទ “ជីវិតលើនាវា” ហើយអ្នកត្រៀមឆ្លើយនឹងសំណួរខាងក្រោមនេះ :

១. ហេតុអ្វីបានជាក្រឡាហោមគង់អង្គុយត្រមង់ត្រមោច ឯកឯងនៅលើនាវា?

២. តើទិដ្ឋភាពតាមដងទន្លេបានជំរុញឱ្យក្រឡាហោមគង់មានអារម្មណ៍ដូចម្តេច?

៣. តើអារម្មណ៍ទាំងនោះ បានឆ្លុះបញ្ចាំងឱ្យឃើញថា ក្រឡាហោមគង់ជាបុគ្គលដូចម្តេច?

៤. តើអ្នកមានអារម្មណ៍ដូចម្តេច ដែលយើងមានបុគ្គលដ៏ឆ្នើមដូចជាក្រឡាហោមគង់?

៥. ចូរអ្នករកឈ្មោះបុគ្គលដែលមានលក្ខណសម្បត្តិដូចក្រឡាហោមគង់ ឱ្យបាន ៤ រូប ។



# សម្ភាសជាមួយបុគ្គលសំខាន់ក្នុងសហគមន៍

ការសម្ភាសគឺជាការនិយាយឆ្លើយឆ្លងរវាងមនុស្សពីរម្នាក់ ដើម្បីផ្តល់ព័ត៌មានដែលទាក់ទងនឹងបញ្ហាផ្ទាល់ខ្លួន បញ្ហាការងារ ឬបញ្ហាផ្សេងៗជាច្រើនទៀត ។ ក្នុងការសម្ភាសត្រូវមានអ្នកសម្ភាសគេនិងអ្នកដែលត្រូវគេសម្ភាស ។ អ្នកសម្ភាសគេត្រូវចេះរៀបចំសំណួរសម្ភាសឱ្យមានលំដាប់លំដោយដោយផ្តោតទៅលើបញ្ហាណាដែលយើងចង់ដឹងជាចាំបាច់យកមកចោទសួរ ។

ចូរអ្នកអានអត្ថបទនៃកិច្ចសម្ភាសខាងក្រោម ដែលនិយាយពីប្រវត្តិនិងការងាររបស់លោកអ៊ំម្នាក់ដែលជាប្រធាននៅក្នុងសហគមន៍មួយ ។ អ្នកដែលចាប់ផ្តើមកិច្ចសម្ភាស គឺនាងធារី ។

ធារី : នាងខ្ញុំសូមជម្រាបសួរលោកអ៊ំ ! នាងខ្ញុំឈ្មោះធារីជាសិស្សថ្នាក់ទី៨"ក១"នៃវិទ្យាល័យទួលទំពូង ។ នាងខ្ញុំសុំការអនុញ្ញាតជួបនិងធ្វើសម្ភាសលោកអ៊ំជុំវិញជីវប្រវត្តិផ្ទាល់ខ្លួន ព្រមទាំងប្រវត្តិការងារកន្លងមក ។ សូមលោកអ៊ំមេត្តាអនុញ្ញាតឱ្យនាងខ្ញុំបានសម្ភាសផងចុះ ! ព្រោះនាងខ្ញុំត្រូវរៀបចំឯកសារ អំពីជីវប្រវត្តិបុគ្គលដែលមានស្នាដៃ ។

សោយសម្បត្តិ : បាទ ! មិនអីទេ... អ៊ំពេញចិត្តនឹងឆ្លើយសំណួរក្មួយ !

ធារី : ចាស៎ ! អរគុណលោកអ៊ំ ! សូមអត់ទោស តើលោកអ៊ំឈ្មោះអ្វី ? តើលោកអ៊ំមានតួនាទីជាអ្វីដែរ ?

សោយសម្បត្តិ : អ៊ំឈ្មោះសោយសម្បត្តិ ជាប្រធានសហគមន៍ភូមិនេះណាក្មួយ !

ធារី : តើលោកអ៊ំមានអាយុប៉ុន្មានឆ្នាំហើយ ? មានកូនចៅប៉ុន្មាននាក់ ? តើស្រុកកំណើតលោកអ៊ំនៅឯណាដែរ ? ក្រៅពីតួនាទីជាប្រធានសហគមន៍ តើលោកអ៊ំប្រកបការងារអ្វីដែរ ?

សោយសម្បត្តិ : អ៊ំអាយុ ៥៨ឆ្នាំ មានកូនប្រុសមួយនាក់ កូនស្រី ២នាក់ ។ អ៊ំមានស្រុកកំណើត នៅភូមិកោះតាង៉ោ ឃុំសូរគង ស្រុកកងមាស ខេត្តកំពង់ចាម ... ហើយអ៊ំ ប្រកបរបរកសិកម្មធ្វើស្រែចម្ការ ព្រោះអ៊ំស្រឡាញ់ការងារកសិកម្ម ដែលជាតំណាតាំងពីដូនតាអ៊ំមកម្ល៉េះណាក្មួយ !

ធារី : អរគុណលោកអ៊ំ សូមលោកអ៊ំមេត្តាជួយបំភ្លឺនាងខ្ញុំបន្ថែម អំពីដំណើរដើមទងដែលលោកអ៊ំទទួលតួនាទីជាប្រធានសហគមន៍នេះ ។

សោយសម្បត្តិ : អ៊ុំរីករាយនឹងប្រាប់ក្មួយ ព្រោះអ៊ុំចងចាំហេតុការណ៍នោះជារៀងរហូតមក ! ក្មួយដឹងទេ ! ប៉ុន្មានឆ្នាំកន្លងមកនេះ ក្នុងស្រុកភូមិអ៊ុំមានគ្រោះទឹកជំនន់មួយយ៉ាងធំ ផ្ទះសម្បែងត្រូវជន់លិច ផលដំណាំត្រូវខូចខាតយ៉ាងដំណំ ... ។ ពេលនោះចរន្តទឹកហូរខ្លាំងណាស់ មានក្មេងស្រីម្នាក់ត្រូវទឹកហូរនាំយកទៅ អ៊ុំឃើញដូច្នោះអ៊ុំក៏ប្រញាប់ហែលទៅជួយសង្គ្រោះនាងភ្លាម ។ ទឹកហូរខ្លាំងនាំយើងទាំងពីរទៅ តែសំណាងល្អក៏ទើរនៅលើដើមរាំងមួយដើម ។ ក្មេងស្រីក៏បានរួចផុតពីគ្រោះអាសន្ន តែអ៊ុំត្រូវពស់ចឹកសន្លប់អស់ជាច្រើនម៉ោង ។ អ្នកភូមិមិនសូវសង្ឃឹមថា អ៊ុំមានជីវិតឡើយ ប៉ុន្តែដោយមានការព្យាបាលពីសំណាក់គ្រូពេទ្យទាន់ពេលវេលានិងយកចិត្តទុកដាក់ អ៊ុំក៏បានរួចជីវិតមកដល់ពេលនេះ ។ ពីពេលនោះមក អ៊ុំក៏ត្រូវអ្នកភូមិចាត់ទុកជាបុគ្គលគំរូក្នុងភូមិ ។ ទន្ទឹមនឹងនេះ អ៊ុំតែងតែចូលរួមក្នុងការងារសហគមន៍ ដោយផ្តល់បទពិសោធល្អៗក្នុងការងារកសិកម្ម ហើយជួយផ្តល់កម្លាំងចិត្តដល់អ្នកជួបការលំបាកនិងជួយណែនាំក្មេងៗក្នុងភូមិឱ្យចេះជួយគ្នា ស្រឡាញ់រាប់អានគ្នា ទើបប្រាំឆ្នាំមកនេះ អ៊ុំក៏ត្រូវប្រជាជនក្នុងភូមិជ្រើសតាំងជាប្រធានសមាគមន៍នៅក្នុងភូមិនេះ ក្រោយពីបងប្រធានសហគមន៍សុំចូលនិវត្តន៍ ។

ធារី : អរគុណណាស់លោកអ៊ុំ ! ក្មួយសូមកោតសរសើរនូវទឹកចិត្តដ៏ល្អប្រពៃនិងមនុស្សធម៌របស់អ៊ុំណាស់ ! នាងខ្ញុំសូមលើកយកជីវប្រវត្តិលោកអ៊ុំ ទៅចងក្រងទុក បើលោកអ៊ុំមិនយល់ទាស់ទេនោះ ។

សោយសម្បត្តិ : ពិតជាបាន ! អ៊ុំរីករាយនិងត្រេកអរណាស់ ព្រោះនេះជាកិច្ចការល្អមួយនៅក្នុងសង្គម ដើម្បីបណ្តុះនូវសាមគ្គីធម៌ មនុស្សធម៌ សច្ចធម៌ ការចេះជួយគ្នាទៅវិញទៅមកកុំឱ្យសាបសូន្យណាំក្មួយ !

ធារី : មុននឹងបញ្ចប់កិច្ចសម្ភាសនេះ ក្មួយសូមលោកអ៊ុំបញ្ជាក់ពីអារម្មណ៍ឬទឹកចិត្តរបស់លោកអ៊ុំចំពោះតួនាទីនេះ !

សោយសម្បត្តិ : ជាទស្សនៈអ៊ំផ្ទាល់ ក្នុងនាមជាអ្នកឈានមុខគេ យើងមិនគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួននោះឡើយ ហើយត្រូវមានការទទួលខុសត្រូវ មានទឹកចិត្តមនុស្សធម៌ ។ អ៊ំយល់ថា ជីវិតមនុស្សមានតម្លៃណាស់ យើងត្រូវចេះប្រើប្រាស់ជីវិត ឱ្យមានប្រយោជន៍ដល់សង្គមជាតិនិងត្រូវឱ្យដំណើរជីវិតទៅតាមផ្លូវសីលធម៌របស់សង្គមនិងបម្រើសេចក្តីត្រូវការរបស់ជាតិ ។ អ៊ំនៅតែខិតខំកសាងអំពើល្អនិងរៀបចំផែនការអភិវឌ្ឍភូមិនេះឱ្យរីកចម្រើនដើម្បីលើកកម្ពស់ជីវភាពប្រជាជនភូមិនេះឱ្យប្រសើរឡើង ។

ធារី : ការធ្វើសម្ភាសថ្ងៃនេះ ពិតជាធ្វើឱ្យនាងខ្ញុំមានមោទនភាពណាស់ហើយបានយល់កាន់តែច្បាស់ថែមទៀត អំពីបំណងប្រាថ្នារបស់លោកអ៊ំក្នុងការអភិវឌ្ឍភូមិ ជាពិសេសនាងខ្ញុំបានទទួលបទពិសោធល្អ ក៏ដូចជាមាគ៌ាឈានទៅកសាងខ្លួនជាបុគ្គលឆ្នើមមួយរូបនិងជាគំរូដល់អ្នកដទៃ ។ នាងខ្ញុំសូមអរគុណលោកអ៊ំសាជាថ្មីដែលបានផ្តល់ឱកាសនិងអនុញ្ញាតឱ្យនាងខ្ញុំឱ្យបានជួបសម្ភាសអំពីជីវប្រវត្តិលោកអ៊ំយ៉ាងក្បោះក្បាយបែបនេះ ។ នាងខ្ញុំសង្ឃឹមថា នឹងបានជួបសម្ភាសលោកអ៊ំម្តងទៀតនៅថ្ងៃក្រោយ ។ នាងខ្ញុំសូមគោរពជូនពរលោកអ៊ំ សូមបានជួបប្រទះតែសេចក្តីសុខនិងទទួលបានជោគជ័យក្នុងការងារជាបន្តទៅទៀត ។
ក្មួយសុំអរគុណលោកអ៊ំនិងសូមជម្រាបលា !

## សំណួរ

១. តើអ្នកណាជាអ្នកសម្ភាស ? អ្នកណាជាអ្នកដែលត្រូវគេសម្ភាស ?

២. តើធារីបានប្រើពាក្យសំដីដូចម្តេចទៅកាន់លោកអ៊ំសោយសម្បត្តិ នៅពេលជួបគ្នាដំបូង ? បន្ទាប់មក ? បញ្ចប់សម្ភាស ?

៣. តើធារីចង់ដឹងពីអ្វីខ្លះ ?

៤. តើលោកអ៊ំសោយសម្បត្តិប្រើពាក្យសំដីបែបណាខ្លះ ដើម្បីបញ្ជាក់ពីអារម្មណ៍របស់គាត់ ?

## លំហាត់

១. ចូរអ្នកត្រៀមសំណួរតាមគំរូខាងលើនេះ ដោយរកដៃគូក្នុងការធ្វើសម្ភាស ហើយប្រើសំណួរដែលអ្នកបានត្រៀមទុកអំពីជីវប្រវត្តិរបស់កវីនិពន្ធដូចខាងក្រោមនេះ :

- ជីវប្រវត្តិ ភិក្ខុសោម
- ជីវប្រវត្តិលោក ញ៉ុកថែម
- ជីវប្រវត្តិលោក រីម គីន
- ជីវប្រវត្តិលោក នូ ហាច ។

២. ចូរអ្នករៀបចំការសម្ភាសតាមទម្រង់បែបបទខាងក្រោម :

**ក. ចំពោះអ្នកដែលធ្វើការសម្ភាសគេ**

• ផ្ដើមការសម្ភាស

មុននឹងធ្វើការសម្ភាសនរណាម្នាក់ អ្នកត្រូវយកចិត្តទុកដាក់លើចំណុចសំខាន់ៗមួយចំនួន :

- ប្រើពាក្យគួរសមនិងមានឥរិយាបថសមរម្យ ចំពោះអ្នកដែលត្រូវសម្ភាស ដោយប្រកាន់ខ្ជាប់នូវការគួរសមតាមរបៀបខ្មែរ (ខ្ញុំសូមជំរាបសួរ លោកអ៊ំ ...) ។
- បង្ហាញឬណែនាំខ្លួនឱ្យច្បាស់លាស់ ដោយបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន បើមានលិខិតបង្គាប់ការត្រូវយកចេញ រួចជូនទៅអ្នកដែលត្រូវសម្ភាស...(ខ្ញុំបាទ ឬនាងខ្ញុំមកពី ...)
- សម្រាប់អ្នកដែលត្រូវសម្ភាសអំពីប្រធានបទសម្ភាស (សូមធ្វើសម្ភាស ស្ដីពី ...)
- បញ្ជាក់ពីគោលបំណងនៃការធ្វើសម្ភាស (ដើម្បីចុះផ្សាយឬសរសេរសៀវភៅដែលទាក់ទងនឹង ...)

• ខ្លឹមសារសម្ភាស

ដើម្បីឱ្យការសម្ភាសសម្រេចតាមបំណងអ្នកត្រូវប្រើសំណួរដែលទាក់ទងនឹងព័ត៌មានផ្ទាល់នៃអ្នកដែលត្រូវសម្ភាសដូចជា

- សូមទោសលោកអ៊ំ ... តើ ...មានឈ្មោះអ្វីដែរ ?
- តើលោកអ៊ំ ... មានអាយុប៉ុន្មានឆ្នាំហើយ ?
- តើស្រុកកំណើតលោកអ៊ំនៅឯណាដែរ ?
- តើគ្រួសារលោកអ៊ំមាននរណាខ្លះ ?

- តើលោកអ៊ំប្រកបការងារឬមានតួនាទីអ្វីដែរ ?
- តើលោកអ៊ំ ... ពេញចិត្តនឹងតួនាទីនេះដែរឬទេ ? ព្រោះអ្វី ?

• បញ្ចប់សម្ភាស

ក្រោយពីសម្ភាសខ្លឹមសាររួច អ្នកត្រូវត្រៀមបញ្ចប់ការសម្ភាសដោយយកចិត្តទុកដាក់លើ :

- ការបង្ហាញពីសារប្រយោជន៍កិច្ចសម្ភាសនោះ
- ការថ្លែងអំណរគុណចំពោះអ្នកដែលផ្តល់ឱ្យខ្លួនបានសម្ភាស
- ការសម្តែងអារម្មណ៍រីករាយក្នុងកិច្ចសម្ភាស ។

**ខ. ចំពោះអ្នកដែលត្រូវគេសម្ភាស**

អ្នកដែលត្រូវគេសម្ភាសត្រូវរៀបចំពាក្យពេចន៍និយាយនិងចម្លើយទៅតាមសំណួរដែលគេសួរពោលគឺ

- មុននឹងឆ្លើយគប្បីស្វែងយល់ពីសំណួរឱ្យបានច្បាស់លាស់
- ចម្លើយត្រូវឆ្លើយឱ្យចំចំណុចនៃសំណួរ ឬព័ត៌មានដែលគេចង់បាន
- បកស្រាយគំនិតឱ្យចំបញ្ហា ដោយមិនត្រូវនិយាយបរិយាយអ្វីដែលប្រាសចាកពីប្រធានបទទេ ហើយគួរលើកឧទាហរណ៍បន្ថែម ប្រសិនបើចាំបាច់ ។
- ឥរិយាបថ សមរម្យ ថ្លៃថ្នូរ ប្រកបទៅដោយសុជីវធម៌ ។
- បញ្ជាក់ពីអារម្មណ៍រីករាយរបស់ខ្លួនក្រោយពីកិច្ចសម្ភាសចប់ ។

## របាយការណ៍សម្ភាស

អ្នកបានធ្វើការសម្ភាសអំពីជីវប្រវត្តិរបស់ប្រធានសហគមន៍រួចមកហើយ ។ ចូរអ្នកសរសេររបាយការណ៍សម្ភាសនោះឱ្យបានច្បាស់លាស់មានលំដាប់លំដោយល្អ ។

### របាយការណ៍សម្ភាសស្ដីពីជីវប្រវត្តិប្រធានសហគមន៍

នៅសប្ដាហ៍ទីពីរនៃខែនេះ នាងខ្ញុំបានធ្វើការសម្ភាសស្ដីពីជីវប្រវត្តិលោកអ៊ំសោយសម្បត្តិដែលជាប្រធានសហគមន៍ក្នុងភូមិមួយ ។ ជីវប្រវត្តិលោកអ៊ំមានដូចតទៅ ៖

លោកអ៊ំសោយសម្បត្តិមានអាយុ៥៨ឆ្នាំ មានកូនបីនាក់ក្នុងបន្ទុក ។ អ៊ំមានស្រុកកំណើត នៅភូមិកោះតាង៉ោ ឃុំសូរគង ស្រុកកងមាស ខេត្តកំពង់ចាម ។ គាត់ប្រកបរបរកសិកម្ម ។ មូលហេតុដែលនាំឱ្យគាត់ចាប់អាជីពនេះមកពីគាត់ចូលចិត្តការងារកសិកម្ម ហើយក៏មានបទពិសោធជាកសិករតាំងពីដូនតាមកម៉្លេះ ។ បច្ចុប្បន្នគាត់មានតួនាទីជាប្រធានសហគមន៍ គាត់ទទួលបានតួនាទីនេះ ដោយសារតែប្រជាជនមើលឃើញពីទង្វើប្រកបទៅដោយមនុស្សធម៌របស់គាត់ក្នុងការជួយសង្គ្រោះក្មេងស្រីម្នាក់ឱ្យរួចផុតពីការលង់ទឹក នៅពេលភូមិគាត់មានគ្រោះទឹកជំនន់កើតឡើង ។ គាត់ហ៊ានលះបង់អាយុជីវិតខ្លួនរហូតត្រូវពស់ចឹកស្ទើរតែស្លាប់ខ្លួនទៀតផង ។ គាត់ជាចាស់ទុំម្នាក់ដែលមានទឹកចិត្តទូលាយ ចេះអប់រំក្មេងៗឱ្យធ្វើល្អ ។ ដោយសារតែគុណសម្បត្តិនេះហើយ ទើបអ៊ំត្រូវអ្នកភូមិជ្រើសរើសជាបុគ្គលគំរូក្នុងភូមិ ។ ប្រាំឆ្នាំមកនេះ ក្រោយពីប្រធានសហគមន៍ចូលនិវត្តន៍ គាត់ក៏ត្រូវប្រជាជនក្នុងភូមិជ្រើសរើសជាប្រធានសហគមន៍ ដើម្បីជួយដឹកនាំការងារភូមិ ។ ជាមួយនឹងការរៀបរាប់ពីជីវប្រវត្តិនេះ គាត់បានសម្ដែងនូវមោទនភាពនិងទឹកចិត្តរំភើបយ៉ាងខ្លាំងនូវដំណើរជីវិតរបស់គាត់ ដោយសារច្រើនឆ្នាំមកនេះគាត់ពិតជាបានបំពេញកាតព្វកិច្ចជាមេគ្រួសារផង និងជាមេដឹកនាំផង ហើយរាល់កាតព្វកិច្ចទាំងនោះគាត់ចេះបែងចែកនិងមានផែនការជាក់លាក់មិនឱ្យច្របូកច្របល់គ្នានោះឡើយ ។ ទង្វើបែបនេះ ទើបធ្វើឱ្យការងាររបស់គាត់ប្រព្រឹត្តទៅដោយជោគជ័យ ។ អ្នករស់នៅក្នុងភូមិមានសុភមង្គលនិងមានសន្តិភាព ។ គាត់បានរៀបរាប់បទពិសោធល្អៗ ការទទួលខុសត្រូវប្រកបទៅដោយគតិបណ្ឌិត ទឹកចិត្តមនុស្សធម៌ សច្ចធម៌ ដោយមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួនធំជាងផលប្រយោជន៍រួមនោះឡើយ ។

នៅចុងបញ្ចប់នៃជីវប្រវត្តិនេះ លោកអ៊ំបានសម្ដែងនូវចិត្តរំភើបនិងបានលើកពីផែនការអភិវឌ្ឍភូមិនិងបញ្ជាក់ច្បាស់ពីការអភិវឌ្ឍភូមិនេះឱ្យរីកចម្រើនថែមទៀត ។

## សំណួរ

១. តើខ្លឹមសារនៃរបាយការណ៍នេះនិយាយពីអ្វី ?

២. តើរបាយការណ៍នេះចែកជាប៉ុន្មានផ្នែក ? តើផ្នែកនីមួយៗនិយាយពីអ្វី ?

## លំហាត់

ចូរអ្នកជ្រើសរើសជីវប្រវត្តិ នៃបុគ្គលសំខាន់ណាមួយ ក្នុងចំណោមបុគ្គលសំខាន់ខាងក្រោមនេះ មកសរសេរជារបាយការណ៍តាមគំរូខាងលើនេះ :

- ជីវប្រវត្តិភិក្ខុសោម
- ជីវប្រវត្តិលោក ញ៉ុកថែម
- ជីវប្រវត្តិ លោក រីម គីន
- ជីវប្រវត្តិ លោក នូ ហាច ។

ដើម្បីឱ្យសំណេររបាយការណ៍អ្នកទទួលបានលទ្ធផលល្អ អ្នកអាចធ្វើតាមការរៀបចំគម្រោងដូចខាងក្រោម :

### គម្រោងសំណេររបាយការណ៍សម្ភាស

## ១ . ផ្ដើមរបាយការណ៍

- បញ្ជាក់ពីពេលវេលា ទីកន្លែង ដែលខ្លួនត្រូវសម្ភាស
- បង្ហាញពីប្រធានបទ និងគោលបំណងក្នុងការធ្វើសម្ភាស
- ប្រាប់ឈ្មោះ តួនាទីរបស់បុគ្គលដែលត្រូវធ្វើសម្ភាស ។

## ២ . ខ្លឹមសាររបាយការណ៍សម្ភាស

- បង្ហាញពីឈ្មោះ អាយុ ស្រុកកំណើត
- ជនជាតិ តួនាទី មុខរបរ (មូលហេតុនៃការចាប់យកអាជីពនោះបើចាំបាច់)
- ស្ថានភាពកូន (ភេទ អាយុ ការងារ) ។

- ស្ថានភាពគ្រួសារ ៖
  - ដំណាក់កាលនីមួយៗនៃការកសាងជីវភាពរស់នៅ
  - តួនាទីនិងស្នាដៃ
  - បង្ហាញអារម្មណ៍អ្នកដែលត្រូវសម្ភាស លើសមិទ្ធផលឬស្នាដៃរបស់ខ្លួនកន្លងមក ។

## ៣ . បញ្ចប់របាយការណ៍សម្ភាស

- ការសន្និដ្ឋាននៃការធ្វើសម្ភាស អ្នកដែលត្រូវធ្វើសម្ភាស
- ការសម្តែងអារម្មណ៍សុទិដ្ឋិនិយមរបស់អ្នកដែលត្រូវសម្ភាស ។

មេរៀនទី
២

# ភាពស្មោះត្រង់



ភាពស្មោះត្រង់ គឺជាភាពទៀងត្រង់អស់ពីចិត្តគ្មានកិច្ចកលមាយា ។ ភាពស្មោះត្រង់បង្ហាញឱ្យឃើញតាមវាចានិងទង្វើ ។ វាចាស្មោះត្រង់ គឺជាសម្ដីពិតមិនភូតភរកុហកបោកប្រាស់ ។ ឯទង្វើស្មោះត្រង់ គឺសកម្មភាពមិនលួចលាក់ កេងបន្លំ ឆបោក បំភ័ន្តភ្នែកអ្នកដទៃ ។ ទឹកចិត្តស្មោះ គឺជាទឹកចិត្តស្រឡាញ់ដោយគ្មានកលល្បិច ឬពុតត្បុត មិនវៀចវេរ មិនច្រណែននិន្ទា ឈ្នានីស មិនធ្វើបាបគ្នា មិនធ្វើឱ្យខូចផលប្រយោជន៍ផងគ្នា ។ មនុស្សស្មោះត្រង់ គឺមនុស្សប្រកបដោយគុណធម៌ សីលធម៌រស់នៅថ្លៃថ្នូរដែលមនុស្សក្នុងសង្គមស្រឡាញ់រាប់អាននិងផ្ដល់កិត្តិយសជូនជានិច្ច ។

ក្នុងមេរៀននេះ អ្នកនឹងសិក្សាអត្ថបទមួយចំនួនដែលទាក់ទងនឹងប្រធានបទភាពស្មោះត្រង់ ភក្ដីភាព មិត្តភាព ដើម្បីជាប្រយោជន៍ដល់ខ្លួនឯងនិងសង្គមទៀតផង ។ ទន្ទឹមនេះ អ្នកនឹងសិក្សាផងដែរអំពីលក្ខណៈសម្គាល់នៃរឿងនិទានបុរាណខ្មែរនិងបរទេស អ្នកនិពន្ធនិងកាលកំណត់តែង កាលអាកាសនិងតម្លៃអប់រំនៃរឿង ការនិយាយសង្ខេប ការសរសេររឿងនិទានបុរាណខ្លីៗ និងសញ្ញាដំពីរ ។

# លក្ខណៈសំគាល់រឿងនិទានបុរាណខ្មែរ

ក្នុងមេរៀនមុនៗ អ្នកបានសិក្សារួចមកហើយអំពីរឿងនិទានបុរាណទាក់ទងនឹងព្រេងកថា និង ទេវកថា ដែលជាប្រភេទរឿងនិទានបុរាណខ្មែរ ។ ឥឡូវនេះអ្នកនឹងសិក្សាអំពីលក្ខណៈសម្គាល់នៃរឿងនិទានប្រភេទនេះបន្តទៀត ។

## ១ . ភាពប្លែកៗនៃរឿងនិទានបុរាណខ្មែរ

រឿងនិទានបុរាណជាប្រភេទរឿងប្រឌិត ដែលបុព្វបុរសខ្មែរឬអ្នកប្រាជ្ញចាស់ទុំពីបុរាណ បានតាក់តែងឡើង ប្រឌិតឡើងទៅតាមលំនាំរឿងរ៉ាវក្នុងធម្មជាតិនិងវិបត្តិទំនាស់ក្នុងគ្រួសារ ដូចជាការឈ្លោះប្រកែកគ្នារវាងសមាជិកគ្រួសារ ការឈ្លោះទាស់ទែងគ្នារវាងប្តីប្រពន្ធ ការព្យាបាទឬឈ្នានីសគ្នាទៅវិញទៅមកនៅក្នុងសង្គម .... ក្នុងសម័យកាលមួយនៃប្រវត្តិសាស្ត្រ... ដើម្បីបង្ហាញជាសេចក្តីសម្រាប់និទានប្រាប់កូនចៅ ញាតិមិត្តជិតឆ្ងាយ ឱ្យយល់ហេតុផលផ្សេងៗទុកជាការទូន្មាន ប្រៀនប្រដៅណែនាំជនានុជនទូទៅតាមចរិយាធម៌ ច្បាប់ទម្លាប់ប្រពៃណីល្អៗឱ្យបានដឹងតៗគ្នារៀងមក ។

រឿងទាំងនោះមានភាពប្លែកៗ ដោយរឿងខ្លះនិទានអំពីសត្វ រឿងខ្លះនិយាយអំពីធម្មជាតិនិងមនុស្ស រឿងខ្លះទៀតនិយាយអំពីអមនុស្សជាដើម ។

រឿងបែបនេះពីមុនមក មិនបានកត់ត្រាទុកជាសៀវភៅឬក្បួនខ្នាតឡើយ ។ គេចេះចាំតៗគ្នា ហើយនិទានប្រាប់គ្នាទៅវិញទៅមកពីមាត់មួយទៅមាត់មួយ ពីស្រុកមួយទៅស្រុកមួយ រហូតពាសពេញប្រទេស ។ រឿងដែលអ្នកស្រុកនិយមចូលចិត្តក៏ចេះតែលើកយកមកនិទានរហូតដល់ក្លាយទៅជាមានប្រជាប្រិយភាព ហើយក៏មានការចូលចិត្ត ពេញចិត្តពីសំណាក់ប្រជាជនទូទៅ ។

លុះក្រោយមក អ្នកស្រុកបានចាត់ទុករឿងខ្លះដូចជាគំរូនៅក្នុងការរស់នៅដែលមានជាអាទិ ពិធីផ្សេងៗ ការគោរពជាប្រពៃណីហូរហែមកទាំងភូមិ ទាំងស្រុក ទាំងប្រទេសជារៀងរហូតតរៀងដល់សព្វថ្ងៃ ។ ឯរឿងខ្លះត្រូវបានគេគិតថាជារឿងរ៉ាវពិតថែមទៀត ។

ចូលមើលឧទាហរណ៍ខាងក្រោម :

រឿងធនញ្ជ័យ ដែលអ្នកស្រុកខ្មែរទាំងមូលសឹងតែជឿជាក់ថាជារឿងពិត ជឿថាខ្មែរមានអ្នកប្រាជ្ញមួយរូបដែលមានឈ្មោះថាធនញ្ជ័យ ។

រឿងមរណៈមាតា ដែលអ្នកស្រុកចេះចាំ និទានតគ្នាហើយអ្នកស្រុកខ្លះមានជំនឿថា នាងកុលកេសី ប្រពន្ធនាយកុដុម្ពិកៈស្លាប់ហើយទៅកើតជាត្រីដំរី ទើបមានអ្នកខ្លះគេអាណិតអាសូរ ហើយពុំហ៊ានបរិភោគត្រីដំរីទៀតផង ។

រឿងពុទ្ធិសែននាងកង្រី ដែលអ្នកស្រុកខេត្តកំពង់ឆ្នាំងនិយមជឿថាជារឿងពិត ព្រោះមានភ្នំមួយដែលមានទ្រង់ទ្រាយដូចរាងមនុស្សដេកដែលជានិមិត្តរូបនៃសាកសពនាងកង្រីស្លាប់ទៀបនឹងឆ្នេរសមុទ្រ (តែឥឡូវជាទន្លេ) ដើម្បីសម្តែងនូវស្វាមីភក្តិចំពោះពុទ្ធិសែន ។

រឿងអ្នកតាឃ្លាំងមឿង ដែលអ្នកស្រុកខេត្តពោធិ៍សាត់មានជំនឿយ៉ាងមុតមាំ ហើយតែងតែគោរពបូជា ធ្វើពិធីបុណ្យឡើងអ្នកតាជារៀងរាល់ឆ្នាំ ដើម្បីរំឭកដល់គុណបំណាច់នៃវិញ្ញាណក្ខន្ធខ្មោចលោកតា ឃ្លាំង មឿងដែលបានបូជាជីវិតក្នុងបុព្វហេតុការពារទឹកដី ។ល ។

សរុបមក រឿងប្រឌិតខាងលើនេះបានបង្កើតនូវជំនឿ ទំនៀមទម្លាប់ ប្រពៃណី ដែលជិតជាមជាប់ក្នុងដួងចិត្តអ្នកស្រុកដូចមានឈ្មោះ ទីកន្លែង ភូមិស្រុក ឃុំ ...ឬឈ្មោះក្នុងប្រវត្តិសាស្ត្ររហូតមកហើយត្រូវបានគេចងក្រងទុករឿងទាំងនោះថាជារឿងព្រេងឬព្រេងកថា ។ ដូចនេះរឿងនិទានបុរាណខ្មែរគឺជារឿងប្រឌិត ឬរឿងព្រេងបែបខាងលើ ។

*(សិក្សាអត្ថបទ "សិក្សាស្នាដៃអក្សរសិល្ប៍ខ្មែរ" របស់លោក លាង ហាប់អាន បោះពុម្ពលើកទី ១ ឆ្នាំ១៩៦៦)*

*រឿងនិទានបុរាណខ្មែរ គឺជារឿងប្រឌិតដែលបុព្វបុរសខ្មែរឬអ្នកប្រាជ្ញចាស់ទុំពីបុរាណបានគាត់តែងប្រឌិតឡើង ដោយលើកយកនូវរឿងរ៉ាវទាក់ទងនឹងវិបត្តិទំនាស់បន្តិចបន្តួចក្នុងគ្រួសារ ក្នុងសង្គម ក្នុងសម័យកាលមួយដ៏យូរលង់មកហើយនៃប្រវត្តិសាស្ត្រ មកលើកជាសេចក្តីសម្រាប់និទានប្រាប់តៗគ្នា ពីមាត់មួយទៅមាត់មួយ ពីស្រុកមួយទៅស្រុកមួយ ពាសពេញផ្ទៃប្រទេស ហើយក្លាយជាការនិយមពេញចិត្ត ជក់អារម្មណ៍ ហើយចេះចាំស្ទាត់គ្រប់ៗគ្នា ។*

## ២ . លក្ខណៈសម្គាល់រឿងនិទានបុរាណខ្មែរ

រឿងនិទានបុរាណខ្មែរមានលក្ខណៈសម្គាល់ខុសពីរឿងសម័យទំនើបលើផ្នែកសិល្បវិធីនិពន្ធ ក៏ដូចជាអត្ថន័យ អត្ថរូប និងអត្ថរស ។

រឿងនិទានបុរាណខ្មែរមានលក្ខណៈសម្គាល់ដូចតទៅ ៖

### ក. អត្ថន័យ

រឿងនិទានបុរាណខ្មែរ ទោះជាប្រឌិតកថាក្តី ព្រេងកថាក្តីជាទូទៅច្រើនយកបញ្ហាជីវិត ក្នុងសង្គមនាសម័យកាលណាមួយមកចោទនិងដោះស្រាយ ដូចជាការទាស់ទែងខ្វែងគំនិត ការប្រច័ណ្ឌផិតក្បត់ប្តីប្រពន្ធ ការច្រណែនឈ្នានីសសងសឹក ព្យាបាទគ្នា រឿងរ៉ាវក្តីក្តាំអំពីកេរមរតក ឬវិវាទផ្សេងៗដែលកើតទៅជាការប្រទូស្តរ៉ាយ ឡើងតុលាការដោយសារទាស់ខ្វែងសម្តីគ្នាក្នុងគ្រួសារឬជាមួយ

អ្នកដទៃ ។ ឯរឿងមួយបែបទៀតច្រើនទាក់ទងនឹងប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ទំនៀមទម្លាប់ប្រពៃណី ជំនឿឬសាសនា ។ លក្ខណៈទាំងនេះបាននាំរឿងនិទានទៅជារឿងព្រេង ។

តួអង្គក្នុងរឿងនិទានបុរាណខ្មែរភាគច្រើនជាមនុស្ស ហើយមានគ្រប់ស្រទាប់វណ្ណៈ។ ប៉ុន្តែជាទូទៅគេច្រើនផ្តោតទៅលើប្រជាជនសាមញ្ញ។ ទោះបីគេយកតួអង្គសត្វ ធម្មជាតិ អមនុស្ស ទេវតា យក្ស ខ្មោចព្រាយ ។ល។ មកធ្វើជាតួអង្គក៏ដោយក៏ដើម្បីជានិមិត្តរូបតំណាងឱ្យមនុស្សគ្រប់ប្រភេទទាំងល្អ ទាំងអាក្រក់នៅក្នុងសង្គមដែរ ។

*ឧទាហរណ៍ :* ក្នុងរឿងសុភាទន្សាយ តួអង្គទន្សាយតំណាងឱ្យមន្ត្រីតុលាការប្រកបដោយគតិបណ្ឌិត សុចរិត យុត្តិធម៌ មានសុភវិនិច្ឆ័យ បរិបូណ៌ដោយវិចារណញ្ញាណ ។

តួអង្គអ្នកតាទឹក អ្នកតាភ្នំ តំណាងឱ្យមនុស្សល្អនិងអាក្រក់ ដែលមានទំនាស់ក្តីក្តាំនឹងគ្នានៅក្នុងការស្តីដណ្តឹងកូនក្រមុំតាយាយមកធ្វើជាភរិយា រួចកើតការខឹងសម្បាដណ្តើមនាងជាភរិយារៀងៗខ្លួន ហើយបង្កឱ្យមានព្យុះភ្លៀងទឹកជំនន់ (អ្នកតាទឹក) ដើម្បីប្រឆាំងគូបដិបក្ខ (អ្នកតាភ្នំ) ឱ្យលិចលង់វិនាសអន្តរាយ ... ។

លក្ខណៈសម្គាល់អត្ថន័យនៃរឿងបុរាណខ្មែរគឺ

- **សង្គមបរិយាកាស** គឺខ្មែរតាំងពីបុរាណដូចជា ទំនៀមទម្លាប់ប្រពៃណី ទាក់ទងនឹងប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ...
- **តួអង្គ** ជារាស្ត្រ សេដ្ឋី មន្ត្រី ខ្ញុំកំដរ តំណាងឱ្យមនុស្សគ្រប់ស្រទាប់វណ្ណៈនិងមានតួអង្គសត្វដូចជា ទន្សាយ ចចក ខ្លា គោ ។ល។ តួអង្គទេវតា អារុក្ខអារក្សអ្នកតា យក្ស ខ្មោចព្រាយ បិសាច ។ល។ តំណាងឱ្យសភាវៈល្អនិងអាក្រក់របស់មនុស្សទាំងអស់ ។
- **កាលអាកាស** ជារឿងស្ថិតក្នុងសម័យដើមរបស់ខ្មែរ ។ ជារឿងស្ថិតនៅក្នុងស្រុក ភូមិ ឬកន្លែងណាមួយ(ជួនមានឈ្មោះ ជួនក៏ពុំមានឈ្មោះ)ហើយទាក់ទងទៅនឹងការប្រកបអាជីវ កម្មរបស់ខ្មែរពិតៗ
- **ចលនារឿង** មានលក្ខណៈខ្លីៗមានបញ្ហាទំនាស់វិបត្តិរវាងខ្លួនឯងនិងអ្នកដទៃ បញ្ហាទំនាស់ខ្លួនឯងនឹងគ្រួសារអ្នកដទៃ និងបញ្ហាទំនាស់រវាងអ្នកដទៃនឹងគ្រួសារខ្លួនឯង ។ល ។
- មានបញ្ហាចោទនិងស្រាយចំពោះមនុស្សលោកិយបច្ចុប្បន្ន ដោយអប់រំឱ្យយើងខិតខំត្រិះរិះដោះស្រាយបញ្ហារស់នៅក្នុងសង្គមខ្មែរគ្រប់បែបយ៉ាងមកចោទនិងដោះស្រាយតាមលក្ខណៈមនុស្ស ឬស្របនឹងរឿងបច្ចុប្បន្ន ។

*ឧទាហរណ៍ :* រឿងពស់កេងកងនិងរឿងមាយាស្ត្រី គឺចោទទៅលើបញ្ហាផិតក្បត់ប្ដី ហើយស្រាយបញ្ហានេះតាមរយៈការអប់រំដោយការធ្វើទោសទណ្ឌ (រឿងពស់កេងកង) ឬស្រាយបញ្ហាដោយប្រើមធ្យោបាយលុបលាងទោសកំហុសតាមរយៈបញ្ញា (រឿងមាយាស្ត្រី) ។

## ខ. អត្ថរូប

ជាទូទៅ រឿងនិទានបុរាណខ្មែរមានការតាក់តែងឡើងដោយមានឯកភាពទាំងការផ្ដើមរឿង ដំណើររឿង ក៏ដូចជាការបញ្ចប់រឿងដោយឱ្យតម្លៃលើឧត្តមគតិ ... ។

រឿងនិទានបុរាណខ្មែរមានលក្ខណៈសម្គាល់ផ្នែកអត្ថរូបដូចខាងក្រោម :

- ជាអត្ថបទពាក្យរាយខ្លះដូចជាប្រជុំរឿងព្រេងភាគ ១ ២ ៣ ៤ ... ៩ និងជាអត្ថបទពាក្យកាព្យខ្លះ ដូចជារឿងសុភាទន្សាយ ... ។
- ជារឿងបែបរៀបរាប់ និទានរ៉ាយរ៉ាប់ តំណាលពីអ្វីមួយ
- មានប្រើពាក្យសម្ដីសាមញ្ញ ពាក្យអ្នកស្រុកជាន់កណ្ដាល ជាន់ទាប គ្មានពាក្យ បាលីសំស្ក្រឹតទេ ដូចជា ស៊ី ផឹក ដុះ មី អា ហាង ង៉ែង មេនេះ ឯង អញ អានោះ អាដែង ។ល ។
- ឃ្លាប្រយោគមិនសូវពេញលេញតែស្ដាប់បាន ហើយពុំមានទម្រង់ជាល្បះស្មុគស្មាញទេ ។
  *ឧទាហរណ៍ :* ធនញ្ជ័យតបថា បើមីងឱ្យខ្ញុំរើស(ត្រល់)តើឱ្យអ្វីខ្ញុំ ? ប្រពន្ធសេដ្ឋីឆ្លើយថា អញឱ្យអំបុកឯងស៊ី ... ។
- ក្នុងការផ្ដើមរឿង អ្នកនិពន្ធប្រើពាក្យ កាលពីព្រេងនាយមាន ....ចាស់ៗតំណាលថា ......គេតំណាលតៗគ្នាថា ......កាលពីដើម ......កាលដើមឡើយ ........កាលនោះមាន .......នេះនឹងស្រដីឡើង .........អតីតនិទាននេះជារឿងព្រេងពុំដឹងកើតមកពីជំនាន់ណា ......នេះនឹងថ្លាថ្លែងដំណើរដំណែងតំណាលពីមុនមាន ។ល ។ រួចចូលដល់ដំណើររឿងតែម្ដង ។

  *ឧទាហរណ៍ :*

  - មានតំណាលថា ព្រះអាទិត្យ ព្រះពាយ ព្រះពិរុណ និងព្រះចន្ទ្រជាបងប្អូនបង្កើតនឹងគ្នា ... ។ (រឿងព្រះចន្ទ្រ)
  - កាលពីព្រេងនាយ នគរកម្ពុជាមានឈ្មោះថា "កោះគោកធ្លក" ព្រោះមានដើមធ្លកមួយដើមដុះនៅលើកោះនោះ ។ មានរឿងតំណាលថា ... (រឿងព្រះថោងនាងនាគ) ។
  - កាលដើមឡើយ មានបុរសម្នាក់ចេះចាក់ស្នុក ។ បុរសនោះចង់បានខ្ញុំបម្រើប្រើក៏ឡើងទៅចាក់ស្នុកនៅលើចុងត្នោត ...(រឿងចៅចាក់ស្នុក) ។

## គ. អត្ថរស

អត្ថរសគឺជាតម្លៃនៃរឿង ។ អត្ថរសក្នុងប្រភេទរឿងនិទានបុរាណខ្មែរភាគច្រើនលើកយកហេតុការណ៍ក្នុងសម័យកាលមួយមកលាតត្រដាង ដើម្បីបង្កើតនូវរសពិសេសមួយហៅថា "តថរស" ។ ចំណែកដំណើររឿង ជួនកាលមានភាពកម្សត់ ជួនកាលកំប្លែងធ្វើឱ្យទប់សំណើចមិនបាន ។ រឿងខ្លះប្រកបដោយភាពតានតឹងឬពេលខ្លះធូរស្រាលដែលបង្កើតបានជារសពិសេសថែមទៀត គឺ"នាដ្យរស" និង"ហាសរស" ។ ម្យ៉ាងទៀតដោយហេតុថារឿងនិទាន ច្រើនលើកយកបញ្ហាសង្គមរបស់មនុស្សមកឆ្លុះបញ្ចាំងនិងលាតត្រដាងផងនោះ ទើបធ្វើឱ្យរឿងប្រភេទនេះមានតម្លៃឬរសដោយឡែកមួយថ្មីទៀត គឺ "សង្គមរស" ។ ម្យ៉ាងទៀតដោយសាររឿងនិទានបុរាណជាប្រភេទប្រឌិតកថាឬព្រេងកថា ដែលមានអត្ថរូបប្រកបដោយសេចក្ដីផ្ដើម ដំណើររឿង និងឧត្ដមគតិរឿងជាការបញ្ចប់រឿងដែរនោះ រឿងប្រភេទនេះមានបច្ចេកទេសរសរបស់ខ្លួនមួយទៀត ដែលមានឈ្មោះថា "ប្រឌិតរស" ឬ "ព្រេងរស" ។

ដូចនេះ លក្ខណៈសំគាល់រឿងនិទានបុរាណខ្មែរ ផ្នែកអត្ថរសគឺសំដៅរសរបស់រឿងឬតម្លៃរបស់រឿង ដែលអ្នកនិពន្ធចេះតាក់តែង លើកយកបញ្ហាមួយចំនួនមកលាតត្រដាង :

- ការពិតក្នុងសង្គម ហៅថា តថរស
- ភាពកំប្លុកកំប្លែង ហៅថា ហាសរស
- ភាពកម្សត់ ហៅថា នាដ្យរស
- បញ្ហាសង្គមរបស់មនុស្ស ហៅថា សង្គមរស ។ល។

## ឃ. ដំណើររឿង

ក្នុងដំណើររឿងនិទានបុរាណ គេច្រើននិយាយរៀបរាប់យ៉ាងឆាប់រហ័ស ដោយពុំមានបរិយាយរៀបរាប់ធម្មជាតិ ទេសភាពលន្លង់លន្លោច ស្រងេះស្រងោច ... ដូចរឿងសម័យទំនើបឡើយ ។ ពិសេសការនិយាយ ការរចនាឬការប្រើប្រាស់ពាក្យពេចន៍ឬពាក្យសម្ដី ឃ្លាប្រយោគច្រើនខ្លីៗច្បាស់លាស់ ជាពាក្យសាមញ្ញ ងាយស្ដាប់ងាយយល់ ពោលគឺពុំមានប្រើពាក្យពិបាកៗឬពាក្យវប្បធម៌ខ្ពង់ខ្ពស់អ្វីឡើយ ។ *ឧទាហរណ៍ :* សម័យថ្ងៃមួយ បងប្អូនទាំងបួននាក់បានទៅចូលរួមក្នុងពិធីជប់លៀងមួយដែលមានម្ហូបអាហារពោរពាស ។ ព្រះអាទិត្យ ព្រះពាយ ព្រះពិរុណ ទាំងបីនាក់ស៊ីឆ្អែតបរិបូណ៌មិនគិតគូរដល់ម្ដាយសោះ ។ មានតែព្រះចន្ទមួយទេដែលជាកូនពៅបានយកបង្អែមទៅផ្ញើម្ដាយ ។ ម្ដាយខឹងយ៉ាងខ្លាំងក៏ជេរប្រទេចពួកអ្នកល្មោភស៊ី "អំណឹះតទៅពួកឯងទាំងអស់គ្នានឹងត្រូវគេស្អប់គ្រប់ទីកន្លែង" ។ ប៉ុន្តែអ្នកម្ដាយឱ្យពរព្រះចន្ទ "អំណឹះតទៅ នៅកន្លែងណាក៏ដោយក៏ត្រូវគេស្វាគមន៍អបអររីករាយ ជាមួយកូន"(រឿងព្រះចន្ទ) ។

## ៣ . គម្លៃអប់រំ

រឿងនិទានបុរាណខ្មែរ គេច្រើនលើកឡើងពីដំណើររឿងផ្សេងៗដោយឡែកពីគ្នា ទៅតាមស្ថានភាពស្រុកទេសយើង ដោយបង្ហាញនូវគំនិតអប់រំឱ្យមនុស្សទូទៅឱ្យចេះស្រឡាញ់យុត្តិធម៌ ប្រព្រឹត្តអំពើល្អ លះបង់អំពើអាក្រក់ ស្រឡាញ់ចំណេះវិជ្ជា មិនលោភលន់ មិនកេងប្រវ័ញ្ច មានអធ្យាស្រ័យល្អ មានសាមគ្គីភាព ចេះជួយទុក្ខធុរៈគ្នាទៅវិញទៅមក មានបម្រុងប្រយ័ត្ន ចេះអត់ឱននិងលើកលែងទោសដល់គ្នានិងផ្តល់ដំបូន្មាន ចរិយាសាស្ត្រ ច្បាប់ទម្លាប់ ប្រពៃណីល្អៗ គតិល្អៗទុកជាការប្រៀនប្រដៅកូនចៅជំនាន់ក្រោយ ។

## ៤ . សេចក្តីបញ្ចប់

រឿងនិទានបុរាណច្រើនបញ្ចប់ដោយប្រារព្ធប្រាប់នូវឧត្តមគតិឬបង្ហាញនូវគតិឬគំនិតល្អៗឬជាពាក្យទូន្មានប្រៀនប្រដៅ ជាដំបូន្មាន ជាពាក្យហាមប្រាម ឬជាសុភាសិត សម្រាប់ជាការពិចារណា ឬទុកជាបទពិសោធក្នុងជីវិត ... ។

*ឧទាហរណ៍ :* ចាប់តាំងពីពេលនោះមក កាលណាមានថ្ងៃក្តៅខ្លាំង មានខ្យល់ មានភ្លៀងខ្លាំង តែងមានមនុស្សត្អូញត្អែរ មិនចូលចិត្តជានិច្ច ។ ប៉ុន្តែគេនាំគ្នាសប្បាយរីករាយទាំងសកលនឹងពន្លឺ រស្មីដ៏ស្រទន់នៃព្រះចន្ទឬលោកខែទៅវិញ (រឿងព្រះចន្ទ) ។

## លំហាត់

១. ប្អូនធ្លាប់សិក្សារួចមកហើយនូវរឿង មួយចំនួនដូចខាងក្រោម ឥឡូវនេះ ចូរប្អូនអានចំណងជើង :

រឿងទាំងនេះរួចបង្ហាញថា តើរឿងណាជារឿងនិទានបុរាណខ្មែរ ?

រឿងមិត្តសានិត រឿងអាកុហកស៊ី រឿងកុំត្រាប់តាមបង រឿងចង្កឹះមួយបាច់ រឿងប្រាសាទស្វាយអង្គ រឿងអ្នកតាទឹក អ្នកតាភ្នំ រឿងចចក រឿងត្រីចំពុះដាវ រឿងចៅចាក់ស្មុគ រឿងខ្ញុំខុសហើយ ។

២. ចូរបង្ហាញលក្ខណៈសម្គាល់រឿងនិទានបុរាណមួយចំនួនដូចខាងក្រោម :

- រឿងចចក រឿងសង្គ្រាមរវាងគីង្គក់និងតាព្រហ្ម រឿងចៅចាក់ស្មុគ ។



## ក. សិក្សាពាក្យគន្លឹះ

- ជវ៉ន (ន) : កម្លាំងដែលស្ទុះលឿន ។
- អស្សូ (ន) : សេះ ។
- មរណ៍ (ន) : សេចក្ដីមរណៈ សេចក្ដីស្លាប់ ។
- ព្រះភូធររាជ (ន) : ព្រះរាជាអ្នកទ្រទ្រង់នៅលើផែនដី ។
- ភូបាល (ន) : អ្នកគ្រប់គ្រងរក្សាផែនដី ។
- ហឫទ័យ (ន) : ចិត្ត បេះដូង ។
- បារម្ភ (ន) : ការព្រួយ ។
- សីមា (ន) : ព្រំប្រទល់ ព្រំដែន ។
- មកុដ (ន) : គ្រឿងប្រដាប់ធ្វើដោយមាសសុទ្ធមានរាងក្រឡូមមានកំពូលរំលេចដោយក្បាច់ រចនាល្អវិចិត្រ ដាំត្បូងសម្រាប់ក្សត្រទ្រង់រាជ្យពាក់ព្រះសិរ ។
- ព្រះថនា (ន) : សុដន់ ដោះ ។
- សិរសា (ន) : ក្បាល ។

- ពពារ (ន) : អាការសម្បើមរបស់ពស់ដែលប្រឹងដំឡើងកឱ្យរីកធំជាងប្រក្រតី ។
- មហិមា (គុ) : ដែលធំ ។
- ទៀប (អា. និ) : ក្បែរ ជិត ។ ឧទាហរណ៍ : ម៉ោង ៤ទៀបភ្លឺ ។
- យាត្រា (កិ) : ដើរចេញ ចេញចរ ។
- ជៀសជ័យ (គុ) : ដែលមានជ័យជំនះលើអ្នកដែលជាចម្បង ។
- និមល (គុ) : ដែលឥតមានសៅហ្មង ។
- បពិត្រ (ន) : ពាក្យសម្រាប់បព្វជិតក្នុងពុទ្ធសាសនាហៅក្សត្រិយ៍ សេនាបតី ។
- មណ្ឌល (ន) : តំបន់ ទីប្រជុំ ។
- អសារ (គុ) : ដែលឥតខ្លឹមសារ ឥតប្រយោជន៍ ដែលគ្មានតម្លៃ ។
- ឧត្តម (គុ) : ដែលខ្ពង់ខ្ពស់ ល្អប្រសើរថ្លៃថ្លា ។
- ឥស្សូរ (គុ) : ដែលជាធំចម្បង ជាកំពូលលើគេ ជាម្ចាស់លើគេ ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទកាព្យខាងក្រោម ចូរអ្នកអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរមួយចំនួនទាក់ទងនឹងលក្ខណៈសម្គាល់របស់រឿងបុរាណ អ្នកនិពន្ធ កាលកំណត់តែង និងកាលអាកាសរឿង ។

### រឿងមាយើង

(បទកាកគតិ)

១. មាយើងដាស់ស្តេច ឆាប់មួយរំពេច ទើបទូលទៅថា
បពិត្រស្តេចឡើង ជវីនអស្សា ឆាប់ៗម្ទីម្ទា
ឥឡូវនេះនៃ ។

២. ត្បិតមានទេពតា និត្យនៅរក្សា លើដើមព្រះជ្រៃ
ខឹងថាស្តេចនឹង និយាយហើយនៃ ផ្តំលក់រឹងរៃ
ស្ងៀមស្ងាត់ភាសា ។

៣. ខ្ញុំចាំស្តេចផ្ទំ រលីវទៅខ្ញុំ ឮពាក្យទេពតា
ស្តេចស្តាប់មាយើង ស្ទុះឡើងអស្សពាហ៍ បំផាយម្ទីម្ទា
មាយើងដោយជិត ។

៤. ក្សិណមែកព្រះជ្រៃ ធ្លាក់ផុតក្សត្រថ្លៃ ព្រះបាទព្រហ្មទត្ត
ស្តេចទៅរំលង ពីភ័យមរណ៍ថ្វាត់ ទើបមាយើងគិត
ទូលទៅទៀតថា ។

៥. បពិត្រព្រះភូ ធររាជឥសូរ នេះឯងមួយគ្រា
មួយទៀតខ្ញុំព្ន ពាក្យអស់ទេពតា ថាដល់សីមា
ព្រះអង្គនាយនោះ ។

៦. នឹងកាច់ខ្លោងទ្វារ សង្កត់ភូបាល រឹងរិញទៀតស្មោះ
ថាបើកន្លង រំលងពីនោះ លុះព្រះអង្គឆ្ពោះ
ចូលក្នុងបន្ទំ ។

៧. នឹងប្រែកាឡា ជាពស់មហិមា ខាំក្សត្រឧត្តម
បពិត្រក្សត្រា ទេពតាជំនុំ ដូច្នេះនេះខ្ញុំ
ព្នជាក់តែម្តង ។

## បទពំនោល

៨. មហាក្សត្រព្រហ្មទត្តច្បាស់ច្បង ស្តេចស្តាប់ទំនង ទំនួលនៃថៅមាយើង ។
៩. ទើបមហាក្សត្រថ្កុលថ្កើង ថាច្នោះមាយើង ប្រយ័ត្ននៅខ្លោងទ្វារនោះ ។
១០. ថៅកាន់រំពាត់វាត់គោះ ចេះជួយតឿនស្មោះ ឱ្យរួចពីភ័យទ្វារធំ ។
១១. ស្តេចមានហឫទ័យបារម្ភ បរសេះខែងខំ លុះទៀបនៃខ្លោងទ្វារនោះ ។
១២. ក្សត្រថ្កើងមាយើងវាត់គោះ សេះសោតលោតផ្លោះ ច្រៀវច្រូចគ្រលួចមហិមា ។
១៣. បាក់ខ្លោងទ្វាររាជសីមា ផុតមហាក្សត្រា ក៏រួចរំលងពីក្ស័យ ។
១៤. លុះដល់មណ្ឌលទិព្វថ្លៃ ថៅមាយើងវៃ ក្រាបលាទៅថ្កានគ្រឹះស្ថាន ។
១៥. ព្រះបាទព្រហ្មទត្តទ្រង់មាន បន្ទូលផ្តាំថ្កាន ថាចូរថៅទៅហោងណា៎ ។
១៦. ហើយថៅវិលវិញយាត្រា មកឆាប់មិ៑ម្នា ថៅចាំដូចថៅព្នហោង ។
១៧. មាយើងក្រួញក្រាបទូលស្នង បពិត្រនេះម្តង កុំព្រួយព្រះរាជហឫទ័យ ។
១៨. បានទៅនៅវិលរឹងវៃ ចាំក្សត្រជៀស្នជ័យ ដ៏ជាមកុដសិរសា ។
១៩. ទូលស្រេចមាយើងមិ៑ម្នា មកផ្ទះអាត្មា ប្រាយប្រាប់ភរិយាអស់ក្តី ។

[ ... ]

២០. មាយើងនោះនិងភរិយា ហួបបាយហើយណា ក៏កាន់ដាវឡើងទៅចាំ ។

២១. អង្គុយជិតនៅកៀនឃ្លាំង ក្នុងចុងរោងរាំ ព្រះបាទសម្តេចព្រហ្មទត្ត ។

២២. មន្ត្រីក្រាស់ក្រៃច្រើនក្តាត់ ប្រុងប្រាណប្រយ័ត្ន ដ៏ពេញនៅរាជរោងរម្យ ។

២៣. លុះដល់អធ្រាត្រដាស់ទុំ ដេកស្ងាត់ជ្រងំ ពុំភ្ញាក់ដល់ម្នាក់ឡើយណា ។

២៤. កាលនោះឯងឯទេពតា ប្រាណប្រែកាឡា ជាតិជាពស់ទៅហោង ។

២៥. ទំហំពស់ធំកន្លង ប៉ុនដើមត្នោតផង ក៏លើកពពារគួរខ្លាច ។

២៦. មានភ្នែកនោះធំត្រដាច ចង្កូមសស្វាច នឹងខាំព្រះនៃមហាក្សត្រា ។

២៧. មាយើងដោះឡើងម៉ឺម្នា លើកខាន់មុតថ្លា ក៏វាត់ត្រូវសិរសាសល់ ។

២៨. ឈាមពស់ខ្ទាត់ខ្ទាយទៅដល់ ទេពីនិមល ក៏ពេញនាព្រះថនា ។

២៩. ទើបចៅមាយើងគិតថា ពស់នេះមរណា អសារសោះសូន្យជីវី ។

*(ដកស្រង់ និងសម្រួលពីសៀវភៅប្រជុំរឿងព្រេងភាគ ៤)*

## សំណួរ

១. តើអត្ថបទកាព្យខាងលើនិយាយពីអ្វី ?

២. តើមាយើងនិងព្រះបាទព្រហ្មទត្តនៅឯណា ? កំពុងធ្វើអ្វី ?

៣. តើទេពតាខឹងនឹងព្រះរាជាពីរឿងអ្វី ?

៤. តើមាយើងជាសេនាដែលមានទឹកចិត្តដូចម្តេច ចំពោះព្រះរាជា ?

៥. តើអត្ថបទខាងលើនេះ ជាកាព្យប្រភេទណា ?

៦. ចូររកចំណាប់ចួនក្នុងវគ្គនិងចំណាប់ចួនឆ្លងវគ្គ ក្នុង ២វគ្គខាងដើមនិង ៣វគ្គខាងក្រោយដោយគូរគំនូសតាងជាពងត្រីបញ្ជាក់ ។

៧. ចូរបង្ហាញពីលក្ខណៈរឿងមាយើង ។

# សញ្ញាដំពីរ (៖)

ក្នុងមេរៀនមុនអ្នកបានសិក្សារួចមកហើយពីសញ្ញាដំពីរ (៖)។ ក្នុងមេរៀននេះអ្នកនឹងសិក្សាពីសញ្ញាដំពីរ (៖) បន្តទៀត ។

ចូរអ្នកសង្កេតល្បះខាងក្រោម ៖

១. ភាពស្មោះត្រង់របស់មនុស្សសម្ដែងឡើងតាមលក្ខណៈពីរយ៉ាង ៖ វាចានិងកម្ម ។

២. អត្ថបទនោះសរសេរជាអាទិ៍ ៖ ក្នុងមួយជីវិតរស់របស់មនុស្សគ្មានអ្វីប្រសើរជាងសេចក្ដីល្អនិងភាពស្មោះត្រង់ចំពោះគ្នានោះទេ ។

៣. បុប្ផានិយាយ ៖ "ថ្ងៃនេះខ្ញុំត្រូវទៅសាលា ព្រោះខ្ញុំត្រូវប្រឡង" ។

៤. តារាតបវិញ ៖ "ខ្ញុំក៏ត្រូវទៅសាលាប្រឡងដែរ" ។

៥. គ្រានោះថែមទាំងមានសត្វរាត្រីចរយំស្រែកជុំវិញខ្លួនយើង ៖ ខ្លះមានសំឡេងដូចកូនង៉ែតស្រែក ខ្លះដូចជាមនុស្សថ្ងូរ បណ្ដាលឱ្យយើងរឹតតែព្រឺព្រួចទ្វេឡើងទៀត ។

តាមការសង្កេតល្បះទាំង៥ខាងលើនេះ យើងឃើញថាក្នុងល្បះនីមួយៗសុទ្ធតែប្រើសញ្ញាដំពីរ (៖)។ ប៉ុន្តែសញ្ញានីមួយៗក្នុងល្បះសុទ្ធតែមានមុខងារខុសៗគ្នាដូចជា

- ល្បះទី១ : បង្ហាញការពង្រីកសេចក្ដី
- ល្បះទី២ : បង្ហាញសម្រង់សេចក្ដី
- ល្បះទី៣ : បង្ហាញសម្ដីផ្ទាល់ ឬកថាផ្ទាល់ ( របស់អ្នកនិយាយ )
- ល្បះទី៤ : បង្ហាញសម្ដីផ្ទាល់ឬកថាផ្ទាល់
- ល្បះទី៥ : បង្ហាញសេចក្ដីពន្យល់ ។

*សញ្ញាដំពីរ គឺជាសញ្ញាសម្រាប់ប្រើនៅចន្លោះសង្កេតសេចក្ដីក្នុងល្បះ ។*

## លំហាត់

ចូរអ្នកតែងល្បះដែលមានប្រើសញ្ញាដំពីរ (៖) តាមប្រភេទមុខងារទាំង៤ ដូចបានសិក្សាខាងលើឱ្យបាន៤ល្បះ ។

# អាជ្ជវៈគឺការត្រង់



## ក. សិក្សាពាក្យគន្លឹះ

- មាត្រ (ន) : ការវាស់ ការថ្លឹង ការស្ទង់ ។
- ទសពិធរាជធម៌ (ន) : រាជធម៌ទាំង១០យ៉ាង ឬ១០ប្រការរបស់ព្រះរាជាទ្រង់ប្រព្រឹត្តនិងណែនាំពួកនាម៉ឺន សេនា មន្ត្រីតូចធំ និងប្រជានុរាស្ត្រឱ្យប្រព្រឹត្តផងដូចខាងក្រោម :

១. ការធ្វើទាន ២. ការប្រកាន់សីល ៣. ការបរិច្ចាគ ៤. គឺការលះបង់ ៥. មទ្ទវៈ សេចក្តីទន់ភ្លន់ ៦. តថៈ ការកាន់ឧបោសថសីលតាមកាលកំណត់ម្តងៗ ៧. អក្កោធនៈ មិនធ្វើឱ្យអ្នកដទៃក្តៅក្រហាយ ៨. អវិហឹសា មិនបៀតបៀនអ្នកដទៃ ៩. ខន្តី មានសេចក្តីអំណត់ ១០.អវិរោធនៈមិនបំពានលើធម៌ លើច្បាប់ ។

- ធម្មៈ (ន) : សភាវៈទ្រទ្រង់សត្វលោក (មានបាបបុណ្យ សុចរិត ទុច្ចរិត) ។
- អាជ្ជវៈ (ន) : សេចក្តីត្រង់ ។
- ទសបារមី (ន) : បារមី ១០យ៉ាង ចរិយាដ៏លើសលប់ ឬគុណជាតិដ៏ល្អ ដែលគួរបំពេញ

១. ទាន ២. សីល ៣. នេក្ខម្ម : ការបួស ៤. បញ្ញា : ការដឹងច្បាស់នូវសេចក្តីពិត ៥. វីរិយៈ ការព្យាយាម ៦. ខន្តី : សេចក្តីអត់ធន់ ៧. សច្ចៈ ការកាន់សម្តីពិត មិនវើរុះ

៨. អធិដ្ឋាន : ការអធិដ្ឋានឱ្យឃើញជាក់ស្តែងតាមហេតុពិត ៩. មេត្តា : ការផ្សាយសេចក្តីរាប់អាន ចំពោះសព្វសត្វមិនរើសមុខ ។ ១០. ឧបេក្ខា : ដំណើរតាំងចិត្ត ដោយស្មោះស្មើ ។

- ករណីយកិច្ច (ន) : កិច្ចដែលត្រូវធ្វើ ។
- អង្គុលីលេខ (ន) : គ្រឿងប្រដាប់វាយពុម្ពអក្សរ ដោយចុងម្រាមដៃ ម៉ាស៊ីនវាយពុម្ពអក្សរ ។
- ព្រះសម្មាសម្ពុទ្ធ (ន) : លោកអ្នកត្រាស់ដឹង ព្រះនាបាទព្រះសម្ពុទ្ធ ។
- តម្រា (ន) : សេចក្តីកត់ត្រាទុក រឿងដែលកត់ត្រាទុកដោយសង្ខេប ក្បួន ។
- អន្តរាយ (ន) : សេចក្តីវិនាសហិនហោច សេចក្តីវិនាសបាត់បង់ ។
- ទោសពៃរ៍ (ន) : ទោសនិងពៀរ ទោសជាពៀរ ។
- ពុទ្ធវចនៈ (ន) : ពាក្យសម្តីរបស់ព្រះពុទ្ធ ។
- អាសន្ន (ន) : ពេលមានគ្រោះភ័យជិតមកដល់ គួរខ្លាច ។
- ភក្តីភាព (ន) : ភាពស្មោះត្រង់ ។
- បដិបត្តិ (ន) : ការប្រតិបត្តិ ការធ្វើតាម ការប្រព្រឹត្ត ។
- សច្ចៈ (ន) : សេចក្តីពិត ទៀងទាត់ ទៀងត្រង់ ។
- កម្ម (ន) : អំពើ ទោះអំពើល្អក្តី អាក្រក់ក្តី ។
- ចេតនា (ន) : គំនិតដែលនាំឱ្យចិត្តភ្ញាក់ ឬផ្តួចផ្តើម ។
- បដិញ្ញាកម្ម (ន) : ការកំណត់ពាក្យសម្តីឱ្យដឹងគ្នាទៅវិញទៅមក ។
- ព្រឹត្តិកម្ម (ន) : អំពើ កិច្ចការ ការប្រព្រឹត្តទៅ ការរស់នៅ ការចិញ្ចឹមជីវិត ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទខាងក្រោម សូមអ្នកអានដោយយកចិត្តទុកដាក់ ដើម្បីឆ្លើយសំណួរមួយចំនួនទាក់ទងសេចក្តីលំអិតសំខាន់និងតម្លៃអប់រំនៃអត្ថបទឱ្យបានត្រឹមត្រូវ ។

## គ. អត្ថបទ

កាលណានិយាយពីពាក្យ "ត្រង់" គេតែងតែនឹកដល់បន្ទាត់ដែលជាឧបករណ៍មាត្រដ្ឋានសម្រាប់គូសបន្ទាត់ ។ បើគេចង់ដឹងថាគំនូសណាមួយ ឬខ្សែណាមួយត្រង់ ឬមិនត្រង់ ឬវៀចខ្លាំងប៉ុណ្ណា គេត្រូវយកគំនូសនោះទៅផ្ទៀបនឹងបន្ទាត់ត្រង់ ។ ដូចគ្នានេះដែរ "ត្រង់" កាលណាគេប្រើជាមួយមនុស្ស ដូចជា "មនុស្សត្រង់" គឺសំដៅទៅលើលក្ខណសម្បត្តិរបស់មនុស្សដែលជាមាត្រដ្ឋាន ឬគំរូសម្រាប់យក

ទៅវាស់វែងមនុស្សដទៃទៀត ។ ដូច្នេះ អ្នកដឹកនាំទាំងឡាយដែលជាមនុស្សប្រមុខគេនោះ ត្រូវតែជាមនុស្សត្រង់ព្រោះថា បើប្រធានទាំងឡាយមិនត្រង់ អ្នកនៅខាងក្រោមទាំងឡាយ ក៏នឹងមិនត្រង់ជាបន្តបន្ទាប់ជាមិនខាន ។ ឯការដែលមិនត្រង់នោះ យើងដឹងគ្រប់គ្នាហើយថា គឺការកោងកាច វៀចវេរ ក្រងិចក្រងក់នេះឯង ។

ក្នុងទសពិធរាជធម៌ ដែលជាធម្មៈទាក់ទងនឹងការគ្រប់គ្រងផ្លូវលោក ព្រះសម្មាសម្ពុទ្ធទ្រង់ប្រើពាក្យអាជ្ជវៈ ដែលជាធម៌មួយក្នុងចំណោមធម៌ទាំង ១០ សម្រាប់អធិប្បាយពីរឿងត្រង់ តែនៅក្នុងទសបារមី ព្រះអង្គប្រើពាក្យសច្ចៈដែលជាធម៌សម្រាប់បដិបត្តិដើម្បីឆ្ពោះទៅរកពុទ្ធភាវៈសម្រាប់អធិប្បាយពីរឿងទៀងត្រង់ ។ ដូច្នេះ អ្នកអានដែលពុំសូវធ្លាប់ជិតស្និទ្ធនឹងពាក្យអាជ្ជវៈនេះ សូមសម្គាល់ថា ពាក្យអាជ្ជវៈនេះមានលក្ខណៈស្រដៀងនឹងពាក្យថាសច្ចៈដែរ ថ្វីត្បិតតែមិនដូចទាំងស្រុង ។

បើយើងចង់ដឹងថារបស់ណាមួយត្រង់ ឬមិនត្រង់នោះ លោកឱ្យយើងពិនិត្យមើលចំណុចបីគឺ ចំណុចដើម កណ្ដាល និងចុង ។




ព្រោះថារបស់ខ្លះត្រង់ពីដើមដល់ចុង របស់ខ្លះត្រង់ពីដើមដល់កណ្ដាល តែវៀចពីកណ្ដាលដល់ចុង ឯរបស់ខ្លះវៀចពីដើមដល់កណ្ដាល តែត្រង់ពីកណ្ដាលទៅចុងក៏មាន ។ អ្វីដែលហៅថាត្រង់ពិតប្រាកដនោះ គឺត្រូវត្រង់តាំងពីដើមដល់កណ្ដាល រហូតដល់ចុង ។

ឯមនុស្សវិញ តើយើងមើលត្រង់ណា ? ការមើលមនុស្សលោកថា ឱ្យមើលនូវទង្វើ ឬកម្មរបស់មនុស្សនោះ ព្រោះបើមើលតែរូបមនុស្ស គឺសំបកក្រៅនោះយើងមិនអាចរក "ត្រង់" ឃើញទេ ។ កម្មរបស់មនុស្សយើងក៏មានដើម កណ្ដាល ចុងដែរគឺ

- ដើម គឺជាការគិត
- កណ្ដាល គឺជាសំដី
- ចុង គឺជាទង្វើ

ការគិត គឺចេតនារបស់អ្នកធ្វើ ដែលនឹងធ្វើឱ្យអ្នកផងយល់ថា សំដីឬពាក្យនិយាយ គឺបដិញ្ញាកម្មធ្វើឱ្យអ្នកដទៃបានឮ ឬបានឃើញ ឯទង្វើ គឺព្រឹត្តិកម្ម ដែលសម្ដែងមកដោយបញ្ជាក់លើសំដី គឺនិយាយយ៉ាងណា ធ្វើយ៉ាងនោះ ។ ទាំងនេះ គឺជាលក្ខណៈរបស់មនុស្សត្រង់ គឺត្រង់ពីចំណុចដើម កណ្ដាលដល់ចុង ។ ការដែលពិនិត្យមើលទៅលើតែពាក្យសម្ដីនិងព្រឹត្តិកម្ម មិនអាចឱ្យយើងអះអាងថា អ្នកនោះជាអ្នកត្រង់បាន ១០០ភាគរយទេ តែត្រូវពិនិត្យទៅលើចេតនារបស់អ្នកនោះទៀតទើបគ្រប់គ្រាន់សម្រាប់ការសន្និដ្ឋាន បើមិនដូច្នោះទេ ប្រាកដជាសន្និដ្ឋានខុសជាមិនខាន ។

បុរាណាចារ្យបានចែងទុកថា មនុស្សយើងគួរត្រង់ចំពោះអ្វីខ្លះ ដោយលោកបានប្រៀបធៀបទៅនឹងម្រាមដៃទាំង ៥ ដើម្បីឱ្យងាយស្រួលចាំ ដូចខាងក្រោម :

**១. ត្រង់ចំពោះនាទី** គឺបានដល់ការទទួលស្គាល់ថា "នាទីជារឿងសំខាន់"។ នាទីដែលអ្នកដឹកនាំត្រូវត្រង់ជាមួយ មានពីរប្រភេទ គឺ :

ក. ត្រង់ចំពោះនាទីខ្លួន គឺបដិបត្តិការងារក្នុងនាទីរបស់ខ្លួន ឱ្យបានច្បាស់លាស់មិនលះបង់នាទី មិនក្លែងបន្លំ បំផ្លាញនាទី យកនាទីរបស់ខ្លួនជាធំ ។

ខ. ត្រង់ចំពោះនាទីរបស់អ្នកតូច គឺមិនបៀតបៀននាទីរបស់អ្នកតូច មិនជ្រៀតជ្រែកនាទីរបស់អ្នកតូចតែ :

- ត្រួតពិនិត្យឱ្យអ្នកតូចធ្វើការងារក្នុងមុខនាទី
- មិនលើកទឹកចិត្តចំពោះអ្នកតូចណា ដែលយកចិត្ត យកថ្លើមអ្នកធំពេលលះបង់នូវមុខនាទីខ្លួន
- ផ្តល់កិត្តិយសដល់អ្នកតូចដែលខំបំពេញនាទី ។

នាទីជាករណីយកិច្ចដែលអ្នកដឹកនាំត្រូវធ្វើចាំបាច់ ដោយខានមិនបាន ។ អ្នកដឹកនាំដែលមិនធ្វើករណីយកិច្ចរបស់ខ្លួន ជារឿងគួរឱ្យអាម៉ាស់ជាពន់ពេក ហើយនឹងនាំទៅរកសេចក្តីអន្តរាយជាមិនខាន ឧទាហរណ៍ដូចជានាទីខ្លួន គឺត្រូវទទួលព័ត៌មានតាមវិទ្យុពីសមរភូមិមុខ ចុះបើអ្នកនោះបែរជាទៅលេងអុក ឬដើរទៅនេះទៅនោះបាត់ ហើយជួនពេលនោះចំពេលដែលមានអាសន្ននៅសមរភូមិមុខ តើនឹងមានហេតុការណ៍ធ្ងន់ធ្ងរប៉ុនណាទៅ ដែលនឹងកើតឡើង ។

អ្នកដែលលះបង់ករណីយកិច្ចខ្លួនបាន អ្នកនោះអាចលះបង់កិច្ចការសំខាន់គ្រប់យ៉ាង តែមិនអាចលះបង់អំពើអាក្រក់បានឡើយ ។

**២. ត្រង់ចំពោះការងារ** គឺបានដល់ការធ្វើការងារគ្រប់យ៉ាងឱ្យបាន "ល្អ" និង"ឱ្យល្អដល់កម្រិត" នៃការងារនោះ ។ ការងារល្អនោះ គឺការងារដែលមិនខ្វក មិនខ្ចោះ មានសុក្រឹតភាព ។ មេទ័ពខ្លះពេលទៅត្រួតកូនទាហាន ក៏ស្លៀកពាក់ជាស៊ីវិល បែបនេះហៅថាមិនត្រង់ចំពោះការងាររបស់ខ្លួន ។ ជួនកាលការងារខ្លះធ្វើមិនបានចប់ចុងចប់ដើមទេ ។ បែបនេះចូលក្នុងតម្រាពាក្យខ្មែរដែលលោកថា **"ចាប់នេះចាប់នោះ មិនឆ្ពោះត្រង់ណា"** ។

រួមសេចក្តីទៅ ត្រង់ចំពោះការងារ គឺការធ្វើការងារឱ្យបានល្អជាទីបំផុត តាមកម្រិតល្អនៃការងារនោះ ។ ម្យ៉ាងទៀត ចំពោះការងាររបស់អ្នកតូច ក៏ត្រូវប្រិតប្រៀនឱ្យបានល្អជានិច្ច មិនត្រូវបណ្តែតបណ្តោយស្រេចតែនឹងចិត្តដោយមាក់ងាយ ឬរាយមាយចំពោះការងារនោះឡើយ ។

សូមចាំថា របៀបធ្វើការងារមានតែម្យ៉ាងប៉ុណ្ណោះ គឺធ្វើឱ្យល្អនិងមានការទទួលខុសត្រូវខ្ពស់ ។

៣. **ត្រង់ចំពោះវាចា** គឺការផ្ដល់សារៈសំខាន់ទៅលើពាក្យនិយាយរបស់ខ្លួន គោរពពាក្យនិយាយរបស់ខ្លួនថាជារបស់ខ្ពង់ខ្ពស់ស្មើជីវិត គឺនិយាយយ៉ាងណាក៏ធ្វើតាមការនិយាយនោះ សន្យារឿងអ្វីជាមួយអ្នកណា ក៏ធ្វើតាមពាក្យសន្យានោះ ទោះបីរឿងនោះជារឿងតូចតាចយ៉ាងណាក្ដី ។ តែបើខ្លួនធ្វើតាមពាក្យនិយាយមិនបានទេ ក៏គប្បីរកហេតុផលមកបញ្ជាក់ប្រាប់ឱ្យគេដឹង ហើយធ្វើការសុំអភ័យទោសចំពោះការដែលខ្លួនមិនអាចធ្វើតាមពាក្យនិយាយនោះបាន ។ ដូចគ្នានេះដែរ អ្នកដឹកនាំក៏ត្រូវយកចិត្តទុកដាក់ចំពោះពាក្យអ្នកនៅក្រោមឱវាទដែរ បើនិយាយយ៉ាងណា សន្យាយ៉ាងណា ទោះជារឿងតូចក្ដី ធំក្ដី ក៏ត្រូវតាមមើលឱ្យចប់ចុងចប់ដើម ថាអ្នកនោះបានធ្វើតាមពាក្យដែលខ្លួននិយាយមែនឬទេ បើធ្វើមិនបាន ក៏ត្រូវតែមានហេតុផលគ្រប់គ្រាន់មកបញ្ជាក់ដោះស្រាយ ។ ការធ្វើដូច្នេះ អ្នកតូចនឹងមិនហ៊ានធ្វេសប្រហែសនឹងការងារពួកគេទៅថ្ងៃក្រោយ ។ សូមកុំភ្លេចថា ការកុហក ការនិយាយមិនពិត ការមិនត្រង់ចំពោះវាចាខ្លួនម្ដង គឺជាការបន្ថយនូវជំនឿទុកចិត្តដែលគេមានចំពោះយើងមួយកម្រិតផងដែរ ដូចពាក្យចាស់លោកថា "ឈើផ្លែច្រើន ចាញ់ស្លឹក ពាក្យច្រើនភូត ចាញ់អាត្មា" ។

៤. **ត្រង់ចំពោះបុគ្គល** គឺការមិនលេងល្បិច ការមិនឆបោកបញ្ឆោតអ្នកដទៃ ធ្វើកិច្ចការអ្វីត្រង់ទៅត្រង់មក មានភក្ដីភាពស្មោះត្រង់ដូចជា

- មិនបោកអ្នកតូចឱ្យធ្វើខុស ហើយយករួចខ្លួនតែឯង
- មិនត្រូវមួលបង្កាច់គេនៅពីក្រោយ ដោយចេតនាអាក្រក់
- មិនគិតព្យាបាទមិត្ត
- មិនទុរយសក្បត់ចំពោះអ្នកធំ
- មិនរមិលគុណចំពោះអ្នកដែលធ្វើគុណ
- មិនធ្វើខ្លួនឱ្យទៅជាមនុស្ស "នៅនឹងមុខហៅលោក កំបាំងដំបូកហៅអា" ។

ខ្មែរយើងមានសុភាសិតមួយឃ្លា ដែលបញ្ជាក់ពីភាពមិនស្មោះត្រង់ ការគិតតែប្រយោជន៍ផ្ទាល់ខ្លួនមានការកេងយកផលពីគេដូច្នេះ គឺ "**ចូលព្រៃសត្វសាហាវ រកអំពាវគ្នាមកជុំ ដល់បានស្គរទឹកឃ្មុំ ពួនសំងំនីម្នាក់ឯង**" ។

៥. **ត្រង់ចំពោះសេចក្ដីល្អ** គឺជាកំពូលនៃសេចក្ដីត្រង់ នៃសេចក្ដីល្អ ។ ចំពោះការត្រង់បែបនេះ បុរាណប្រើពាក្យធម៌ គឺបានន័យថា ត្រង់ចំពោះសេចក្ដីល្អ គឺការរក្សាធម៌នេះឯងដូចជា មានយុត្តិធម៌ត្រឹមត្រូវតាមធម៌ តាមគន្លងធម៌ ប្រកបដោយធម៌ ឬបើជាពាក្យអវិជ្ជមាននាំមុខវិញ មានដូចជាមិនស៊ីសំណូក មិនឆបោក មិនអយុត្តិធម៌ មិនលំអៀង ។ល ។

រួមសេចក្ដីមក នៅក្នុងការបំពេញនាទីរបស់ខ្លួនជាអ្នកធំ បើទោះជាមានអ្វីមករុញច្រាន ឬបង្ខំឱ្យខ្លួនងាកវេខុសពីធម៌យ៉ាងណាក៏ដោយ ក៏ត្រូវពង្រឹងចិត្ត មិនព្រមលុះទៅតាមអំណាចទាំងនោះ ហ៊ានតស៊ូពុះពារដើម្បីរក្សាធម៌ឱ្យគង់វង្ស ។ អំណាចដែលនឹងអាចឱ្យយើងខូចធម៌នោះមានដូចជា សំណូក រង្វាន់ ស្រី បក្សពួក ស្នេហា កំហឹង ការស្រើង ការខ្លាច ការញុះញង់របស់សត្រូវជាដើម ។ គប្បីចាំនូវពុទ្ធវចនៈថា "ធម្មោ ហវេ រក្ខតិ ធម្មចារី គឺអ្នករក្សាធម៌ ធម៌តែងរក្សាអ្នកនោះ" ជាគតិសម្រាប់តស៊ូជាមួយអធម៌ទាំងឡាយនោះ ។

ការអធិប្បាយ ពីផលប្រយោជន៍របស់ត្រង់ទាំង ៥ ប្រការខាងលើនេះប្រៀបបាននឹងម្រាមដៃទាំង ៥ ។ ដៃដែលនឹងស្អាតនោះ ព្រោះមានម្រាមគ្រប់ទាំងប្រាំ បើបាត់ម្រាមណាមួយដៃនោះនឹងទៅជាដៃពិការ បើបាត់ម្រាមកាន់តែច្រើន ដៃក៏កាន់តែលែងមានប្រយោជន៍ច្រើនដែរ ។

ដូចនេះ មនុស្សត្រង់ គឺមនុស្សមិនវៀចវេរ ធ្វើការអ្វីនឹងបានឆាប់សម្រេចមិនខាន ដូចជាផ្លូវត្រង់និងផ្លូវវៀចអ៊ីចឹងដែរ គឺផ្លូវត្រង់ទៅដល់គោលដៅឆាប់ជាងផ្លូវវៀច ។ ផ្លូវត្រង់ គឺផ្លូវកណ្ដាល ជាមជ្ឈិមប្បដិបទា មិនងាកឆ្វេង ងាកស្ដាំរបស់ព្រះពុទ្ធបរមគ្រូរបស់យើង ។ ជនដែលដើរតាមផ្លូវត្រង់ ផ្លូវកណ្ដាល គឺជននោះជាអរិយសាវ័ករបស់ព្រះសម្មាសម្ពុទ្ធដ៏ពិតៗ ។ អ្នកដឹកនាំដែលត្រង់ គឺពិតជាអ្នកដឹកនាំដែលកំពុងនាំរាស្ត្រប្រជាដើរលើផ្លូវមជ្ឈិមប្បដិបទា ឆ្ពោះទៅរកការរួចផុតពីសេចក្ដីទុក្ខលំបាករបស់រាស្ត្រប្រជានិងឆ្ពោះទៅរកសេចក្ដីសុខចម្រើនពិតប្រាកដ ។

*(ដកស្រង់និងកែសម្រួលពីសៀវភៅ "ព្រះបាទធម្មិក" របស់ឥន្ទបញ្ញាភិក្ខុហេង មណីចិន្តា
បោះពុម្ពឆ្នាំ១៩៩៥ ទំព័រទី ១១៧-១២៤)*

## សំណួរ

១. តើអត្ថបទខាងលើនេះ និយាយពីអ្វី ? អ្នកនិពន្ធឈ្មោះអ្វី ?

២. តើអ្វីជា អាជ្ជវៈ ឬសេចក្ដីត្រង់ ?

៣. តើសេចក្ដីត្រង់មានដូចម្ដេចខ្លះ ?

៤. តើសេចក្ដីត្រង់មានប្រយោជន៍អ្វី ចំពោះមនុស្សគ្រប់រូប ?

៥. តើអត្ថបទខាងលើមានបំណងអប់រំដូចម្ដេចខ្លះ ?

# កាលអាកាស

កាលអាកាស គឺជាពេលវេលានិងទីកន្លែងដែលដំណើររឿងប្រព្រឹត្តទៅ ។ កាលបង្ហាញពីអតីត បច្ចុប្បន្ន និងអនាគត ថ្ងៃឬយប់ នាររដូវណាមួយ ។ អាកាស គឺជាកន្លែងដែលរឿងកើតឡើង ។ អាកាសអាចជាកន្លែងក្នុងមនោគតិរបស់អ្នកនិពន្ធ ឬកន្លែងមានពិតនៅទីណាមួយ ។

ចូរអានអត្ថបទរឿង តាត្រសក់ផ្អែមខាងក្រោម :

កាលពីព្រេងនាយ មានតាចាស់ម្នាក់ដាំត្រសក់ ។ អ្នកស្រុកតែងហៅគាត់ថា "តាត្រសក់ផ្អែម" ព្រោះត្រសក់របស់គាត់មានរសជាតិផ្អែមប្លែកពីត្រសក់ដទៃ ។

ថ្ងៃមួយគាត់បាននាំយកត្រសក់ទៅថ្វាយព្រះរាជា ។ ស្ដេចសោយទៅ ទ្រង់សព្វព្រះទ័យខ្លាំងណាស់ដោយសាររសជាតិត្រសក់នោះផ្អែម ។ ស្ដេចក៏ទ្រង់បញ្ជាដល់តាដាំត្រសក់មិនឱ្យត្រសក់ដល់អ្នកណាទៀតទេ បើគ្មានការអនុញ្ញាតពីព្រះអង្គ ហើយទ្រង់ក៏ប្រទានលំពែងមួយដល់គាត់ ដើម្បីការពារត្រសក់មិនឱ្យចោរលួច ។

មានយប់មួយ ស្ដេចនឹកភ្នកចង់ល្បងតាត្រសក់ផ្អែមមើល ។ ទ្រង់ក៏លួចយាងតាមផ្លូវសម្ងាត់ មិនឱ្យអាមាត្យ នាម៉ឺន សព្វមុខមន្ត្រីឃើញឡើយ ។ ទ្រង់បានលបលូនចូលក្នុងចម្ការតាត្រសក់ផ្អែម ។ តាត្រសក់ផ្អែមឃើញក៏ចោលលំពែងត្រូវ ហើយទ្រង់ក៏សុគតនៅទីនោះទៅ ។

ដោយនគរគ្មានស្ដេចសោយរាជ្យបន្ត ប្រជាជនក៏លើកតាត្រសក់ផ្អែមឱ្យឡើងសោយរាជ្យតាំងពីពេលនោះរហូតអស់ជីវិតទៅ ។

កាលអាកាសរបស់រឿងខាងលើ គឺ :

- កាល : ថ្ងៃមួយ ... យប់មួយ ...
- អាកាស : នៅរាជវាំងនិងនៅចម្ការ ។

- *កាលអាកាស ជាពេលវេលានិងទីកន្លែងដែលដំណើររឿងប្រព្រឹត្តទៅ ។*
- *កាល អាចជាពេលវេលាក្នុងអតីតកាល បច្ចុប្បន្នកាល អនាគត ពេលថ្ងៃ ពេលយប់ ឬរដូវកាលណាមួយ ... ។*
- *អាកាស ជាកន្លែងដែលរឿងកើតឡើង ។ អាកាសអាចជាកន្លែង ដែលអ្នកនិពន្ធប្រឌិតឡើងតាមមនោគតិរបស់ខ្លួនដូចជា ឋានសួគ៌ ឋាននរក ឋានត្រៃត្រិង្ស ឬពិភពណាមួយ ។ ជួនកាលជាទីកន្លែងដែលមានពិតនៅទីណាមួយផងដែរ ។*

## លំហាត់

ចូររកកាលអាកាសនៃរឿងខាងក្រោម ៖

### ១. រឿង ព្រះចន្ទ

មានតំណាលថា ព្រះអាទិត្យ ព្រះពាយ ព្រះពិរុណ និងព្រះចន្ទជាបងប្អូនបង្កើតនឹងគ្នា ។ សម័យថ្ងៃមួយ បងប្អូនទាំងបួននាក់ទៅចូលរួមក្នុងពិធីជប់លៀងមួយដែលមានម្ហូបអាហារពោរពាស ។ ព្រះអាទិត្យ ព្រះពាយ ព្រះភិរុណទាំងបីនាក់ស៊ីឆ្អែតបរិបូរមិនគិតដល់ម្ដាយសោះ ។ មានតែព្រះចន្ទមួយទេដែលជាកូនពៅបានយកបង្អែមទៅផ្ញើម្ដាយ ។

អ្នកម្ដាយខឹងយ៉ាងខ្លាំងជេរប្រទេចពួកអ្នកល្មោភស៊ី ៖

- អំណឹះតទៅ ពួកឯងទាំងអស់គ្នានឹងត្រូវគេស្អប់គ្រប់ទីកន្លែង ។ អ្នកម្ដាយឱ្យពរព្រះចន្ទ ៖
- អំណឹះតទៅ នៅកន្លែងណាក៏ដោយ ក៏ត្រូវគេស្វាគមន៍អបអររីករាយជាមួយកូន ។

ចាប់តាំងពីពេលនោះមក កាលណាមានថ្ងៃបើកខ្លាំង មានខ្យល់ មានភ្លៀងខ្លាំង តែងមានមនុស្សត្អូញត្អែរដល់ជានិច្ច ។ ប៉ុន្តែគេនាំគ្នាសប្បាយរីករាយទាំងសកលនឹងរស្មីដ៏ស្រទន់នៃព្រះចន្ទ ។

### ២. រឿង ជាងកាត់សក់ចំណាប់

កាលពីព្រេងនាយមានស្ដេចមួយអង្គតែងតែដាក់ទណ្ឌកម្មដោយវាយឬដោយដាក់គុកដល់ជាងកាត់សក់ណាដែលកាត់សក់ទ្រង់ ដោយចោទប្រកាន់ថាកាត់ឱ្យព្រះអង្គមិនសម ។ ថ្ងៃមួយមានជាងកាត់សក់ក្មេងម្នាក់ត្រូវវេនខ្លួនកាត់ថ្វាយស្ដេច ។ អាមាត្យនាំជាងទៅព្រះរាជដំណាក់ ។ ជាងក៏ចាប់ផ្ដើមបំពេញការងារខ្លួន ។ ស្ដេចចេះតែនិយាយងាកចុះងាកឡើងជាមួយស្នំរកតែជាងកាត់មិនកើត ។ ជាងកាត់សក់ទ្រាំពុំបានក៏អុកព្រះកេសមួយកន្ត្រៃ ។ ស្ដេចសួរ ៖

- ម៉េចបានជាឯងវាយក្បាលអញ ?

ជាងកាត់សក់ឆ្លើយដោយសុភាព ៖

- ព្រះរាជទានទោស មានតែវិធីនេះមួយទេទើបកាត់សក់ថ្វាយទ្រង់សម ក្រាបទូល !

## ៣. រឿង សត្វឥន្ទ្រីនិងក្រពើដណ្ដើមដរីគ្នាស៊ី

មាននិទានមួយថា មានសត្វឥន្ទ្រីមួយនៅកោះកណ្ដាលសមុទ្រ ហើយមានក្រពើមួយធ្វើរូងនៅកោះនោះផង ។ សត្វឥន្ទ្រីនោះតែងទៅឆាបដរីពីត្រើយសមុទ្រយកមកឆីនៅខាងរូងក្រពើនោះជាប្រក្រតី ។ ថ្ងៃមួយក្រពើមើលយល់ឥន្ទ្រីពាំដរីនឹងឆីហើយ ក្រពើនោះគិតគ្នាន់ក្នុងចិត្តថា "អញនឹងដណ្ដើមសាច់ដរីពីឥន្ទ្រីឆី" ។ លុះឥន្ទ្រីពាំដរីមកដាក់ដល់ស្ថានដែលធ្លាប់តែបរិភោគរៀងរាល់ថ្ងៃនោះ ក្រពើនោះវារចេញអំពីរូងឡើងទៅរកឥន្ទ្រីហើយសួរថា "ម្នាលឥន្ទ្រី ម្ដេចក៏ព្រះស្ដែងមកលួចសាច់ដរីជាអាហារអញ ?" ។ ឥន្ទ្រីឆ្លើយថា "ដរីនេះអញឆាបយកមកពីត្រើយសមុទ្រជាប្រាកដ ទើបតែមកដល់អម្បាញ់មិញនេះឯង ម្ដេចក៏ស្ដែងថាអញលួចអាហារព្រះស្ដែង ?" ។ ក្រពើនិងឥន្ទ្រីវិវាទគ្នាប្រាថ្នាចង់បានសាច់ដរីទៅវិញទៅមកពុំដាច់ស្រេចឡើយ ទើបនាំគ្នាទៅប្ដឹងពោធិសត្វដែលជាតាបសនៅទីនោះ ។ ក្រពើនិងឥន្ទ្រីប្ដឹងដោយដំណើរទីទៃៗ ។ ក្រពើថា "ខ្ញុំខាំដរីនឹងឆីនៅខាងរូងលំនៅខ្ញុំ ឥន្ទ្រីនេះមកដណ្ដើមសាច់ដរី នឹងយកមកឆីជាអាហារ" ។ ឥន្ទ្រីថា "ដរីនេះខ្ញុំឆាបអំពីត្រើយសមុទ្រជាប្រាកដ ទើបតែមកដល់ខ្ញុំគិតនឹងឆី ស្រាប់តែក្រពើនេះវារឡើងអំពីរូងទៅថាខ្ញុំលួចចំណីអាហារវា ទាំងនេះសូមព្រះអង្គពិចារណាឱ្យខ្ញុំហោង" ។ តាបសមើលដល់ទីកន្លែងដរី ទើបឃើញតែស្នាមក្រចកឥន្ទ្រី ពុំឃើញចង្កូមក្រពើនោះឡើយ ព្រះអង្គយកក្រចកឥន្ទ្រីមកផ្ទាប់មើលយល់ថាមែន ។ តាបស "ឥន្ទ្រីនេះយល់ជាមានសាក្សីមែនពិត ឯក្រពើឥតសាក្សីអ្វីឡើយ ទើបកាត់សេចក្ដីនោះឱ្យក្រពើចាញ់ឥន្ទ្រី ។ តាបសកាត់សេចក្ដីដូច្នេះ ហៅសុគតិគមនំហោង" ។

*(ដកស្រង់ពីប្រជុំរឿងព្រេងខ្មែរភាគ ៣)*

## អ្នកនិពន្ធនិងកាលកំណត់តែង

ការសិក្សាអក្សរសិល្ប៍បុរាណ ឬរឿងបុរាណ សំដៅដល់ការសិក្សារឿងព្រេងនិងរឿងប្រឌិត ដែលកើតមានឡើងក្នុងសម័យកាលដំបូងនៃប្រវត្តិអក្សរសិល្ប៍បុរាណ ។ រឿងបុរាណជាច្រើនមិនថា រឿងបុរាណខ្មែរ ឬបរទេស គ្មានឈ្មោះអ្នកនិពន្ធនិងកាលបរិច្ឆេទច្បាស់លាស់ទេ គឺមានត្រឹមតែការ និទានឬនិយាយតៗគ្នាពីមាត់មួយទៅមាត់មួយ ហើយក្រោយមកក៏មានការនិយមចូលចិត្ត និងមានការ រៀបចំចងក្រងតាមការនិទានឡើងវិញដើម្បីទុកជាឯកសារដូចជា សៀវភៅប្រជុំរឿងព្រេងខ្មែរ ដែល មានចំនួន ៩ភាគ ដោយក្រុមពុទ្ធសាសនបណ្ឌិតជាដើម ។ ស្នាដៃខ្លះ ជួនកាលមានឈ្មោះអ្នកនិពន្ធដែរ តែគ្មានកាលកំណត់តែងពិតប្រាកដដូចជា ប្រភេទរឿងទសជាតក បញ្ញាសជាតក ។ល។ ប៉ុន្តែមាន លក្ខណៈសម្គាល់ជារឿងបុរាណ ទាំងផ្នែកអត្ថន័យ អត្ថរូប និងអត្ថរស ។

ការសិក្សាអំពីអ្នកនិពន្ធ កាលកំណត់តែងរបស់អ្នកនិពន្ធ អាចឱ្យយើងស្គាល់ឈ្មោះនិងជីវប្រវត្តិ របស់អ្នកនិពន្ធ ដឹងពីកាលបរិច្ឆេទក្នុងការតែងនៅពេលណា សម័យកាលណា ហើយដឹងទៀតថារឿង នោះកើតឡើងយ៉ាងដូចម្ដេច ប្រព្រឹត្តទៅយ៉ាងណា ហើយមានព្រឹត្តិការណ៍អ្វីកើតឡើងនៅសម័យកាល នោះ ដើម្បីទុកជាមេរៀន ជាបទពិសោធ ឬធ្វើការប្រៀបធៀបគ្នានឹងស្នាដៃថ្មីទំនើប ពីលក្ខណៈខុសគ្នា ការវិវត្តទាំងផ្នែកវប្បធម៌ សេដ្ឋកិច្ច សង្គមកិច្ចឬផ្នត់គំនិត ជាពិសេសគឺប្រពៃណី ទំនៀមទម្លាប់ ជំនឿ សាសនា ដែលទាក់ទងនឹងជីវភាពរស់នៅរបស់ប្រទេសមួយចំនួននៃតំបន់ខ្លះ ។

### លំហាត់

ចូរអានរឿងខាងក្រោម រួចបង្ហាញពីអ្នកនិពន្ធនិងកាលកំណត់តែង ។

### ១. រឿង ខ្លានិងភេពីរ

មានថ្ងៃមួយ ភេពីរចាប់បានត្រីមួយនៅក្នុងបឹង ។ ប៉ុន្តែវាចែកគ្នាមិនដាច់ស្រេចសោះ ។ ភេទី មួយនិយាយថា ៖

- អញចង់បានខាងក្បាល ។
- ភេទីពីរ ក៏និយាយ ៖
- អញចង់បានខាងក្បាលដែរ ព្រោះមានសាច់ច្រើន ។

ភេទាំងពីរក៏ឈ្លោះប្រកែកគ្នាដណ្ដើមចំណែកខាងក្បាលរៀងៗខ្លួន ។ ពេលនោះមានខ្លាត្រីមួយ ដើរមកដល់សួរថា ៖

- អ្នកទាំងពីរហេតុអ្វីក៏ជជែកប្រឈ្លោះគ្នា ? ភេទាំងពីរឆ្លើយ ៖
- យើងចាប់បានត្រីមួយ ប៉ុន្តែយើងចែកគ្នាមិនដាច់ស្រេចសោះ ។

ខ្លាក៏សួរបញ្ជាក់ ៖ ព្រោះអ្វី ?

ភេទាំងពីរឆ្លើយ ៖ ដោយមកពីយើងចង់បានចំណែកខាងក្បាលទាំ [illegible] ។

ខ្លានិយាយឡើង ៖ ទុកឱ្យខ្ញុំចែកឱ្យអីចឹង ! ឱ្យត្រីមកខ្ញុំ ។ ខ្លាកា [illegible] ណាត់ ក្បាល ខ្លួន និង កន្ទុយ ។ កំណាត់ត្រង់ខ្លួនមានសាច់យ៉ាងច្រើន ។ ខ្លាហុចក្បាលទៅឱ្ [illegible] ុយ ហើយហុចកន្ទុយទៅឱ្យភេទីពីរទាំងស្រដីថា អ្នកខាងណេះបានក្បាល ហើយអ្នកខា [illegible] បានកន្ទុយ ។ ឯខ្ញុំជាមេចំណែក ខ្ញុំហាត់ខ្លាំងណាស់ ខ្ញុំយកកំណាត់ខ្លួននេះហើយ ។

ពោលដូចនេះ ខ្លាកាន់ចំណែកខ្លួន ដើរចេញបាត់ទៅ ។ ភេទាំងពីរនឹកស្ដាយក្រោយគ្រប់គ្នា ។

## ២. រឿង ព្រះថោងនាងនាគ

កាលពីព្រេងនាយ នគរកម្ពុជាមានឈ្មោះថា កោះគោកធ្លក ព្រោះមានដើមធ្លកមួយដើមដុះនៅលើកោះនោះ ។ មានរឿងតំណាលថា ស្ដេចឥន្ទបុរី នៅឥណ្ឌាភាគខាងត្បូងទ្រង់ពិរោធយ៉ាងខ្លាំងនឹងព្រះរាជបុត្រព្រះអង្គព្រះនាមព្រះថោង ដោយមិនដឹងជាមកពីហេតុអ្វីជាក់លាក់ ។ ទ្រង់បានបណ្ដេញព្រះថោងចេញពីនគរ ។ ព្រះថោងទ្រង់ឡើងលើសំពៅចេញដំណើរមកទិសខាងត្បូង ។ លុះមកដល់កោះគោកធ្លក ទ្រង់ក៏ឈប់សំពៅនៅទីនោះ[១] ។

នាថ្ងៃមួយ ដោយទ្រង់អផ្សុកខ្លាំង ព្រះថោងទ្រង់យាងក្រសាលតាមផ្នូកខ្សាច់នៅលើកោះគោកធ្លក ។ នៅវេលារសៀល ទឹកក៏ជន់ជោរខ្លាំងឡើង វិលមកវិញពុំបានក៏សម្រាកនៅទីនោះ ។ រាត្រីស្ងាត់ នាងនាគ បុត្រីស្ដេចភុជង្គនាគ នាំបរិវារមកលេងលើផ្នូកខ្សាច់ដូចប្រក្រតី ។ ព្រះថោងឃើញនាងនាគមានរូបឆោមលោមពណ៌ល្អក៏ចាប់ចិត្តប្រតិព័ទ្ធ ទើបទ្រង់បន្ទូលប្រលោមសាកសួរជាមេត្រី ។ នាងនាគយល់ព្រមក្នុងចិត្ត ហើយសន្យានឹងយករឿងនេះទៅទូលបិតានាងសិន ។

ស្ដេចភុជង្គនាគព្វបន្ទូលបុត្រីទ្រង់យល់ស្របតាម ទើបទ្រង់ដង្ហែនាងនាគមករៀបអភិសេកជាមួយព្រះថោងនៅលើកោះគោកធ្លក ។ ដើម្បីជាកិត្តិយសដល់បុត្រសុណិសាររបស់ព្រះអង្គ ទ្រង់សម្ដែងរឹទ្ធិស្រូបទឹកសមុទ្រឱ្យគោកជាផែនដីធំទូលាយឡើង ហើយនិម្មិតជាវាំងប្រាសាទគ្រប់គ្រាន់ថ្វាយបុត្រាបុត្រី ។ ពេលនោះ ព្រះថោងទ្រង់ចង់ស្គាល់ពិភពនាគ ទើបនាងនាគឱ្យតោងជាយស្បៃចុះទៅតាមនាង ដើម្បីគាល់បិតាមាតានាង[២] ។

---

*(១) តាមសម្ដីអ្នកស្រុកថា ព្រះថោងត្រូវប្រយុទ្ធតតាំងជាមួយនាងនាគ លុះដណ្ដើមបានជ័យជំនះហើយ ទើបទ្រង់អភិសេកជាមួយនាងនាគ សោយរាជ្យសុខដុមរៀងមក ។*

*(២) ក្នុងប្រពៃណីខ្មែរ ពេលសំពះផ្ទឹមរួច ភ្លេងលេងបទព្រះថោង ហើយកូនកកំលោះត្រូវតោងជាយស្បៃកូនក្រមុំចូលក្នុងបន្ទប់ ។ ទំនៀមនេះ គេយកតាមគំរូព្រះថោងនាងនាគ ។*

# រឿង អ៊ុយលីសវិលវិញ



ប្អូនបានសិក្សារួចមកហើយអំពីលក្ខណៈសម្គាល់នៃរឿងនិទានបុរាណ អ្នកនិពន្ធ កាលកំណត់តែង កាលអាកាស និងតម្លៃអប់រំនៃរឿង ។

ឥឡូវនេះ ចូរប្អូនត្រៀមនិងស្ដាប់រឿង "អ៊ុយលីសវិលវិញ" ។ សូមប្អូនស្ដាប់ដោយយកចិត្តទុកដាក់និងកត់ចំណាំចំណុច ឬសេចក្ដីលម្អិតសំខាន់ៗនៃរឿង ហើយឆ្លើយនឹងសំណួរទាក់ទងនឹងបំណិនខាងលើឱ្យបានត្រឹមត្រូវ ។

## សំណួរ

១. តើរឿងនេះជាប្រភេទរឿងអ្វី ? មានប្រភពពីប្រទេសណា ?

២. តើរឿងនេះមានអ្នកនិពន្ធដែរឬទេ ? ឈ្មោះអ្វី ?

៣. តើរឿងនេះបានកើតឡើងពីពេលណា ?

៤. ចូរបង្ហាញកាលអាកាសនៃរឿងខាងលើ ។

៥. តើភាពស្មោះត្រង់មាននៅក្នុងសាច់រឿងត្រង់ចំណុចណា ? ចូរបង្ហាញ ។

៦. តើរឿងនេះមានតម្លៃអប់រំដូចម្ដេចខ្លះ ?



បោះពុម្ពផ្សាយឆ្នាំ ២០១៦ PDH



# ការនិយាយសង្ខេប

ប្អូនៗធ្លាប់បានសិក្សារួចមកហើយពីការឡើងសូត្រកំណាព្យ ការធ្វើរបាយការណ៍ឬព័ត៌មានផ្ទាល់មាត់ និងនិទានរឿងឡើងវិញ ។ល ។

ឥឡូវនេះ ប្អូននឹងសិក្សាពីការនិយាយសង្ខេប ។

ការនិយាយសង្ខេប គឺជាការនិយាយដកស្រង់តែចំណុចគោលសំខាន់ៗនៃអត្ថបទ ឬរឿងរ៉ាវណាមួយមកនិយាយឡើងវិញដោយមានខ្លឹមសារសំខាន់ៗខ្លីៗងាយស្តាប់ ងាយចាំ ងាយយល់ ហើយមិនវែងអន្លាយដូច ឬប្រហាក់ប្រហែលនឹងអត្ថបទ ឬរឿងដើមទាំងស្រុងនោះទេ ។

*ឧទាហរណ៍ :*

"គំនិតសំខាន់របស់រឿងតាត្រសក់ផ្អែម គឺតាដាំត្រសក់មានរសជាតិផ្អែម" គោលសំខាន់នៃរឿងគឺ

- ស្តេចពេញចិត្តរសជាតិត្រសក់របស់តាត្រសក់ផ្អែម រួចប្រគល់លំពែងមួយឱ្យតាដាំត្រសក់ដើម្បីការពារ
- ស្តេចល្បងចូលចំការតាត្រសក់ផ្អែម ។ តាត្រសក់ផ្អែមចោលលំពែងត្រូវស្តេចសុគត
- តាត្រសក់ផ្អែមឡើងសោយរាជ្យបន្ត ។

## សង្ខេប

មានតាម្នាក់ដាំត្រសក់ ។ ត្រសក់គាត់មានរសជាតិផ្អែមខុសគេ ។ គាត់បានយកត្រសក់ទៅថ្វាយព្រះរាជា ។ ព្រះរាជាពេញចិត្ត ក៏ប្រគល់លំពែងមួយសម្រាប់ការពារចម្ការត្រសក់និងហាមមិនឱ្យត្រសក់នោះទៅអ្នកដទៃ ។

ថ្ងៃមួយ ស្តេចចង់ល្បងតាត្រសក់ផ្អែម ក៏លបលួចចូលចម្ការតាត្រសក់ផ្អែម ដោយមិនឱ្យនរណាដឹងទាំងអស់ ។ តាត្រសក់ផ្អែមស្មានថាចោរក៏ចោលលំពែងត្រូវព្រះអង្គសុគតទៅ ។ ដោយព្រះអង្គគ្មានបុត្រស្នងរាជ្យ គេក៏លើកតាត្រសក់ផ្អែមស្នងរាជ្យបន្តតាំងពីពេលនោះមក ។

## លំហាត់

ចូរប្អូនអានអត្ថបទដកស្រង់រឿង "មាយើង" ក្នុងអំណានទី១ រួចសង្ខេប ។

# ប្រឌិតរឿងនិទានបុរាណខ្លីៗ

អ្នកបានសិក្សារួចមកហើយអំពីលក្ខណៈសម្គាល់រឿងបុរាណអំពីអ្នកនិពន្ធ កាលកំណត់តែង កាលអាកាសនិងតម្លៃអប់រំ ។ ឥឡូវនេះ ចូរអ្នកសរសេរប្រឌិតរឿងបុរាណខ្លីមួយ ដែលទាក់ទងប្រធានបទ "ភាពស្មោះត្រង់"ដោយអនុវត្តតាមការណែនាំដូចខាងក្រោម ៖

១. ចូរអ្នកសរសេរល្បះដោយប្រើពាក្យពេចន៍របស់អ្នកផ្ទាល់ដែលជាអ្នកតំណាងឱ្យអ្នកនិពន្ធ

២. ចូរអ្នកសរសេររឿងដោយបង្ហាញពី

- **អត្ថន័យ**
  - ទាក់ទងនឹងសង្គមបរិយាកាសរបស់ខ្មែរដូចជា ទំនៀមទម្លាប់ ប្រពៃណី ភូមិសាស្ត្រ ...
  - មានតួអង្គជាមនុស្សគ្រប់ស្រទាប់វណ្ណៈ (រាស្ត្រ សេដ្ឋី មន្ត្រី ខ្ញុំបម្រើ)
  - បើតួអង្គជាសត្វមានដូចជា សត្វទន្សាយ ចចក គោ ខ្លា ...
  - បើតួអង្គជាអមនុស្សមានដូចជា យក្ស ខ្មោច ព្រាយ អ្នកតា ទេវតា ...
  - ជារឿងស្ថិតក្នុងសម័យបុរាណ ស្ថិតនៅក្នុងភូមិ ស្រុក ឬកន្លែងណាមួយពុំមានឈ្មោះ
  - ដំណើររឿងខ្លីៗ : មានទំនាស់វិបត្តិរវាងខ្លួនឯងនិងខ្លួនឯង បញ្ហាទំនាស់វិបត្តិរវាងខ្លួនឯងនឹងគ្រួសារ បញ្ហាទំនាស់វិបត្តិរវាងខ្លួនឯងនិងអ្នកដទៃ
  - បញ្ហាចោទ : ទាក់ទងបញ្ហាមនុស្ស ដោយអប់រំយើងឱ្យចេះដោះស្រាយស្របតាមលក្ខណៈនឹងរឿងបច្ចុប្បន្នដូចជាទាក់ទងការតស៊ូ អំណត់ព្យាយាម អង់អាចក្លាហាន ស្មោះត្រង់ ... ។
- **អត្ថរូប**
  - ប្រើពាក្យពេចន៍ធម្មតា សាមញ្ញ ឃ្លា ល្បះខ្លីៗ
  - ផ្តើមរឿង ដោយប្រើពាក្យ "កាលពីព្រេងនាយ កាលដើមឡើយ តាំងពីបុរាណកាលមកមានបុរសពីរនាក់ ...
  - ជារឿងដែលពុំដឹងជាកើតឡើងតាំងពីសម័យ ឬជំនាន់ណាមួយ ... រួចចូលដល់ដំណើររឿង
  - ដំណើររឿង មិនលន្លង់លន្លោច ឬប្រើសញ្ចេតនារវើរវាយដូចប្រលោមលោកទំនើបទេ
  - ប្រើពាក្យសម្តីខ្លីៗ តែច្បាស់លាស់ ងាយអាន ងាយយល់
  - ការបញ្ចប់រឿង ត្រូវបង្ហាញពីគំនិតអប់រំ ជាពាក្យប្រៀនប្រដៅ ដំបូន្មាន ឬសុភាសិត ។
- **អត្ថរស**

  អាចបង្ហាញភាពកម្សត់ កំប្លុកកំប្លែង ។

៣. ពេលអ្នកសរសេរចប់ អ្នកត្រូវផ្ទៀងផ្ទាត់ឡើងវិញ ចៀសវាងកំហុសអក្ខរាវិរុទ្ធ ។

មេរៀនទី ៣

# អធ្យាស្រ័យ



អធ្យាស្រ័យជាឥរិយាបថដ៏ប្រសើរជំរុញឱ្យមានមិត្តភាពនិងសន្តិភាព។ ការអត់ធ្មត់ ការសន្ដោស ការអត់ឱន និងការលើកលែងរាល់កំហុសឆ្គងដែលគួរលើកលែង គឺរួមចំណែកកាត់បន្ថយនិងវៀរចាកអំពើហិង្សានិងទំនាស់។ គ្រួសារ សហគមន៍ ឬសង្គមដែលគ្មានអំពើហិង្សានិងទំនាស់នាំឱ្យគ្រួសារ សហគមន៍ និងសង្គមនោះមានសន្តិភាពនិងការអភិវឌ្ឍ។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាស្វែងយល់ពីការអធ្យាស្រ័យ ការអត់ឱន ការលើកលែង នូវកំហុសឆ្គងមួយចំនួន។ ទន្ទឹមនឹងនោះ អ្នកនឹងបានសិក្សាបន្ថែមទៀតអំពីទំនាស់ក្នុងខ្លួននិងទំនាស់ក្រៅខ្លួន អាកប្បកិរិយារបស់តួអង្គ សព្វនាមឈ្មោះ សញ្ញាលាក់ ឬបេយ្យាលៈ ភាសារស់រវើក ការនិយាយ និងសំណេរសូមអភ័យទោស។

# ទំនាស់

រឿងនីមួយៗ អ្នកនិពន្ធតែងបង្កើតបញ្ហាចោទនិងដោះស្រាយទៅតាមសិល្បវិធីរៀងៗខ្លួន ។ តួអង្គសំខាន់ៗនៅក្នុងរឿងត្រូវប្រឈមមុខនឹងបញ្ហាចោទនិងដំណោះស្រាយទាំងនោះ ដែលជំរុញឱ្យមានទំនាស់កើតឡើង ។ ទំនាស់មាន ទំនាស់ក្នុងខ្លួន និងទំនាស់ក្រៅខ្លួន ។ តើទំនាស់ទាំងពីរមានលក្ខណៈខុសគ្នាដូចម្ដេចខ្លះ?

## ក. ទំនាស់ក្នុងខ្លួន

នៅពេលតួអង្គប្រឈមនឹងបញ្ហាចោទយ៉ាងខ្លាំងក្លា តឹងតែង ពិបាកដោះស្រាយ គឺធ្វើឱ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់អារម្មណ៍ ឬមនោសញ្ចេតនារបស់តួអង្គ ដូចជា ភ័យ ព្រួយ ខឹង អាណិត ស្រឡាញ់ ស្អប់ សប្បាយរីករាយ ស្ដាយ ទុក្ខសោក.... ។ ការណ៍នេះកើតឡើងនៅក្នុងអារម្មណ៍តួអង្គតែម្នាក់ឯង ។

*ឧទាហរណ៍ :*

[...] ដំណឹងធនញ្ជ័យស្លាប់ មិនយូរប៉ុន្មានក៏ឮដល់ស្រុកចិន ។ ស្ដេចស្រុកចិននឹកថា បើអ្នកប្រាជ្ញនោះស្លាប់ហើយ នគរខ្មែរពិតជាបានមកអញប្រាកដ ។ ស្ដេចចិនចាត់អ្នកប្រាជ្ញចិនបួនអ្នកឱ្យមកចោទប្រស្នាព្រមទាំងនាំសាររបស់ព្រះអង្គមួយច្បាប់មកផង ។ អ្នកប្រាជ្ញទាំងនោះជិះសំពៅម្នាក់មួយៗមកដល់កម្ពុជា ក៏យកសាររបស់ស្ដេចគេមកថ្វាយស្ដេចខ្មែរ ។ ព្រះរាជាខ្មែរទតឃើញព្រះរាជសារស្ដេចក្រុងចិនថាមកចោទប្រស្នាដូចនេះ ទ្រង់ព្រួយព្រះទ័យយ៉ាងខ្លាំង ហើយនឹកក្នុងចិត្ត "អត់ពីធនញ្ជ័យទៅហើយ មិនដឹងជាបាននរណាមកដោះប្រស្នានេះទេ ។ ឱ !អញនេះចំជាគិតខុស បើកុំតែសម្លាប់ធនញ្ជ័យ មិនពិបាកដល់ម្ល៉េះទេ !" ។

ឧទាហរណ៍នេះបង្ហាញពីទំនាស់ក្នុងខ្លួនដូចខាងក្រោម :

- **តួអង្គស្ដេចស្រុកចិន :** សប្បាយរីករាយក្នុងចិត្តដោយនឹកថាអស់ពីធនញ្ជ័យអ្នកប្រាជ្ញ នគរខ្មែរពិតជាក្លាយជាចំណុះរបស់នគរចិន ។
- **តួអង្គស្ដេចខ្មែរ :**
  - ព្រួយបារម្ភគ្មានអ្នកដោះប្រស្នាជាមួយអ្នកប្រាជ្ញចិន
  - ស្ដាយកំហុសរបស់ខ្លួនដែលបញ្ជាឱ្យគេសម្លាប់ធនញ្ជ័យ
  - ភ័យព្រួយខ្លាចនគរខ្មែរក្លាយជាចំណុះនគរចិន ។

*ទំនាស់ក្នុងខ្លួនគឺជាបញ្ហាទាំងឡាយដែលចោទឡើងនៅក្នុងអារម្មណ៍ ឬមនោសញ្ចេតនារបស់តួអង្គ ។*

## ខ. ទំនាស់ក្រៅខ្លួន

ការប្រឈមមុខដាក់គ្នារវាងតួអង្គនិងតួអង្គ រវាងតួអង្គនិងហេតុការណ៍ផ្សេងៗនៅក្នុងដំណើររឿងដែលជំរុញឱ្យមានការប្រើកម្លាំងកាយ ប្រាជ្ញាស្មារតី ចិត្តគំនិត ថ្វីមាត់ ... គេហៅថាទំនាស់ក្រៅខ្លួន ។

*ឧទាហរណ៍ :*

១. រឿងសង្គ្រាមគីង្គក់និងតាព្រហ្ម គឺទំនាស់រវាងតួអង្គតាព្រហ្មនិងតួអង្គទ័ពរបស់គីង្គក់ ។ ទំនាស់នេះកើតឡើងបណ្តាលមកពីគ្មានភ្លៀងធ្លាក់ធ្វើឱ្យសត្វទាំងឡាយខឹងយ៉ាងខ្លាំងហើយក៏កេណ្ឌទ័ពទៅប្រយុទ្ធនឹងតាព្រហ្មដើម្បីយកទឹកភ្លៀង ។

២. [....] លុះទៅដល់បឹងធំមួយ មានទឹកថ្លាឈ្វេងត្រជាក់ស្រិប ចចកក៏ចុះទៅក្នុងទឹក ពពួកត្រីកំពឹស ក៏លោតចូលទៅក្នុងទឹកបឹងហើយប្រាប់ចចក "បងឯងទៅជញ្ជូនពួកខ្ញុំឱ្យអស់សិនចាំមកស៊ីឱ្យឆ្អាញ់ ពួកខ្ញុំរង់ចាំនៅទីនេះ" ។ ចចកក៏ទៅជញ្ជូនត្រីនិងកំពឹសលុះត្រាតែអស់ពីត្រពាំង យកមកដាក់នៅក្នុងទឹកនោះ ។ ឯពួកត្រី កំពឹស ក្តាម ខ្យងដឹងថាចចកជញ្ជូនពួកខ្លួនអស់ហើយក៏លោតចូលមុជក្នុងទឹកជ្រៅអស់ទៅ ។ ចចកខឹងណាស់ក៏ដើរទៅបបួលអស់សត្វតូចធំ មានដំរី រមាស ខ្លា ពស់ធំ តូច ពស់ថ្លាន់ ទាំងសត្វហើរថែមទៀត មកបាចទឹកបឹងនោះឱ្យរីងនឹងបានចាប់ពពួកមច្ឆជាតិទាំងអស់នោះស៊ីឱ្យអស់ ។

*(ប្រជុំរឿងព្រេងខ្មែរភាគ ១)*

ទំនាស់នេះកើតឡើងរវាងតួអង្គក្រុមត្រីមាន កំពឹស ក្តាម ខ្យង និងតួអង្គក្រុមចចកមាន ចចក ពស់ ដំរី រមាស ខ្លា ។

*ទំនាស់ក្រៅខ្លួន គឺជាការប្រឈមដាក់គ្នារវាងតួអង្គនិងតួអង្គ រវាងតួអង្គនិងហេតុការណ៍ផ្សេងៗនៅក្នុងដំណើររឿងតាមរយៈការប្រើកម្លាំងកាយ ប្រាជ្ញា ស្មារតី ចិត្តគំនិត ល្បិចថ្វីមាត់ ។*

*តាមការបង្ហាញខាងលើ យើងសន្និដ្ឋានបានថា ទំនាស់ គឺជាកម្លាំងប្រឈមដែលកើតឡើងរវាងតួអង្គនិងតួអង្គ រវាងតួអង្គនិងហេតុការណ៍(ទំនាស់ក្រៅខ្លួន)រវាងតួអង្គនិងមនោសញ្ចេតនាឬអារម្មណ៍របស់តួអង្គផ្ទាល់ (ទំនាស់ក្នុងខ្លួន) ។*

## លំហាត់

ចូរបង្ហាញពីទំនាស់ក្នុងខ្លួននិងទំនាស់ក្រៅខ្លួនក្នុងរឿងខាងក្រោមនេះ ៖

[...] ឆ្លើយរួចស៊ីមបានបរឡានទៅសាលារៀនបារាំងខាងលិចវត្តភ្នំ ទទួលកូនលោកជូនទៅផ្ទះរួចជាស្រេច ក៏បានបរឡានត្រលប់មកដល់ហាងថៃសានវិញជិតម៉ោង ១១កន្លះ។ ស៊ីមចោលភ្នែកទៅក្នុងហាងថៃសានឃើញថៅហ្កាយគាត់អង្គុយជាមួយលោកបីនាក់ទៀត។ ដល់ម៉ោង ១១កន្លះ ស៊ីមចោលភ្នែកទៅម្តងទៀត ឃើញមិត្តលោកម្នាក់ថែមមួយដូសទៀត។ អផ្សុកពេក ណាដល់ពេលប្រពន្ធចាំបាយផង ស៊ីមបានចុះពីឡានដើរបៀតចិនលក់ទឹកកក មើលរូបកុនដែលបិទនៅជញ្ជាំងទ្រឿងកុក។ សាវ៉ែនស្រែក ស៊ីមមើលទៅហាងថៃសាន ឃើញអ្នកបម្រើចាក់ឱ្យលោកមួយដូសទៀត ហើយអ្នកឡើងតុទាំងបួននាក់ជជែកគ្នាយ៉ាងរីករាយ។ ឃើញដូចនេះ ស៊ីមលាន់មាត់ម្នាក់ឯងថា "មិនមែនតែម្តងនេះទេ ម៉េចក៏ម៉េចចុះអញទៅមុនហើយ ..."។

រួចពីរអ៊ូនេះ ស៊ីមក៏ឡើងឡាន បញ្ឆេះរោទ៍ម៉ាស៊ីនយ៉ាងខ្លាំងឱ្យលោកឮ តែលោកមិនឮ ស៊ីមក៏ដាក់លេខបើកឡានមកផ្ទះមុន។ ចតឡានក្នុងរោងស្រួលបួលរួច ស៊ីមក៏បានជិះកង់កញ្ចាស់មកដល់ផ្ទះគាត់។

ដល់ម៉ោងមួយជិតកន្លះ ស៊ីមបានស្លៀកពាក់ជិះកង់ទៅផ្ទះលោក ជូនកូនលោកទៅសាលារៀនហើយត្រលប់មកចាំលោកវិញ។ កំពុងតែជូតឡានស្រាប់តែសំឡេងលោកមកពីលើផ្ទះស្រែកហៅ ៖

- ស៊ីមឡើងមកលើ។

ស៊ីមបានរត់ឡើងទៅលើផ្ទះរួចសួរ ៖

- មានការអ្វីហៅខ្ញុំបាទទាន ?
- ហេតុអ្វីក៏បើកឡានចោលខ្ញុំពីថ្ងៃត្រង់នេះ ? លោកបាននិយាយមើលមុខស៊ីមដោយខឹង។
- ខ្ញុំបាទចាំតេជគុណដល់ម៉ោង ១២សាវ៉ែនស្រែក បានខ្ញុំបាទចេញឡានមក ...។
- ស៊ីមធ្វើការស្រេចតែចិត្តស៊ីមឯងឬ ? លោកបានកាត់ញ័រមាត់។
- បាទទេ តេជគុណឱ្យខ្ញុំបាទចាំត្រឹមតែម៉ោង ១១កន្លះ។ ខ្ញុំបានចាំរហូតដល់ម៉ោង ១២ យូរលើសកន្លះម៉ោងពីតេជគុណបង្គាប់ ខ្ញុំបាទស្មានតែតេជគុណមិនអញ្ជើញមកពិសាបាយផ្ទះ។
- ឃើញខ្ញុំរាប់អាន ស៊ីមឯងមើលងាយខ្ញុំណាស់។ លោកបានបន្ទោស។
- ខ្ញុំបាទមើលងាយតេជគុណឯណា ? ខ្ញុំបាទខំយកចិត្តទុកដាក់ថែទាំឡានតេជគុណ ហើយខំផ្គាប់ជូនកូនតេជគុណ ជូនលោកស្រីទៅរៀន ទៅផ្សារ ...។

- កុំជជែកនឹងអាមនុស្សតូចតាចនោះ ។ បើវាមិនស្តាប់កោតខ្លាចថៅហ្វាយទេផ្លាស់វាទៅ ដេញវាចោលទៅ ។ ខ្វះអីមនុស្សបរឡាន ។ លោកស្រីដែលនៅក្បែរនោះបានអារកាត់ ។ ឮលោកស្រីឡើងសំឡេងដូចនេះ លោកប្រុសក៏ឈប់និយាយ ។ លោកចុះមកដីឡើងឡាន ។ ស៊ឹមក៏បានបរសំដៅទៅមន្ទីរធ្វើការ ។ ចូលក្នុងរបងមន្ទីរធ្វើការ ស៊ឹមបានចតឡានទុកស្រួលបួលហើយក៏ចុះពីឡានដើរសំដៅគល់ឈើ ដែលពូសនបានអង្គុយនៅទីនោះ ។ ពូសនបានឃើញក៏សួរ ៖
- មានដំណឹងប្លែកទៀតទេស៊ឹម ?
- បាទមានច្រើន ហើយពិសេសថ្ងៃនេះ គឺរឿងផ្ទាល់ខ្លួនខ្ញុំនឹងលោក ។
- រឿងដូចម្តេចទៅ ?
- រឿងលោកចង់ផ្លាស់ខ្ញុំចោល ។
- ព្រោះអ្វី ?
- ព្រោះខ្ញុំបើកឡានចោលលោកថ្ងៃត្រង់នេះ ។ លោកឱ្យខ្ញុំចាំលោកនៅមុខផ្ទះសាន សន្យាត្រឹមម៉ោង ១១កន្លះ ។ ខ្ញុំចាំដល់សារ៉ែនស្រែក តែលោកមិនគិតខ្ញុំចាំលោកសោះ លោកនឹងមិត្តលោកចេះតែថែមមួយដូស ហើយមួយដូសទៀត ... ។ ខ្ញុំឃ្លានបាយពេកទ្រាំមិនបានក៏បើកឡានទៅមុនទៅ ។
- ម៉េចអីចឹងស៊ឹម ឯងលេងធំណាស់តើ ហ៊ានបើកឡានចោលថៅហ្វាយ ! ពូសនបន្ទោស ៖
- យើងធ្វើការមានម៉ោងមានពេលពូ ។ យើងមានភារៈជូនលោកមកមន្ទីរធ្វើការ ហើយនឹងធ្វើការក្នុងរាជការជាការចប់ មិនមែនបើកប្រាក់ខែខ្វះព្រឹក ខ្វះល្ងាចបើកឡានជូនគេស៊ីផឹកដូចនេះទេ ... ។
- ឥឡូវលោកគិតដូចម្តេច ?
- លោកស្រីថាខ្ញុំជាមនុស្សតូចតាច ហើយប្រាប់លោកឱ្យផ្លាស់ខ្ញុំចោល ។
- ស៊ឹមឯងត្រូវសូមទោសលោកទៅ ... ។
- ខ្ញុំមានទោសឯណាសុំ ។ ខ្ញុំធ្វើតាមច្បាប់ បើលោករៀនចេះច្បាប់ ហើយមិនគោរពច្បាប់ មុខតែយើងតូចតាចទាំងអស់វេទនាជានិច្ច ។ ថ្ងៃនេះវេនខ្ញុំ ថ្ងៃស្អែកវេនពូ ថ្ងៃក្រោយវេនអ្នកបរឡានទាំងអស់គ្នា ... ។
- ឱនដាក់គ្រាប់ ដើយវាស្អកស៊ឹម ! ពូសនបានទូន្មាន ។ ឯងត្រូវគិតដល់កូនប្រពន្ធផង ... ។
- ខ្ញុំគិតដល់កូនប្រពន្ធខ្ញុំហើយ បានជាខ្ញុំខំការពារកម្រិតម៉ោងធ្វើការឱ្យត្រឹមត្រូវតាមច្បាប់ កុំឱ្យមានការរំលោភគ្រប់នាទីដូចនេះ ... ដើម្បីខ្ញុំអាចថែទាំវាឱ្យបានសុខ រៀនស្រួល ... ។[...]

*(ដកស្រង់ពីរឿងស៊ឹមអ្នកបរឡាន អ្នកនិពន្ធ អ៊ឹម ថុក)*



# រឿង គ្រូពេទ្យជើងបួន



## ក. សិក្សាពាក្យគន្លឹះ

- សេដ្ឋី (ន) បា.សំ : អ្នកមានទ្រព្យច្រើន អ្នកមានធំ ។
- អភ័ព្វ (គុ) បា : ដែលឥតសំណាង មានសំណាងតិចតួច... ។
- ព្រាហ្មណ៍ (ន) បា សំ : អ្នកគ្មានកិលេស មនុស្សដែលកំណត់តាមសាសនាព្រាហ្មណ៍ ថាមានពូជកើតអំពីមាត់ព្រះព្រហ្ម ។
- អនាថា (គុ) បា.សំ : ដែលគ្មានទីពឹង ដែលអត់អ្នកជាទីពំនាក់ ។
- ឧត្តមមន្ត្រី (ន) បា.សំ : អ្នកធ្វើការថ្នាក់ខ្ពស់ក្នុងរាជការ អ្នកមានបុណ្យសក្តិធំ ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ អ្នកគប្បីអានដោយយកចិត្តទុកដាក់ដើម្បីឆ្លើយនឹងសំណួរទាក់ទងនឹងខ្លឹមសារតួអង្គ ទំនាស់ ភាសារស់រវើក និងតម្លៃអប់រំរបស់អត្ថបទ ។

## គ. អត្ថបទ

គ្រួសារសេដ្ឋីមួយមានកូន៥នាក់សុទ្ធតែប្រុសទាំងអស់ ។ ដោយឡែកកូនទី៥អភ័ព្វជាងគេ ព្រោះកើតមកពុំមានជើងដូចគេ ។ សេដ្ឋីជាមាតាបិតាមានសេចក្តីអៀនខ្មាស ដោយគិតថា កូនពិការបែបនេះនឹងធ្វើឱ្យអាប់ឱនកិត្តិយសខ្លួន ក៏ប្រើឱ្យទាសីយកកូននោះដាក់ក្នុងឆ្នាំងបណ្តែតតាមទឹកហូរចោលទៅ ។

ឆ្នាំងបាននាំទារកកម្សត់នោះទៅតាមល្បឿនទឹកហូរអស់មួយរាត្រី បានដល់ភូមិជនបទមួយដែលព្រាហ្មណ៍រស់នៅ ។ ព្រាហ្មណ៍នោះជាអ្នកចេះវិជ្ជាពេទ្យយ៉ាងស្ទាត់ជំនាញផង ។ ព្រាហ្មណ៍បានរើសឆ្នាំងនោះ ក៏ឃើញទារកកំបុតជើងទាំងសងខាងនៅរស់នៅឡើយ ។ គាត់មានសេចក្តីត្រេកអរខ្លាំងណាស់ បានយកទារកនោះទៅចិញ្ចឹមបីបាច់ថែរក្សាទុកដូចជាកូនបង្កើតរបស់ខ្លួនអ៊ីចឹង ដោយដាក់ឈ្មោះឱ្យកូននោះថា "កុម្ភកុមារ" ។

ចំណែកទាសីដែលបានយកទារកទៅបណ្តែតទឹកចោលនោះវិញ មានសេចក្តីអាណិតអាសូរទារកនោះជាពន់ពេក ដេកមិនលក់ នៅពាក់កណ្តាលអធ្រាត្រនាងសម្រេចរត់ចេញពីផ្ទះសេដ្ឋី ដើម្បីទៅតាមស្វែងរកទារកនោះមកចិញ្ចឹម ។ លុះទៅដល់ភូមិមួយ នាងបានជួបទារកនៅជាមួយព្រាហ្មណ៍ ប៉ុន្តែនាងមិននិយាយអ្វីទាំងអស់ បែរជាសុំព្រាហ្មណ៍នៅបម្រើដោយឥតយកថ្លៃឈ្នួលអ្វីទៅវិញ ។ ព្រាហ្មណ៍នឹកក្នុងចិត្តថាអស្ចារ្យណាស់ ទារកនេះជាមហាប្រសើររបស់អញហើយ គ្រាន់តែមកដល់ផ្ទះមានខ្ញុំបម្រើភ្លាម ។

ប្រាំបីឆ្នាំកន្លងផុតទៅ កុម្ភកុមារចេះនិយាយស្តីដឹងការសព្វបែបយ៉ាង ។ នាងទាសីមានឱកាសក៏បានប្រាប់អាថ៌កំបាំងដល់កុមារតាមដំណើររឿង ធ្វើឱ្យកុមារហូរទឹកភ្នែករហាមនឹកស្រណោះអាណិតខ្លួន ជាមនុស្សខ្វិនខ្វង់កួងក្ងែងពិការអនាថា គ្មានទីពឹងដែលត្រូវគេបំបរបង់ចោលអណ្តែតត្រសែតដូចគល់ឈើក្នុងមហាសាគរ គ្មានអាណិតអាសូរ និងមិនអាចធ្វើខ្លួនឱ្យជាមនុស្សមានទ្រព្យដូចគេឡើយ ។

ព្រាហ្មណ៍ជាឪពុកចិញ្ចឹមបានឮដំណឹងនេះ ក៏បាននិយាយអប់រំទូន្មានកុម្ភកុមារថា "ទ្រព្យសម្បត្តិ កិត្តិយស មិនមែនកើតពីដៃជើង ពីឪពុកម្តាយ ពីញាតិមិត្តទេ គឺពិតជាកើតមកពីសេចក្តីព្យាយាម ។ សូម្បីតែជាតំណក់ទឹកជាវត្ថុទន់ជ្រាយគ្មានវិញ្ញាណ គ្មានដៃជើង គ្មានឪពុកម្តាយ គ្មានញាតិមិត្ត ក៏អាចទម្លុះផ្ទាំងថ្មភ្នំដ៏រឹងមាំបាន ដោយសារតែសេចក្តីព្យាយាម ដែលស្រក់តក់ៗ ជារៀងរាល់ថ្ងៃនោះដែរ" ។ ចំណែកកូនគ្រាន់តែគ្មានជើងប៉ុណ្ណោះ បើកូនមានសេចក្តីព្យាយាម កូនអាចប្រសើរវិសេសជាងអ្នកមានដៃជើង ច្រើនទៅទៀត ។ កូនឃើញទេ អ្នកសុំទានមានដៃជើងគ្រប់គ្រាន់ ហេតុអ្វីបានជាគ្មាន

ទ្រព្យសម្បត្តិនិងកិត្តិយសដូចគេឯង ។ ម្យ៉ាងទៀតនៅក្នុងរឿងរាមកេរ្តិ៍ដូចជា យក្សទសកណ្ឋមានដៃជើងមួយពាន់ មានក្បាលដប់ ហេតុអ្វីច្បាំងចាញ់ព្រះរាមនិងហនុមានទៅវិញ ។ ម្នាលកូនសម្លាញ់ ចាប់ពីថ្ងៃនេះទៅកូនត្រូវព្យាយាមរៀនសូត្រអក្សរសាស្ត្រនិងវិជ្ជាពេទ្យពីឪពុកចុះ ឪពុកនឹងបង្រៀនកូន ។

ដប់ពីរឆ្នាំកន្លងផុតទៅ កុម្ភកុមារបានសម្រេចវិជ្ជាអក្សរសាស្ត្រនិងវិជ្ជាពេទ្យយ៉ាងស្ទាត់ជំនាញ ។ ឪពុកចិញ្ចឹមបាននាំទៅប្រឡងនៅទីក្រុង បានជាប់លេខ១ ថ្នាក់បណ្ឌិតខាងវិជ្ជាពេទ្យ មានកិត្តិសព្ទល្បីល្បាញពេញទីក្រុង ។ ព្រះរាជាបានប្រទានឋានន្តរស័ក្តិជាឧត្តមមន្ត្រីកិត្តិយស ហើយទ្រង់ប្រទានបុរសមានកម្លាំងខ្លាំងក្លាពីរនាក់ ជាមួយនឹងអង្រឹងស្នែងមួយសម្រាប់ជាយានជំនិះ ។ តាំងពីពេលនោះមកមនុស្សម្នាទាំងឡាយនាំគ្នាហៅកុម្ភកុមារថា គ្រូពេទ្យជើងបួន ដោយហេតុថាមានមនុស្សពីរនាក់ជាអ្នកសែងគាត់ទៅគ្រប់ទីកន្លែង ។

និយាយពីបងប្អូន៤នាក់ទៀតរបស់កុម្ភកុមារ ដែលរស់នៅជាមួយឪពុកម្ដាយជាសេដ្ឋីនោះវិញ មិនបានសិក្សារៀនសូត្រជ្រៅជ្រះឡើយ ។ ម្នាក់ៗគិតតែសប្បាយខ្លះយកប្រពន្ធដោយចិត្តឯង ខ្លះលួចទ្រព្យសម្បត្តិទៅឱ្យប្រពន្ធដោយមិនរវល់ជាមួយឪពុកម្ដាយឡើយ ។ ថ្ងៃមួយ លោកសេដ្ឋីធ្លាក់ខ្លួនឈឺជាទម្ងន់ គ្រូពេទ្យជាច្រើនមើលមិនជាសោះ សេដ្ឋីបានឱ្យអ្នកបម្រើទៅអញ្ជើញលោកគ្រូពេទ្យជើងបួនមកព្យាបាលម្ដងវិញ ព្រោះល្បីថាពូកែខ្លាំងណាស់ ។

អ្នកបម្រើបានទៅជួបទាសី ប៉ុន្តែនាងមិនប្រាប់អាថ៌កំបាំងទេ នាងបែរជានិយាយថា សព្វថ្ងៃនេះខ្ញុំទៅបម្រើលោកគ្រូពេទ្យជើងបួន តែឥឡូវលោករវល់ណាស់ ទៅមើលថៅហ្វាយបងមិនបានទេ សូមទៅជម្រាបលោកវិញចុះ ។ អ្នកបម្រើបានទៅជម្រាបលោកសេដ្ឋីតាមដំណើររឿង តែលោកសេដ្ឋីនិងប្រពន្ធមិនអស់ចិត្ត បានឱ្យអ្នកបម្រើទៅអញ្ជើញលោកគ្រូពេទ្យជើងបួនម្ដងទៀត ។ អ្នកបម្រើនិយាយប្រាប់ទាសីថា "បើមើលលោកសេដ្ឋីជា លោកសេដ្ឋីនិងប្រគល់ទ្រព្យសម្បត្តិឱ្យទាំងអស់" ។ នាងទាសីឮអ្នកបម្រើពោលដូច្នោះ ក៏នាំអ្នកបម្រើទៅជួបគ្រូពេទ្យ តែនាងមិននិយាយប្រាប់លោកគ្រូពេទ្យជើងបួនថាសេដ្ឋីនោះជាឪពុកខ្លួននោះទេ ។ គ្រូពេទ្យបានយល់ព្រមទទួលទៅព្យាបាលសេដ្ឋី ។ មួយរយៈពេលខ្លីកន្លងទៅ សេដ្ឋីបានជាសះស្បើយដូចបំណង សេដ្ឋីក៏បានប្រគល់ទ្រព្យសម្បត្តិឱ្យគ្រូពេទ្យតាមពាក្យសន្យា ។ នៅខណៈនោះទាសីបានចូលទៅបង្ហាញខ្លួននិងបានជម្រាបលោកសេដ្ឋីថា ៖ "លោកគ្រូពេទ្យជើងបួននេះហើយ ជាកូនរបស់លោកសេដ្ឋី ដែលនាងខ្ញុំបានយកទៅបណ្ដែតទឹកចោលនោះ" ។ គ្រាន់តែឮទាសីនិយាយប៉ុណ្ណោះ លោកសេដ្ឋីនិងភរិយាស្ទុះទៅឱបគ្រូពេទ្យជើងបួន សុំឱ្យគ្រូពេទ្យអភ័យទោសដល់ពួកគាត់ទាំងពីរនាក់ រីឯគ្រូពេទ្យមានសេចក្ដីត្រេកអរយ៉ាងក្រៃលែង ដោយបានជួបឪពុកម្ដាយ ។

ចំណែកតាព្រាហ្មណ៍ជាឪពុកចិញ្ចឹម លោកគ្រូពេទ្យបានយកមករស់នៅជួបជុំជាមួយគ្រួសារលោកសេដ្ឋី ហើយនាងទាសីត្រូវបានលោកគ្រូពេទ្យលើកតម្កើងជាបងស្រីបង្កើត រស់នៅក្នុងគ្រួសារលោកសេដ្ឋីផងដែរ ។

## សំណួរ

១. តើកុម្ភកុមារជានរណា ?

២. ក្រោយពីដឹងប្រវត្តិខ្លួន តើកុម្ភកុមារមានអារម្មណ៍ដូចម្តេច ?

៣. តើព្រាហ្មណ៍ជាឪពុកចិញ្ចឹមបានអប់រំនិងលើកទឹកចិត្តកុម្ភកុមារដូចម្តេចខ្លះ ?

៤. ហេតុអ្វីបានជាកុម្ភកុមារមានឈ្មោះជាគ្រូពេទ្យជើងបួន ?

៥. តើរឿងនេះមានតួអង្គណាខ្លះ ? នរណាជាតួអង្គឯក ?

៦. ចូរបង្ហាញពីទំនាស់ក្នុងខ្លួនរបស់តួអង្គក្នុងអត្ថបទខាងលើនេះ ។

៧. ចូរស្រង់ឃ្លាឬល្បះដែលបង្ហាញពីភាសារស់រវើក ។

# សព្វនាមឈ្នាប់ (ដែល)

អ្នកបានសិក្សារួចមកហើយពីសព្វនាមនិងប្រភេទរបស់សព្វនាម ។ សព្វនាមគឺជាពាក្យឬកន្សោមពាក្យសម្រាប់ប្រើជំនួសកន្សោមនាមដែលនិយាយរួចហើយ ។ សព្វនាម មានសព្វនាមបុរិសៈ សព្វនាមចង្អុល សព្វនាមសំណួរ សព្វនាមមិនច្បាស់ ។ ពេលនេះ អ្នកនឹងសិក្សាអំពីសព្វនាមឈ្នាប់ ។

ដូចម្ដេចហៅថាសព្វនាមឈ្នាប់ ? តើសព្វនាមឈ្នាប់មាននាទីដូចម្ដេចខ្លះ ?

ចូរពិនិត្យឧទាហរណ៍ :

១. ឪពុកខ្ញុំដឹកគោឈ្មោលមួយនឹមទៅស្រែ ។

២. គោឈ្មោលមួយនឹមនេះពូកែអូសរនាស់ណាស់ ។

៣. បុប្ផាដាក់ប៊ិកហ្វឹតមួយប្រអប់ក្នុងសំពៀត ។

៤. បុប្ផាទើបនឹងទិញប៊ិកហ្វឹតមួយប្រអប់នេះ ។

គេអាចបង្រួមល្បះទី១ និងទី២ដោយផ្លាស់កន្សោមនាម "**គោឈ្មោលមួយនឹម**" ក្នុងល្បះទី២រួចជំនួសដោយ "**ដែល**" ។ យើងបាន **ក** → គោឈ្មោលមួយនឹមដែលឪពុកខ្ញុំដឹកទៅស្រែពូកែអូសរនាស់ណាស់ ។ ល្បះ "**ពូកែអូសរនាស់ណាស់**" ជាល្បះរណប ។

គេអាចបង្រួមល្បះទី៣ និងទី៤ដោយផ្លាស់កន្សោមនាម "**ប៊ិកហ្វឹតមួយប្រអប់**" ក្នុងល្បះទី៤ រួចជំនួសដោយ "**ដែល**" ។ យើងបាន **ខ** → បុប្ផាដាក់ប៊ិកហ្វឹតមួយប្រអប់ដែលទើបនឹងទិញក្នុងសំពៀត ។ ល្បះ "**ទើបនឹងទិញ**" ជាល្បះរណប ។

តាមឧទាហរណ៍ខាងលើសព្វនាមឈ្នាប់ "**ដែល**" ប្រើជំនួសកន្សោមនាមនិងបង្កើតល្បះរណប ។ តើគេប្រើប្រាស់សព្វនាមឈ្នាប់ "**ដែល**" ដូចម្ដេចខ្លះនៅក្នុងល្បះ?

ចូរពិនិត្យឧទាហរណ៍ :

១. នេះជាកុមារដែលរៀនពូកែជាងគេ ។

២. សៀវភៅទាំងអស់ដែលពុកខ្ញុំទើបនឹងទិញឱ្យខ្ញុំ សុទ្ធតែជាសៀវភៅរឿងនិទាន ។

៣. តុមូលមួយដែលគេដាក់ថូផ្កា នៅលើនោះជារបស់លោកគ្រូ ។

តាមឧទាហរណ៍ខាងលើ :

- ល្បះទី១ : សព្វនាមឈ្នាប់ "ដែល" ជាប្រធានរបស់កិរិយា "រៀន" ។
- ល្បះទី២ : សព្វនាមឈ្នាប់ "ដែល" ជាកម្មបទរបស់កិរិយា "ទិញ" ។

- ល្បះទី ៣ : សព្វនាមឈ្នាប់ "ដែល" ជាកម្មទេសកាលប្រាប់កន្លែងកិរិយា "ដាក់" (នៅលើ) ។

ដូចនេះ នៅក្នុងល្បះ សព្វនាមឈ្នាប់ "ដែល" មានមុខងារជាប្រធាន ជាកម្មបទ ឬជាកម្មទេសកាល ។

## លំហាត់

១. ចូរបង្ហាញមុខងារសព្វនាមឈ្នាប់ "ដែល" នៅក្នុងល្បះខាងក្រោម :

ក. សំជាកល្យាណមិត្ត ដែលខ្ញុំស្រឡាញ់ជាងគេ ។

ខ. ប្រាសាទព្រះវិហារជាបេតិកភណ្ឌជាតិ ដែលខ្មែរគ្រប់រូបត្រូវចូលរួមការពារ ។

គ. សត្វពាហនៈទាំងឡាយ ដែលកំពុងស៊ីស្មៅនេះជាកម្លាំងអូសទាញយ៉ាងសំខាន់របស់យើង ។

ឃ. ថ្ងៃអាទិត្យដែលយើងបានជួបគាត់នោះ ជាថ្ងៃស្គាល់គ្នាដំបូង ។

ង. ម៉ូតូដែលបញ្ឈរក្រោមដើមឈើនោះជារបស់ដាណេ ។

២. ចូរតែងល្បះដែលប្រើសព្វនាមឈ្នាប់ "ដែល" មានមុខងារជាប្រធាន កម្មបទ និងកម្មទេសកាលឱ្យបានពីរៗល្បះ ។

## សញ្ញាលាក់ ឬបេយ្យាលៈ (។ល។)

អ្នកបានសិក្សាខ្លះៗហើយអំពីសញ្ញាពិសេស។ សញ្ញាពិសេសជាសញ្ញាដែលប្រើទាក់ទងនឹងឃ្លា ល្បះនិងអត្ថបទ។ សញ្ញាពិសេសមានដូចជា សញ្ញាគូសមួយ(-) ដំពីរ(៖) ក្បៀសបើកបិទ ( "....", "......") វង់ក្រចកជ្រុងឬតង្កៀប ( [ ] ) វង់ក្រចក ( ) លាក់ ( ។ល។)។

ដូចម្តេចហៅថាលាក់ ឬបេយ្យាលៈ?

ចូរពិនិត្យឧទាហរណ៍ :

១. ការស្រូបផ្សែងរបស់កុមារបណ្តាលឱ្យកុមារមានជំងឺផ្លូវដង្ហើម បន្ថយការលូតលាស់នៃសួត និងមានជំងឺហឺត មហារីកឈាម មហារីកខួរក្បាល ។ល។ ដែលជាជំងឺពិបាកព្យាបាល។

២. ថ្វីត្បិតតែផ្សារនេះតូចមែន ប៉ុន្តែខ្ញុំឃើញលក់គ្រឿងបរិភោគច្រើនមុខដូចជា ខាងបន្លែមានស្ពៃ សាលាដ ខាត់ណា ត្រកួន ផ្ទី ត្រយូងចេក ។ល។ ខាងផ្លែឈើមានចេក ស្វាយ ដូង ខ្នុរ ឪឡឹក ចំណែកម្ហូបមានត្រី សាច់ជ្រូក មាន់ ទា សាច់គោ ។ល។

តាមឧទាហរណ៍ទាំងពីរខាងលើបង្ហាញឱ្យឃើញថា សញ្ញាលាក់គេអាចប្រើដាក់នៅក្នុងល្បះ ឬខាងចុងល្បះ ឬក៏ចុងអត្ថបទ ហើយសម្គាល់ថា អ្វីៗដែលគេរៀបរាប់មិនទាន់អស់នៅមានតទៅទៀត។

### លំហាត់

១. ចូរប្រើសញ្ញាលាក់ ឬបេយ្យាលៈក្នុងកថាខណ្ឌខាងក្រោមឱ្យបានត្រឹមត្រូវ :

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលបុព្វបុរសខ្មែរបានបន្សល់ទុកនូវកេរដំណែលវប្បធម៌ជាច្រើនសម្រាប់កូនចៅជំនាន់ក្រោយដូចជា ប្រាសាទបុរាណនានា របាំ ចម្លាក់ ចម្រៀង ព្រមទាំងសម្បត្តិធម្មជាតិច្រើនទៀតដូចជា ទឹកដី ព្រៃឈើ សត្វព្រៃ ត្រី។

២. ចូរតែងកថាខណ្ឌមួយដោយប្រើសញ្ញាលាក់ឬបេយ្យាលៈនៅក្នុងល្បះ ឬចុងល្បះឱ្យបានត្រឹមត្រូវ។



# ទឹកចិត្តមិត្តខ្ញុំ



## ក. សិក្សាពាក្យគន្លឹះ

- គូកន (ន) : មិត្តភក្តិ អ្នកសេពគប់ជាមួយគ្នា ។
- បំណុល (ន) : ទ្រព្យដែលជំពាក់បុលគេ ព្រោះខ្ចីគេ ។
- អភិជន (ន) : មនុស្សខ្ពង់ខ្ពស់ ជនដែលសំបូរដោយទ្រព្យធននិងបុណ្យសក្តិ ។
- ឋានន្តរសក្តិ (ន) បា.សំ : អំណាចតាមមុខងារ បណ្តាសក្តិតាមនាទី ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ អ្នកគប្បីអានដោយយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹងសេចក្តីលំអិតសំខាន់ៗ ទំនាស់ សព្វនាមឈ្មោះ និងតម្លៃអប់រំរបស់អត្ថបទ ។

## គ. អត្ថបទ

កាលនៅរៀនអនុវិទ្យាល័យអ៊ីស្វារ ក្នុងក្រុងអូវែញ មានសិស្សពីរនាក់ជាកល្យាណមិត្តនឹងគ្នា ។ សាណូតជាកូនអ្នកជំនួញសេះនិងលា មានទ្រព្យសម្បត្តិស្តុកស្តម្ភ ។ ឯកូឡាំងជាកូនអ្នកស្រែដែលមានវង្សត្រកូលល្អ ។

ថ្ងៃមួយ ឪពុកសាណូតបានចំណាយទ្រព្យគិតគូរឱ្យបានងារជាមន្ត្រី ដែលមានកិត្តិយសយ៉ាងខ្ពង់ខ្ពស់ ។ កូឡាំងគ្មានចិត្តច្រណែននឹងសាណូតដែលឡើងឋានៈជាកូនមន្ត្រីនេះឡើយ ។ ចំណែកសាណូតវិញបែរជាប្រកាន់ឫកពាជាអ្នកធំហួសទៅវិញ ធ្វើឱ្យកូឡាំងធុញថប់ក្នុងចិត្តជាពន់ពេក ។ តាំងពីថ្ងៃបានឡើងជាកូនមន្ត្រីធំមក សាណូតលែងខិតខំរៀនសូត្រ គិតតែស្លុះកញ្ចក់តែងខ្លួន ហើយមើលងាយគូកនទាំងឡាយ ដែលមានអាយុប្រហាក់ប្រហែលនឹងវា ។

ក្រោយមក ឪពុកសាណូតក៏នាំកូនទៅនៅឯទីក្រុងប៉ារីស ។ សាណូតចាកចេញពីអនុវិទ្យាល័យដោយគ្មានទៅលាគូកនសោះ គ្រាន់តែញញឹមរកកូឡាំងបន្តិចជាការគួរសោះតែខាន ។ នៅទីក្រុងប៉ារីស មាតាបិតាសាណូតជួលអ្នកអប់រំម្នាក់មកបង្ហាញសាណូតអំពីរបៀបអ្នកធំ ។ ផ្ទុយពីសាណូត កូឡាំងតែងនឹកឃើញសាណូតជានិច្ច ។ គេបានសរសេរសំបុត្រមួយច្បាប់ផ្ញើទៅសាណូត ។ ដោយកំពុងស្រវឹងនឹងបុណ្យសក្តិ សាណូតមិនអើពើនឹងតបសំបុត្រមកសម្លាញ់វិញឡើយ ។ ប៉ុន្តែរបៀបជាអភិជននេះ ធ្វើឱ្យមាតាបិតាសាណូត វិនាសអស់ភោគសម្បត្តិក្នុងពេលដ៏ខ្លី ។ លោកមន្ត្រីធំនេះធ្លាក់ខ្លួនដល់ជាប់គុកពីព្រោះបំណុល ។ ឯផ្ទះលោកសោតក៏ត្រូវម្ចាស់បំណុលរឹបអូសយកអស់ដែរ ។ ក្នុងគ្រាលំបាកនេះ កាលណាសាណូតនិយាយ មិត្តណាក៏បែរខ្នងឱ្យវាដែរ ។

ថ្ងៃមួយ ពេលសាណូតកំពុងឈរកើតទុក្ខនៅក្បែរសសរដងគោម មានរថយន្តមួយសណ្តោងរទេះផ្ទុកទំនិញពេញមកជិតវា ។ បណ្តាពួកអ្នកជិះរទេះនោះ មានយុវជនម្នាក់ស្រែកទាំងភ្ញាក់ផ្អើលៈ "ឱ! លោកអើយ ! សាណូតគូកនខ្ញុំទេដឹង !" ។ អ្នកស្រែកនោះ គឺកូឡាំង ។ ស្គាល់ជាក់ថាសាណូតហើយ កូឡាំងក៏លោតចុះពីរថយន្តទៅឱបសម្លាញ់ដោយរាក់ទាក់ ។ ឯសាណូតមុខឡើងក្រហមទឹកភ្នែកហូររហាម ដោយអៀនខ្មាស ។ កូឡាំងនិយាយទៅកាន់សាណូត "ឯងសុខសប្បាយឬទេសាណូត ?" ។ ឃើញសម្លៀកបំពាក់រយីករយាករបស់សាណូត កូឡាំងបន្ត "ជីវភាពឯងមានបញ្ហាឬ ? ទោះជាយ៉ាងណាក៏ដោយ អញនៅតែស្រឡាញ់ឯងជាដរាប" ។ សាណូតថ្លែងសេចក្តីទុក្ខរបស់ខ្លួនប្រាប់សម្លាញ់សព្វគ្រប់ទាំងអៀនអន់អាក់អួល ។

កូឡាំងនិយាយកាត់ "កុំព្រួយថ្វីសម្លាញ់ ទៅបាយជាមួយនឹងអញ នេះប្រពន្ធអញ អីវ៉ាន់ក្នុងរទេះទាំងប៉ុន្មានជារបស់អញ ។ អញធ្វើជាម្ចាស់រោងចក្រសិតដែកនិងស្ពាន់មួយ ចាំអញជួយឯងឱ្យរកស៊ី ឈប់ធ្វើនាម៉ឺនទៅ ។ នៅក្នុងលោកនេះ ឋានន្តរសក្តិដ៏ខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ ក៏ពុំមានតម្លៃស្មើនឹងកល្យាណមិត្រឡើយ ។ ចាំអញបង្ហាត់បង្ហាញឯងឱ្យចេះធ្វើការជាមួយនឹងអញ ហើយនាំគ្នារកស៊ីឱ្យបានកើតកាលវាលគុម្ព នៅស្រុកកំណើតយើង ។ ឯម្តាយសាណូតឯង ចាំអញជួយចិញ្ចឹមរក្សាគាត់ ហើយអញនឹងគិតគូរឱ្យឪពុកឯងរួចពីគុកទាល់តែបាន ។ ឯងជឿអញចុះ! អញមិននិយាយបាតដៃខ្នងដៃទេ" ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅមូលវិជ្ជាខេមរភាសាមធ្យមដ្ឋានទី២និងឧត្តមដ្ឋាន)*

## សំណួរ

១. តើសាណូតមានអាកប្បកិរិយាដូចម្តេចនៅពេលដែលរូបគេជាកូនអភិជន ? ហេតុអ្វីបានជាជីវភាពសាណូតមានការប្រែប្រួល ?

២. តើកូឡាំងមានគំនិតបែបណាចំពោះឥរិយាបថសាណូត ?

៣. ចូរបង្ហាញពីទំនាស់ក្រៅខ្លួនរបស់តួអង្គសាណូតក្នុងអត្ថបទខាងលើ ។

៤. ចូរស្រង់សព្វនាមឈ្នាប់ "ដែល" រួចបង្ហាញមុខងារផង ។

 

# រឿង ចិត្តចៅ



## ក. សិក្សាពាក្យគន្លឹះ

- ខ្ទីវខ្ទូវ (គុ) : ដែលជ្រួញក្រញូវ វក់វី ។
- ខ្សែឡ (កិ) : ស្រែកឡូឡា ហ៊ោកញ្ជ្រៀវអឺងកង ស្រែកផ្ដេសផ្ដាស ។
- អសុរោះវាចា (ន) : សំដីគ្មានការគួរសម សំដីមើលងាយ សំដីខ្មោះខ្មួរ ។
- សាចព្រាច (កិ) : បាចសាច ចាំងថែង ។
- ពិតាន (ន) : របាំងក្រោមដំបូល ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ អ្នកគប្បីអានដោយយកចិត្តទុកដាក់ ដើម្បីឆ្លើយនឹងសំណួរទាក់ទងនឹងកាលអាកាស ទំនាស់ ភាសាច្បាស់លាស់ និងតម្លៃអប់រំរបស់អត្ថបទ ។

## គ. អត្ថបទ

ថ្ងៃនោះ នៅផ្ទះសុខមានសភាពស្ងាត់ជ្រងំ ខុសប្រក្រតី ។

ឪពុកវាជាអ្នកបើបររថយន្ត ដឹកទំនិញកំពង់ផែកំពង់សោម ។ គាត់បានចេញដំណើរទៅដាក់ទំនិញ តាំងពីថ្ងៃមកម្ល៉េះ ។ ម្ដាយសុខក៏បាននាំប្អូនស្រីវាទៅជាមួយ ដើម្បីព្យាបាលភ្នែកនៅមន្ទីរពេទ្យប្រហែលពីរបីថ្ងៃទៀត ទើបគាត់ត្រឡប់មកវិញ ។ ក្នុងផ្ទះ នៅសល់តែដូនចាស់ខ្វិនម្នាក់ និងក្មេងប្រុសអាយុ ១៥ ឆ្នាំ គឺសុខ ។ [.....]

រាត្រីនោះ នាឡិកាបន្លឺម៉ោងប្រាំបួន ។ ខាងក្រៅផ្ទះ មេឃងងឹតចាក់ភ្នែកមិនធ្លុះ ភ្លៀងបង្អុរមិនឈប់ ខ្យល់បក់បោកយ៉ាងខ្លាំង ។ ដូនចាស់មិនទាន់សម្រាន្តនៅឡើយ គាត់អង្គុយចាក់ប្ញសក្នុងកៅអីបង្អែកមួយ ក្នុងបន្ទប់ដែលស្ថិតនៅជាប់នឹងសួនបន្លែ ។ បន្ទប់នេះ មានសុទ្ធតែតុ ទូចាស់ៗដាក់រាយពាសពេញ ។ ដូនចាស់កើតក្ដីព្រួយបារម្ភពន់ពេក ។ ស្នូរនីមួយៗតែងធ្វើឱ្យគាត់ចាប់អារម្មណ៍ហើយផ្ទៀងត្រចៀកស្ដាប់ ស្រាប់តែ ៖

តុក ! តុក ! ស្នូរគោះទ្វារ លាន់ឮឡើង ។

"ច្បាស់ជាអាសុខ មកពីដើរលេងហើយ" ដូនចាស់នឹកក្នុងចិត្ត ។

ពិតជាអាសុខមែន ខ្លួនវាទទឹកជោក ។ សក់ក្បាលខ្ចីវខ្ចូវដូចកណ្ដុរលង់ទឹក ។ ថ្ពាល់វាឡើងហើម ។ វាឈ្លោះជាមួយគេ ត្រូវគេវាយជាដំណាំ ។ មួកវាត្រូវខ្យល់ប៉ើងធ្លាក់ទៅក្នុងរណ្ដៅ មិនតែប៉ុណ្ណោះ វាថែមទាំងលេងល្បែងចាញ់អស់ប្រាក់ គ្មានសល់លុយកាក់ ។

ទោះបីចង្កៀងប្រេងកាតមានពន្លឺព្រឹមៗក៏ដោយ ដូនចាស់នៅតែមើលឃើញភាពស្លេកស្លាំង គួរឱ្យអាណិតនៃចៅគាត់ ។ គ្រាន់តែសួរមួយម៉ាត់ពីរ ដូនចាស់ដឹងភ្លាមថាចៅសម្លាញ់គាត់ឈ្លោះគ្នា ។ កាលបើដឹងថាមិនអាចលាក់លៀមតទៅទៀតបាន សុខក៏ទទួលសារភាពអស់គ្មានសល់ ។ ដោយអាណិតស្រឡាញ់ចៅខ្លាំងពេក ដូនចាស់យំខ្សឹកខ្សួល តំណក់ទឹកភ្នែកហូរកាត់ផែនថ្ពាល់ដ៏ជ្រីវជ្រួញរបស់គាត់ ។ គាត់ត្អូញ ៖

"ចៅអើយ ! ចៅមិនស្រឡាញ់យាយតិចតួចឡើយ ។ បើមិនអីចឹង ហេតុអ្វីបានជាចៅឆ្លៀតឱកាសឪពុកម្ដាយមិននៅ ដើរលេងប៉ោវឡៅទុកឱ្យយាយនៅផ្ទះម្នាក់ឯងយ៉ាងនេះ ? អីក៏ដាច់ចិត្តម្ល៉េះ ចៅមិនអាណិតយាយទេឬ ? សុខចៅសម្លាញ់ ! ចៅចាប់ផ្ដើមដើរផ្លូវខុសហើយ ផ្លូវដែលនាំទៅកាន់អបាយមុខដ៏អាស្រូវបំផុត ។ ជីដូនបានឃើញជាច្រើននាក់មកហើយ ដែលចាប់ផ្ដើមខិលខូចដូចចៅ

ហើយក្រោយមកក៏ក្លាយជាជនពាលទុច្ចរិត។ ដំបូងឡើយ គេគេចពីផ្ទះ ដើរលេងមិនចូលរៀន ប្រវាយប្រតប់ជាមួយមិត្តភក្តិ ងប់នឹងល្បែង។ អស់ពីដាល់តប់ទាត់ធាក់ តាំងគប់គ្នានឹងដុំថ្ម រួចប្រើកាំបិតចាក់គ្នា។ អស់ពីហៀប៉ោ ធ្លាក់ដល់អំពើផ្តេសផ្តាស តាំងធ្លាក់ដល់លួចប្លន់"។

សុខឈរផ្អែកទូនៅស្ងៀមឱនមុខជ្រប់ ចម្ងាយពីដូនចាស់ប្រហែលបីជំហាន។ ដូនចាស់និយាយបណ្តើរយំបណ្តើរ "ពីហៀប៉ោទៅលួចប្លន់មិនឆ្ងាយទេចៅ។ ចៅមើលអាម៉ូវ អាចោរលួចប្លន់រអាវអូមនៅតំបន់នេះ។ អាយុវាទើបតែ ២៤ឆ្នាំ តែវាចូលគុកពីរបីដងរួចទៅហើយ។ ម្តាយវា យាយក៏ស្គាល់។ គាត់ស្លាប់ដោយព្រួយចិត្តនឹងកូនខ្លាំងពេក។ អស់សង្ឃឹម ឪពុកវាក៏ចុះកាសែតកាត់កាល់លែងទទួលស្គាល់កូនទៀត។ អាម៉ូវនេះ យាយស្គាល់វាតាំងពីតូច។ ដើមឡើយវាដើរអាវ៉ាសែដូចចៅ យូរទៅវារឹតតែខិលខូចខ្លាំងឡើងៗ។ បើចៅមិនស្តាប់យាយ ឪពុកចៅមុខជាទទួលវាសនាអភ័ព្វ ដូចម្តាយឪពុកវាមិនខាន"។ [...]

ស្តាប់ដល់ត្រឹមនេះ សុខរំជួលចិត្តយ៉ាងខ្លាំង ហៀបនឹងរត់ទៅរកយាយ ស្រាប់តែឮសំឡេងសស្រោកសស្រាំនៅខាងក្រៅ។ សុខឈប់ស្ងៀមខំផ្ទៀងត្រចៀកស្តាប់។ [....]

បុរសម្នាក់ស្ទុះហោមក ដៃម្ខាងចាប់សុខជាប់ ដៃម្ខាងខ្ទប់មាត់វា។ បុរសម្នាក់ទៀតលោតមកច្របាច់កដូនចាស់។

បុរសទីមួយនិយាយ : "បើចង់រស់នៅឱ្យស្ងៀម"។

បុរសទីពីរយារកាំបិតបន្លី : "ស្ងៀម"។

ទាំងពីរនាក់សុទ្ធតែបិទមុខ។ បុរសទីពីរឈ្លេចសួរសុខ : "មាសប្រាក់ឪពុកអាឯងនៅឯណា ?"

សុខឆ្លើយញ័រមាត់ ធ្មេញរណ្តំក្រឹកៗ : "ខ្ញុំមិនដឹងទេ"។

បុរសទីពីរគំហកដូនចាស់ : "ប្រាប់ភ្លាមមកកុំឱ្យឈឺសាច់ទាន់ មីកញ្ជាស់"។

ដូនចាស់ក្បាលងឺងើនិយាយមិនរួច ទើបបុរសទីមួយសង្កុញទៅសុខ : "ម៉ែឯងធ្លាប់ទុកខោអាវនៅឯណា ?"

បុរសទីពីរបញ្ជា : " មកតាមអញ!"។

រួចដៃម្ខាងកាន់ចង្កៀងគោម ដៃម្ខាងគាស់ទូ យករបស់របររួច មុននឹងចេញទៅ ពួកវាគំរាមយាយនិងចៅ នឹងត្រឡប់មកប្រដៅឱ្យស្គាល់ដៃកាលណាយាយ និងចៅស្រែកហៅអ្នកផងឱ្យមកជួយ។

ពេលនោះឮសំឡេងមនុស្សនិយាយគ្នា និងច្រៀងខ្សៀវឡូនៅតាមផ្លូវ ។ បុរសទីពីរងាកមុខមកក្រៅគំហុកពេក បណ្ដាលឱ្យរបូតស្បែកបិទមុខ ។

ដូនចាស់ភ្លាត់មាត់ស្រែក : "អាម៉ូវ !"

ជនទុច្ចរិតស្រែក : "ចង្រៃវាយក៏ ទុកជីវិតហាងមិនបានទេ" ។

ផុតអសុរោះវាចា វាយារកាំបិតសស្វាចចាក់ដូនចាស់ ។

សុខស្ទុះភ្លែតទៅឱបយាយរហ័សដូចព្រួញ ដើម្បីពាំងមុខកាំបិត ។ ដូនចាស់ផ្ងារទៅក្រោយបាត់មាត់ឈឹង ។

ជនទុច្ចរិតទាំងពីររវៀសរវៃពន្លត់ចង្កៀង រួចវេះទៅបាត់ ។ សុខរសាយដៃបន្តិចៗ ដងខ្លួនចុះសស្រឹម ជង្គង់ទាំងពីរដល់ដី ក្បាលផ្ទប់ទៅលើទ្រូងយាយ ។ [...]

ដូនចាស់ដកដង្ហើមធំហាក់ដូចជាដកបន្លាពីទ្រូង ។ សុខនៅតែលុតជង្គង់ឱបយាយបន្លឺបែបផុតៗដង្ហើម ។

"លោកយាយជាទីស្រឡាញ់របស់ ... ចៅ" ។ យាយនៅស្រឡាញ់ ... យាយមិនស្អប់ ... មិនប្រកាន់ ... ខឹងនឹងចៅទេឬ" ?

"ទេចៅកុំថាអីចឹង យាយលែងនឹកនាដល់រឿងនេះហើយ ។ យាយបំភ្លេចចោលហើយ យាយស្រឡាញ់ចៅរបស់យាយណាស់ ... ។"

ដោយសម្ដីញ័រ សុខខិតខំនិយាយតទៅទៀត "ចៅចេះតែធ្វើឱ្យយាយកើតទុក្ខ ប៉ុន្តែចៅស្រឡាញ់យាយជាងគេបង្អស់ សូមយាយលើកលែងទោសឱ្យចៅណា៎ យាយណា៎ យាយកុំប្រកាន់ ... ចៅ ... ទៀត" ។

... ពន្លឺព្រះអាទិត្យនៅពេលព្រឹកចាំងចំកញ្ចក់នៃបន្ទប់អាគារមួយខ្នង ក្នុងមន្ទីរពេទ្យព្រះសីហនុ (មិត្តភាពខ្មែរសូវៀត) សាចព្រាចលើរូបកុមារកម្សត់ដែលដេកស្ដូកស្ដឹងលើគ្រែ ដែលត្រូវរបួសយ៉ាងដំណំលើឆ្អឹងខ្នង ដោយផ្លែកាំបិត ឈាមប្រឡាក់ពាសពេញខ្លួន ។ មួយសន្ទុះក្រោយមក សុខក្រឡេកមើលជុំវិញខ្លួនឃើញអ៊ីសាន ដែលមានលំនៅជាប់គ្នា ឈរសម្លឹងខ្លួនដោយកែវភ្នែកស្រទន់ ។ សុខងាកទៅសម្លឹងទៅពិតានដោយទឹកមុខស្រស់ស្រាយ ។ ក្នុងចិត្តប្រហែលជាប្ដូនរីករាយក្រៃលែងដោយបានសង្គ្រោះជីដូន ជាទីស្រឡាញ់ឱ្យរួចពីសេចក្ដីស្លាប់ ។ [...]

*(ដកស្រង់ និងកែសម្រួលពីសៀវភៅអក្សរសិល្ប៍ថ្នាក់ទី៦ ក្រសួងអប់រំឆ្នាំ១៩៨៤)*

## សំណួរ

១. តាមរយៈដំណើររឿង ដំបូងសុខជាមនុស្សដូចម្ដេច ?

២. តើជីដូនសុខបានអប់រំសុខដូចម្ដេចខ្លះ ?

៣. តើសំដីត្រង់ណាដែលបញ្ជាក់ថាសុខភ្ញាក់រលឹកយល់កំហុសរបស់ខ្លួន ?

៤. តើរឿងនេះមានតួអង្គណាខ្លះ ? នរណាជាតួអង្គឯក ?

៥. ចូរបង្ហាញទំនាស់ក្រៅខ្លួននិងទំនាស់ក្នុងខ្លួនរបស់តួអង្គឯកក្នុងរឿងនេះ ។

៦. ចូរបង្ហាញកាលអាកាសរបស់រឿង ។

៧. ចូរស្រង់ពាក្យជាភាសាច្បាស់លាស់ពីក្នុងអត្ថបទយ៉ាងតិចឱ្យបានបីពាក្យ ។



# ការសូមអភ័យទោស

ក្នុងការរស់នៅប្រចាំថ្ងៃ មនុស្សម្នាក់ៗមិនអាចចៀសផុតពីកំហុសឆ្គងទាំងឡាយនោះទេ ទោះបីកំហុសឆ្គងទាំងនោះកើតឡើងដោយអចេតនា ឬចេតនាដោយសារមោហ៍បាំងមួយពេលក្តី ។ ប៉ុន្តែការទទួលកំហុស ការចេះកែប្រែខ្លួន និងការអធ្យាស្រ័យជាមាគ៌ាដ៏ប្រពៃដែលញ៉ាំងឱ្យសង្គមមានសន្តិភាព ។

ការសូមអភ័យទោសក៏ជាមធ្យោបាយមួយ ឬជាឥរិយាបថប្រពៃមួយ បង្ហាញឱ្យឃើញថាការទទួលស្គាល់នូវកំហុសឆ្គងទាំងឡាយ ដែលគេបានប្រព្រឹត្តកន្លងមកហើយលុបចំបាត់នូវកំហឹង ការគុំគួន ឬការព្យាបាទនានា នាំឱ្យមានភាពរីករាយស្រស់ស្រាយនិងសាមគ្គីភាព ។

ខាងក្រោមនេះជាអត្ថបទគំរូមួយ ស្តីពីការសូមទោសរបស់បូណាចំពោះនារី ព្រោះកាលនៅពេលចេញលេង គេបានប្រលែងគ្នាលេងជាមួយមិត្តភក្តិ រួចក៏ជ្រុលជាន់លើសៀវភៅនារីធ្វើឱ្យប្រឡាក់និងរហែកក្រប ។

- បូណា ៖ នារី !ឱ្យខ្ញុំសូមទោសមិត្តផង ចំពោះទង្វើមិនគួរគប្បីរបស់ខ្ញុំពីអំបាញ់មិញនេះ !
- នារី ៖ មិនអីទេបូណា ! ឱ្យតែមិត្តស្គាល់កំហុស !
- បូណា ៖ ខ្ញុំសោកស្តាយណាស់នារី !មិនគួរណាខ្ញុំរត់ប្រលែងលេងផ្តេសផ្តាសយ៉ាងនេះសោះ ! ខ្ញុំភ្លេចគិតពីបណ្តាំរបស់លោកគ្រូ អ្នកគ្រូ និងបទបញ្ជាផ្ទៃក្នុងរបស់សាលា ទើបមានរឿងនេះកើតឡើង !
- នារី ៖ ណ្ហើយចុះបូណា ! ការប្រឡាក់និងរហែកសៀវភៅបន្តិចបន្តួចនេះមិនអីទេ ! ខ្ញុំមិនប្រកាន់ខឹងនឹងបូណាទេ ! ប៉ុន្តែប្រការសំខាន់មួយទៀតនោះ គឺខ្លាចមានការបាក់បែកតុសម្រាប់យើងអង្គុយសិក្សាសព្វថ្ងៃ ឬក៏មានគ្រោះថ្នាក់ផ្សេងៗទៀតចំពោះយើង ។
- បូណា ៖ ខ្ញុំសូមអរគុណដល់ការអត់អោនរបស់នារីចំពោះកំហុសរបស់ខ្ញុំ ! ពិសេសទៅទៀតខ្ញុំក៏សូមអរគុណចំពោះការដាស់តឿនក្រើនរំលឹករបស់នារីដែរ ! ខ្ញុំប្តេជ្ញាថានឹងឈប់ធ្វើដូចនេះទៀតហើយ !
- នារី ៖ ប្រសើរណាស់មិត្ត ! យើងនៅតែជាមិត្តល្អនឹងគ្នាជានិច្ច ... !

## សំណួរ

១. តើបូណាមានកំហុសអ្វី ទើបគេទៅសូមទោសនារី ?

២. តើបូណាប្រើពាក្យដូចម្ដេចខ្លះដើម្បីសំដែងការសោកស្ដាយនិងការសូមទោសចំពោះនារី ?

៣. តើនារីអធ្យាស្រ័យចំពោះកំហុសឆ្គងរបស់បូណាឬទេ ? ហើយនាងបានដាស់តឿនបូណាដូចម្ដេចខ្លះ ?

៤. តើបូណាប្ដេជ្ញាចិត្តដូចម្ដេចខ្លះ ?

៥. តើក្នុងអត្ថបទគំរូខាងលើ គេប្រើសំនួនអ្វីខ្លះ ដើម្បីសូមទោសនិងការអធ្យាស្រ័យ ?

## លំហាត់

១. ចូរអ្នកចាប់គូគ្នាសម្ដែងពីការសូមអភ័យទោសនិងការអធ្យាស្រ័យឱ្យគ្នា ដោយរើសយកប្រធានបទខាងក្រោម :

ក. ការធ្វើឱ្យរហែកអាវមិត្តភក្ដិខ្លួន

ខ. ការដើរទៅទង្គិចដូនចាស់ម្នាក់នៅក្នុងពិធីបុណ្យមួយ

គ. ការខកខានមិនបានទៅសួរសុខទុក្ខមិត្តភក្ដិដែលមានជំងឺសម្រាកនៅមន្ទីរពេទ្យ

ឃ. ការធ្វើឱ្យបាត់សៀវភៅមិត្តរួមថ្នាក់ ។

២. នៅពេលអ្នកសំដែង ចូរអ្នកយកចិត្តទុកដាក់ទៅលើពាក្យពេចន៍ ឃ្លាល្បះ និងបង្ហាញឥរិយាបថឱ្យសមស្របតាមស្ថានភាពនៃប្រធានបទ ព្រមទាំងប្រើសំនួនឱ្យបានត្រឹមត្រូវ ។

**សំនួនសូមអភ័យទោស**

- សូមអត់ទោសឱ្យខ្ញុំផង ព្រោះ ..........
- សូមលើកលែងទោស .........
- សូមអធ្យាស្រ័យឱ្យខ្ញុំ ..........
- ខ្ញុំសោកស្ដាយណាស់ចំពោះកំហុស ........
- ខ្ញុំដឹងថា ......មានចិត្តទូលាយមិនប្រកាន់ .........
- ខ្ញុំធ្វើនេះដោយអចេតនាទេ សូម ....... ។ល ។

**សំនួនអធ្យាស្រ័យ ឬលើកលែងទោស :**

- មិនអីទេ ! ខ្ញុំគិតថានេះជាកំហុសដោយអចេតនា .........
- ណ្ហើយ ! កុំបារម្ភអ្វី ! ខ្ញុំមិនប្រកាន់ទេ ..........
- មិនអីទេ ! ....ឱ្យតែ .....ចេះភ្ញាក់រឭក ...........
- ប្រសើរណាស់ ! .....ចេះស្គាល់កំហុសដូចនេះ ........ ។ល ។

# សំបុត្រសូមអភ័យទោស

អ្នកបានសិក្សារួចមកហើយអំពីការនិយាយសូមអភ័យទោស ។ ឥឡូវនេះ អ្នកនឹងសិក្សាពីការសរសេរសំបុត្រសូមអភ័យទោសជាបន្ថែមទៀត ។ តើការសរសេរសំបុត្រសូមអភ័យទោសមានលក្ខណៈដូចម្ដេចខ្លះ ។ ចូរពិនិត្យសំបុត្រគំរូខាងក្រោម ដែលវីរៈបានសរសេរសូមអភ័យទោសចំពោះតារា ព្រោះកាលពីថ្ងៃអាទិត្យមុន វីរៈបានឈ្លោះប្រកែកគ្នាជាមួយមិត្តភក្តិដែលលេងបាល់ជាមួយគ្នា ។ តារាជាអ្នកចូលទៅឃាត់និងសម្រុះសម្រួលគ្នា តែត្រូវវីរៈរករឿងវាយតារាថែមទៀត ។

ថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៩

មកដល់តារា ជាទីរាប់អាន !

តារា ! ខ្ញុំមានការសោកស្ដាយណាស់ ចំពោះអំពើខុសឆ្គងរបស់ខ្ញុំទៅលើតារា កាលពីសប្ដាហ៍មុនកន្លងទៅនេះ ។ តារា សូមមិត្តអភ័យទោសឱ្យខ្ញុំផង ចំពោះពាក្យសម្ដីមិនសមរម្យ និងកាយវិការប្រងេងប្រងាងរបស់ខ្ញុំចំពោះតារា ។ គ្រានោះដោយសារខ្ញុំមានចិត្តឆេវឆាវពេក មិនបានគិតពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយ ទើបធ្វើឱ្យខ្ញុំបានប្រព្រឹត្តទង្វើមិនគួរគប្បីចំពោះតារា ។

ក្រោយពីបានធ្វើការពិចារណាមក ខ្ញុំដឹងច្បាស់ថាចិត្តឆេវឆាវរបស់ខ្ញុំ ពុំអាចជួយខ្លួនខ្ញុំឱ្យទទួលបានការរាប់អានស្រឡាញ់ពីមិត្តភក្តិនិងអ្នកដទៃបានឡើយ ខ្ញុំខឹងនឹងខ្លួនឯងណាស់ ហើយជាពិសេសមានការខ្មាសអៀនយ៉ាងខ្លាំងចំពោះតារាតែម្ដង ។ ខ្ញុំពិតជាសោកស្ដាយណាស់ ទើបខ្ញុំសម្រេចចិត្តសរសេរកូនសំបុត្រនេះ សុំឱ្យតារាអភ័យទោសដល់រូបខ្ញុំ ចំពោះការខុសឆ្គងរបស់ខ្ញុំទៅលើតារា ។ ខ្ញុំសង្ឃឹមជឿជាក់ថា តារាពិតជាអធ្យាស្រ័យដល់ខ្ញុំមិនខានឡើយ ហើយយើងទាំងពីរនាក់នៅតែជាមិត្តល្អនឹងគ្នាជានិច្ច ។

សូមតារាទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ

ជិន វីរៈ

## សំណួរ

១. តើនរណាសរសេរសំបុត្រទៅនរណា ? សំបុត្រនេះសរសេរពីបញ្ហាអ្វី ?

២. តើក្បាលសំបុត្រនេះគេសរសេរអ្វីខ្លះ ? តួសំបុត្រគេនិយាយពីអ្វីខ្លះ ? នៅផ្នែកបញ្ចប់សំបុត្រ តើគេសរសេរអ្វីខ្លះ ?

## លំហាត់

១. ចូរអ្នកសរសេរសំបុត្រមួយច្បាប់សូមអភ័យទោស តាមប្រធានបទខាងក្រោម :

ក. អ្នកខកខានមិនបានទៅសួរសុខទុក្ខមិត្តភក្តិម្នាក់ដែលមានជំងឺសម្រាកព្យាបាលនៅមន្ទីរពេទ្យ ។

ខ. អ្នកធ្វើឱ្យបាត់សៀវភៅ ដែលអ្នកបានខ្ចីពីមិត្តភក្តិនៅសាលាផ្សេងគ្នា ។

២. នៅពេលអ្នកសរសេរសំបុត្រសូមអភ័យទោស អ្នកគប្បីអនុវត្តតាមលំនាំខាងក្រោម :

ក. ចុះកាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំសរសេរសំបុត្រ)

ខ. សរសេរពាក្យគោរព គារវកិច្ច សំដែងនូវការនឹករលឹក ស្រឡាញ់រាប់អាន ចំពោះអ្នកទទួល

គ. សរសេរបង្ហាញនូវអារម្មណ៍សោកស្តាយ ចំពោះទោសកំហុសរបស់អ្នក

ឃ. សរសេរសារភាពពីកំហុសនានានិងបង្ហាញពីមូលហេតុ ដែលអ្នកប្រព្រឹត្តខុសឆ្គង

ង. សរសេរសុំឱ្យអ្នកទទួល អភ័យទោសដល់អ្នក

ច. សរសេរសម្តែងការជឿទុកចិត្តថា អ្នកទទួលនឹងមានការអធ្យាស្រ័យដល់អ្នក

ឆ. សរសេរសម្តែងនូវទឹកចិត្តចំពោះអ្នកទទួល ចុះហត្ថលេខា និងឈ្មោះរបស់អ្នក ។

មេរៀនទី ៤

# មិត្តភាព



មិត្តភាពជាដើមចមនៃសន្តិភាពនិងការអភិវឌ្ឍ។ មិត្តភាពចាប់ផ្តើមចេញពីសេចក្តីស្រឡាញ់ ភាពស្មោះត្រង់និងការមានអធ្យាស្រ័យល្អ។ ការយោគយល់ អធ្យាស្រ័យ ស្មោះត្រង់ រាប់រកគ្នា សាមគ្គីភាពទូលំទូលាយ ធ្វើឱ្យយើងបង្កើនបាននូវមិត្តភាព និងភាពសុខដុមរមនានៅក្នុងសង្គម។

ក្នុងមេរៀននេះ អ្នកនឹងបានស្វែងយល់ពីចំណងមិត្តភាពមួយចំនួនព្រមទាំងមធ្យោបាយផ្សេងៗ ដើម្បីពង្រឹងនិងពង្រីកចំណងមិត្តភាព។ អ្នកនឹងបានសិក្សាបន្ថែមទៀតអំពីបំណិនមួយចំនួនទាក់ទង នឹងការសន្ទនាតាមទូរស័ព្ទ ទម្រង់និងធាតុសំខាន់ៗនៃសំបុត្រផ្ទាល់ខ្លួន នាមផ្ញើ សំណេរសំបុត្រផ្ទាល់ខ្លួន។



# សំបុត្រសួរសុខទុកមិត្តភក្តិ




## ក. សិក្សាពាក្យគន្លឹះ

- មន្ត្រីរាជការ (ន) : អ្នករាជការ ដែលមានសក្តិយស អ្នកធ្វើការបម្រើក្នុងក្រសួងនានារបស់ប្រទេស ... ។
- ធូរធារ (គុ) : រីកចម្រើន ទូលាយ ទប់ទល់បាន ... ។
- ស្វ័យសិក្សា (កិ) : រៀនសូត្រដោយខ្លួនឯង ។
- រមណីយដ្ឋាន (ន) : ទីកន្លែងកម្សាន្តនានា ។
- វិថី (ន) : ផ្លូវ ដងផ្លូវ ។
- អវសាន (ន) : ទីបំផុត ចុងក្រោយបំផុត ។

## ខ. អភិវឌ្ឍន៍បំណិន

ពេលអ្នកអានសេចក្តីសំបុត្រនេះ អ្នកត្រូវអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹងលក្ខណៈខុសគ្នារវាងភាសានិយាយធម្មតានិងភាសាសរសេរក្នុងសំបុត្រ ខ្លឹមសារនិងទម្រង់ទូទៅរបស់សំបុត្រ ។

## គ. អត្ថបទ

### រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១០

### មកដល់មករាជាទីនឹករលឹក

សួស្តីមករា ! អស់រយៈពេលជិតមួយឆ្នាំកន្លងមកហើយ ដែលខ្ញុំបានឃ្លាតពីសម្លាញ់និងមិត្តភក្តិទាំងអស់មករស់នៅនិងបន្តការសិក្សានៅរាជធានីភ្នំពេញ ។ រយៈពេលមួយឆ្នាំនេះ ខ្ញុំតែងនឹករលឹកមកដល់សម្លាញ់គ្រប់ពេលវេលា ។ ខ្ញុំពុំដឹងពីសុខទុក្ខរបស់សម្លាញ់សោះ ។ តើមិត្តមានសេចក្តីសុខ ឬទុក្ខយ៉ាងណា ? ចុះការសិក្សារបស់សម្លាញ់យ៉ាងណាដែរ ?

ចំណែករូបខ្ញុំនិងក្រុមគ្រួសារមានសេចក្តីសុខជាធម្មតាទេ ។ សព្វថ្ងៃ ខ្ញុំរៀននៅថ្នាក់ទី ៨ "ខ"នៃអនុវិទ្យាល័យហ៊ុនសែនពោធិ៍ចិនតុង ។ ឥឡូវនេះ ជីវភាពគ្រួសារខ្ញុំមានភាពធូរធារជាងមុនឆ្ងាយណាស់ ។ ឪពុករបស់ខ្ញុំធ្វើការជាមន្ត្រីរាជការ ចំណែកឯម្តាយខ្ញុំ ប្រកបរបរលក់ដូរ ។ សម្លាញ់ដឹងទេ សព្វថ្ងៃឪពុកម្តាយខ្ញុំ មិនឱ្យខ្ញុំដើរលេងផ្តេសផ្តាស ភ្លេចការរៀនសូត្រនោះទេ ។ គាត់ឱ្យខ្ញុំខិតខំរៀនសូត្រ ដូចជាស្វ័យសិក្សា ទៅរៀនបន្ថែមក្រៅម៉ោង អានសៀវភៅក្នុងបណ្ណាល័យ ឬទៅក្លិបសិក្សាជាមួយមិត្តភក្តិ ។ នៅល្ងាចថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ ឪពុកម្តាយខ្ញុំតែងតែនាំខ្ញុំទៅលំហែកាយនៅតាមសួនច្បារនានា រមណីយដ្ឋាន មាត់ទន្លេ វិមានឯករាជ្យ ។ល ។ សម្លាញ់ជាទីនឹករលឹក! រាជធានីភ្នំពេញឥឡូវសប្បាយណាស់ ភ្លើងចម្រុះពណ៌ភ្លឺចិញ្ចាចគ្រប់ទីកន្លែង សួនច្បារនិងរមណីយដ្ឋានល្អប្រណីត វិថីតូចធំនានាស្អាតល្អជាងមុន ។ ភ្ញៀវទេសចរជាតិនិងអន្តរជាតិច្រើនណាស់បានមកកម្សាន្ត ទស្សនារាជធានីនៃប្រទេសកម្ពុជាយើង! ពិសេសទៅទៀតនៅពេលមានពិធីបុណ្យជាតិម្តងៗ ដូចជាបុណ្យចូលឆ្នាំប្រពៃណីខ្មែរ បុណ្យអុំទូក អកអំបុក និងសំពះព្រះខែ និងបុណ្យផ្សេងៗទៀត ។ រាជធានីភ្នំពេញកាន់តែអ៊ូអរ ហើយកាន់តែសប្បាយថែមទៀត ! មនុស្សច្រើនកុះករ សម្លៀកបំពាក់គ្រប់បែបគ្រប់ម៉ូតចម្រុះពណ៌ ស្តង់លក់អីវ៉ាន់និងផលិតផលផ្សេងៗកាន់តែសម្បូរបែប ដាក់តាំងលក់ទាំងយប់ទាំងថ្ងៃហើយមានតម្លៃសមរម្យទៀតផង ។ បច្ចុប្បន្ននេះ នៅរាល់ពេលព្រឹកនិងរាល់ពេលល្ងាចនៅតាមសួនច្បារ រមណីយដ្ឋានមាត់ទន្លេ មុខបរមរាជវាំង តែងមានមនុស្សមកហាត់ប្រាណនិងដើរកម្សាន្តកកកុញ ។ សោកស្តាយណាស់សម្លាញ់ ! ខ្ញុំមិនអាចរៀបរាប់ប្រាប់សម្លាញ់គ្រប់ទិដ្ឋភាពអស់នោះទេ ! តែទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំព្យាយាមសរសេរសំបុត្ររៀបរាប់ពីអ្វីដែលកើតមានថ្មីៗទៀតឱ្យសម្លាញ់បានដឹង ។

មិត្តដឹងទេ ការសិក្សារបស់ខ្ញុំទទួលបានលទ្ធផលល្អរាល់ខែ ។ លោកគ្រូ អ្នកគ្រូ តែងសរសើរខ្ញុំគ្រប់គ្នា ។ ឯមិត្តភក្តិនិងមិត្តរួមថ្នាក់ដទៃទៀតក៏ទទួលបានលទ្ធផលល្អដូចគ្នាដែរ ។

ចុះសម្លាញ់វិញ តើការសិក្សាយ៉ាងដូចម្ដេចដែរ ? ប្រហែលជាជាប់ចំណាត់ថ្នាក់ល្អដូចខ្ញុំដែរហើយមែនទេ ?

ព្រមជាមួយគ្នានេះដែរ ខ្ញុំសូមផ្ញើការនឹករឭកនិងសួរសុខទុក្ខពីចម្ងាយដល់ឪពុកម្ដាយនិងក្រុមគ្រួសាររបស់មករាផង ។ ខ្ញុំសង្ឃឹមថានឹងបានទទួលដំណឹងរីករាយពីមិត្ត ហើយជឿជាក់ថានឹងមានឱកាសបានជួបនឹងមិត្ត ព្រោះបច្ចុប្បន្ននេះ ការធ្វើដំណើរទៅរតនគិរីឬពីរតនគិរីមកភ្នំពេញងាយស្រួលច្រើនណាស់ ។

ដោយពេលវេលានេះខ្ញុំត្រូវចូលក្លិបសិក្សា ខ្ញុំសូមលាសម្លាញ់តែត្រឹមនេះសិនចុះ ។ យើងនឹងជួបគ្នាតាមសំបុត្រ ឬជួបគ្នាផ្ទាល់នៅពេលដ៏ខ្លីខាងមុខនេះ ។

ជាអវសាន ខ្ញុំសូមឱ្យសម្លាញ់និងក្រុមគ្រួសារព្រមទាំងអតីតមិត្តរួមថ្នាក់ទាំងអស់ជួបប្រទះតែសេចក្តីសុខគ្រប់ទិវារាត្រី ។

ពីសម្លាញ់របស់អ្នក

ដារណេ

## សំណួរ

១. តើនរណាជាអ្នកសរសេរសំបុត្រនេះ ? ផ្ញើទៅនរណា ? នៅឯណា ?

២. តើក្នុងសេចក្តីសំបុត្រ គេសួរពីព័ត៌មានអ្វីខ្លះ ?

៣. តើសេចក្តីសំបុត្រនេះ គេផ្តល់ព័ត៌មានអ្វីខ្លះដល់អ្នកទទួល ?

៤. តើផ្នែកផ្សេងៗរបស់សំបុត្រនេះមានអ្វីខ្លះ ?

៥. ចូរបង្ហាញពីទីតាំងផ្នែកនីមួយៗនៃសំបុត្រ ។

# ពាក្យផ្សំបែបខ្មែរនិងពាក្យសមាស បាលីសំស្ក្រឹត

ពាក្យខ្មែរយើងមួយចំនួនកើតឡើងពីបន្សំរវាងពាក្យនិងពាក្យពីរ ឬបី ហើយពាក្យទាំងនោះជួនកាលកើតឡើងពីបន្សំរវាងពាក្យខ្មែរនិងពាក្យខ្មែរ ឬរវាងពាក្យកម្ចីពីភាសា ។ ចំណែកពាក្យខ្លះទៀតកើតឡើងពីបន្សំរវាងពាក្យបាលីសំស្ក្រឹតតាមក្បួនបាលីសំស្ក្រឹត ។ ពាក្យផ្សំទាំងនោះអាចក្លាយជាបញ្ញត្តិសម្គាល់អ្វីមួយ ។ គេចែកពាក្យផ្សំជាពីរ ៖

## ក. ពាក្យផ្សំបែបខ្មែរ

តើពាក្យផ្សំបែបខ្មែរកើតឡើងយ៉ាងដូចម្ដេច ?

*ឧទាហរណ៍ :*

១. ផ្ទះខ្ញុំមានបន្ទប់ទឹកពីរ ។

២. ជីតាខ្ញុំចូលចិត្តពិសាបាយអង្ករផ្កាខ្ញី ហើយជាអង្ករស្រូវថ្មីទៀត ។

៣. មីងសនលក់សុទ្ធតែអង្ករដំណើបខ្មៅ ។

៤. លោកគ្រូឱ្យសុផលទិញទឹកខ្មៅក្រហមមួយដបនិងខ្មៅដៃមួយប្រអប់ ។

៥. បន្ទាត់របស់ឯងនៅលើតុសរសេរឯនោះ ។

៦. ឈើចាក់ធ្មេញនៅក្នុងប្រអប់ ។

តាមឧទាហរណ៍ខាងលើ ចូរអ្នកសង្កេតមើលពាក្យផ្សំខាងក្រោម ៖

| | | |
|---|---|---|
| ១. ពាក្យ | បន្ទប់ទឹក | < បន្ទប់(នាម) + ទឹក(នាម) |
| ២. ពាក្យ | អង្ករផ្កាខ្ញី | < អង្ករ(នាម) + ផ្កា(នាម) + ខ្ញី(នាម) |
| ពាក្យ | អង្ករស្រូវថ្មី | < អង្ករ(នាម) + ស្រូវ(នាម) + ថ្មី(គុណនាម) |
| ៣. ពាក្យ | អង្ករដំណើបខ្មៅ | < អង្ករដំណើប(នាម) + ខ្មៅ(គុណនាម) |
| ៤. ពាក្យ | ទឹកខ្មៅក្រហម | < ទឹក(នាម) + ខ្មៅ(គុណនាម) + ក្រហម(គុណនាម) |
| ពាក្យ | ខ្មៅដៃ | < ខ្មៅ(គុណនាម) + ដៃ(នាម) |
| ៥. ពាក្យ | តុសរសេរ | < តុ(នាម) + សរសេរ(កិរិយា) |
| ៦. ពាក្យ | ឈើចាក់ធ្មេញ | < ឈើ(នាម ) + ចាក់(កិរិយា) + ធ្មេញ(នាម) |

ដូចនេះ ពាក្យផ្សំបែបខ្មែរកើតឡើងតាមទម្រង់ ៖

- នាម + នាម : *ឧទាហរណ៍* តុបាយ អណ្តើកមាស សណ្តែកដី ... ។
- នាម + នាម + នាម : *ឧទាហរណ៍* ដំឡូងឈាមមាន់ ត្រីគល់រាំង ... ។
- នាម + នាម + គុណនាម : *ឧទាហរណ៍* ទឹកត្នោតជូរ ទំពាំងបាយជូរ ... ។
- នាម + គុណនាម + គុណនាម : *ឧទាហរណ៍* ទឹកខ្មៅខៀវ ... ។
- នាម + គុណនាម : *ឧទាហរណ៍* ទឹកខ្មៅ សាច់ជូរ ... ។
- គុណនាម + នាម : *ឧទាហរណ៍* ខ្មៅដៃ ពពាលខែ ... ។
- នាម + កិរិយា : *ឧទាហរណ៍* បន្ទប់ដេក តុសរសេរ ... ។
- នាម + កិរិយា + នាម : *ឧទាហរណ៍* បន្ទប់ទទួលភ្ញៀវ អង្រែបុកគ្រឿង ត្បាល់កិនម្សៅ ... ។
- កិរិយា + នាម : *ឧទាហរណ៍* ឡើងអ្នកតា បាំងខ្លែង ... ។
- កិរិយា + កិរិយា : *ឧទាហរណ៍* បាំងសាច ... ។
- កិរិយា + គុណនាម : *ឧទាហរណ៍* បាំងស្មើរ ... ។

*កំណត់សម្គាល់ :* ពាក្យផ្សំខ្លះអាចមានទម្រង់ផ្សេងពីនេះ ។

*ពាក្យផ្សំបែបខ្មែរ គឺជាពាក្យដែលកើតឡើងពីការផ្សំចូលគ្នារវាងពាក្យខ្មែរនិងពាក្យខ្មែរ បង្កើតបានជាបញ្ញត្តិសម្រាប់សម្គាល់អ្វីមួយផ្សេងៗទៀត ។*

## ខ. ពាក្យសមាសបែបបាលីសំស្ក្រឹត

តើពាក្យសមាសបែបបាលីសំស្ក្រឹតកើតឡើងដូចម្តេច ?

*ឧទាហរណ៍ :*

១. ខ្ញុំស្រឡាញ់មាតុភូមិខ្ញុំ ។

២. វុក្ខជាតិជាគម្របផែនដី ។

៣. មហាជនទូទៅចាត់ទុកគាត់ជាវីរបុរសជាតិដ៏ឆ្នើម ។

តាមឧទាហរណ៍ខាងលើយើងឃើញថា ៖

១. ពាក្យ មាតុភូមិ < មាតុ(នាមបាលី) + ភូមិ(នាមបា. សំ)

២. ពាក្យ រុក្ខជាតិ < រុក្ខ(នាមបា. សំ) + ជាតិ(នាមបា. សំ)

៣. ពាក្យ មហាជន < មហា(គុណនាមសំ) + ជន(នាមបា. សំ)

៤. ពាក្យ វីរបុរស < វីរៈ(គុណនាមបា. សំ) + បុរស(នាមបា. សំ)

ដូចនេះ នាមសមាសបែបបាលីសំស្ក្រឹតកើតឡើងតាមទម្រង់ ៖

- នាម + នាម : *ឧទាហរណ៍* ខេមរបុត្រ ពិភពលោក ... ។

- គុណនាម + នាម : *ឧទាហរណ៍* មហាបុរស បាបមិត្ត វីរជន ... ។

*កំណត់សម្គាល់ :* ពាក្យសមាសបាលីសំស្ក្រឹតអាចកើតឡើងតាមទម្រង់ផ្សេងជាច្រើនទៀត ។

*ពាក្យសមាសបាលីសំស្ក្រឹត គឺជាពាក្យកើតឡើងពីបន្សំចូលគ្នារវាងពាក្យបាលីសំស្ក្រឹត និងពាក្យបាលីសំស្ក្រឹតបង្កើតបានជាបញ្ញត្តិ ឬជាពាក្យថ្មី សម្រាប់សម្គាល់អ្វីមួយថ្មីផ្សេងទៀត ។*

## លំហាត់

១. ក្នុងចំណោមពាក្យខាងក្រោម តើពាក្យណាខ្លះជាពាក្យផ្សំបែបខ្មែរ ? ពាក្យណាខ្លះជាពាក្យសមាសបែបបាលីសំស្ក្រឹត ? ជំឡូងជ្វា ផ្លែស្រែង ក្រុងសិរិទ្ធ ត្រីកន្ត្រង់ប្រេង វិទ្យាសាស្ត្រ ប្រជាធិបតេយ្យ ត្រីអណ្តាតឆ្កែ ឱសថស្ថាន អកអំបុក ជុំកន្លង់ ទិវាករ ទណ្ឌឃាត ទល់ផ្លូក ទស្សនាចរណ៍ បសុពេទ្យ ប្រក់ផ្លែ ផ្កាអំបិល ។

២. ចូរបង្ហាញទម្រង់របស់ពាក្យផ្សំបែបខ្មែរ និងពាក្យសមាសបែបបាលីសំស្ក្រឹតដែលបានរកឃើញក្នុងសំណួរទីមួយ ។

 

# ទូរស័ព្ទ



## ក. សិក្សាពាក្យគន្លឹះ

- បច្ចេកវិទ្យា (ន) : វិជ្ជាខាងវិទ្យាសាស្ត្រ ជំនាញមួយប្រភេទកើតឡើងពីការរកឃើញជាក់ស្តែង ... ។
- គមនាគមន៍ (ន) : ការធ្វើដំណើរ ការទាក់ទងទៅវិញទៅមក ... ។
- ពេញនិយម (គុ) : ចូលចិត្ត ពេញចិត្ត ... ។
- គុណវិបត្តិ (ន) : ភាពអវិជ្ជមាន ភាពមិនល្អ ... ។
- កាស (ន) : ឧបករណ៍ដាក់ជាប់នឹងត្រចៀកដើម្បីស្តាប់សំឡេងផ្សេងៗ ដូចជាចម្រៀង ព័ត៌មាន ដែលចេញពីទូរស័ព្ទ ឧបករណ៍ចាក់ចម្រៀង ។
- សេវា (ន) : ការបម្រើផ្សេងៗ ។
- ឥទ្ធិពល (ន) : អំណាច កម្លាំង ។
- យុវវ័យ (ន) : មនុស្សវ័យជំទង់ទាំងពីរភេទ ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទនេះ អ្នកត្រូវអានដោយយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹងសេចក្តីលម្អិតសំខាន់ៗ តម្លៃអប់រំរបស់អត្ថបទនិងពាក្យផ្សំ ។

## គ. អត្ថបទ

បច្ចុប្បន្ន បច្ចេកវិទ្យាកំពុងរីកដុះដាលដូចផ្សិតពាសពេញពិភពលោក ។ បច្ចេកវិទ្យារួមចំណែកយ៉ាងសកម្មក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្ស ។ ទូរស័ព្ទ ជាបច្ចេកវិទ្យាគមនាគមន៍មួយប្រភេទដែលក្នុងពេលបច្ចុប្បន្ននេះកំពុងដើរតួយ៉ាងសំខាន់ក្នុងការផ្ដល់និងទទួលព័ត៌មាននិងទំនាក់ទំនងជាមួយផ្នែកផ្សេងៗទៀត ហើយមានមុខងារច្រើនយ៉ាងផងដែរ ។

អត្រាអ្នកប្រើប្រាស់ទូរស័ព្ទដៃនៅលើពិភពលោក នៅពេលបច្ចុប្បន្ននេះ កំពុងកើនឡើងជាលំដាប់ ។ តាមការទស្សន៍ទាយរបស់ក្រុមហ៊ុនទូរស័ព្ទចល័តធំៗនៅលើពិភពលោក បានបង្ហាញថា នៅឆ្នាំ ២០០៩-២០១០និងឆ្នាំខាងមុខបន្តបន្ទាប់ទៅទៀត អត្រាអ្នកប្រើប្រាស់ទូរស័ព្ទចល័តនឹងមានសន្ទុះកើនឡើងយ៉ាងខ្លាំង ពិសេសនៅឧបទ្វីបអឺរ៉ុបនិងប្រទេសចិន ។

ក្រុមហ៊ុនផលិតទូរស័ព្ទដៃមួយចំនួនធំនៅលើពិភពលោក បានខិតខំរចនាផលិតផលរបស់ខ្លួនឱ្យមានសភាពប្លែកៗ ជាទីពេញនិយម ដើម្បីបម្រើសេចក្ដីត្រូវការរបស់អតិថិជន និងប្រកបដោយការប្រកួតប្រជែង ។

នៅព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ការលក់ទូរស័ព្ទកំពុងក្លាយជាមុខរបរពេញនិយម ហើយក៏កំពុងរីកដុះដាលនៅទីប្រជុំជនតាមបណ្ដាខេត្តនានានិងរាជធានីភ្នំពេញ ។ ប្រជាពលរដ្ឋខ្មែរយើងភាគច្រើនកំពុងទទួលឥទ្ធិពលនៃភាពជឿនលឿនរបស់បច្ចេកវិទ្យានេះ ពិសេសបច្ចេកវិទ្យាទូរស័ព្ទ ។ ឥទ្ធិពលនេះធ្វើឱ្យមានការពេញនិយមទាំងការប្រើប្រាស់ទូរស័ព្ទ ទាំងមុខរបរលក់ទូរស័ព្ទ ។ ក្រុមហ៊ុនលក់ទូរស័ព្ទ ក្រុមហ៊ុនលក់ប្រព័ន្ធបម្រើសេវានានាកំពុងប្រកួតប្រជែងដណ្ដើមទីផ្សារនិងអតិថិជន ។

តាមបច្ចេកវិទ្យាបច្ចុប្បន្ន ទូរស័ព្ទមិនត្រឹមតែមានមុខងារទទួលនិងផ្ដល់ព័ត៌មានប៉ុណ្ណោះទេ ថែមទាំងមានមុខងារជាច្រើនទៀតដូចជា ថតរូប ថតវីដេអូ ចាក់ចម្រៀង មើលវីដេអូ មើលទូរទស្សន៍ ផ្ទុកឯកសារ ។ល។ អ្នកប្រើប្រាស់ទូរស័ព្ទ ក្រៅពីត្រូវគិតគូរទៅលើកត្តាជីវភាពផ្ទាល់ខ្លួននិងគ្រួសារក៏ត្រូវគិតគូរពីគុណវិបត្តិជាច្រើនទៀតផងដែរ ។ យុវវ័យជាមុខសញ្ញាដែលប្រឈមមុខនឹងគុណវិបត្តិទាំងនេះខ្លាំងជាងគេ ។ យុវវ័យនៅឧបទ្វីបអឺរ៉ុបរាប់លាននាក់មានបញ្ហាត្រចៀក ក្រោយពីពួកគេបានស្ដាប់តន្ត្រីតាមរយៈកាសទូរស័ព្ទ ដោយបើកសំឡេងខ្លាំងនិងមានរយៈពេលច្រើនម៉ោង ។

តាមអ្នកវិទ្យាសាស្ត្រអឺរ៉ុបបានប្រាប់ថា ការស្ដាប់ចម្រៀងតាមរយៈកាសទូរស័ព្ទមានផលប៉ះពាល់មិនល្អដល់ត្រចៀកនិងខួរក្បាលយ៉ាងធ្ងន់ធ្ងរ ។ ប្រជាពលរដ្ឋរវាងពី ៥០ទៅ ១០០លាននាក់នៅអឺរ៉ុបបានស្ដាប់តន្ត្រីតាមរយៈកាសទូរស័ព្ទ ឬឧបករណ៍ចាក់ចម្រៀងផ្សេងៗជារៀងរាល់ថ្ងៃ ។ បញ្ហាដ៏ធំបំផុត

ច្រើនកើតមានចំពោះអ្នកស្តាប់ចម្រៀងដោយប្រើកាស ដែលប្រើរយៈពេលលើសពី ៥ម៉ោងឡើងទៅក្នុងមួយសប្តាហ៍។ អ្នកស្តាប់ចម្រៀងដោយប្រើប្រាស់កាស មានគ្រោះថ្នាក់ពី ៥% ទៅ ១០% ហើយបច្ចុប្បន្ន នៅឧបទ្វីបអឺរ៉ុបមានមនុស្សទទួលរងគ្រោះប្រមាណ ១០លាននាក់។

*(ដកស្រង់ និងកែសម្រួលពីទស្សនាវដ្តីទីក្រុងទូរស័ព្ទលេខ ៥២ ឆ្នាំ ២០០៩)*

## សំណួរ

១. តាមរយៈអត្ថបទ តើអត្រាអ្នកប្រើប្រាស់ទូរស័ព្ទដៃនៅលើពិភពលោកមានសភាពដូចម្តេចខ្លះ ?

២. តើព្រះរាជាណាចក្រកម្ពុជាយើងបច្ចុប្បន្ន ទទួលឥទ្ធិពលដូចម្តេចខ្លះដែរផ្នែកបច្ចេកវិទ្យាទូរស័ព្ទនេះ?

៣. តាមបច្ចេកវិទ្យាបច្ចុប្បន្ន ទូរស័ព្ទមានមុខងារអ្វីខ្លះ ?

៤. តាមអ្នកវិទ្យាសាស្ត្រ ការស្តាប់ចម្រៀងតាមរយៈកាសទូរស័ព្ទមានផលអាក្រក់ដូចម្តេចខ្លះ ?

៥. តាមយោបល់អ្នក តើទូរស័ព្ទផ្តល់គុណសម្បត្តិនិងគុណវិបត្តិដូចម្តេចខ្លះ ?

៦. ចូរស្រង់នាមសមាសបាលីសំស្ក្រឹតពីក្នុងអត្ថបទឱ្យបាន ៥ ព្រមទាំងបង្ហាញពីទម្រង់ផង។

# កល្យាណមិត្ត




## ក. សិក្សាពាក្យគន្លឹះ

- ត្រពាំង (ន) : ថ្លុកធំកកើតពីមនុស្សជីកសម្រាប់ឱ្យដក់ទឹក ឬកើតដោយសារកម្លាំងទឹកហូរច្រោះក៏មាន ។
- កំណាត់ (ន) : អ្វីៗដែលគេកាត់ ឬដាច់ដោច កំណាត់ឈើ ឬស្សីមួយកំណាត់ ។
- លាភ (ន) : ការបាន ដំណើរប្រទះលើការបានអ្វីៗដែលគួរបានចំណេញ ។
- កាំភ្លើង (ន) : ឈ្មោះអាវុធធ្វើពីដែកសម្រាប់បាញ់ប្រហារដោយប្រើគ្រាប់ ។
- ទំហឹង (ន) : ការប្រឹងរត់ ឬប្រឹងស្រែក ប្រឹងនិយាយ ឬការធ្វើអ្វីមួយដោយពេញកម្លាំង ការប្រឹងដោយពេញកម្លាំង ។
- ថ្លោះ (កិ) : របូត ភ្លាត់ ទាស់ ធ្លាក់ ប្រែ វិនាស ខូច ។
- កាំប្រមា (ន) : កាំគឺព្រួញស្រួចៗ ជាជំនួសរោមរបស់ប្រមាដុះចេញវែងច្រូងច្រាងពេញទាំងខ្លួនសម្រាប់ប្រើជាអាវុធផ្ទាត់បាញ់ទម្លាក់ផ្លែឈើជាអាហារ ឬការពារខ្លួនវា ។
- ជ្រោះ (ន) : ជ្រលងជ្រៅក្នុងភ្នំ ចង្អូរទឹកចេញពីភ្នំ ។
- មើម (ន) : ឬសដែលកើតជាពកមានសាច់និងសម្បកក្រាស់ឬស្តើង មើមដំឡូង ។
- ស្អិត (គុ) : ដែលជាប់ល្អិតពិបាកបេះចេញ ។

- ស្ងាត់ច្រៀប (គុ) : ដែលស្ងប់ស្ងាត់ស្ងួនស្ងឹងឥតមានសូរសព្ទ ឥតលេចឮ ដែលស្ងប់ឥតជ្រួលច្រាល ។
- នឹកមមៃ (កិ.វិ) :នឹករឿយៗ គឺដែលភ្នកនឹករឿយៗមិនភ្លេច ។
- ងើបភ្លែត (កិ) : ងើបយ៉ាងរហ័ស ។
- ឆ្វែលឆ្វាត់ (កិ.វិ) : ដែលហើរក្រវែលបណ្ដើរ គន់មើលបណ្ដើរ ។
- ក្រេប (កិ) : ជញ្ជក់ ឬផឹកតិចៗ ។
- សារិកា (ន) : ឈ្មោះបក្សីពួកមួយ មានបីប្រភេទ គឺសារិកាកែវឬសារិកាឪឡុងសម្បុរខ្មៅ ចំពុះលឿងទុំ ទងត្រចៀកយារ សម្បុរសនិងលឿងខ្ចី សំឡេងក្រអួន សារិកាក្របីសម្បុរខ្មៅមាឌតូចជាងសារិកាកែវចំពុះលឿងខ្ចី សារិកាឪម៉ៃ មាឌនិងសម្បុរស្រដៀងនិងប្រចៀវ ចំពុះលឿងខាងចុងត្រចៀកសម្បុរលឿង ។
- ទ្រហឹងអឺងកង (គុ) : ដែលមានសូរឮអឺងកងនាំឱ្យទ្រហឹងត្រចៀក ។
- រំពៃ (កិឬកិ.វិ) : មៀងមើល ឬគន់មើលរឿយៗ ។
- តែលតោល (កិ.វិ) : ណែលណោល ឈរតែលតោល ។

### ខ. អភិវឌ្ឍន៍បំណិន

តាមរយៈខ្លឹមសារនៃអត្ថបទនេះ អ្នកនឹងអាចរកកាលអាកាស តម្លៃអប់រំ ភាសាច្បាស់លាស់ដែលមានក្នុងអត្ថបទ ជាពិសេសអ្នកនឹងបានស្គាល់ពីកល្យាណមិត្តពិតប្រាកដ ។

### គ. អត្ថបទ

## រឿង ដំរីនិងស្រមោច

មានដំរីមួយដើរវង្វេងផ្លូវក្នុងព្រៃជ្រៅតែម្នាក់ឯង ។ វាខំដើរស្កាត់រកហ្វូងរបស់វាគ្រប់ទិសទី ប៉ុន្តែពុំប្រទះសោះ ។ វាក៏ចុះទៅផឹកទឹកក្នុងត្រពាំងមួយ ។ វាកំពុងផឹកទឹក ស្រាប់តែប្រទះឃើញស្រមោចមួយហែលទឹកខ្វៃៗ ។ វាមានចិត្តអាណិតស្រមោចជាពន់ពេក ណាខ្លាចក្រែងវាត្រូវលង់ស្លាប់ ណាខ្លាចក្រែងត្រីចឹកស៊ីស្រមោច ។ ដំរីក៏ចាប់មែកឈើមួយកំណាត់បោះទៅក្នុងទឹក ដើម្បីឱ្យស្រមោចតោង ។ ស្រមោចកាលបើឃើញកំណាត់ឈើ វាខំប្រវេប្រវាឡើងតោង ដោយសេចក្ដីត្រេកអរក្រៃលែង ។ មែកឈើត្រូវខ្យល់ផាត់ក៏អណ្ដែតមកមាត់ត្រពាំង ។ ស្រមោចក៏វារឡើងគោកបានរួចជីវិតគ្រានោះ ក៏ដោយសារគុណដំរីសង្គ្រោះ ។

ចំណេរតមក មានព្រានព្រៃម្នាក់ស្វែងរកបរបាញ់សត្វ ក៏ប្រទះឃើញដំរីនោះឈរនៅក្រោមម្លប់ឈើមួយដើម ។ ព្រានព្រៃមានចិត្តត្រេកអរណាស់ ដោយនឹកថា អញមានលាភធំហើយម្តងនេះ ក៏លើកកាំភ្លើងតម្រង់ទៅដំរីបម្រុងនឹងបាញ់ ។ វេលានោះ ស្រមោចដែលដំរីធ្លាប់បានជួយសង្គ្រោះជីវិតឱ្យរួចពីការលង់ទឹកស្លាប់ក្រឡេកឃើញព្រានកំពុងតម្រង់បាញ់ដំរី វាក៏ខំវារយ៉ាងលឿនចូលទៅក្នុងត្រចៀកព្រាន ។ វាខំប្រឹងខាំអស់ទំហឹង ។ ព្រានព្រៃឈឺភ្ញាក់ដូចគេកន្ត្រាក់ កាំភ្លើងធ្លាក់ពីដៃ ថ្ងូរះកៃព្ទសូរផូង ។ ដំរីភ័យក៏រត់រួចជីវិតដោយសារស្រមោចជួយសង្គ្រោះវិញ ។

*(ដកស្រង់ចេញពីអត្ថបទស្តាប់រឿងដំរីនិងស្រមោច សៀវភៅភាសាខ្មែរសម្រាប់គ្រូ ថ្នាក់ទី ៨ របស់ក្រសួងអប់រំ បោះពុម្ពនៅឆ្នាំ ១៩៩៧)*

## រឿង ដើររកមិត្ត

ទន្សាយនិងកាំប្រមាលេងជាមួយគ្នាយ៉ាងស្និទ្ធស្នាល ។ រៀងរាល់ព្រឹកនារដូវក្តៅ មិត្តទាំងពីរបបួលគ្នាទៅមាត់ជ្រោះនិងជីកមើមឈើ ។ ពេលយប់គេតែងតែចេញទៅវាលស្មៅ ហក់លោតប្រឡែងគ្នាលេងក្រោមពន្លឺព្រះចន្ទដ៏ភ្លឺថ្លា ។ មិត្តភាពរបស់គេកាន់តែស្អិតរមួតពីមួយថ្ងៃទៅមួយថ្ងៃ ។ ថ្ងៃមួយនោះ ខ្យល់ត្រជាក់ធ្លាក់ពីទិសខាងជើង ។ រុក្ខជាតិជ្រុះស្លឹករពុយ ។ តាមផ្លូវស្វាត់ច្រៀបខ្យល់បក់ត្រជាក់ដល់ឆ្អឹង ។

- កាំប្រមាទៅណាហ្ន៎ ? គ្មានកាំប្រមាទន្សាយមានអារម្មណ៍ដូចខ្លួនគេតែលតោលកំព្រាឯកា ។

ទន្សាយរកកាំប្រមាជាមិត្ត ដើររកឥតឈប់គ្រប់កន្លែង មួយថ្ងៃហើយមួយថ្ងៃទៀត ។ ទន្សាយដេកនឹកមមៃដល់មិត្ត :

- ចចកចាប់វាស៊ីបាត់ហើយទេដឹង ។ នឹកដល់រឿងនេះ ទន្សាយស្ទុះងើបភ្លែតរត់រកមិត្តរកគ្រប់ច្រកល្ហក ។ ប៉ុន្តែទន្សាយនៅតែរកកាំប្រមាមិនឃើញដដែល ។ ទន្សាយឧទានឡើងខ្លាំងៗ :
- ព្រះអើយ ! ខ្ញុំនឹកកាំប្រមាណាស់ ! ខ្ញុំអាណិតកាំប្រមាណាស់ !

រដូវក្តៅឈានចូលមកដល់ រុញច្រានអាកាសធាតុត្រជាក់ទៅបាត់អស់ ។ ព្រៃទាំងមូលហាក់ដូចទើបភ្ញាក់ពីដំណេក ។ ហ្វូងមេអំបៅហើរឆ្វែលឆ្វាត់ក្រេបលំអងផ្កាលើវាលស្មៅពណ៌បៃតងស្រស់ ។ សារិកា ចាបស្រុក ចាបព្រៃស្រែកច្រៀងប្រណាំងគ្នាទ្រហឹងអឹងកង ។ ទន្សាយដើរតត្រុកភ្នែករំពៃរកមើលកាំប្រមាមិត្តរបស់ខ្លួន ។ មួយរំពេចនោះស្រាប់តែ :

- យី ! នរណានោះ ដូចជាកាំប្រមា ! ទន្សាយបើកភ្នែកមូលក្រឡង់សម្លឹងឥតព្រិច :
- អូ ! មែនហើយ ! កាំប្រមាមែន ! សួស្តីមិត្តកាំប្រមា ។

- សួស្តី ! មិត្តទន្សាយ ។

- ខ្ញុំដើររកសម្លាញ់ឯង មើលផ្លូវឯង ផ្សាភ្នែកអស់ហើយ ។

- សម្លាញ់អើយ ! ខ្ញុំនឹកសម្លាញ់ឯងណាស់ដែរ ។ តែដល់រដូវរងា ពួកខ្ញុំត្រូវរកកន្លែងស្ងាត់ ហើយជិតស្លុង ដេករហូតផុតត្រជាក់តែម្តង ទើបចេញមកវិញ ។

- អូ ! អីចឹងទេ ! ខ្ញុំខំតែភ័យ ស្មានថាមិត្ត ... ។

ទន្សាយសើចបិទភ្នែក រង្គើអស់ស្លឹកត្រចៀកវែងៗទាំងគូ ។ រួចមិត្តទាំងពីរ កាន់ដៃគ្នារត់លេងរាំច្រៀង លើវាលស្មៅខ្ចីទន់ល្មើយយ៉ាងសប្បាយ ។

*(ដកស្រង់ចេញពីអត្ថបទរឿង ដើររកមិត្ត បោះពុម្ពឆ្នាំ ១៩៨៧ ដោយក្រសួងអប់រំ)*

## សំណួរ

១. ហេតុដូចម្តេច បានជាដំរីស្រង់ស្រមោចចេញពីទឹក ? ឯស្រមោច ហេតុដូចម្តេចបានជាវាវារទៅខាំភ្លៀកព្រានព្រៃ ?

២. តើអំពើរបស់ដំរីនិងស្រមោច ហើយនិងអំពើរបស់ទន្សាយនិងកាំប្រមា ចាត់ទុកជាអំពើដែលកើតចេញពីទឹកចិត្តស្រឡាញ់ពិតប្រាកដដែរឬទេ ? ហេតុអ្វី ?

៣. រឿងដំរីនិងស្រមោច ទន្សាយនិងកាំប្រមា បានផ្តល់តម្លៃអប់រំយ៉ាងណាខ្លះ ?

៤. ចូររកកាលអាកាស :

ក. នៅពេលដំរីកាច់មែកឈើស្រង់ស្រមោចពីក្នុងទឹកនិងនៅពេលស្រមោចវារខាំភ្លៀកព្រានព្រៃ ។

ខ. នៅពេលទន្សាយស្និទ្ធស្នាលជាមួយកាំប្រមានិងពេលទន្សាយនៅឯកា ។

៥. តើតម្លៃទឹកចិត្តរវាងដំរីនិងស្រមោច ហើយតម្លៃទឹកចិត្តរវាងទន្សាយនិងកាំប្រមាមានចំណុចដូចគ្នាត្រង់ណា ? មិនដូចគ្នាត្រង់ណា ?

៦. តើពាក្យ :

ក. ហែលទឹកខ្វៗ ងើបភ្លែត ហើរឆ្វែលឆ្វាត់ ដើរតត្រុក បើកភ្នែកមូលក្រឡង់ ទន់ល្មើយ ជិតស្លុង ជាភាសារស់រវើក ឬជាភាសាច្បាស់លាស់ ឬមួយមិនមែនជាភាសាទាំងពីរនេះ ?

ខ. "ផ្សា" មានន័យអ្វីខ្លះ ? ចូរអ្នកកំណត់ន័យនៃពាក្យមួយទៀត ដែលមានសូរដូចពាក្យនេះដែរ ប៉ុន្តែមានន័យផ្សេង ។

# រំលឹកបញ្ញត្តិ

## ១ . កាលអាកាស

កាលអាកាស គឺពេលវេលានិងទីកន្លែងដែលដំណើររឿងប្រព្រឹត្តទៅ ។

កាល គឺពេលវេលាដែលអ្នកនិពន្ធអាចបង្ហាញក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ។ ពេលវេលាអាចជាម៉ោងពេលយប់ ពេលថ្ងៃ រដូវ ថ្ងៃ ខែ ឬឆ្នាំ ... រួមទាំងរយៈពេលដែលដំណើររឿងប្រព្រឹត្តទៅ ។

អាកាស គឺទីកន្លែងដែលអ្នកនិពន្ធបង្ហាញនៅក្នុងដំណើររឿងប្រព្រឹត្តទៅ ឬកន្លែងដែលព្រឹត្តិការណ៍កើតឡើងជាបន្តបន្ទាប់ ។ ទីកន្លែងជួនកាលកើតឡើងតាមការប្រឌិតរបស់អ្នកនិពន្ធ ជួនកាលកន្លែងនោះមានពិតជាក់ស្ដែង ។ ទីកន្លែងទាំងនោះមានដូចជា នៅឋានសួគ៌ ឋាននរក ឋានកណ្ដាល នៅក្នុងផ្ទះ វាលស្រែ នៅភូមិ ស្រុក ... ។

## ២ . តម្លៃអប់រំ

តម្លៃអប់រំជាគំនិតទូន្មាន ជាគំនិតអូសទាញរបស់អ្នកនិពន្ធតាមរយៈស្នាដៃរបស់ខ្លួន ។ អ្នកនិពន្ធមានវិធីអប់រំប្លែកៗដូចជា ការបង្ហាញអំពើល្អឱ្យអ្នកអាន អ្នកសិក្សាយកតម្រាប់តាម ឬយកជាបទពិសោធ ឬក៏បង្ហាញអំពើអាក្រក់ឱ្យអ្នកអាន អ្នកសិក្សាស្អប់ខ្ពើម ចៀសវាងលះបង់ ។

## ៣ . ភាសាច្បាស់លាស់

ភាសាច្បាស់លាស់ ជាពាក្យ ឬកន្សោមពាក្យ ដែលជាគុណកិរិយាសម្រាប់បញ្ជាក់លក្ខណៈ ឬសកម្មភាពរបស់មនុស្ស សត្វ រុក្ខជាតិ វត្ថុ ឬធម្មជាតិឱ្យកាន់តែច្បាស់លាស់ថែមទៀត ។

*ឧទាហរណ៍ :*

- ទង់ជាតិខ្មែរនិងទង់អង្គការសហប្រជាជាតិកំពុងបក់រវិចៗនៅលើកំពូលប្រាសាទព្រះវិហារ ។
- ប្រជាជនកម្ពុជា កំពុងញញឹមពព្រាយអបអរសាទរយ៉ាងគគ្រឹកគគ្រេង ចំពោះការដាក់បញ្ចូលប្រាសាទព្រះវិហាររបស់ខ្មែរចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ។

*ពាក្យ :* បក់រវិចៗ ជាភាសាច្បាស់លាស់ ។

| | | |
|---|---|---|
| - បក់រវិចៗ | < បក់(កិ) | + រវិចៗ (គុកិ) |
| - ញញឹមពព្រាយ | < ញញឹម (កិ) | + ពព្រាយ (គុកិ) |
| - អបអរសាទរយ៉ាងគគ្រឹកគគ្រេង | < អបអរសាទរ (កិ) | + យ៉ាងគគ្រឹកគគ្រេង (គុកិ) ។ |

# រឿង ស្មាន់ កណ្ដុរ អណ្ដើក និងក្អែក



នៅពេលអ្នកស្ដាប់រឿង ស្មាន់ កណ្ដុរ អណ្ដើក និងក្អែក ដែលគ្រូរបស់អ្នកអាន អ្នកត្រូវស្ដាប់ដោយយកចិត្តទុកដាក់ ដើម្បីឆ្លើយនឹងសំណួរទាក់ទងនឹងសេចក្ដីលម្អិតសំខាន់ៗ កាលអាកាសនិងតម្លៃអប់រំរបស់រឿង ។

## សំណួរ

១. តើស្មាន់ កណ្ដុរ អណ្ដើក និងក្អែករស់នៅឯណា ? ពួកគេត្រូវជាអ្វីនឹងគ្នា ?

២. នៅពេលដឹងថាស្មាន់ជាប់អន្ទាក់ព្រាន តើអ្នកទាំងបីធ្វើដូចម្ដេចខ្លះ ?

៣. តើអ្នកទាំងបីជួយសង្គ្រោះស្មាន់ចេញពីអន្ទាក់ព្រាន ដោយប្រើវិធីដូចម្ដេចខ្លះ ?

៤. ចូរបង្ហាញពីកាលអាកាសរបស់រឿងនេះ ។

៥. តើរឿងនេះអប់រំយើងដូចម្ដេចខ្លះ ?

៦. ប្រសិនបើមានមិត្តភក្តិជួបឧបសគ្គដូចស្មាន់ តើយើងហ៊ានលះបង់ជួយមិត្តភក្តិដូច កណ្ដុរ អណ្ដើក និងក្អែកដែរឬទេ ? ព្រោះអ្វី ?

# ការសន្ទនាតាមទូរស័ព្ទ

ទំនាក់ទំនងជាកត្តាចាំបាច់របស់យើងក្នុងការរស់នៅប្រចាំថ្ងៃ ។ ទំនាក់ទំនងក៏អាចចាត់ទុកថាជាកត្តាមួយជួយពង្រឹងនិងធ្វើឱ្យមិត្តភាពស្ថិតស្ថេរយូរអង្វែងបានដែរ ។ នាពេលបច្ចុប្បន្ន ទូរស័ព្ទជាឧបករណ៍សម្រាប់ទាក់ទងគ្នាយ៉ាងឆាប់រហ័ស ទំនើបទាន់សម័យ និងពេញនិយម ។

*ឧទាហរណ៍ :*

រ៉ឹងៗ ... រ៉ឹងៗ ... (សំឡេងទូរស័ព្ទរោទិ៍)

លោកសំបូរ : អាឡូ ! ខ្ញុំសំបូរ តើអញ្ជើញមកពីខាងណាបាទ ?

ដាណេ : ជម្រាបសួរលោកពូ !ខ្ញុំដាណេ ជាមិត្តរួមថ្នាក់របស់មករា ។ លោកពូជាឪពុករបស់មករាឬ ?

លោកសំបូរ : បាទខ្ញុំហ្នឹងហើយ ! មានការអ្វីដែរក្មួយ ?

ដាណេ : បាទជម្រាបប្រសាសន៍លោកពូ ! ពីព្រឹកមិញនេះលោកគ្រូប្រាប់ពួកខ្ញុំថា មករាមានជំងឺ ។ សូមទោសលោកពូ តើមករាមានជំងឺអ្វី ?

លោកសំបូរ : អរគុណក្មួយ ! មករាក្ដៅខ្លួនពីរថ្ងៃហើយ ! គ្រូពេទ្យថា រលាកបំពង់កធ្ងន់ធ្ងរ ។ ឥឡូវគេសម្រាកព្យាបាលនៅមន្ទីរពេទ្យ "សប្បុរស" ឯណោះក្មួយ !

ដាណេ : អរគុណលោកពូ ! ស្អែកនេះពួកក្មួយនឹងទៅសួរសុខទុក្ខមករានៅឯមន្ទីរពេទ្យតែម្ដង ! តើមករាសម្រាកនៅបន្ទប់លេខប៉ុន្មានលោកពូ ?

លោកសំបូរ : អូ ! ពូភ្លេចប្រាប់ក្មួយ ! មករាសម្រាកនៅបន្ទប់លេខ៨ជាន់ផ្ទាល់ដីជាប់ជណ្ដើរខាងលិចណាក្មួយ ! បើពួកក្មួយអញ្ជើញទៅនឹងជួបម៉ាក់របស់មករាហើយ ! ព្រោះគាត់នៅកំដរមករានៅទីនោះ ! ពូអរគុណហើយក្មួយ ដែលបានទូរស័ព្ទមកសួរសុខទុក្ខមករា !

ដាណេ : អរគុណលោកពូ ! អ៊ីចឹងក្មួយសុំជម្រាបលាលោកពូសិនហើយ ! ...

## សំណួរ

១. តើដាណេទូរស័ព្ទទៅនរណា ? មានកិច្ចការអ្វី ?

២. តើដាណេប្រើសំនួនអ្វី នៅពេលឮសំដីលោកសំបូរជាដំបូង ?

៣. តើដាណេប្រើសំនួនបែបណានៅពេលបញ្ចប់សន្ទនា ?

## លំហាត់

ចូរអ្នកចាប់គូគ្នាធ្វើការសន្ទនាតាមទូរស័ព្ទ ដោយយកលំនាំតាមការសន្ទនាគំរូខាងលើ ។ ការសន្ទនាគ្នាទាក់ទងនឹងប្រធានបទដូចខាងក្រោម ៖

- ការសួរសុខទុក្ខមិត្តភក្តិ
- ការសួរសុខទុក្ខឪពុកម្តាយ បងប្អូន ...
- ការសួរ ឬផ្តល់ព័ត៌មានផ្សេងៗ ។

នៅពេលសន្ទនាអ្នកត្រូវយកចិត្តទុកដាក់លើ ៖

ក. ពេលវេលានៃការសន្ទនា

**ខ. ពាក្យសំដីសន្ទនា** (ពេលចាប់ផ្តើម ពេលកំពុងសន្ទនា និងពេលបញ្ចប់ការសន្ទនា) ប្រើពាក្យសម្តីសមរម្យ គួរសម ត្រឹមត្រូវ និងថ្លៃថ្នូរជាមួយគូសន្ទនា ហើយសមស្របទៅតាមវ័យ ឋានៈ និងស្ថានភាព ។

- តាមវ័យ : ក្មេងឬប្អូន មិត្តភក្តិ បង ចាស់ទុំ ... ។
- តាមឋានៈ : ឪពុកម្តាយ បងប្អូន លោកគ្រូអ្នកគ្រូ ថ្នាក់ដឹកនាំតាមស្ថាប័ន ... ។
- តាមស្ថានភាព : ពេលទុក្ខព្រួយ សប្បាយរីករាយ សាកសួរព័ត៌មានចាំបាច់ ឬពិភាក្សាការងារ ... ។

**គ. ឥរិយាបថនិងសំឡេង** : ប្រើឥរិយាបថសមរម្យត្រឹមត្រូវនិងសំឡេងឮល្មមកុំឱ្យរំខានដល់អ្នកដទៃ ។

# សំបុត្រសួរព័ត៌មាន

ក្នុងការរស់នៅប្រចាំថ្ងៃ មនុស្សតែងមានបណ្ដូរទំនាក់ទំនងគ្នាទៅវិញទៅមកតាមមធ្យោបាយផ្សេងៗ ។ មធ្យោបាយទំនាក់ទំនងទាំងនោះមានដូចជា ការនិយាយទាក់ទងដោយផ្ទាល់មាត់ ឬផ្ដាំផ្ញើតាមរយៈមនុស្សដទៃ ឬតាមរយៈទូរស័ព្ទ ឬតាមសំបុត្រស្នាមជាលាយលក្ខណ៍អក្សរជាដើម ។ តាមរយៈមធ្យោបាយទាក់ទងទាំងនោះហើយ ដែលធ្វើឱ្យការផ្ដល់និងទទួលព័ត៌មានប្រកបដោយប្រសិទ្ធភាព ។

ខាងក្រោមនេះ ជាសំបុត្រសួរព័ត៌មានរបស់ដារី ផ្ញើទៅបូណា ។

**ព្រះវិហារ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៩**

## មកដល់បូណា

សួស្ដីបូណា ! តើមិត្តសុខសប្បាយឬទេ ? ចំណែកខ្ញុំឯណេះវិញ សុខសប្បាយជាធម្មតាទេ ។

ពេលនេះខ្ញុំឆ្លៀតសរសេរសំបុត្រមកបូណាដោយសារខ្ញុំបានឮការផ្សាយរបស់វិទ្យុអំពីការជ្រើសរើសសិស្សឱ្យចូលរៀនផ្នែកបច្ចេកទេសជួសជុលគ្រឿងអេឡិចត្រូនិចផ្សេងៗនិងជួសជុលគ្រឿងយន្តដូចជាម៉ូតូ រថយន្ត និងម៉ាស៊ីនផ្សេងៗទៀតរបស់សាលាបច្ចេកទេសសាធារណៈនិងឯកជនមួយចំនួន ។ ខ្ញុំចង់ដឹងព័ត៌មានមួយចំនួនឱ្យបានកាន់តែច្បាស់ តើសាលាបច្ចេកទេសណាដែលល្អជាងគេ ជាពិសេសគ្រូជំនាញជួសជុលម៉ូតូរថយន្ត ? តើការបង់ប្រាក់ត្រូវបង់តាមខែឬតាមវគ្គសិក្សា ? តើសាលានោះមានកន្លែងឱ្យសិស្សមកពីតាមបណ្ដាខេត្តស្នាក់នៅដែរឬទេ ? ពិសេសសូមមិត្តបញ្ជាក់ពីកាលបរិច្ឆេទនៃការចូលរៀន ពីថ្ងៃណា ខែណាដែរ និងទីតាំងរបស់សាលាឱ្យបានច្បាស់លាស់ផង ។

ហេតុដែលខ្ញុំចង់ដឹងព័ត៌មាននេះច្បាស់លាស់ ព្រោះនៅពេលវិស្សមកាលខាងមុខនេះ បងប្រុសរបស់ខ្ញុំគាត់ចង់ទៅភ្នំពេញរៀនជំនាញជួសជុលគ្រឿងយន្តដូចជា ម៉ូតូ រថយន្ត ឬគ្រឿងម៉ាស៊ីនផ្សេងៗទៀត ។ បូណាដឹងទេថា នៅស្រុកកំណើតយើងឥឡូវ ទោះជាជនបទដាច់ស្រយាលយ៉ាងណាក៏ដោយក៏មានម៉ូតូ រថយន្តដែរ ។ ប៉ុន្តែកន្លែងជួសជុលរថយន្តឬម៉ូតូមិនទាន់មានច្រើនទេ ។ ហេតុដូចនេះហើយទើបគាត់ចង់ទៅរៀនចំណេះនេះ ដើម្បីយកមកប្រកបរបរនៅស្រុកយើង ។

ដូចនេះ សូមមិត្តជួយផ្ដល់ព័ត៌មានខាងលើនេះមកខ្ញុំផង ។ ខ្ញុំសូមអរគុណមិត្តទុកជាមុន ។

ទីបញ្ចប់ខ្ញុំសូមជូនពរមិត្តនិងក្រុមគ្រួសារសូមជួបតែសេចក្ដីសុខ សុភមង្គលគ្រប់ពេលវេលា ។

**ពីមិត្ត**

**នារី**

## សំណួរ

១. តើនរណាជាអ្នកសរសេរសំបុត្រនេះ ? តើគេផ្ញើទៅនរណា ?

២. តើអ្នកសរសេរសំបុត្រចង់ដឹងព័ត៌មានអ្វីខ្លះ ?

៣. ហេតុអ្វីបានជាអ្នកសរសេរសំបុត្រចង់ដឹងពីព័ត៌មានទាំងនោះ ?

៤. តើអ្នកសរសេរសំបុត្រអួតសរសើរពីស្រុកកំណើតរបស់គេដូចម្ដេចខ្លះ ?

៥. តើនៅទីបញ្ចប់គេសរសេរអំពីអ្វី ?

## លំហាត់

១. ចូរអ្នកជ្រើសរើសប្រធានបទខាងក្រោមមកសរសេរ ដោយអនុវត្តទៅតាមគំរូសំបុត្រខាងលើ ៖

ក. សំបុត្រសួរព័ត៌មានពីការជ្រើសរើសឱ្យចូលបម្រើការងាររបស់ក្រុមហ៊ុនណាមួយ ។

ខ. សំបុត្រសួរព័ត៌មានពីសាលារៀនណាមួយ ដែលខ្លួនមានបំណងចង់បន្តការសិក្សានៅទីនោះ ។

គ. សំបុត្រសួរព័ត៌មានពីគ្រោះធម្មជាតិដោយខ្យល់ព្យុះនៅកន្លែងណាមួយ ។

២. នៅពេលសរសេរអ្នកគប្បីអនុវត្តតាមការណែនាំខាងក្រោម ៖

- ចុះកាលបរិច្ឆេទនិងអាសយដ្ឋានរបស់អ្នក
- ផ្ដើមសំបុត្រដោយសំដែងការគួសម ឬក្ដីនឹករលឹក (ចំពោះមិត្តភក្ដិឬអ្នកស្និទ្ធស្នាល)
- ប្រាប់ពីប្រធានបទ
- ប្រាប់ពីបំណងរបស់អ្នកចំពោះប្រធានបទ
- សួរព័ត៌មានផ្សេងៗទាក់ទងនឹងប្រធានបទឬព័ត៌មានផ្សេងៗទៀត ដែលអ្នកចង់ដឹង ។
- អាចលើកឡើងពីចំណុចខ្លះៗ ដែលទាក់ទងនឹងប្រធានបទចំពោះអ្នក ដែលអ្នកបម្រុងនឹងសួរ ។
- ប្រើពាក្យជូនពរឬបណ្ដាំផ្ញើ
- ចុះហត្ថលេខានិងឈ្មោះរបស់អ្នកសរសេរសំបុត្រ ។

មេរៀនទី ៥

# ការគោរពខ្លួនឯង



ការស្គាល់ខ្លួនឯង ការជឿជាក់លើខ្លួនឯង និងការធ្វើឱ្យខ្លួនឯងមានតម្លៃ គឺជាការគោរពខ្លួនឯង។ មុននឹងឱ្យអ្នកដទៃគោរពយើង ឱ្យតម្លៃយើង លុះត្រាតែយើងចេះឱ្យតម្លៃខ្លួនយើង ហើយធ្វើខ្លួនឱ្យគេគោរពស្រឡាញ់។ អ្នកដទៃគោរពស្រឡាញ់យើង លុះត្រាណាខ្លួនយើងមានចំណេះដឹង មានឥរិយាបថថ្លៃថ្នូរសមជាពលរដ្ឋល្អ មានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ និងប្រទេសជាតិ។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអំពីការអប់រំទូន្មានមួយចំនួនតាមរយៈស្នាដៃបុព្វបុរសខ្មែរ ដើម្បីជាទុនសម្រាប់អភិវឌ្ឍខ្លួនឱ្យក្លាយទៅជាពលរដ្ឋមានតម្លៃ។ ទន្ទឹមនឹងនេះ អ្នកនឹងបានសិក្សាបន្ថែមទៀតអំពីតម្លៃអប់រំរបស់អត្ថបទ បែបនៃល្បះ ទំហៀបន័យ ឬឧបមាន ការសូត្រកំណាព្យ និងការតែងកំណាព្យ។



# ច្បាប់ពាក្យចាស់



## ក. សិក្សាពាក្យគន្លឹះ

- ព្រេង (គុ) : ដែលយូរអង្វែងមកហើយ ដែលមានក្នុងកាលពីដើម ... ។
  *ឧទាហរណ៍ :* ទ្រព្យព្រេង គូព្រេង រឿងព្រេង ... ។
- ព្នង (ន) : មនុស្សជាតិមួយពួក ពីមុនច្រើនរស់នៅតំបន់ព្រៃមានប្រពៃណីទំនៀមទម្លាប់ផ្សេងពីយើង ។ ក្រោយមក យើងច្រើនហៅថា ខ្មែរលើ ។
- ជង (ន) : មនុស្សជាតិមួយពួកនៅក្នុងដែនកម្ពុជាយើង ច្រើនហៅថា ស្មៀង ។
- កួយ (ន) : មនុស្សជាតិមួយពួកនៅក្នុងដែនកម្ពុជាយើងដូចជនជាតិជងដែរតែមានភាសាច្រើនបែប សម្រាប់ប្រាស្រ័យទាក់ទងគ្នា ដូចកួយដែក កួយដំរី ... ។
- គជា (ន) : ដំរី ។
- ស៊ាំស៊ិន (គុឬគុកិ) : ដដែលៗ សាំដដែល ច្រំដែល ... ។
- សំប៉ាន (ន) : ទូកអុំមួយប្រភេទ ច្រើនតក្ការប្រាំសន្លឹក ខាងក្បាលនិងកន្សៃរាងង ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ អ្នកគប្បីអានដោយប្រុងប្រយ័ត្ននិងយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹងខ្លឹមសារអត្ថបទ ចំណាប់ចួន ផ្ទួន រណ្តំ កាព្យមាត្រ តម្លៃអប់រំរបស់អត្ថបទ ។

## គ. អត្ថបទ

ពាក្យចាស់ពាក្យពីព្រេង ទោសខ្លួនឯងមើលពុំយល់
ទោសគេតូចសោតសល់ រមិលយល់ប៉ុនទាំងភ្នំ ។
ចូលព្រៃសត្វសាហាវ រកអំពាវគ្នាមកជុំ
ដល់បានស្អុរទឹកឃ្មុំ ពួនសម្ងំស៊ីម្នាក់ឯង ។
បានហើយចង់បានទៀត ឆ្លៀតហើយឆ្លៀតពុំគិតឈ្វេង
មើលយល់តែមុខឯង មិនយល់គេឯទៀតផង ។
នឹងស៊ីចង់ពិសា ខ្ជិលទំពាឱ្យម៉ត់ហ្មង
យល់ចាមថាជាពួង យល់ឯជងថាជាក្អួយ ។
យល់តាថាជាដូន យល់ឯកូនថាជាក្អួយ
យល់ពីរថាជាមួយ យល់ឯព្រួយថាជាសុខ ។
យល់ទោសថាជាគុណ យល់បុណ្យថាជានរក
យល់ល្អថាអាក្រក់ យល់លាមកថាជាផ្កា ។
ស្លៀកស្បង់មិនកោរសក់ ឆ្លុះកញ្ចក់ធ្មេចនេត្រា
យល់សេះថាជាលា យល់គជាថាកណ្ដុរ ។
នេះពាក្យលោកពីព្រេង ឱ្យអ្នកឈ្វេងប្រាជ្ញាយល់
ឃើញថ្លុកកុំថាថ្នល់ ក្រែងកំហល់កំហុសមាន ។
អ្នកប្រាជ្ញកាន់ពាក្យទៀង កុំលំអៀងពាក្យបុរាណ
កុំដើរផ្លូវបំពាន ពាក្យអ្នកចាស់លោកដៀលថា ។
ពាក្យនេះពីព្រេងព្រឹទ្ធ គួរឱ្យគិតពិចារណា
កុំអួតអង្គអាត្មា ថាចំណេះចំណាំមាន ។
ដេកយប់កុំដេកយូរ ខ្លាចក្ដីទុរជនដល់ប្រាណ
បើឆីកុំតាមឃ្លាន គិតប្រមាណគ្រប់គ្នីគ្នា ។
លើកដាក់តាមកម្លាំង កុំភើចខ្លាំងឈឺដល់ស្មា
ប្រើគេប្រើឱ្យត្រា កុំស៊ាំស៊ននរាន់ថៅរ៉ៅ ។

ទោះគិតកុំរួសរាន់ គិតឱ្យគ្រាន់ទើបដើរទៅ
កុំឱ្យមានអាស្រូវ កើតដំនៀលដល់អាត្មា ។
កុំយកឆ្អិនជាឆៅ កិច្ចក្នុងក្រៅមានតម្រា
កុំអាងឯងប្រាជ្ញា ចោលច្បាប់ក្បួនលោកព្រេងនាយ ។
ស្រដីឱ្យស្រួលស្រេច គិតស្រេចត្រិចកុំគិតងាយ
រំពឹងឱ្យវែងឆ្ងាយ យល់លង្វែកសព្វនានា ។
ពាក្យព្រេងលោកស្រដី ថាកុំបីចញ្ចឹមខ្លា
ពាក្យព្រេងលោកឧបមា គិតត្រង់ណាធ្វើឱ្យបាន ។
កាន់កពស់កាន់ឱ្យខ្ជាប់ ខ្លាចក្រឡាប់ទាំងប្រាណ
អូសទូកកុំឱ្យល្អាន ទឹកថ្លាសោតកុំឱ្យល្អក់ ។
ស្លឹកឈើឥតកម្រើក បើកក្រើកត្បិតខ្យល់បក់
ទឹកថ្លាល្អក់បើល្អក់ ត្បិតរលកខ្លាំងសោះសា ។
យល់តូចកុំខិតខំ គួរសន្សំយកជាគ្នា
បានច្រើនកុំខំពារ សន្សឹមក្សិណតិចពុំទៅ ។
អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ
អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនូវសំប៉ាន ។
អ្នកខ្ពស់រក្សាទាប ដោយសុភាពធម៌បុរាណ
អ្នកឆ្អែតរក្សាឃ្លាន នាអ្នករុងរក្សាផ្សារ ។
រក្សាទៅមករឹង ឥតកំដឹងអស់អំបាល
ចំណោរចិរកាន់កល្ប ដូចរបងបាច់បន្លា ។
កុំឆ្អែតពេកតែឯង មិនគិតក្រែងអស់គ្នីគ្នា
គេឃ្លានអស់ផ្ទៃផ្សា ឱ្យឆីរ៉ាបានឆ្អែតផង ។
កុំមានចិត្តលលើ ពឹងក្រពើឱ្យចម្លង
កុំកាច់អុសរបង វាំងចំណារអាត្មា ។

មានទូកហើយមានថ្នោល មានបង្គោលមានយុថ្កា
ទាំងពួរទាំងច្រវា ដើងថែវណាឱ្យសព្វគ្រប់ ។
ប្រយ័ត្នក្រែងព្យុះខ្យល់ បក់បោកដល់នឹងទល់ទប់
ប្រយ័ត្នប្រយោជន៍គ្រប់ ទើបហៅជាក់ថាគំនិត ។
ពាក្យព្រេងគិតគួរចាំ ជាបណ្ដាំប្រដៅស្ថិត
ពាក្យព្រេងពាក្យព្រឹទ្ធ មុខគួរគិតគិតឱ្យគ្រាន់ ។
ពាក្យនេះជាសណ្ដាប់ ទុកជាច្បាប់ទៀងជាក់ស្បាន់
ពាក្យនេះជាកំណាន់ កំណត់នៅឥតឃ្លាតឃ្លា ។
ថែងចប់នូវប្រការ ដោយដំណើរតំណាលថា
ពាក្យព្រេងអតីតា ចូរចាំសព្វគ្រប់ពាក្យពេចន៍ ។
ពាក្យនេះអស់ម្ល៉េះហោង ចូរអ្នកផងចាំកុំភ្លេច
អស់អាថ៌ពាក្យនេះសេច គ្រេចជាសុរេចម្ល៉េះហោង ។

*(ដកស្រង់ចេញពីប្រជុំច្បាប់ បោះពុម្ពឡើងវិញ JSRC 1990)*

## សំណួរ

១. តើកំណាព្យខាងលើដកស្រង់ចេញពីសៀវភៅណា ? តែងជាបទអ្វី ?
២. ចូរបង្ហាញពីកាព្យមាត្រនិងចំណាប់ចួន ផ្ទួន រណ្ដំរបស់កំណាព្យនេះ ។
៣. ចូរបកស្រាយន័យក្នុងវគ្គទី ១ និងទី ២០ នៃអត្ថបទនេះ ។
៤. ចូរបង្ហាញត្រួសៗពីតម្លៃអប់រំរបស់អត្ថបទនេះ ។

## បែបនៃល្បះ

ដើម្បីទាក់ទងគ្នា ឬដើម្បីសម្តែងគំនិតប្រាប់គ្នាទៅវិញទៅមក គេប្រើល្បះ ។

ល្បះ គឺជាបន្សំរវាងកន្សោមពាក្យនិងកន្សោមពាក្យ ហើយមានន័យគ្រប់គ្រាន់ស្តាប់បាន ។ គេអាចនិយាយបានម្យ៉ាងទៀតថា ល្បះ គឺជាក្រុមពាក្យ ដែលមានន័យគ្រប់គ្រាន់ស្តាប់បាន ។

អ្នកបានសិក្សារួចមកហើយអំពីប្រភេទខ្លះរបស់ល្បះ ។ ឥឡូវនេះ អ្នកនឹងសិក្សារំលឹកឡើងវិញនិងសិក្សាបន្ថែមប្រភេទល្បះមួយចំនួនទៀត ។

ល្បះមានបួនបែប ៖

### ក. ល្បះបញ្ជាក់

ដូចម្តេចហៅថា ល្បះបញ្ជាក់ ? ចូរពិនិត្យឧទាហរណ៍ :

១. កុមារនៅភូមិខ្ញុំបានទៅរៀនគ្រប់ៗគ្នា ។

២. ខ្ញុំបានអានច្បាប់ប្រុសនិងច្បាប់ស្រីរួចហើយ ។

៣. ខ្ញុំមិនទាន់យល់ច្បាស់ពីខ្លឹមសារមួយចំនួនរបស់មេរៀននេះទេ ។

តាមឧទាហរណ៍ខាងលើយើងឃើញថា

- ល្បះទី ១ : បញ្ជាក់ពីស្ថានភាពកុមារនៅភូមិខ្ញុំ(អ្នកនិយាយ)ថាបានទៅរៀនគ្រប់ៗគ្នា ។
- ល្បះទី ២ : បញ្ជាក់ពីខ្ញុំ(អ្នកនិយាយ)ថាបានអានច្បាប់ប្រុសនិងច្បាប់ស្រីរួចហើយ ។
- ល្បះទី ៣ : បញ្ជាក់ប្រាប់ថាខ្ញុំ(អ្នកនិយាយ) យល់មិនទាន់ច្បាស់ទៅលើខ្លឹមសារមេរៀននេះទេ ។

ល្បះខាងលើសុទ្ធតែបញ្ជាក់ពីព័ត៌មាន ឬសកម្មភាពរបស់អ្នកនិយាយ ហើយល្បះទាំង ៣ នេះគេសរសេរសុទ្ធតែបញ្ចប់ដោយសញ្ញាខណ្ឌ “ ។” ។

ល្បះបញ្ជាក់ គឺជាល្បះសម្រាប់ប្រើប្រាស់បញ្ជាក់ ឬបង្ហាញប្រាប់ព័ត៌មាន សកម្មភាពផ្សេងៗតាមរយៈអ្នកនិយាយ ឬអ្នកសរសេរ ។ ល្បះបញ្ជាក់ បញ្ចប់ដោយសញ្ញាខណ្ឌ “ ។” ។

## ខ. ល្បះបញ្ជា

ចូរពិនិត្យឧទាហរណ៍ :

១. កុំមាត់ឡូឡា រំខានមិត្តភក្តិយើងកំពុងអានសៀវភៅ ។

២. អ្នកត្រូវក្រោកពីព្រលឹម ដើម្បីទន្ទេញមេរៀន ។

៣. ចូរប្អូនខិតខំរៀនទាន់ខ្លួននៅក្មេង !

៤. កុំកាប់បំផ្លាញខ្ញុំ ខ្ញុំក៏មានជីវិតដូចអ្នកដែរ !

ល្បះទី ១និងទី ២ បង្ហាញពីការបង្គាប់បញ្ជា "កុំមាត់ឡូឡា ..., អ្នកត្រូវ ..." ។

ល្បះទី ៣ បង្ហាញពីការឱ្យដំបូន្មាន ដាស់តឿន "ចូរប្អូនខិតខំរៀន ..." ។

ល្បះទី ៤ បង្ហាញពីការអង្វរ(ព្រៃឈើ) "កុំកាប់បំផ្លាញខ្ញុំ ..." ។

ល្បះទាំងបួនខាងលើបញ្ចប់ដោយសញ្ញាខណ្ឌ "។"និងសញ្ញា "!" ។

> ល្បះបញ្ជា គឺជាល្បះសម្រាប់បង្គាប់បញ្ជា ផ្ញើសំណើ សំណូមពរ ឱ្យដំបូន្មាន អង្វរ ...ឱ្យនរណាម្នាក់ធ្វើអ្វីមួយ ។ ល្បះបញ្ជា បញ្ចប់ដោយសញ្ញាខណ្ឌ "។" ឬសញ្ញា "!" ។

## គ. ល្បះសំណួរ

ចូរពិនិត្យឧទាហរណ៍ :

១. ហេតុអ្វីបានជាមិត្តចង់ឈប់រៀន ?

២. ឯងធ្វើលំហាត់ហើយ ឬនៅ ?

៣. ឯងក្រោកទន្ទេញមេរៀននៅម៉ោងប៉ុន្មាន ?

ល្បះទាំងបីខាងលើបង្ហាញពីការចង់ដឹងពីព័ត៌មានផ្សេងៗដែលគេចង់ដឹង ។ ល្បះទាំងនេះបញ្ចប់ដោយសញ្ញាសួរ "?" ។

> ល្បះសំណួរ គឺជាល្បះសម្រាប់សួរព័ត៌មានផ្សេងៗ ។ ល្បះសំណួរ បញ្ចប់ដោយសញ្ញាសួរ"?" ។

## ឃ. ល្បះឧទាន

ចូរពិនិត្យឧទាហរណ៍ :

១. កូនគេនេះរៀនពូកែណាស់តើ !

២. យុវជននេះសុភាពរាបសាណាស់ !

៣. យីអើ ! មិនគួរដូចនេះសោះ ។

៤. យី ! ពស់ធំណាស់ ។

ល្បះខាងលើបង្ហាញពីការស្ងើចសរសើរ ហួសចិត្ត ភ្ញាក់ផ្អើល ឬភ័យ ...ចំពោះបញ្ហាអ្វីមួយ ។

ល្បះទាំងនេះ បញ្ចប់ដោយសញ្ញាឧទាន "!" ។ ប៉ុន្តែ មានល្បះខ្លះបញ្ចប់ដោយសញ្ញាឧទាន "!" និងសញ្ញាខណ្ឌ " ។ " ។

**ល្បះឧទាន គឺជាល្បះសម្រាប់បញ្ជាក់ពីការភ្ញាក់ផ្អើល ភ័យរន្ធត់ ត្រេកអរ រំភើប តក់ស្លុត... ។ ល្បះឧទាន បញ្ចប់ដោយសញ្ញាឧទាន "!" ។**

## លំហាត់

១. ក្នុងចំណោមល្បះខាងក្រោម តើល្បះណាខ្លះជាល្បះបញ្ជាក់ បញ្ជា សួរ និងល្បះឧទាន?

- ពេលបើកបរម៉ូតូ យើងត្រូវពាក់មួកសុវត្ថិភាពជានិច្ច ។
- តើពូមកដល់ម៉ោងប៉ុន្មាន ?
- កុំប្រើប្រាស់ទឹកខ្ជះខ្ជាយពេកកូន ។
- អែយ៉ា ! ពូកែមែនទ៉ីយ !
- ថ្ងៃនេះ ឯងរៀនមុខវិជ្ជាអ្វីខ្លះ ?
- គួរឱ្យសោកស្ដាយណាស់ ! មិនគួរកាប់ដើមឈើនេះទេ ។
- នៅពេលប្អូនៗត្រឡប់ទៅផ្ទះវិញ ចូរប្អូនអានអត្ថបទកាព្យ "គោថ្ម"ឡើងវិញ ។

២. ចូរអ្នកតែងល្បះតាមប្រភេទនីមួយៗឱ្យបានបីៗល្បះ ។

# ទំហៀបន័យ ឬឧបមាន

ក្នុងការប្រៀបធៀបសភាវៈ សកម្មភាពពីរ ឬច្រើន គេប្រើទំហៀបន័យ ឬឧបមាន។ ទំហៀបន័យ ឬឧបមានបង្ហាញឱ្យឃើញតាមរយៈចំណងធៀប ។

ចូរពិនិត្យឧទាហរណ៍ ៖

១. រស់ឥតសង្ឃឹម ខំប្រឹងញញឹម ក្លាយជាសោកា
សំណើចសោះក្រោះ ដូចលេបសិលា ហាតែចង្កា
ផ្សារអាចិត្ត ។
មាត់ស្រែកសប្បាយ តែចិត្តនិងកាយ រីងស្រពោនស្វិត
សុភមង្គល ដូចយប់ងងឹត ចងឆ្វាក់រួតរឹត
ដូចពស់លេបប្រាណ ។
អន់ជាងបក្សី សត្វមានសេរី ត្រាច់ហើរសព្វឋាន
ខ្លួនឯងជាមនុស្ស អន់ជាងតិរច្ឆាន ដូចត្រីជាប់ប្រាណ
លង់ក្នុងអណ្ដូង ។
ផ្គរភរអ្នកស្រែ មេឃមីរខ្មៅអែ ហាក់រលំប្រេះ
សង្ឃឹមថាភ្លៀង មិនទៀងជាផេះ ក្លាយជាភ្លើងឆេះ
ខ្លោចអស់ព្រឹក្សព្រៃ ។

*(ដកស្រង់ពីកំណាព្យមើលផែនដីខ្មែរ សម័យប៉ុលពត អ្នកនិពន្ធជួន ម៉េន)*

២. រូបប្អូនសព្វថ្ងៃប្រៀបដូចផ្កា រូបបងឧបមាដូចកន្លង់
កន្លង់ឃើញផ្កាចូលត្រឹបត្រង់ រួចមិនបង្អង់ចរលីលា ។

*(រឿងទុំទាវ ភិក្ខុសោម)*

ក្នុងឧទាហរណ៍ទី ១ កវីប្រើចំណងធៀប "ដូច ហាក់"
... សុភមង្គល ដូចយប់ងងឹត ... ។
... សំណើចសោះក្រោះ ដូចលេបសិលា ... ។
... មេឃមីខ្មៅអែ ហាក់រលំប្រេះ ... ។

ចំណែកក្នុងឧទាហរណ៍ទី ២ កវីប្រើចំណងធៀប "ប្រៀបដូច" ៖
រូបប្អូនសព្វថ្ងៃប្រៀបដូចផ្កា... ។

តាមឧទាហរណ៍ខាងលើ បញ្ជាក់ថា ក្នុងការពណ៌នាបង្ហាញពីសភាវៈ សកម្មភាព ឬអំពើឱ្យកាន់តែច្បាស់លាស់និងមានលក្ខណៈរូបី គេប្រើទំហៀបន័យ ឬឧបមាន ។

*ទំហៀបន័យ ឬឧបមាន ជាវិធីប្រៀបធៀបដោយប្រើចំណងធៀប ។*

*ចំណងធៀបមានដូចជា ដូច ដូចជា ហាក់ដូចជា ប្រៀបបាន ហាក់ ប្រៀបដូច ប្រហែល ប្រហែលជាយ៉ាងណា ... យ៉ាងនោះ ។ល ។*

## លំហាត់

ចូរបង្ហាញពីទំហៀបន័យនិងចំណងធៀបក្នុងវគ្គកាព្យខាងក្រោម ៖

១. ទុំថាឱបងដូចត្រីធំ ខ្លួនទាវស្រីមុំដូចគង្គា
ត្រីបានទឹកជ្រៅហែលរេរា កុំកែវពុំងាគិតសង្ស័យ ។
ទាវថាខ្លួនប្អូនដូចព្រឹក្សា អ្នកដូចសារិកាទំសព្វថ្ងៃ
ចតជាទ្រនំទំអាស្រ័យ ហើយហើរច្រៀវព្រៃទៅទីទៃ ។

*(រឿងទុំទាវ ភិក្ខុសោម)*

២. រូបខ្ញុំប្រៀបបានសូរិយា ពន្លឺភ្លឺថ្លាចាំងរស្មី
តែខ្ញុំភ្លឺរាល់ថ្ងៃរាត្រី មិនបាច់ផ្លាស់ថ្មីប្តូរវេនគ្នា ។
អាទិត្យភ្លឺថ្ងៃចាំងរស្មី ពេលយប់រាត្រីព្រះចន្ទ្រា
តែខ្ញុំជួយអ្នកភ្លឺគ្រប់គ្រា បើរាល់ជនាខំសិក្សា ។

៣. ក្នុងខណៈនោះ មានសូរស្បែកជើងលាន់ឮពីខាងក្រោមឡើងមកលើផ្ទះ ព្រមទាំងមានសំឡេងយ៉ាងឆ្មារតូចលាន់រំពងមកពីខាងក្រោយ ចៅ ចិត្រៗ ក៏ចោលភ្នែកក្រឡេកមើលទៅប្រទះនឹងភ្នែកទាំងគូកំពុងតែសម្លឹងចំត្រង់មកជាដួងភ្នែកប្រកបដោយទឹកដមគួរជាទីចាប់ចិត្តស្នេហា តែមានបួកពាឆ្មើងឆ្មៃបន្តិចមានកិរិយាក្និកក្នក់ញ៉ែងញ៉ង ល្វាសល្វន់ល្អណាស់ សម្បុរស្បែកសស្អាតមុខមូលក្រឡង់ដូចវង់ព្រះចន្ទ្រា សូរសំឡេងស្រួយស្រស់ដូចសូររគាំងប្រាក់ ដំណើរល្វាសល្វន់ដូចផ្កាកុលាប ដែលត្រូវខ្យល់បក់ល្ងិចៗនៅកណ្តាលសួនច្បារដូច្នោះ ឱ!ល្អអី ល្អម្ល៉េះ! នេះប្រហែលជាអញយល់សប្តិឃើញទេដឹង ?

ចៅ ចិត្រ ភ្ញាក់ស្មារតី លែងសម្លឹង ស្រឡាំងកាំងក្នុងពេលដែលលោក ហ្លួង ស្រែកហៅកូនស្រីនោះ ឱ្យឡើងមកខាងលើផ្ទះ "មកឯណេះ នារី! ថ្ងៃនេះ ប៉ាបានមនុស្សចូលមកធ្វើការថ្មីម្នាក់ទៀតហើយ"។

នាងក្រមុំនារី ឈានជើងឡើងជណ្ដើរមួយៗ ភ្នែកសំឡឹងមើលចៅ ចិត្រ ដោយកិរិយាឆ្មើងឆ្មៃបន្តិចដែលជាទំនៀមរបស់ស្ត្រីក្រមុំរូបស្រស់ ហើយសួរទៅឪពុកថា "ប៉ា! នេះឬអ្នកចូលមកធ្វើការថ្មីរបស់យើង ?"

លោក ហ្លួង ញាក់មុខទទួលហើយងាកទៅនិយាយនឹង ចៅ ចិត្រថា "ចៅ ចិត្រ! នេះ នារី កូនស្រីតែមួយរបស់ខ្ញុំ"។

ចៅ ចិត្រ លើកដៃសំពះសួរ នាង នារី ងក់ក្បាលទទួលគំនាប់ដោយកិរិយាឆ្មើងៗតាមនិស្ស័យរបស់នាង ។

នាង នារី សម្លឹងមើលកម្មករថ្មីរបស់ឪពុក តាំងអំពីក្បាលរហូតដល់ចុងជើង មើលហើយមើលទៀត នៅទីបំផុតក៏លាន់មាត់ថា "កម្មករនេះ ស្គមដូចអ្នកញៀនអាភៀននឹងមានកម្លាំងជីកដីបាន ឬប៉ា ?"។

ចៅ ចិត្រ កាលបើត្រូវស្រីក្រមុំស្ដីដាក់មុខដូច្នេះ ក៏នឹកអៀនខ្មាសណាស់ក្រឡេកចោលកន្ទុយភ្នែកទៅនាងមួយភ្លែត ហើយតបទៅថា "មនុស្សត្រង់គេមិនដែលសម្គាល់ថាជាមនុស្សល្ងង់ទេ ឯមនុស្សស្គមក៏គេមិនសម្គាល់ថា ជាមនុស្សខ្សោយដែរ ស្គមយ៉ាងខ្ញុំបាទនេះ មានកម្លាំងខ្លាំងដូចមនុស្សធាត់មាំដែរ គ្រាន់តែមិនសូវមានសាច់ឈាមធាត់បរិបូណ៌ប៉ុណ្ណោះទេតើ!"។

នាង នារី ធ្វើមុខក្រញូវទំនងខឹងបន្តិចៗផង ដោយនាងមិននឹកនាថា ចៅ ចិត្រ ហ៊ានឆ្លើយដូច្នេះសោះ ព្រោះមិនធ្លាប់មានមនុស្សណាមួយក្នុងផ្ទះហ៊ាននិយាយលេងសំដីវោហារនឹងនាងឡើយ ។

លោក ហ្លួង ឃើញកូនខឹងដូច្នោះក៏បញ្ឈប់ថា "ចៅ ចិត្រ! ល្ហើយឈប់ស្លេះប៉ុណ្ណឹងសិនចុះ ឯងកំពុងនឿយហត់អស់កម្លាំង ទៅរកសម្រាកខ្លួនឱ្យបាត់នឿយហត់សិនទៅ"។ [...]

*(ដកស្រង់ពីរឿងកុលាបប៉ៃលិន អ្នកនិពន្ធញ៉ុក ថែម)*

# តោថ្ម



## ក. សិក្សាពាក្យគន្លឹះ

- ថាយ៉ាង (ន) : កាយវិការ ឫកពា ។
- វាសុក្រី (ន) : ស្ដេចនាគ ។
- នាគបាសាណ (ន) : នាគដែលបើកពពារ ឬធំឡើងរឹទ្ធិ ។
- ថាវរៈ (គុ) : មាំមួន ស្ថិតស្ថេរ មាំទាំ ។
- សង្ខារ (ន) : ជីវិត ។
- ហ្មាយ (កិ) : សម្គាល់ ចំណាំ កំណត់ដឹង ... ។
- ចិរកាល (គុ) : កាលដ៏យូរអង្វែង តរៀងទៅ ... ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទកាព្យនេះ អ្នកគប្បីអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹងខ្លឹមសារអត្ថបទ កាព្យមាត្រ ចំណាប់ចួន ទំហៀបន័យ ឬឧបមាន ... ។

## គ. អត្ថបទ

### បទពាក្យប្រាំបី

អនិច្ចាគោថ្មលោកកសាង មើលថាថាងយ៉ាងរស់ស្ទុះប្រែប្រាយ
ឥឡូវមកធ្លាយធ្លាក់បាក់ខ្ទាត់ខ្ទាយ ស្តាយអើយស្តាយមិនគួរមកពិការ ។
មានអ្នកព្រៃចង្រៃឥតគំនិត ទៅសំលៀងកាំបិតគ្រឿងប្រហារ
ឱ្យខូចខាតសាច់បង់អាសា មិនស្តាយការស្នាដៃបុរាណសោះ ។
ឱគោអើយគោឈរមិនមើលមៀង មកឱ្យគេសំលៀងខ្នងគោចុះ
ម្តេចមិនខឹងខាំវាសំលៀងនោះ ឱ្យវាលុះក្ដីមរណ៍យក៍វាទៅ ។
អាណាអើយបំផ្លាញរូបគោលោក គ្មានប្រយោគឱ្យយល់ការរាក់ជ្រៅ
គួរឬលោកខំសាងតាំងទុកនៅ មកសត្រូវបំផ្លាញរបស់លោក ។
គន់ៗស្នានថ្មតប្រជិត ជាក្តារថ្មជាសជិតប្រកិតគោក
ទោះដីរីថ្មបរជាន់ក៏គ្មានយោក ឥឡូវជ្រោកស្រុតខ្លះតែដើរបាន ។
បង្កាន់ដៃច្នៃវាសុគ្រី ដប់សិរសីដូចស្និតជិតជុំប្រាណ
លើកពពារឡើងពភ្លាក់ហាក់ហៅហាន សម្តែងប្រាណប្រួញរួមជាមួយគ្នា ។
មើលនាគរាជអង់អាចអំណាចស្វែង ខ្លួនក៏វែងក្បាលក៏វក់តាមទ្វារ
លូនលើស្ពានមានជើងកល់គង្គា កន្ទុយបែកញែកគ្នាតាមធ្លាផ្លូវ ។
ឱរូបវាសុគ្រីពឥតក្រែងគ្រុឌ តាំងសម្តែងរឹទ្ធិរុទ្ធតសត្រូវ
ប្រសិនគ្រុឌមកយល់យ៉ាងពុំនៅ គង់ស្ទុះទៅជ្រកក្នុងកសិណនេះ ។
នាគអើយនាគបាសាណបូរាណសាង ពីដើមយ៉ាងល្អងងដូចម្តេចអេះ
ឥឡូវនាគងាកធ្លាក់បាក់របេះ ឃើញតែរាងយ៉ាងនេះអស់លំអ ។
ខ្លួនក៏ឃ្លាតក្បាលក៏ឃ្លៀងទៅដោយខ្លួន ឃើញតែក្បួនជើងទៀនប្រចាំទ្រ
ស្តាយអើយស្តាយស្នាដៃលោកតែងមក៏ មិនតាំងតថាវរៈឱ្យវែងទៅ ។

ឱអនិច្ចាសង្ខារនាគាថ្ម ហ្មាយតស្ថិតស្ថេរចិរកាលនៅ

នេះពុំទាន់ប៉ុន្មានមកហ្មងសៅ មករុះរោយធ្លាយទៅទីទៃផ្លាស ។

*(ដកស្រង់ពី "និរាសនគរវត្ត" របស់ឧកញ៉ា សុត្តន្តប្រីជាឥន្ទ)*

## សំណួរ

១. តើអត្ថបទកាព្យនេះដកស្រង់ចេញពីណា ? អ្នកនិពន្ធឈ្មោះអ្វី ?

២. តាមអត្ថបទ តើនរណាជាអ្នកបំផ្លាញគោថ្ម ? គេបំផ្លាញដោយវិធីណា ?

៣. ចូរស្រង់ឃ្លាកាព្យដែលបង្ហាញពី ៖

- ការមិនពេញចិត្តរបស់កវីចំពោះអំពើបំផ្លិចបំផ្លាញ ។
- ការស្តាយស្រណោះរបស់កវីចំពោះការខូចខាត ។
- មោទនភាពរបស់កវីចំពោះសម្បត្តិវប្បធម៌ជាតិ ។

៤. តើកំណាព្យនេះតែងជាបទពាក្យប៉ុន្មាន ? ចូរបង្ហាញកាព្យមាត្ររបស់បទនេះ ។

៥. ចូរបង្ហាញចំណាប់ចួនក្នុងវគ្គនិងឆ្លងវគ្គរបស់កាព្យនេះ ។ តើការចួននេះ គោរពទៅតាមក្បួនទៀងទាត់ឬទេ ? ចូរបង្ហាញ ។

៦. ចូរបង្ហាញពីទំហៀបន័យដែលកវីប្រើក្នុងអត្ថបទកំណាព្យខាងលើ ។



# ច្បាប់ប្រុស



## ក. សិក្សាពាក្យគន្លឹះ

- ច្រលាស់ (គុ) : ព្រហើន មើលងាយ ឆ្មើន ។
- ប៉ោ (ន) : ឈ្មោះល្បែងស៊ីសងមួយប្រភេទរបស់ចិន ។
- ធួ (ន) : ឈ្មោះល្បែងលេងភ្នាល់ស៊ីសងប្រាក់កាសជាល្បែងរបស់ចិន ។
- ទុរយស (គុ) : ចង្រៃ ឧត្បាត ។
- ផ្សា (គុ) : ដោយហេតុពីព្រោះ ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ អ្នកគប្បីអានដោយប្រុងប្រយ័ត្ននិងយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងខ្លឹមសារអត្ថបទ ចំណាប់ចួន ផ្ទួន រណ្តំ កាព្យមាត្រ តម្លៃអប់រំរបស់អត្ថបទ ។

## គ. អត្ថបទ

### បទព្រហ្មគីតិ

រៀនបទរៀនបាទចាស    កុំច្រឡាស់លើរៀមច្បង
ស្រដីនឹងអ្នកផង    ពាក្យឱ្យគួរកុំឯងរឺ ។

អីអើអញដាច់សាច់ ឆ្គងពាក្យពេចន៍គេស្រដី
ដើមដៀលឱ្យអប្រិយ ស្រដីថាកូនអត់ពូជ ។
ចាស់ទុំមិនប្រដៅ ជេរកូនចៅទើបវាខូច
គេថាកូនឥតពូជ មិនដឹងច្បាប់នឹងចាស់ទុំ ។
គេដៀលដល់ម៉ែឪ កេរ្តិ៍អាស្រូវស្អុយរហ៊ុម
គេស្តីដើមជៀវជុំ ដំនៀលនោះដល់មកចាស់ ។
កុំកាចកុំស្លូតពេក កុំចំអៀកវៀនរហ័ស
កុំខ្លាចកុំហ៊ានណាស់ ឱ្យរំពឹងរំពៃគ្រប់ ។
ទោះដេកឱ្យរហ័ស ភ្ញាក់មុនចាស់ដោះឡើងលុប
មុខមាត់មើលឱ្យគ្រប់ ទ្រព្យរបស់សឹមដេកវិញ ។
មាសប្រាក់ស្រូវអង្ករ ទុកឱ្យល្អកុំសប្បុរស
សំចៃកុំឱ្យអស់ មើលថែថ្នួនខ្លួនឯងណា ។
ស្ងូវស្ងួចកុំឱ្យដាច់ បើវាតិចឱ្យឧស្សាហ៍
រិះរកផ្សំទៀតណា ឱ្យបានច្រើនក្រវើនទុក ។
នឹកចាយឱ្យគិតក្រោយ ទោះនឹងឱ្យៗមើលមុខ
កុំឱ្យស៊ុកគ្រលុក ទោះនឹងទុកឱ្យចំណាំ ។
រដូវធ្វើចម្ការ ឱ្យឧស្សាហ៍គ្រឿងគ្រាប់ដាំ
ស្លឹកគ្រៃខ្ទឹត្រប់ត្រុំ ត្រាវត្រសក់ត្រប់បន្លែ ។
កុំខ្ជិលកុំច្រអូស ទៅរងូសរត់សុំគេ
គេមិនឱ្យឯងទេ តែគឺមោះព្រោះខ្ជិលដាំ ។
ប្រយ័ត្នប្រយោជន៍យូរ ទោះលក់ដូរមើលថែថ្នួន
ទោះទ្រព្យរបស់ខ្លួន ឱ្យសួរកូនសួរប្រពន្ធ ។
កុំអាងឯងជាប្រុស ចាយរបស់មិនគិតគន់
មិនដឹងដល់ប្រពន្ធ ព្រមព្រៀងគ្នាឥតបើថា ។
ទោះបីបើបងប្អូន រកពឹងខ្លួនទៅទីណា
ទោះទៅលេងឥតការ ឥតគេរកដើរឆ្ងាយជិត ។
ឱ្យប្រាប់អ្នកនៅផ្ទះ កុំរលះឥតគំនិត
គេភ័យព្រួយចិត្តគិត ព្រោះមិនដឹងជាទៅណា ។

បើសិនជាមានភ័ព្វ ប្រសើរគាប់នោះឥតថា
ប្រសិនពានពស់ខ្លា ខ្យល់ចុកចាប់ឥតបើសម ។
កូនអើយបាកុំធ្លោយ កុំធ្លាប់ឱ្យអាប់កិត្តិយស
ធម្មតាកើតជាប្រុស ឱ្យរករៀនច្បាប់មាត្រា ។
លោកហៅថាឆ្កួតបី មួយឆ្កួតស្រីមួយឆ្កួតស្រា
មួយឆ្កួតល្បែងពាលា លេងបៀប៉ោធ្វកំតាត់ ។
ទាក់មាន់ទាក់ទទា ជល់ភ្នាល់គ្នាបរបាញ់សត្វ
អន្ទាក់ដាក់បង្កាត់ ល្បែងអស់នោះមិនកំណើត ។
ធម្មតាប៉ោនិងបៀ មិនដែលខ្មែរណានឹងកើត
មិនព្វមានកំណើត មានតែលិចលង់ខ្លួនទេ ។
ជួនកាលគេចាញ់ឯង រៀងរាល់ល្បែងតែងនឹងរេ
មានកាលឯងចាញ់គេ កុំទុកចិត្តថាឯងប៉ិន ។

*(ដកស្រង់ចេញពីច្បាប់ប្រុសរបស់បណ្ឌិត ម៉ៃ)*

## ច្បាប់ស្រី (បទភុជង្គលីលា)

ហៃកូនស្រីស្ងួនមាសម្តាយ ក្រណាស់នាងអាយ តាមដោយច្បាប់ស្រី ។
ក្រមួយមិនបានសម្តី ពាក្យទន់តិចនៃ ឱ្យញាតិចូលចិត្ត ។
ក្រមួយមិនចេះរិះគិត ឃើញញាតិឆ្ងាយជិត ហៅឡើងឆីស្លា ។
ទោះមានមិនមានក្តីណា ពាក្យផ្អែមចរចា ទើបគេស្រឡាញ់ ។
កុំជួរចិត្តស្នូរកំណាញ់ មិនមានអស់អញ នឹងញាតិសន្តាន ។
កើតយសរបស់ផងបាន កើតសុខក្សេមក្សាន្ត ពីព្រោះកូនស្រី ។
ទោះនឹងនិយាយស្រដី ការកេរ្តិ៍ជាស្រី កុំស្តីឡេះឡោះ ។
ថាលេងដូចក្មេងញ៉េះញ៉ោះ ឃើញប្រុសកំលោះ សសៀរចូលជិត ។
សើចព្រៀងបញ្ឆៀងមិនគិត ប្រុសព្រើលបានចិត្ត វាហ៊ានដោយសារ ។
ហៅស្រីអប្រិយឥតការ ឥតមានឥរិយា មារយាទក្នុងខ្លួន ។
សើរើពុំធ្វើនឹមនួន ស្រដីមិនមួន មិនមានអៀនអន់ ។
ឃើញគេបៀតបែរគយគន់ សើចសួរចំអន់ ចំអកឱ្យប្រុស ។
ហៅស្រីអប្រិយទុរយស មិនខ្លាចខ្លួនខុស មារយាទត្រីត្យក្រម ។
ធ្វើការអង្គុយច្រទ្បំ នឹងសមពុំសម ផ្សាឯងជាស្រី ។

| | | |
|---|---|---|
| មិនកោតមិនខ្លាចចិត្តប្ដី | ឱ្យប្រុសដទៃ | មាក់ងាយប្ដីណា ។ |
| ហៅស្រីឥតលក្ខណា | ឥតមានកិរិយា | មារយាទពុំសម ។ |
| ធ្វើការផងណាប្រើខំ | ទោះត្បាញចាក់ដំ | នាងខំឱ្យហើយ ។ |
| កុំទុកទៅមុខទៀតឡើយ | ថាចាំបង្ហើយ | កម្រណាស់ណា ។ |
| ទោះធ្វើហូលគោមព្រែផ្កា | ដាក់ត្បាញហើយណា | បានស្រេចសឹមធ្វើ ។ |
| ធ្វើឱ្យកើតកេរ្តិ៍ប្រសើរ | ហើយកុំឱ្យដើរ | លេងផ្ទះគេណា ។ |
| ឱស្ងួនខ្ញីមខ្លួនរក្សា | នាងខំធ្វើការ | ទាន់ខ្លួនក្រមុំ ។ |
| មានប្ដីបានអ្វីជាខំ | រវល់កូនយំ | កម្រចេះឆ្លៀត ។ |
| ព្រួយចិត្តគំនិតចង្អៀត | មួយហើយមួយទៀត | យំទារតែឆី ។ |
| រឹងព្រួយទាំងមួយទាំងពីរ | រកបានឱ្យឆី | ទើបបានបាត់មាត់ ។ |
| ទោះកាន់ការធ្វើឱ្យស្អាត | ហូលគោមគាតកាត់ | អន្ទងត្បាញទៅ ។ |
| កុំទុកក្នុងស្នុកស្នួញនៅ | ក្រែងដល់យូរទៅ | ខាតខូចអសារ ។ [...] |
| ធ្វើវត្តប្រតិបត្តិសោកណា | ឱ្យនាងរក្សា | ភ្នក់ភ្លើងទាំងបី ។ |
| ឱ្យកាត់ឱ្យគង់ប្រក្រតី | សព្វថ្ងៃកុំបី | ភ្លេចផ្លុំឱ្យឆេះ ។ |
| ក្រែងរាលដួលដាលព្រាយប្រេះ | កើតក្ដៅរលេះ | រលាយអស់អង្គ ។ |
| ភ្លើងក្រៅកុំនាំទៅក្នុង | ឱ្យឆេះបំផ្លុង | រឹងផ្លុំបង្កាត់ ។ |
| ភ្លើងក្នុងមិនប្រុងប្រយ័ត្ន | នាំមកបង្កាត់ | ឱ្យឆេះឯក្រៅ ។ |
| អុជអាលបណ្ដាលឱ្យក្ដៅ | ដាលដល់កូនចៅ | អសោចិ៍អប្រិយ ។ |
| ឱ្យនាងខំប្រឹងស្មារតី | មើលភ្លើងទាំងបី | រក្សាឱ្យគង់ ។ |
| ភ្លើងនោះឱ្យគុណពុំលង់ | នឹងឱ្យឧត្តុង្គ- | ឧត្តមកន្លង ។ |

## សំណួរ

១. តើអត្ថបទខាងលើតែងជាបទអ្វីខ្លះ ?

២. បង្ហាញចំណាប់ចួនរបស់កំណាព្យ ច្បាប់ប្រុសនិងច្បាប់ស្រី ។

៣. ចូរបង្ហាញត្រួសៗពីតម្លៃអប់រំរបស់ច្បាប់ប្រុស ច្បាប់ស្រី ។



# ការសូត្រកំណាព្យ

អ្នកបានអានរួចមកហើយពីកំណាព្យបទពាក្យ៨ ។ ឥឡូវនេះចូរអ្នកបើកទំព័រអំណាន "គោច្នៃ" រួចសូត្រកំណាព្យនោះឱ្យបានត្រឹមត្រូវ ។

កំណាព្យបទពាក្យ ៨ ៖

## ក. រង្វាស់កាព្យ

- ១វគ្គ = ៤ឃ្លា
- ១ឃ្លា = ៨ព្យាង្គ

## ខ. ចំណាប់ចួន

ចំណាប់ចួនរបស់កំណាព្យបទពាក្យ ៨ មាន ៤បែប តែឥឡូវនេះយើងលើកយកតែចំណាប់ចួន ២ បែបមកបង្ហាញ ។

• បែបទីមួយ

**ចួនក្នុងវគ្គ :**

- ព្យាង្គទី៨នៃឃ្លាទី ១ ចួននឹងព្យាង្គទី៥នៃឃ្លាទី ២
- ព្យាង្គទី៨នៃឃ្លាទី ២ ចួននឹងព្យាង្គទី៨នៃឃ្លាទី ៣ ចួននឹងព្យាង្គទី ៥នៃឃ្លាទី ៤ ។

ចួនឆ្លងវគ្គ : ព្យាង្គទី ៨នៃឃ្លាទី ៤ក្នុងវគ្គទី ១ ចួននឹងព្យាង្គទី៨នៃឃ្លាទី ២វគ្គទី ២ ។

• បែបទីពីរ

**ចួនក្នុងវគ្គ :**

- ព្យាង្គទី៨នៃឃ្លាទី ១ ចួននឹងព្យាង្គទី ៣ ឬទី ៥នៃឃ្លាទី ២ (មិនទៀងទាត់)
- ព្យាង្គទី៨នៃឃ្លាទី ២ ចួននឹងព្យាង្គទី ៨នៃឃ្លាទី ៣ ចួននឹងព្យាង្គទី ៣ ឬទី ៥នៃឃ្លាទី ៤ (មិនទៀងទាត់) ។

**ចួនឆ្លងវគ្គ :** ព្យាង្គទី ៨នៃឃ្លាទី ៤ក្នុងវគ្គទី ១ ចួននឹងព្យាង្គទី ៨ឃ្លាទី ២នៃវគ្គទី ២ ។

## គ. ចង្វាក់

គេសូត្រទម្លាក់សំឡេងលើព្យាង្គទី ៣និងទី ៤នៃឃ្លានីមួយៗ ។

## ឃ. បរិយាកាស

គេប្រើបទនេះបានគ្រប់បរិយាកាសទាំងអស់ដូចជា ពណ៌នាទុក្ខសោក ការខឹង ការសោកស្តាយ ។

# យុវសិស្សសុជាតិ

## (បទពាក្យ៨)

សុជាតិជាសិស្សមកពីជនបទ តស៊ូអំណត់នឹងការសិក្សា
ជាកូនកសិករស្រុកស្រែចម្ការ ជីវភាពសោតណាមិនសូវធូរធារ ។
មករៀនទីក្រុងក្នុងចិត្តមមៃ ខ្លាចជួបគ្រោះភ័យឈឺគ្រុនរងា
ចិត្តមួយព្រួយគិតរឿងជ្រូកមាន់ទា ម្ដាយមិនសូវជាមេម៉ាយនៅផ្ទះ ។
តែបានតាំងចិត្តឆ្ពិតថាមករៀន ចំណេះជាស្ពានឈានបានរហ័ស
តស៊ូព្យាយាមក្បួនចែងថាឈ្នះ ត្រូវហ៊ានលែងលះខ្លះៗកិច្ចការ ។
នៅថ្ងៃដំបូងពេលចូលទៅរៀន សិស្សកូនអ្នកមានឫកគេហ៊ឺហា
រាងកាយថ្លោសៗសម្បុរភ្លឺថ្លា ស្រស់ៗដូចផ្កាក្នុងឧទ្យាន ។
សុជាតិងាកបែរសម្លឹងឯខ្លួន ប្រៀបដូចត្រកួនត្រែងរកទឹកគ្មាន
ស្គមក្រៀមកំព្រឹងឥតអំណោយទាន ចិន្ដាស្រេកឃ្លានចង់បានស្រស់ថ្លា ។
តែបញ្ហានេះពិតជាមិនថ្មី រឿងគួរឱ្យភ័យគឺការសិក្សា
សុជាតិរិះគិតតែឯងឯកា តើធ្វើយ៉ាងណាទើបរៀនពូកែ ។
គេសម្រេចចិត្តរៀបចំផែនការ សម្រាប់សិក្សាត្រឹមត្រូវតាមខែ
រៀនសូត្រគ្រប់មុខទាំងគណិតខ្មែរ អ្វីក៏រៀនដែរអង់គ្លេសភាសា ។
រៀនបានពូកែគ្រប់មុខវិជ្ជា ល្បីឈ្មោះខ្ទរខ្ទារជាសិស្សឧស្សាហ៍
ម៉ោងរៀនគឺរៀនមិនដែលមុសា ដឹងខ្លួនអាត្មាដើរលេងខកខាន ។
លទ្ធផលប្រពៃការសិក្សា រួមទាំងឥរិយាបថចំណាន
ការប្ដេជ្ញាធ្វើដោយក្លាហាន ជាតិទទួលបានជាសិស្សគំរូ ។

# ការតែងកំណាព្យ

អ្នកបានអាននិងសូត្រកំណាព្យបទពាក្យ៨រួចហើយ ។ ឥឡូវនេះចូរអ្នកតែងកំណាព្យបទពាក្យ៨ យ៉ាងតិច ៤វគ្គស្តីពី ៖

១. ការមានវិន័យចំពោះខ្លួនឯង

២. ការគោរពសិទ្ធិអ្នកដទៃ

៣. ការប្ដេជ្ញាចិត្តខិតខំរៀនសូត្រ ។

គំនូសតាងចំណាប់ចួនបទពាក្យ ៨ ៖

## ក. បែបទីមួយ




ចួនក្នុងវគ្គ :

- ព្យាង្គទី ៨នៃឃ្លាទី ១ ចួននឹងព្យាង្គទី ៥នៃឃ្លាទី ២ ។
- ព្យាង្គទី ៨នៃឃ្លាទី ២ ចួននឹងព្យាង្គទី ៨នៃឃ្លាទី ៣ ចួននឹងព្យាង្គទី ៥នៃឃ្លាទី ៤ វគ្គទី ១ ។

ចួនឆ្លងវគ្គ : ព្យាង្គទី ៨នៃឃ្លាទី ៤ក្នុងវគ្គទី ១ ចួននឹងព្យាង្គទី ៨នៃឃ្លាទី ២វគ្គទី ២ ។

## ខ. បែបទីពីរ



ចួនក្នុងវគ្គ :

- ព្យាង្គទី៨នៃឃ្លាទី ១ ចួននឹងព្យាង្គទី ៣ឬទី ៥នៃឃ្លាទី ២ ។
- ព្យាង្គទី៨នៃឃ្លាទី ២ ចួននឹងព្យាង្គទី ៨នៃឃ្លាទី ៣ ចួននឹងព្យាង្គទី ៣ឬទី ៥នៃឃ្លាទី ៤ វគ្គទី ១ ។

ចួនឆ្លងវគ្គ : ព្យាង្គទី ៨នៃឃ្លាទី ៤ក្នុងវគ្គទី ១ ចួននឹងព្យាង្គទី ៨ឃ្លាទី ២នៃវគ្គទី ២ ។

## សេចក្ដីណែនាំការតែងកំណាព្យបទពាក្យ ៨

អ្នកធ្លាប់សរសេរអត្ថបទជាច្រើនមកហើយ តែការសរសេរពណ៌នាអធិប្បាយទាំងនោះ ប្រសិនបើសរសេរជាពាក្យរាយមានភាពងាយស្រួលជាងការសរសេរជាអត្ថបទពាក្យកាព្យព្រោះការសរសេរជាពាក្យរាយមិនចាំបាច់គិតពីចុងចួន ចំនួនពាក្យក្នុងឃ្លា ឬចំនួនឃ្លាក្នុងវគ្គដូចកំណាព្យឡើយ ។ តែទោះជាយ៉ាងណា ក៏ការសរសេរជាពាក្យកាព្យត្រូវផ្ដោតយកចិត្តទុកដាក់លើចំណុចសំខាន់ជាពិសេសមួយដូចគ្នានឹងការសរសេរពាក្យរាយដែរគឺ ត្រូវប្រកាន់ឱ្យខ្ជាប់នូវប្រធានបទដែលអ្នកត្រូវសរសេរ ។ម្យ៉ាងទៀត ត្រូវខិតខំរិះគិតរកនូវគំនិតទាំងឡាយណាដែលគាំទ្រខ្លាំងក្លាឱ្យប្រធានបទនោះ ។ ប៉ុន្តែលក្ខណៈពិសេសដោយឡែកចំពោះការតែងកំណាព្យ បន្ថែមលើការចងចាំនូវប្រធានបទគឺ ត្រូវចាំឱ្យបានច្បាស់លាស់ពីចំនួនព្យាង្គក្នុងឃ្លា ចំនួនឃ្លាក្នុងវគ្គនិងចំណាប់ចុងចួនក្នុងវគ្គនិងឆ្លងវគ្គថែមទៀត ។ បើគោរពចំណុចទាំងអស់នេះមិនបានទេ នោះការតែងកំណាព្យរបស់អ្នកនឹងមិនទទួលបានជោគជ័យឡើយ ។

ចំណុចសំខាន់ៗមួយចំនួនសម្រាប់តែងកំណាព្យរួមមាន :

- ក្ដាប់ឱ្យបានច្បាស់លាស់នូវប្រធានបទដែលត្រូវសរសេរ ។ តើគេតម្រូវឱ្យសរសេរពីអ្វី ?
- ឈ្មោះបទកំណាព្យ ។ តើអ្នកជ្រើសរើស ឬគេឱ្យអ្នកតែងតាមលំនាំបទកំណាព្យអ្វី ? (កាកគតិ ពាក្យ ៧) ។
- ចាំឱ្យបានច្បាស់នូវចំនួនព្យាង្គក្នុងឃ្លា ចំនួនឃ្លាក្នុងវគ្គនិងចំណាប់ចុងចួនទាំងក្នុងវគ្គនិងឆ្លងវគ្គ ។
- ស្វែងរកព្យាង្គចួនណាដែលសម្បូរសួរ (ឧ. ការ សិក្សា បញ្ញា ថ្លា ប្រាថ្នា ...) ។

ការតែងពីឃ្លាមួយទៅឃ្លាមួយនិងវគ្គមួយទៅវគ្គមួយទៀតត្រូវអាន ឬសូត្រឮៗឱ្យបានញឹកញាប់ដើម្បីចៀសវាងការខុសឆ្គង ឬឃ្លាតឆ្ងាយពីខ្លឹមសារប្រធានបទ ។

មេរៀនទី ៦

# ការគោរពច្បាប់




ច្បាប់ជាបញ្ញត្តិទាំងឡាយ ដែលគេតាក់តែងឡើងឱ្យមនុស្សប្រតិបត្តិតាម។ ច្បាប់ជាការកំណត់ជាបទបញ្ជា បទបញ្ញត្តិ ដែលមនុស្សទូទៅត្រូវប្រតិបត្តិតាម។ ការគោរពច្បាប់ផ្តើមចេញពីការចេះគោរពខ្លួនឯង ការចេះច្បាប់និងចេះប្រើសិទ្ធិរបស់ខ្លួន និងចេះគោរពសិទ្ធិអ្នកដទៃ។ គ្រប់ប្រទេសលើសកលលោកសុទ្ធតែមានច្បាប់សម្រាប់ឱ្យប្រតិបត្តិតាម។ ប្រទេសដែលមានការគោរពច្បាប់ហៅថានីតិរដ្ឋ។ ក្នុងមេរៀននេះ អ្នកនឹងបានស្វែងយល់និងស្គាល់ពីស្មារតីទទួលខុសត្រូវនិងការគោរពច្បាប់មួយចំនួន។ ស្មារតីនេះ រួមចំណែកក្នុងការគោរព និងអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព។ អ្នកនឹងបានសិក្សាបន្ថែមទៀតនូវ កាលរបស់កិរិយាអតីតកាល បច្ចុប្បន្នកាល អនាគតកាល ខ្លឹមសារសំខាន់ៗ នៃព័ត៌មាន។ ផ្តល់ព័ត៌មាន ឬហេតុការណ៍ផ្សេងៗ សរសេរសេចក្តីប្រកាសព័ត៌មាន និងសេចក្តីជូនដំណឹង។



# ឧត្តមគតិខ្ញុំ



## ក. សិក្សាពាក្យគន្លឹះ

- ព្រះតេជគុណ (ន) : គុណនៃអំណាចដ៏ប្រសើរលើសលន់ ឬអំណាចនិងគុណដ៏ប្រសើរខ្ពង់ខ្ពស់ ។
- ធី (ន) : បែប យ៉ាង មុខ ។
- ចំនៀរ (ន) : ចំណិត ឬកំណាត់ដែលចៀរ ។
- ម៉ៅការ (ន) : អ្នកទទួលធ្វើការងារណាមួយ ផ្ដាច់មុខ ។
- ប្រណិប័តន៍ (ន) : ការសម្ដែងការគោរព ការគំនាប់ ការឱនសំពះ ។
- អស្តង្គត (កិឬគុ) : ដល់នូវភាវៈមិនប្រាកដ ធ្លាក់ចុះបាត់ទៅ លិចបាត់ទៅ បាត់ពន្លឺទៅ ។
- ប៉ាន់ (ន) : គំរូអ្វីមួយ ។
- បាលដ្ឋ (ន) : ឋានន្តរនៃមន្ត្រីសង្ឃ ថ្នាក់ឋានានុក្រមថ្នាក់ខ្ពស់ជាង ជាសហការីនៃព្រះរាជាគណៈគ្រប់ថ្នាក់ទាំង ៤គឺ ឯក ទោ ត្រី ចត្វា មានឋានន្តរគឺងារជាភាសាបាលីផ្សេងៗគ្នាសម្រាប់មេគណៈគ្រប់ខេត្ត ក៏មានឋានានុក្រមទីបាលដ្ឋដែរ អ្នកមាននាទីខាងថែររក្សា ។
- ដៃប្រណម្យ (កិ) : លើកកម្បង់អញ្ជលីសំពះ ។

- លុតក្រាប (កិ) : កិរិយាអែបអប ។
- ប្រសាសន៍ (ន) : ពាក្យបង្គាប់ ពាក្យផ្ដាំផ្ញើ បណ្ដាំ ។
- លិចលង់ (កិ) : វិនាសអន្តរាយ ។
- ស្រដៀង (គុ) : ប្រហាក់ប្រហែល ។
- ហោប៉ៅ (ន) : ថង់ដេរភ្ជាប់នឹងអាវ ឬខោជាដើម ។
- ឧបាយកល (ន) : ល្បិច ល្បិចល្បង កិច្ចកល កលមាយា ។
- សូកប៉ាន់ (កិ) : ឱ្យសំណូក ឱ្យប្រាក់ឬទ្រព្យរបស់អ្វីទៅគេដោយសម្ងាត់ ឱ្យដើម្បីប្រយោជន៍អ្វីមួយ ។
- អៀនប្រៀន (គុ) : ដែលអៀនអៀវមមៀវ អៀនមូរមុខ ក្រអឺមក្រអៀម ។
- ស្ថានការណ៍ (ន) : ទីតាំងនៅពិតប្រាកដ អាកប្បកិរិយា ហេតុភេទ ដំណើរ ទំនងបែបបទ ដើងការ ដំណើរការណ៍ដែលប្រព្រឹត្តទៅ ។
- ដេញថ្លៃ (កិ) : ដំឡើងឬបញ្ចុះថ្លៃប្រជែងគ្នា ដើម្បីឱ្យបានរបស់ឬអ្វីៗដែលគេដាក់ឱ្យតថ្លៃបាន ដែលរបស់ខ្លះទាមទារថ្លៃខ្ពស់ ឯរបស់ខ្លះទាមទារឱ្យបានក្នុងតម្លៃថោក ។
- ប្រាមោទ្យ (ន) : សេចក្ដីរីករាយ សេចក្ដីពេញចិត្តខ្លាំង ។
- ស្កឹមស្កៃ (គុ) : ធំខ្ពស់សម្បើម ធំធេងល្វឹងល្វើយ ធំល្វល្វេវ ។
- ដង្កៅ (ន) : មេជំនួញ ។
- កេង (កិ) : កាត់តម្រួយដេញគំនិតគ្នា ។
- ទុច្ចរិត (ន) : ដំណើរប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត ។
- ស្រស់ប៉ប្រៃ (គុ) : ស្រស់រីករាយ ស្រស់ស្រឡះស្រឡំ ។
- គយគន់ (កិ) : ចាំមើល ឃ្លាំមើល ។
- សោភណភាព (ន) : ភាពល្អ ប្រសើរក្រៃលែង ។
- ទ័ល (គុ) : ដែលក្រីក្រទ្រព្យ ខ្សត់ទ្រព្យ ។
- បញ្ញត្តិ (ន) : ការហាមប្រាម បម្រាម សេចក្ដីដែលគេតែងតាំងរៀបចំពាក្យដែលគេកំណត់ហៅ ។
- បន្លាស់ (ន) : អំពើដែលផ្លាស់ ឬអ្វីៗដែលផ្លាស់ជាជំនួសគេ ។

- ងោកងុយ (កិ) : ជ្រប់ងប់ដោយងងុយដេក ឱនចុះទាំងក្បាលទាំងខ្លួនពាក់កណ្ដាល ។
- គណៈកម្មាធិការ (ន) : សមាជិកមួយក្រុមដែលតាំងឡើងក្នុងក្រសួងរាជការ ឬក្នុងសភា ដើម្បីឱ្យប្រតិបត្តិ សម្រេចការណាមួយ ។
- ស៊ីញេ (កិ) : ចុះហត្ថលេខា គឺសរសេរឈ្មោះខ្លួន ដោយដៃខ្លួនឯងតាមចំណាំដែលធ្លាប់តែសរសេររៀងមក យ៉ាងណាក៏ដោយឱ្យនៅជាយ៉ាងណានោះ ។

## ខ. អភិវឌ្ឍន៍បំណិន

ដើម្បីទទួលលទ្ធផលល្អ ក្នុងការអានអ្នកគប្បីយកចិត្តទុកដាក់ត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹងគំនិតសំខាន់ក្នុងអត្ថបទ បង្ហាញគោលបំណង ខ្លឹមសារសំខាន់ៗ ។

## គ. អត្ថបទ

[...] ថ្ងៃមួយនៅពេលជិតដល់ម៉ោងចេញធ្វើការ គាត់ចូលមកជួបនឹងលោកបាលដ្ឋក្នុងបន្ទប់ការិយាល័យ ។ គាត់លុតជង្គង់ ហើយលើកដៃប្រណម្យដាក់ខ្លួនយ៉ាងទាប ។ លោកបាលដ្ឋដែលជាអ្នកពុំចូលចិត្តនឹងការលុតក្រាបយ៉ាងនេះក៏ស្ទុះចូលមកទាញដៃថៅកែឱ្យអង្គុយលើកៅអីនៅចំពីមុខគុ ។

ខ្ញុំប្របាទម្ចាស់ហុងឈី (ចាប់និយាយ) អរព្រួចតែម្ដងដោយបានដំណឹងថា ព្រះតេជព្រះគុណម្ចាស់អញ្ជើញមកកាន់តំណែងនេះ ។ ខ្ញុំប្របាទមានមុខរបរបន្តិចបន្តួចសូមជ្រកក្រោមម្លប់បារមីព្រះតេជព្រះគុណផង ។

- កុំមានប្រសាសន៍យ៉ាងនេះមិនត្រូវទេ ខ្ញុំជាអ្នករាជការនៅក្មេងថ្នាក់តូចទាប ហើយទើបមកកាន់ការថ្មីៗពុំអាចមានអំណោយអ្វីជួយលោកបានទេ ។
- ប្រាកដជាជួយបានព្រះតេជគុណ ! ព្រះតេជគុណគង់ជ្រាបស្រាប់ហើយថា ខ្ញុំបាទបានដេញថ្លៃទទួលដេរខោអាវឱ្យពួកប៉ូលីសខេត្ត ។ ឥឡូវនេះ រកសាច់សំពត់ឱ្យបានដូចប៉ាន់រាជការនៅទីនេះពុំបានទេ បើចង់បានតោងទៅភ្នំពេញ ។ ហើយសំពត់កំពុងឡើងថ្លៃយ៉ាងនេះ មុខតែខាតលិចលង់ស្លាប់ហើយ ។
- បើអ៊ីចឹងឱ្យខ្ញុំជួយយ៉ាងម៉េចទៅ?
- ទានប្រោស ! មានសំពត់មួយផ្ទីទៀតពណ៌ខុសពីប៉ាន់បន្តិច តែសាច់ស្រដៀងគ្នាដែរ ។ សូមព្រះតេជគុណពិនិត្យមើលចុះ ។ ថាហើយថៅកែហុងឈី ក៏ទាញយកចំនៀរកំណាត់សំពត់ពីរបែប មកដាក់ផ្ទៀបផ្ទឹមគ្នាឱ្យលោកបាលដ្ឋមើល ។

- ព្រះតេជគុណមើលចុះមិនខុសគ្នាទេ សូម្បីសាច់កំណាត់សំពត់ពីរបែបរបស់ខ្ញុំបាទ ចង់ក្រាស់ជាប់ជាងផង ។

បាលដ្ឋក្មេងស្ទាបពិនិត្យសាច់សំពត់ទាំងពីរធី ដោយប្រុងប្រយ័ត្នស្រាប់តែថៅកែបែរសម្លឹងទៅទ្វារបន្ទប់ឃើញបិទជិតល្អហើយ ទើបទាញស្រោមសំបុត្រមួយខ្សាកពីហោប៉ៅ លើកជូនដោយដៃទាំងពីរទៅមន្ត្រីហើយនិយាយ :

- សូមព្រះតេជគុណជួយសង្គ្រោះចុះ ខ្ញុំប្របាទមិនភ្លេចព្រះតេជគុណទេ ។
- ទីឃាវុធដោយមិនដឹងឧបាយកលអ្នកសូកប៉ាន់ ក៏សួរដោយស្មោះត្រង់:
- ស្រោមសំបុត្រអីនេះ?

ហុងឈី ដែលក្រោកឈរបម្រុងនឹងចេញទៅហើយនោះ ក៏ឆ្លើយដោយអៀនប្រៀនថា ជាសេចក្តីសាសព្ទបំភ្លឺស្ថានការណ៍របស់ខ្លួន ក្នុងរឿងដេញថ្លៃ ។ អ្នកម៉ៅការបានបន្ថែម:

- សូមព្រះតេជគុណ យកសំបុត្រនេះទៅពិចារណាឯផ្ទះផងចុះ ព្រោះឥឡូវនេះហួសម៉ោងធ្វើការរបស់ព្រះតេជគុណហើយ ។ ខ្ញុំប្របាទសូមក្រាបប្រណិប័តន៍លាហើយ ។

ដោយល្ងាចនេះ ខ្លួនបានជាប់ណាត់ជួបនឹងប្រាមោទ្យ ថានឹងជិះទោចក្រយានលំហែតាមដងស្ទឹង ទីឃាវុធក៏ប្រមូលស្រោមសំបុត្រ និងប៉ាន់សំពត់ទាំងពីរបែប ដោយបន្ទាន់ដាក់ក្នុងកាតាបយួរ ។ តែនឹកឆ្ងល់ក្នុងចិត្តថា សេចក្តីអធិប្បាយអីក៏វែងម្ល៉េះ ស្រោមឡើងកំប៉ោងតែម្តង ។

នាម៉ឺនកំលោះទាំងពីរជិះកង់ទន្ទឹមគ្នាជើងធាក់ឈ្នាន់យ៉ាងបន្ថើរៗភ្នែកគន់មើលទេសភាពតាមមាត់ស្ទឹង ក្នុងពេលដែលព្រះអាទិត្យជិតអស្តង្គត ។ រាងកាយនារីខ្លះ ដែលកំពុងអង្គុយត្រាំទឹកហ្វូរ ក្នុងនទីនាំឱ្យទីឃាវុធរំជួលចិត្តកួចនឹកដល់គូប្រចាំចិត្ត ដែលឃ្លាតទៅឆ្ងាយ ។

ជួនជាបានទៅដល់កូនរានទំនេរមួយ ដែលជ្រកក្រោមអំពិលមួយដើមធំស្កឹមស្កៃ មិត្តទាំងពីរក៏ចុះពីទោចក្រយានទៅអង្គុយសន្ទនា ពីនេះបន្តិចពីនោះបន្តិច ។ ជម្រុលនៃការសាសងគ្នាឥតដើមឥតចុងយ៉ាងនេះ បាននាំឱ្យលោកសុភានិយាយពីដង្ហៅហុងឈី "ប្អូន ! ប្អូនដឹងទេផ្ទះប្រក់ក្បឿង នៅត្រើយម្ខាងនោះជាផ្ទះរបស់ដង្ហៅហុងឈី ។ តាប៉ិនេះ រកស៊ីកប់ស៊ីអាំងសម្បើមណាស់ ។ គាត់ទទួលជប់លៀងអ្នករាជការ ដោយឥតរួញរានឹងចាយវាយទេ ។ តែកាលណាគាត់ចាយមួយកាក់ មុខតែគាត់នឹងបានចំណេញមួយរៀល ឬពីររៀល ហើយគាត់ញក់ញីអ្នកក្រីក្រ ។ តើអ្នកណាហ៊ានក្អក បើនាម៉ឺនមិនថាតូច មិនថាធំទេ សុទ្ធតែត្រូវជើងនឹងគាត់អស់ហើយ ។

- យី ! ដល់ប៉ុណ្ណឹងហ្ន៎ ! លោកបាលដ្ឋឆ្ងល់ ។

លោកសុភា បន្ថែមសេចក្តីថា :

ខ្ញុំឮថា គាត់ដេញថ្លៃទទួលដេរខោអាវឱ្យប៉ូលិស ។ ប្អូនចាំមើលចុះមុខតែគាត់យកសំពត់ផ្តេសផ្តាស មិនបានដូចគំរូទេ ។ គេនិយាយលាន់ថាតាប៉ិហុងឈីនេះ កំពុងដើររកទិញសំពត់បាតផ្សារកញ្ចាស់ៗ ផុយគគ្រក់យកទៅដេរដាក់ឱ្យរាជការហើយ ។ ហេតុនេះហើយបានជាគាត់ហ៊ានថ្លៃថោកជាងគេ ។ ទីឃាវុធរៀបនឹងហាមាត់ប្រាប់មិត្តអំពីរឿងដែលខ្លួនបានជួបនឹងអ្នកជំនួញទុច្ចរិតអំបាញ់មិញទៅហើយ ស្រាប់តែមាននារីពីរនាក់រូបរាងស្អាតបាត ហើយតែងខ្លួនស្រស់ប៉ប្រៃ ដើរចេញពីវត្តជិតទីនោះ នាំឱ្យមិត្តទាំងពីរប្រាណឡប់ស្មារតីរវល់តែគយគន់ទៅវិញ ។ លុះនាងក្រមុំបែរក្រោយផុតពីមុខទៅ នាម៉ឺនកំលោះភ្លេចរឿងដើម ក៏នាំគ្នាពិចារណាផ្ទៀបផ្ទឹមតែពីសោភណភាពកញ្ញាដែលទើបតែនឹងបត់ចូលផ្ទះ ។ នាម៉ឺនកំលោះទាំងពីរក៏ត្រឡប់មកផ្ទះវិញ ។ ពេលយប់ទីឃាវុធដេកនឿលបើកភ្នែកភ្លឹះៗព្រោះទាល់ចំណេះ រកដេកឱ្យលង់លក់ពុំបាន ព្រោះប្រាក់៥០០រៀលច្រកក្នុងស្រោមសំបុត្រដែលហុងឈីបានប្រគល់ឱ្យមកដោយកុហកថាជាសេចក្តីអធិប្បាយពន្យល់នោះ ជះចំហាយក្តៅដូចរងើកភ្លើង ។ ថ្វីបើសេចក្តីសុចរិត សេចក្តីស្លូតត្រង់របស់បាលដ្ឋខេត្តថ្មី ពុំមានអ្វីនាំឱ្យសៅហ្មងដល់តូចមួយសោះឡើយ តែក្តីទីទ័លក្រនាំបង្វិលខួរឱ្យរវាតចិត្តម្តងៗពីផ្លូវត្រង់មួយភ្លែតដែរ ។ អ្នកកំលោះជញ្ជឹងក្នុងចិត្ត បើអញទទួលយកទៅម្ល៉េះសមអញនឹងសងជំពាក់ប្រាក់ដែលបានខ្ចីពួកម៉ាកយកមកទិញប្រដាប់ប្រដាផ្សេងៗបានរួចស្រឡះ ។ រំពឹងលើប្រាក់ខែឯណាកើត បានត្រឹមតែ៤៦រៀលកាត់ថ្លៃបាយ ឈ្នួលផ្ទះ ថ្លៃគុយទាវ ឈ្នួលបោកខោអាវចេញមួយខែៗនៅសល់មិនបាន៥ រៀលផង ។

ប៉ុន្តែ មានគំនិតមួយទៀតលេចធ្លោឡើង បើអញទទួលយកសំណូកនេះទៅប៉ូលិសដែលតែងទទួលបញ្ញត្តិឱ្យស្លៀកពាក់ខោអាវនេះ បានមួយឆ្នាំមុខជាវេទនាធំហើយ ។ ស្លៀកពាក់ឱ្យជាប់យូរឯណាកើត បើផុយតាំងពីថ្មីទៅហើយ ។ ពីរខែមិនទាន់ទេ មុខជារហែកខ្ទេច ។ ត្រូវកុំភ្លេចថា គ្នាតែងដើរហត់នឿយណាស់ ។ ឯកសណ្ឋាននេះ លុះត្រូវញើសត្រូវភ្លៀងក៏កាន់តែត្រូវអន្តរាយរហ័សទៀត ។ ប៉ូលិសនោះម្នាក់ៗបានប្រាក់ខែតែ ១២រៀលទេ ។ បើមិនចង់ដើរផ្លូវទុច្ចរិតទេមុខតែបង្អត់បង្អះប្រពន្ធកូនហើយ ទើបសន្សំប្រាក់មកកាត់ដេរបន្លាស់ថ្មីបាន ។ គិតសព្វៗទៅ មិនត្រូវសប្បាយតែម្នាក់ឯងហើយឱ្យមនុស្ស៥០០នាក់ទៀត វេទនាដោយសារខ្លួនឯងយ៉ាងនោះសោះឡើយ ។ ម្យ៉ាងទៀតខ្លួនបានតាំងចិត្តពីសាលាមកថា ស្អប់អំពើពុករលួយណាស់មិនគប្បីលះបង់ឧត្តមគតិខ្លួន តាំងពីដើមមកយ៉ាងនេះទេ ។

លុះបានសម្រេចចិត្តយ៉ាងនេះហើយ មន្ត្រីកំលោះក៏ចូរទ្រូងភ្លាម "ព្រឹកនេះអញនឹងហៅហុងឈី ឱ្យយកប្រាក់ចង្រៃនេះទៅវិញចុះ អញមិនត្រូវការទេ!" ។ ដោយកម្លាំងនៃសេចក្ដីពេញចិត្តនឹងខ្លួនឯងយ៉ាងនេះ ទីឃាវុធក៏ងោកងុយរកដំណេកភ្លាម ។ [...]

តាំងពីទីឃាវុធបានប្រគល់ប្រាក់៥០០រៀលឱ្យហុងឈីវិញ ពីរខែកន្លងផុតទៅហើយ ។ ក្នុងពេលចូលមកជួបនឹងលោកបាលដ្ឋលើកក្រោយនោះ ឈ្មួញទុច្ចរិតបានធ្វើមុខក្រមូវ ហាក់ដូចជាចង់និយាយ "យីអានេះចំជាភ្លើមែន ! គេយកនំមកឱ្យស៊ីហើយ នៅមិនចេះស៊ីទៀត ។ មិនអីទេអានាង ! ចាំមើលចុះគង់តែអញបានសម្រេចដូចប្រាថ្នាទេ" ។ តែទីឃាវុធ ដោយពេលនោះជាប់រវល់ការងារទៀតច្រើន ក៏ពុំបានចាប់អារម្មណ៍នឹងកិរិយាព្រហើនកោងកាចនេះឡើយ ។ ក្នុងចិត្តគិតថា មុខតែក្រុមប៉ូលិសនឹងបានសម្លៀកបំពាក់ធ្វើដោយសំពត់ស្វិត ហើយជាប់បានយូរដូចរាជការកំណត់តាមគំរូមកហើយ ។

ថ្ងៃមួយក្នុងខែឧសភា គឺក្នុងពេលដែលអ្នកម៉ៅការជិតត្រូវយកឯកសណ្ឋានប៉ូលិសមកជូនរាជការស្រាប់តែប្លង់តុងចូលមកជម្រាបលោកបាលដ្ឋថា ទានថៅហ្វាយខេត្តត្រូវការជួប ។ ដើម្បីតបនឹងសេចក្ដីគោរពនៃសហការី "ប្របាទម្ចាស់" ថៅហ្វាយខេត្តគ្រាន់តែងក់ក្បាល ហើយធ្វើមុខមាំដាក់ឱ្យ ៖

- វុធ ! វុធ ឯងជាប្រធានគណៈកម្មាធិការទទួលខោអាវប៉ូលិស អាទិត្យក្រោយនេះ គេនឹងនាំរបស់ទាំងនោះយកមកឱ្យពិនិត្យហើយ ។ [...]

មួយស្របក់ក្រោយមក "ប្របាទម្ចាស់" ហើយថៅហ្វាយខេត្តនិយាយថែម :

- ...យល់ថា ស៊ីញ៉េទទួលយកបាន ។
- ទានប្រោស ! សំពត់ហុងឈីនោះមិនល្អទេ ផុយណាស់ក្រែងតែថៅកែទិញសំពត់ផ្សេងៗ ហើយមានសាច់ស្វិតជាប់ជាងដែលយកមកឱ្យខ្ញុំប្របាទម្ចាស់ពិនិត្យនោះពុំដឹង ។
- គ្មានកំណាត់ឯណាថ្មីទៀតទេ ... ឃើញថាគួរសមល្មមហើយ ។
- ទានប្រោស !បើសំពត់កំផុយដដែលទេ ខ្ញុំប្របាទម្ចាស់មិនហ៊ានចុះហត្ថលេខាទទួលយកទេ ។

ព្រោះកំហឹងចូលមកជ្រួតជ្រាប លោកថៅហ្វាយខេត្តព្រមានដោយមុខក្រញូវ :

- វុធឯងខ្ពីសេចក្ដីណាស់ ម៉េចក៏ក្អេងក្អាងដល់ម្លឹង !

- ទានប្រោសទេ ! ខ្ញុំប្របាទម្ចាស់យល់ឃើញថា បើព្រមទទួលរបស់ផុយពព្រិចយ៉ាងនេះទៅមុខជានាំឱ្យខូចប្រយោជន៍រាជការផង ហើយខូចប្រយោជន៍ប៉ូលិសផង ព្រោះមិនឋិតថេរបានប៉ុន្មានថ្ងៃទេ ។

ចៅហ្វាយខេត្តច្រឡោតតូង :

- យី ! ក្មេងនេះ ពុំទាន់បាត់ធុំក្លិនទឹកដោះផង ហ៊ានមកប្រដៅឯង ។ ទៅចុះមិនបាច់ជួបមុខយូរទៅទៀតទេ ។

ពីរម៉ោងក្រោយមក ទីឃាវុធ ក៏បានទទួលលិខិតបង្គាប់ឱ្យទៅដើរត្រួតពិនិត្យពន្ធ ដែលទារបានតាមឃុំនានាក្នុងស្រុកបាកាន និងក្រគរ ។ នេះជាទណ្ឌកម្មចំពោះទីឃាវុធ តែទីឃាវុធ ខ្ញុំមិនខ្វល់នឹងអ្វីទាំងអស់ ខ្ញុំមិនលះបង់ឧត្តមគតិល្អទេ ។

*(ដកស្រង់និងសម្រួល ចេញពីរឿងមាលាដួងចិត្តរបស់អ្នកនិពន្ធ "នូហាច" ឆ្នាំ១៩៧២)*

## សំណួរ

១. ហេតុដូចម្តេចបានជាចៅកែ យកលុយមកឱ្យលោកបាលដ្ឋទីឃាវុធ ?

២. តើទីឃាវុធសម្រេចចិត្តត្រូវឬខុស ក្នុងការប្រគល់ប្រាក់ឱ្យទៅចៅកែវិញ ? ហេតុអ្វី ?

៣. តើអំពើរបស់លោកចៅហ្វាយខេត្តក្នុងអត្ថបទនេះ ជាអំពើយ៉ាងដូចម្តេច ?

៤. តាមរយៈអត្ថបទនេះ បានផ្តល់តម្លៃអប់រំយ៉ាងណាខ្លះចំពោះអ្នក ?

៥. ក្នុងចំណោមតួអង្គទាំងបីខាងលើនេះ តើអ្នកពេញចិត្តតួអង្គណាមួយ ? ហេតុអ្វី ?

៦. ដោយផ្សារភ្ជាប់ជាមួយនឹងសកម្មភាពតួអង្គខាងលើនេះ តើអ្នកមានគោលជំហរយ៉ាងណាខ្លះក្នុងការប្រកាន់ច្បាប់របស់សង្គម ?

៧. ចូរពន្យល់ន័យតាមសេចក្តី នៃសំនួនសេចក្តី :

- អ្នកណាហ៊ានក្អក
- ត្រូវជើង ។

# រំលឹកបញ្ញត្តិ

- ពាក្យន័យដូច គឺជាពាក្យទាំងឡាយណាដែលមានន័យដូច ឬប្រហាក់ប្រហែលគ្នា តែសំណេរ និងសំណួរពុំដូចគ្នាទេ ។ ពាក្យន័យដូច ក៏ជាប្រភេទមួយ នៃពាក្យដែលមានន័យកំណត់ដោយទីសេចក្ដីដែរ មានន័យថា អាចជ្រើសរើសពាក្យន័យដូច ណាមួយមកប្រើបានអាស្រ័យនឹងការកំណត់របស់សេចក្ដី ។

*ឧទាហរណ៍ :*

| **ពាក្យ** | **ន័យដូច** |
|---|---|
| - ចម្រើន | - លូតលាស់ |
| - ឧបត្ថម្ភ | - ជួយ គាំទ្រ |
| - និពន្ធ | - តែង |
| - ញ៉ាំ | - ស៊ី សោយ ឆាន់ ... ។ |

- ពាក្យផ្ទុយ គឺជាពាក្យទាំងឡាយដែលមានន័យប្រឈមគ្នា ឬផ្ទុយគ្នា ។ ពាក្យន័យផ្ទុយ ក៏ជាប្រភេទមួយទៀតនៃពាក្យ ដែលមានន័យកំណត់ដោយទីសេចក្ដីដែរ ។

ឧទាហរណ៍ :

| **ពាក្យ** | **ន័យផ្ទុយ** |
|---|---|
| - បុរាណ | - ទំនើប |
| - ស្រួច | - ទាល |
| - ស្រស់ | - ស្រពោន |
| - សរសើរ | - បង្អាប់ ។ |

- ទីសេចក្ដី គឺជាកន្សោមពាក្យនៅក្នុងល្បះ ឬកថាខណ្ឌ ដែលជួយយើងឱ្យយល់ន័យរបស់ពាក្យណាមួយក្នុងល្បះ ឬកថាខណ្ឌ ឬឱ្យយើងអាចអានពាក្យបានត្រឹមត្រូវ ។

*ឧទាហរណ៍ :*

- វាប្រឡាក់ *ស្រមក* ពាសពេញខ្លួនប្រាណ ។

([ស្រ-ម៉ក]ដែលប្រឡាក់កខ្វក់ប្រឡាក់ភក់ស្រមក) ។

- ពួកគេប្រដាប់ដោយអាវុធគ្រប់ដៃរត់*ស្រ មក* តម្រង់មកពួកយើង ។

([ស្រ-មក ]ដែលរហ័សលឿនតែរយៈពេលខ្លីក្នុងការធ្វើសកម្មភាពណាមួយស្រុះគ្នា ស្មើគ្នា) ។

# កាលរបស់កិរិយា អតីតកាល បច្ចុប្បន្ន អនាគតកាល

កិរិយានៅក្នុងភាសាខ្មែរ ពុំមានការផ្លាស់ប្ដូររូបរាងតាមកាលវេលាឡើយ ។ ប៉ុន្តែយើងដឹងកាលរបស់កិរិយា អាស្រ័យដោយពាក្យប្រាប់កាល និងជំនួយកិរិយាដែលប្រើប្រាស់ជាមួយកិរិយានោះផ្ទាល់តែម្ដង ។

ចូរអ្នកធ្វើការសង្កេតឧទាហរណ៍ទាំងបីខាងក្រោមនេះ ដើម្បីស្វែងយល់ពីកាលរបស់កិរិយា :

*ឧទាហរណ៍ទី ១ :*

១. យើងបានអនុវត្តច្បាប់ចរាចរណ៍ ។

២. កាលពីម្សិលមិញ យើងបានសិក្សាពីបទបញ្ជាផ្ទៃក្នុង ។

៣. កាលពីថ្ងៃមុនគាត់បានបង្រៀនយើងពីសិទ្ធិមនុស្ស ។

*អតីតកាលក្នុងភាសាខ្មែរបញ្ជាក់កាលកន្លងទៅដែលអ្នកនិយាយលើកយកមកនិយាយដោយប្រើរបៀបបីយ៉ាង :*

- *ប្រើជំនួយកិរិយាប្រាប់អតីតកាល "បាន" ដែលមានទីតាំងនៅខាងដើមកិរិយា ។*
- *ប្រើពាក្យប្រាប់អតីតកាលដូចជា ឆ្នាំមុន ម្សិលមិញ ឆ្នាំទៅ ... ។*
- *ប្រើពាក្យសម្គាល់អតីតកាលឬជំនួយកិរិយា "បាន" ព្រមជាមួយនឹងពាក្យប្រាប់អតីតកាលតែម្ដង ។*

*ឧទាហរណ៍ទី ២ :*

១. យើងទាំងអស់គ្នា កំពុងសិក្សាច្បាប់ចរាចរណ៍ ។

២. ឥឡូវនេះ លោកគ្រូពន្យល់ពីបទបញ្ជាផ្ទៃក្នុងរបស់សាលា ។

៣. ព្រឹកនេះ សិស្សានុសិស្សកំពុងតែស្វែងយល់ពីជំងឺផ្ដាសាយថ្មី ។

៤. សិស្សខ្លះគូររូបរោគសញ្ញាផ្ដាសាយថ្មី សិស្សខ្លះទៀតសម្ដែងតួក្នុងឈុតជួយសង្គ្រោះជនរងគ្រោះ ។

*បច្ចុប្បន្នកាលក្នុងភាសាខ្មែរបញ្ជាក់ពេលវេលាមិនទាន់កន្លងទៅ ឬកំពុងប្រព្រឹត្តទៅ ដែលកំពុងនិយាយដោយប្រើរបៀបបួនយ៉ាង :*

- *ប្រើជំនួយកិរិយាប្រាប់បច្ចុប្បន្នកាល "កំពុងឬកំពុងតែ" ។*
- *ប្រើពាក្យប្រាប់ពេលវេលាបញ្ជាក់ពីបច្ចុប្បន្នកាលដូចជា ឥឡូវនេះ ពេលនេះ ថ្ងៃនេះ ។*
- *ប្រើជំនួយកិរិយាកំពុង កំពុងតែ ព្រមជាមួយនឹងពាក្យប្រាប់បច្ចុប្បន្នតែម្ដង ។*
- *ជួនកាលគេអាចបញ្ជាក់បច្ចុប្បន្នកាល ដោយកិរិយាទោលតែឯង ឬទីសេចក្ដី ។*

*ឧទាហរណ៍ទី ៣ :*

១. ខ្ញុំនឹងរៀនច្បាប់បើកបររថយន្ត ។

២. បងខ្ញុំទៅអង្គរវត្ត នៅខែក្រោយ ។

៣. នាយកសាលាខ្ញុំនឹងផ្សព្វផ្សាយពីវិធានការការពារជំងឺផ្ដាសាយថ្មី នៅសប្ដាហ៍ក្រោយនេះ ។

*អនាគតកាលក្នុងភាសាខ្មែរបញ្ជាក់ពីកាលវេលាខាងមុខដែលនឹងមានសកម្មភាពដោយមានរបៀបបីយ៉ាង :*

- *ប្រើជំនួយកិរិយាប្រាប់អនាគតកាល "នឹង" នៅខាងដើមកិរិយា ។*
- *ប្រើពាក្យប្រាប់អនាគតកាលដូចជា អាទិត្យក្រោយ ថ្ងៃក្រោយ ស្អែក ... នៅខាងដើម ឬខាងចុងល្បះ ។*
- *ប្រើជំនួយកិរិយា "នឹង" ព្រមជាមួយនឹងពាក្យប្រាប់អនាគតកាលតែម្តង ។*

## លំហាត់

១. ចូរអ្នកប្ដូរល្បះខាងក្រោមនេះពីបច្ចុប្បន្នកាល ឱ្យទៅជាល្បះអតីតកាល :

- ភ្ញៀវទេសចរកំពុងទៅទស្សនាប្រាសាទអង្គរវត្ត ។
- រាជរដ្ឋាភិបាលកំពុងឱ្យប្រជារាស្ត្របណ្ដាក់ទុនសម្រាប់ប្រកបមុខរបរកសិកម្ម ។
- សិស្សានុសិស្សកំពុងសិក្សាភាសាខ្មែរ ។

២. ចូរអ្នកឆ្លើយនឹងសំណួរខាងក្រោមនេះ ដោយប្រើជំនួយកិរិយានិងពាក្យប្រាប់បច្ចុប្បន្នកាលរបស់កិរិយា :

- តើថ្ងៃនេះ អ្នកធ្វើកិច្ចការអ្វីខ្លះក្នុងគ្រួសារអ្នក ?
- តើសព្វថ្ងៃនេះ យើងមានកាតព្វកិច្ចអ្វីខ្លះ ដើម្បីការពារបេតិកភណ្ឌជាតិ ?
- តើនៅប្រទេសយើង នាពេលបច្ចុប្បន្ននេះ មានសត្វព្រៃរស់នៅតំបន់ណាខ្លះ ?

៣. ចូរអ្នកគូសពីក្រោមពាក្យជំនួយកិរិយានិងពាក្យប្រាប់អនាគតកាល នៅក្នុងល្បះខាងក្រោមនេះ

- ខ្ញុំនឹងធ្វើលិខិតអញ្ជើញលោកគ្រូឱ្យមកចូលរួមក្នុងពិធីជប់លៀងមួយ ។ ខ្ញុំសង្ឃឹមថា លោកគ្រូនឹងអញ្ជើញមកជាមិនខាន ។
- លោកគ្រូនឹងបង្រៀនមេរៀន "ការគោរពសិទ្ធិ" នៅថ្ងៃស្អែក តែពេលនេះ គ្រូដាក់សំណួរសរសេរមួយ ដើម្បីជាគំនិតសម្រាប់ថ្ងៃស្អែក ។
- គ្រួសារខ្ញុំនឹងទៅទស្សនាប្រាសាទអង្គរវត្តនៅថ្ងៃសម្រាកខាងមុខនេះ ។



# សេចក្តីប្រកាសព័ត៌មាន



## ក. សិក្សាពាក្យគន្លឹះ

- ក្រសួងធនធានទឹក (ន) : ឈ្មោះស្ថាប័នរបស់ក្រសួងមួយ ដែលមានភារៈក្នុងការទទួលបន្ទុកលើធនធានទឹក ។
- ឧតុនិយម (ន) : ឈ្មោះក្រសួងដែលទទួលភារៈព្យាករណ៍ ដើម្បីកំណត់ព័ត៌មានដែលទាក់ទងទៅនឹងធម្មជាតិ ជូនជាដំណឹង ។
- កុងស៊ុន(CONSON) (ន) : ឈ្មោះព្យុះបានកើតឡើងនៅសមុទ្រប៉ាស៊ីហ្វិក កាលពីថ្ងៃ ១១ ខែកក្កដា ឆ្នាំ ២០១០កន្លងមក ។
- តំបន់ខ្ពង់រាប (ន) : តំបន់ភ្នំ ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានសេចក្ដីប្រកាសព័ត៌មាននេះ អ្នកគប្បីអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹងគោលបំណង ខ្លឹមសារសំខាន់ៗនៃសេចក្ដីប្រកាសនិងទម្រង់ទូទៅនៃសេចក្ដីប្រកាសព័ត៌មានតាមអត្ថបទគំរូ ។

## គ. អត្ថបទ

### កម្ពុជារងឥទ្ធិពលព្យុះនៅតំបន់មាត់សមុទ្រ រលកកម្ពស់ ១ទៅ ២ម៉ែត្រ ខ្ពង់រាបខាងជើងនិងឦសានភ្លៀងច្រើន

រាជធានីភ្នំពេញ : សេចក្ដីជូនដំណឹងរបស់ក្រសួងធនធានទឹកនិងឧតុនិយម បានឱ្យដឹងថា បន្ទាប់ពីបានធ្វើការសង្កេតតាមដានលើស្ថានភាពធាតុអាកាសរួចមកឃើញថា ព្យុះទី ២ឈ្មោះ កុងស៊ុន (CONSON) ដែលបានកើតឡើងនៅសមុទ្រប៉ាស៊ីហ្វិក កាលពីថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០១០កន្លងមក បានធ្វើដំណើរឆ្លងកាត់ប្រទេសហ្វីលីពីន មកសមុទ្រចិនខាងត្បូង និងកំពុងបន្តដំណើរកាត់លើកោះហាយណាំ ឆ្ពោះទៅភាគខាងត្បូងប្រទេសចិន ។

ព្យុះនេះនឹងមានឥទ្ធិពលមកលើព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី១៦ដល់ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០១០ពិសេសនៅតំបន់មាត់សមុទ្រ តំបន់ខ្ពង់រាបខាងជើង និងតំបន់ខ្ពង់រាបភាគឦសាន ។ ស្ថានភាពបែបនេះនឹងបង្កឱ្យមានភ្លៀងធ្លាក់ច្រើននិងខ្យល់បក់បោកខ្លាំងនៅតំបន់មាត់សមុទ្រមានខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកំពត ។ ឯរលកសមុទ្រមានកម្ពស់ពី ១ទៅ ២ម៉ែត្រ ។

ដោយឡែក ចំពោះខេត្តព្រះវិហារ ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តក្រចេះ និងខេត្តស្ទឹងត្រែងអាចនឹងមានភ្លៀងធ្លាក់ច្រើន ។ សេចក្ដីជូនដំណឹងនេះ បានស្នើឱ្យអាជ្ញាធរដែនដី ប្រជាពលរដ្ឋដែលរស់នៅតំបន់ខាងលើ ពិសេសប្រជានេសាទតាមតំបន់សមុទ្រ សូមជ្រាបជាព័ត៌មាននិងមានការប្រុងប្រយ័ត្នខ្ពស់ចំពោះបាតុភូតធម្មជាតិខាងលើនេះ ។ ក្រសួងធនធានទឹកនិងឧតុនិយមបាននិងកំពុងតាមដានស្ថានភាពអាកាសធាតុខាងលើនេះ ហើយនឹងធ្វើសេចក្ដីជូនដំណឹងបន្ថែមទៀត ក្នុងករណីដែលស្ថានភាពរបស់ព្យុះនេះមានកាលប្រែប្រួល ។[១]

---

*1 : http: //kohsantepheapdialy.com.kh/category/entertainment/ស្រាវជ្រាវ.html*

## សំណួរ

១. តើស្ថាប័នណា ជាអ្នកធ្វើសេចក្តីប្រកាសព័ត៌មាននេះ ? តើប្រកាសពីបញ្ហាអ្វី ?

២. តើអត្ថបទនៃសេចក្តីប្រកាសព័ត៌មាននេះ ស្រង់មកពីប្រភពណា ?

៣. តើសេចក្តីប្រកាសព័ត៌មាន ធ្វើឡើងដើម្បីនរណា ?

៤. ចូរអ្នកធ្វើការបង្ហាញពីខ្លឹមសារនៃសេចក្តីប្រកាសព័ត៌មាន តាមបម្រាប់ខាងក្រោម :

- ចំនួនកថាខណ្ឌនៃសេចក្តីប្រកាសព័ត៌មាន ។
- ខ្លឹមសារសំខាន់ៗក្នុងកថាខណ្ឌនីមួយៗ ។
- ផលវិជ្ជមាននៃសេចក្តីប្រកាសព័ត៌មាននេះ ចំពោះជីវភាពប្រជាពលរដ្ឋ ។

៥. ចូរបង្ហាញទម្រង់នៃសេចក្តីប្រកាសព័ត៌មានតាមគំរូនៃសេចក្តីប្រកាសព័ត៌មានខាងលើ ។

# សេចក្ដីជូនដំណឹងពីការជ្រើសរើសបុគ្គលិក



អ្នកបានសិក្សារួចមកហើយអំពីសេចក្ដីប្រកាសព័ត៌មាន ។ ឥឡូវនេះអ្នកនឹងបានស្ដាប់នូវសេចក្ដីជូនដំណឹងអំពីការជ្រើសរើសបុគ្គលិក ដែលគ្រូរបស់អ្នកនឹងអានឱ្យអ្នកទាំងអស់គ្នាស្ដាប់ ។ ចូរអ្នកកត់ត្រាចំណុចសំខាន់ៗរួចឆ្លើយនឹងសំណួរខាងក្រោម ៖

១. តើស្ថាប័នណាជាអ្នកប្រកាសជ្រើសរើសបុគ្គលិកនេះ ?

២. តើស្ថាប័នមានលក្ខខណ្ឌដូចម្ដេចខ្លះក្នុងការជ្រើសរើសនេះ ?

៣. តើស្ថាប័ននេះត្រូវការជំនាញអ្វីខ្លះ ?

៤. តើមានការកំណត់កាលបរិច្ឆេទឈប់ទទួលពាក្យសុំចុះឈ្មោះដែរឬទេ ?

៥. ចូរបង្ហាញចំណុចសំខាន់ៗនៃសេចក្ដីជូនដំណឹងនោះ ។

៦. នៅពេលអ្នកត្រលប់ទៅផ្ទះវិញ ចូរអ្នកស្វែងរកព័ត៌មានទាក់ទងនឹងសេចក្ដីប្រកាសព័ត៌មាននិងសេចក្ដីជូនដំណឹងផ្សេងៗដើម្បីចែករំលែកព័ត៌មានទាំងនោះដល់មិត្តភក្ដិក្នុងថ្នាក់ ។



# រៀបរាប់ព័ត៌មានអំពីសេចក្តីប្រកាសព័ត៌មានឬសេចក្តីជូនដំណឹង

អ្នកបានសិក្សារួចមកហើយពីសេចក្តីប្រកាសព័ត៌មាននិងសេចក្តីជូនដំណឹងជ្រើសរើសបុគ្គលិក ។ ទន្ទឹមនឹងនោះ អ្នកក៏បានស្វែងរកព័ត៌មានពីសេចក្តីប្រកាស ឬសេចក្តីជូនដំណឹងផ្សេងៗរួចមកហើយដែរ ។ ឥឡូវនេះ ចូរអ្នកនិយាយប្រាប់មិត្តភក្តិនិងលោកគ្រូ អ្នកគ្រូរបស់អ្នកនូវព័ត៌មានដែលអ្នកបានដឹងទាក់ទងនឹងសេចក្តីប្រកាសព័ត៌មានឬសេចក្តីជូនដំណឹងផ្សេងៗ ។ នៅពេលអ្នកនិយាយ អ្នកគប្បីយកចិត្តទុកដាក់លើ :

## ១ . ប្រភពព័ត៌មាន (កាសែត ទស្សនាវដ្តី វិទ្យុ ទូរទស្សន៍ ...)

## ២ . ខ្លឹមសារ

### ក. ខ្លឹមសារនៃសេចក្តីប្រកាស

- តើស្ថាប័នណាជាអ្នកធ្វើសេចក្តីប្រកាសព័ត៌មាននេះ ?
- តើស្ថិតនៅក្នុងកាលៈទេសៈណាទើបគេធ្វើសេចក្តីប្រកាសព័ត៌មាន ?
- តើមូលហេតុអ្វីបានជាគេធ្វើសេចក្តីប្រកាសព័ត៌មាន ?
- តើគេប្រកាសព័ត៌មានទៅនរណា ?
- តើអ្នកធ្វើសេចក្តីប្រកាសព័ត៌មាន មានការណែនាំឬសំណូមពរដែរឬទេ ? ហេតុអ្វី ?
- តើមានអ្នកទទួលខុសត្រូវឬចុះហត្ថលេខាលើសេចក្តីប្រកាសព័ត៌មានឬទេ ?

### ខ. ខ្លឹមសារនៃសេចក្តីជូនដំណឹង

- តើស្ថាប័នណាជាអ្នកធ្វើសេចក្តីជូនដំណឹង ?
- តើមូលហេតុអ្វីបានជាគេធ្វើសេចក្តីជូនដំណឹង ?
- តើគេជូនដំណឹងទៅនរណា ?
- តើមានអ្នកទទួលខុសត្រូវឬទេនៅក្នុងសេចក្តីជូនដំណឹង ?

## លំហាត់

១. ចូរអ្នកនិយាយបង្ហាញឡើងវិញពីសេចក្ដីប្រកាសព័ត៌មានរបស់ក្រសួងមានសមត្ថកិច្ចទាក់ទងនឹងបញ្ហាគ្រោះធម្មជាតិ ឬបញ្ហាក្នុងសង្គម ។

២. ចូរអ្នកបង្ហាញឡើងវិញពីសេចក្ដីជូនដំណឹងជ្រើសរើសបុគ្គលិករបស់ស្ថាប័នណាមួយដោយអនុវត្តតាមលំនាំគំរូខាងក្រោមនេះ ដើម្បីជាជំនួយក្នុងការនិយាយ ៖

**គំរូសេចក្ដីប្រកាសព័ត៌មាន :**

ក. ឈ្មោះក្រសួង មន្ទីរ ស្ថាប័ន ឬអ្នកប្រកាសព័ត៌មាន

ខ. មូលហេតុនៃការធ្វើសេចក្ដីប្រកាស ។ ***ឧទាហរណ៍ :*** មានវិសម្ពាធទាបមួយនៅតំបន់ ... មានព្យុះភ្លៀងខ្លាំងនៅតំបន់ ... បណ្ដាលឱ្យមានទឹកជំនន់ ... ។

គ. មុខសញ្ញាដែលត្រូវទទួលសេចក្ដីប្រកាសព័ត៌មាន ។ ***ឧទាហរណ៍ :*** សាធារណជន ពលរដ្ឋទាំងអស់នៅឯខេត្ត ... តាមមាត់សមុទ្រ ។ល ។

ឃ. ការអំពាវនាវ

- ទាញបម្រុងប្រយ័ត្ន: ត្រៀមលក្ខណៈ កុំធ្វេសប្រហែស ... ។ ***ឧទាហរណ៍ :*** កុំឱ្យកូនចេញទៅក្រៅផ្ទះកុំចេញទៅនេសាទ ត្រៀមស្បៀងអាហារ ... ។
- បង្ហាញវិធានការ : មធ្យោបាយទប់ស្កាត់ឬដោះស្រាយ ... ។ ***ឧទាហរណ៍ :*** រដ្ឋអំណាចមូលដ្ឋាននិងកងកម្លាំងត្រៀមលក្ខណៈជួយសង្គ្រោះប្រជាពលរដ្ឋ រកទីទួលសុវត្ថិភាព ... ។

**គំរូសេចក្ដីជូនដំណឹងពីការជ្រើសរើសបុគ្គលិក :**

ក. ឈ្មោះស្ថាប័ននិងមុខងារតួនាទីអ្នកចេញសេចក្ដីជូនដំណឹង

ខ. មូលហេតុនៃការធ្វើសេចក្ដីជូនដំណឹង

***ឧទាហរណ៍ :*** ត្រូវការជ្រើសរើសបុគ្គលិកទាំងពីរភេទ ...

- ភេទ
- ចំនួន

គ. លក្ខខណ្ឌក្នុងការជ្រើសរើស (អាយុ កម្រិតវប្បធម៌ ...)

ឃ. ការរំលឹក

- ថ្ងៃខែឆ្នាំ ម៉ោង ឈប់ទទួលពាក្យ
- អាសយដ្ឋាននិងលេខទូរស័ព្ទសម្រាប់ទាក់ទង ។

# សំណេរសេចក្តីប្រកាសព័ត៌មាននិងសេចក្តីជូនដំណឹង

អ្នកបានសិក្សារួចហើយអំពីសេចក្តីប្រកាសព័ត៌មាន  សេចក្តីជូនដំណឹងផ្សេងៗរួចមកហើយ ។ ឥឡូវនេះ  ចូរអ្នកសរសេរសេចក្តីប្រកាសព័ត៌មាននិងសេចក្តីជូនដំណឹងដោយជ្រើសរើសប្រធានបទខាងក្រោម :

១. សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងមន្ទីរ ស្ថាប័នទាក់ទងនឹងគ្រោះធម្មជាតិ ទឹកជំនន់ ខ្យល់ព្យុះ ។ល ។

២. សេចក្តីជូនដំណឹងជ្រើសរើសបុគ្គលិករបស់ក្រុមហ៊ុនឬស្ថាប័នណាមួយ ។

អ្នកគប្បីអនុវត្តទៅតាមលំនាំអត្ថបទគំរូនៅក្នុងអំណាននិងលំនាំដែលបានបង្ហាញនៅក្នុងសមត្ថភាពនិយាយ ។

មេរៀនទី
៧

# ការទទួលខុសត្រូវ



ការទទួលខុសត្រូវ ជាឥរិយាបថដ៏ប្រសើរថ្លៃថ្លាសម្រាប់បុគ្គលម្នាក់ៗ ។ ការទទួលខុសត្រូវបង្ហាញឱ្យឃើញតាមរយៈការហ៊ានទទួលយកការពិត ការហ៊ានទទួលយករាល់អំពើរបស់ខ្លួនដែលបានប្រព្រឹត្តទាំងអំពើល្អនិងអំពើអាក្រក់ ។ ប៉ុន្តែ ការចេះកែប្រែកំហុសឆ្គង ការភ្ញាក់រលឹកមករកផ្លូវល្អ យកច្បាប់ជាធំ ជាទង្វើប្រកបដោយឧត្តមភាព ។ ការទទួលខុសត្រូវក៏បង្ហាញឱ្យឃើញផងដែរ តាមរយៈការយកចិត្តទុកដាក់ ផ្ចិតផ្ចង់ មានប្រសិទ្ធភាពលើរាល់សកម្មភាពរបស់បុគ្គលដែលញ៉ាំងឱ្យមានការជឿជាក់ មានទំនុកចិត្តពីអ្នកដទៃនិងសង្គមជាតិ ។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាស្វែងយល់ពីស្មារតីទទួលខុសត្រូវមួយចំនួននិងសិក្សាបន្ថែមទៀតអំពី ការបញ្ចុះបញ្ចូល ការឆ្លើយតបទៅនឹងការបញ្ចុះបញ្ចូល ការញែកព្យាង្គដើម្បីអានពាក្យពហុព្យាង្គ សរសេរអត្ថបទបញ្ចុះបញ្ចូល និងស្គាល់ប្រភេទគុណនាមនិងទីតាំងរបស់វាក្នុងល្បះ ។

# ការញែកព្យាង្គ

ភាសាជាតិយើងមានពាក្យមួយព្យាង្គ ពីរព្យាង្គ និងពាក្យខ្លះមានច្រើនព្យាង្គ។ ពាក្យច្រើនព្យាង្គហៅថា ពាក្យពហុព្យាង្គ។ ពាក្យពហុព្យាង្គដែលជាពាក្យខ្ចី ពីពាក្យបាលីសំស្រ្កឹតមានការលំបាកក្នុងការអាននិងយល់ន័យ។ ដូចនេះដើម្បីងាយអានពាក្យទាំងនោះ យើងត្រូវបំបែកជាព្យាង្គ។ ការបំបែកព្យាង្គនេះហៅថា ការញែកព្យាង្គ។

ចូរពិនិត្យឧទាហរណ៍ :

| ពាក្យ | ចំនួនពាក្យ | ចំនួនព្យាង្គ | ន័យ |
|---|---|---|---|
| ភូមិន្ទ | ភូមិ+ ឥន្ទ្រ | ភូ- មិន | អ្នកធំជាងអស់ប្រជាជនលើផែនដី(ព្រះរាជា) |
| ប្រយោជន៍ | ប្រយោជន៍ | ប្រ- យ៉ោច | ផលដែលសម្រេច , អ្វីៗដែលត្រូវការ |
| យុត្តិធម៌ | យុត្តិ+ ធម្ម | យុត- តិ- ធ័រ | សេចក្ដីត្រឹមត្រូវ ទៀងត្រង់ ការគួរតាមច្បាប់ |
| ពុទ្ធោវាទ | ពុទ្ធ+ ឱវាទ | ពុត- ធោ- វ៉ាត | ដំបូន្មានរបស់ព្រះពុទ្ធ |
| អនុបវាទ | អនុ+ ឧបវាទ | អៈ- នុប- ប៉ៈ- វាទ | ដែលអត់ធ្មត់ , នៅស្ងៀម , មិនស្ដីថា ... |
| យុគលពិន្ទុ | យុគល+ ពិន្ទុ | យុគៈ- លៈ- ពិន- ទុ | ក្រៃលែង , ហ៊ឹកហ៊ាក់ , រុងរឿង ... |
| បច្ចេកវិជ្ជា | បច្ចេកៈ+ វិជ្ជា | ប៉ុច- ចេកៈ- វិច- ជា | វិជ្ជាដោយឡែកៗពីគ្នាផ្នែកខាងសិល្បៈនិងមុខរបរទូទៅ |
| វិចារណកថា | វិចារណ+ កថា | វិ- ចារ- ណៈ- កៈ- ថា | ពាក្យសម្ដីប្រកបដោយហេតុគួរត្រិះរិះ |
| សម្បជញ្ញៈ | សម្បជញ្ញៈ | ស័ម- ប៉ៈជ័ញ- ញ៉ៈ | សេចក្ដីដឹងខ្លួន |
| សតិសម្បជញ្ញៈ | សតិ+ សម្បជញ្ញៈ | ស- តិ- ស័ម- ប៉ៈ- ជ័ញ- ញ៉ៈ | ស្មារតីនិងសេចក្ដីដឹងខ្លួន |

តាមឧទាហរណ៍ខាងលើយើងឃើញថា យើងអាចអានពាក្យច្រើនព្យាង្គបានអាស្រ័យដោយធ្វើការញែកព្យាង្គឱ្យដឹងចំនួនព្យាង្គនិងយល់អត្ថន័យនៃពាក្យ។

ដូចនេះ ការញែកព្យាង្គគឺជាការបំបែកពាក្យដែលមានច្រើនព្យាង្គ ឱ្យទៅជាព្យាង្គដាច់ៗគ្នាដើម្បីងាយស្រួលក្នុងការអាន។

## លំហាត់

១. ចូរចម្លងតារាងខាងក្រោមដាក់ក្នុងសៀវភៅរបស់អ្នក ហើយញែកព្យាង្គដោយប្រាប់ពីរបៀបអាន ចំនួនព្យាង្គ និងនិយមន័យរបស់ពាក្យទាំងនោះផង ។

| ពាក្យ | ចំនួនពាក្យ | ព្យាង្គ | ន័យ |
|---|---|---|---|
| សម្បទា | | | |
| ព័ត៌មាន | | | |
| បិណ្ឌបាត | | | |
| បដិសេធ | | | |
| សមត្ថភាព | | | |
| បរមោវាទ | | | |
| អស្តង្គត | | | |
| សញ្ញាវុធ | | | |

២. ចូរស្រង់ពាក្យពហុព្យាង្គពីក្នុងអត្ថបទខាងក្រោមឱ្យបាន ៥ ពាក្យ រួចធ្វើការញែកព្យាង្គ ដើម្បីអានពាក្យទាំងនោះតាមលំនាំតារាងខាងលើ ។

នៅគ្រប់កាលៈទេសៈ ពលរដ្ឋត្រូវរួមសាមគ្គីគ្នាធ្វើការតបស្នងមាតុភូមិរបស់យើង ។ សិស្ស និស្សិត បញ្ញវន្ត កវីនិពន្ធ សិល្បករ ត្រូវប្រើសមត្ថភាពដែលខ្លួនមាន ផ្សព្វផ្សាយដល់ជនរួមជាតិនូវភាពថ្កុំថ្កើងនៃទឹកដីតាំងពីយុគសម័យបរមបុរាណ ។ ធម្មជាតិ ទឹកដី វប្បធម៌ ប្រពៃណីដ៏ល្អផូរផង់ សូមឱ្យពលរដ្ឋគ្រប់រូបបង្កើនការយកចិត្តទុកដាក់និងបញ្ចេញអស់សមត្ថភាព ដើម្បីការពារថែរក្សានិងលើកកម្ពស់ភាពរុងរឿងរបស់ជាតិយើងគ្រប់ពេលវេលា ។

# ការទទួលខុសត្រូវរបស់ធនញ្ជ័យ



## ក. សិក្សាពាក្យគន្លឹះ

- ទត (កិ) រ.ស : មើល ។
- ឆាន់ (កិ) រ.ស : ហូប ពិសា ... ។
- ប្រស្នា (ន) បា.សំ : ពាក្យ ឬសេចក្ដីដែលមានអាថ៌កំបាំង ចំណោទ លុះត្រាតែអ្នកមាន ប្រាជ្ញា ទើបដឹង និងអាចដោះស្រាយបាន ។
- គ្រហស្ថ (ន) បា.សំ : អ្នកមានគ្រួសារ មានកូនចៅធម្មតា ផ្ទុយពីអ្នកបួស ។
- ពុទ្ធដីកា (ន) រ.ស : សម្ដី ពាក្យសំដីព្រះពុទ្ធ ។
- ចៅហ្វ៊ា (ន) បា.សំ : អ្នកកាន់ការជំនុំ ត្រួតត្រាលើការងារផ្សេងៗ (ឧទា: ចៅហ្វ៊ាវាំង) ។
- អាត្មា (ន) រ.ស : ខ្ញុំ ។
- និមន្ត (កិ) : ដើរ ត្រាច់ចរ ។
- ភ្នាល់ (កិ) : តាំងប្រឡងគ្នាដោយក្រយាតំណាង ។
- នគរ (ន) : ប្រទេស ។

- បណ្ឌិត (ន) ៖ ជនអ្នកមានប្រាជ្ញា ជនអ្នកប្រព្រឹត្តល្អ ។
- មហាតលិក (ន) ៖ ខ្ញុំរាជការមានមុខងារខាងគាល់បម្រើព្រះរាជា ។
- អាមាត្យ (ន) ៖ មន្ត្រីជិតស្និទ្ធនឹងព្រះរាជា ។
- ចក្រវាឡ (ន) ៖ លោកធាតុ គឺភ្នំជាកំពែងព័ទ្ធជុំវិញនៃពិភពលោកទាំងមូល ។
- ព្រះទ័យ (ន) ៖ ទឹកចិត្តរបស់ស្ដេច ។
- ត្រាស់ (កិ) ៖ បានឡើងជាព្រះសព្វញ្ញុពុទ្ធបានដឹងនូវញេយ្យធម៌សព្វគ្រប់ ។
- គម្ពីរ (ន) ៖ សាស្ត្រា ច្បាប់វិន័យ ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ អ្នកគប្បីអានដោយយកចិត្តទុកដាក់ដើម្បីឆ្លើយសំណួរទាក់ទងនឹងសេចក្ដីលម្អិតសំខាន់ៗ កាលអាកាសនិងទំនាស់ ។

## គ. អត្ថបទ

[...] លោកគ្រូជ័យស្ដាប់ហើយក៏និមន្តទៅតាមអាមាត្យ ។ ស្ដេចទតឃើញធនញ្ជ័យទ្រង់ត្រេកអរឥតឧបមាទើបសួរថា លោកគ្រូជ័យអន់ចិត្តនឹងករុណា ឬដូចម្ដេច ? លោកគ្រូជ័យតបវិញទេ! អាត្មាឥតអន់ចិត្តអ្វីនឹងព្រះអង្គឡើយ ។ ស្ដេចបន្ថែមសេចក្ដី មានអាចារ្យពីស្រុកចិនបួននាក់ មកចោទប្រស្នាជាមួយយើងភ្នាល់ដាក់នគរ តើលោកគ្រូដោះបានឬទេ ? លោកគ្រូជ័យតបតាមភ្លាម កុំព្រួយ អាត្មាភាពដោះបាន ។ ស្ដេចបញ្ជាក់ទៅលោកគ្រូជ័យ បើដូចនោះមានតែលោកគ្រូសឹកមកជាគ្រហស្ថវិញ ។ លោកគ្រូជ័យទទួលថាអាត្មាសឹកថ្ងៃនេះឯង ។ លាចាកសិក្ខាបទរួចហើយធនញ្ជ័យចូលថ្វាយបង្គំស្ដេច ។ គ្រាន់តែក្រឡេកឃើញភ្លាម ស្ដេចឧទានឡើង អើ! បណ្ឌិតជ័យមកហើយទេតើ! យី! មើលរាងរៅសមជាបណ្ឌិត អ្នកប្រាជ្ញមែន ។ នែ! បណ្ឌិតជ័យ ប៉ុន្មានថ្ងៃទៀតយើងឱ្យគេមកចោទប្រស្នា ។

បណ្ឌិតជ័យឆ្លើយតប បីថ្ងៃទៀតសឹមឱ្យគេឡើងមកចុះនឹងចោទឆ្លើយគ្នា ។ សូមព្រះអង្គបង្គាប់ឱ្យរកគម្ពីរឱ្យច្រើនមក ឱ្យមហាតលិក ៤នាក់ យកខ្មៅមកដុសឱ្យបាន ៤ ថាស រកក្ដារបួនជ្រុង ៤ សន្លឹកក្ដាមបួនក្អម ហើយនិងយកក្រដាសសន្លឹកធំៗឱ្យបានច្រើន សឹមខ្ញុំធ្វើប្រស្នាថ្វាយ ។ ស្ដេចចាត់ចែងតាមបង្គាប់ធនញ្ជ័យនោះបានសព្វគ្រប់ហើយ ទើបយកមកប្រគល់ឱ្យបណ្ឌិត ជ័យ រួចស្ដេចបន្ទូលទៅកាន់អាមាត្យ ឯងទៅប្រាប់អ្នកប្រាជ្ញចិន បីថ្ងៃទៀតឡើងមកចោទប្រស្នា ។ អាមាត្យគោរពតាមបញ្ជា

ស្តេចឥតល្អៀង ។ ដល់ថ្ងៃកំណត់ហើយ អ្នកប្រាជ្ញស្រុកចិនឡើងមកចោទឆ្លើយជាមួយធនញ្ជ័យ ។ បណ្ឌិតជ័យចុះទៅទទួលអ្នកប្រាជ្ញចិននៅពាក់កណ្តាលផ្លូវមុខព្រះលានស្តេច ។ ក្រឡេកឃើញធនញ្ជ័យដើរមកពីចម្ងាយ អ្នកប្រាជ្ញចិនក៏ធ្វើប្រស្នាចោទដោយចង្អុលទៅលើមេឃ ។ ធនញ្ជ័យចង្អុលទៅព្រះអាទិត្យ អ្នកប្រាជ្ញចិនចង្អុលទៅក្រោមដី ។ ធនញ្ជ័យលាបាតដៃ ហើយលើកម្រាមដៃបញ្ឈរទៅលើ អ្នកប្រាជ្ញចិនចង្អុលចុះទៅក្រោម ធនញ្ជ័យចង្អុលមកខ្លួនឯង ។ អ្នកប្រាជ្ញចិនសួរ កាលយើងចង្អុលទៅលើមេឃ តើអ្នកឯងដឹងដូចម្តេច ? ធនញ្ជ័យឆ្លើយ អ្នកឯងចង់សួរថា ចក្រវាឡនេះអ្វីដែលមានតែមួយ ចុះយើងចង្អុលទៅព្រះអាទិត្យ តើអ្នកដឹងឬទេ ? អ្នកប្រាជ្ញចិនឆ្លើយ អ្នកចង្អុលទៅព្រះអាទិត្យនោះគឺ អ្នកសំដៅយកព្រះអាទិត្យនិងព្រះចន្ទ ។ អ្នកប្រាជ្ញចិនសួរបន្តទៅទៀត យើងចង្អុលទៅក្រោមដី តើអ្នកដឹងថាម៉េច ? បណ្ឌិតជ័យតបភ្លាម អ្នកសួរថាក្រៅផែនដីមានអ្វីខ្លះ ? ចុះយើងលើកម្រាមដៃធ្វើជុំវិញនោះ តើខ្ញុំថាម៉េច ? អ្នកប្រាជ្ញចិនឆ្លើយ គឺអ្នកប្រាប់ខ្ញុំថាខាងក្រៅផែនដីមានសមុទ្រ មានភ្នំនិងចក្រវាឡ ។ អ្នកប្រាជ្ញចិនសួរបន្ថែម ចុះខ្ញុំចង្អុលទៅក្រោមតើអ្នកដឹងថាយ៉ាងម៉េច ? ធនញ្ជ័យប្រាប់ថាអ្នកសួរថាលើផែនដីមានសត្វអ្វី ? ខ្ញុំចង្អុលមកខ្លួនខ្ញុំ តើអ្នកដឹងថាយ៉ាងម៉េច ? អ្នកប្រាជ្ញចិនតបថាដែលអ្នកចង្អុលខ្លួនឯងនោះ គឺអ្នកប្រាប់ថាលើផែនដីនេះមានតែមនុស្ស លុះឆ្លើយប្រស្នាទៅវិញទៅមករួច ហើយអ្នកប្រាជ្ញចិនលាធនញ្ជ័យត្រឡប់ទៅសំពៅវិញ ។

ព្រឹកឡើងការចោទប្រស្នាគ្នាបន្តទៅទៀត ។ អ្នកប្រាជ្ញចិនចាប់ដៃធ្វើជារង្វង់ ឯធនញ្ជ័យបត់ដុំដៃបង្ហាញ ។ អ្នកប្រាជ្ញចិនលាម្រាមដៃទាំង ៥ ធនញ្ជ័យបង្ហាញម្រាមមួយ ។ អ្នកប្រាជ្ញឃើញដូចនោះក៏លាចុះទៅសំពៅវិញ ធនញ្ជ័យក៏ត្រឡប់មកផ្ទះវិញដែរ ។ លោកគ្រូសង្រ្គាជនិមន្តមកសួរធនញ្ជ័យ អំពីប្រស្នាដែលចោទឆ្លើយជាមួយអ្នកប្រាជ្ញចិន កាលអ្នកចោទប្រស្នានឹងចិននោះយ៉ាងដូចម្តេចខ្លះ ? ធនញ្ជ័យទូលពុទ្ធដីកាលោកថា ចិនធ្វើដៃជារង្វង់ខ្ញុំថាគេយកអង្រុតរុតត្រី ។ ខ្ញុំបង្ហាញដុំដៃមានន័យថា យកអង្រុតរុតត្រីបានប៉ុនដុំដៃ ឯចិនបង្ហាញម្រាមដៃទាំង ៥ នោះគឺថា បើរុតត្រីបានប៉ុនដុំដៃហើយធ្វើជាងៀតបាន៥ចម្រៀក ខ្ញុំបង្ហាញចង្អុលដៃមួយ គឺមួយថ្ងៃស៊ីមួយចម្រៀក ។

លោកគ្រូសង្រ្គាជស្តាប់សព្វគ្រប់ក៏និមន្តទៅវត្តវិញ ។ ក្រោយមកសម្តេចចៅហ៊្វាទៅសួរធនញ្ជ័យទៀត ចង់ដឹងអំពីប្រស្នាចិនដែលគេយកមកចោទនោះ ។ ធនញ្ជ័យឆ្លើយប្រាប់ទៅសម្តេចចៅហ៊្វា ចិនរៀបដៃធ្វើជារង្វង់ប្រស្នានេះគឺគេថានគរយើងត្រូវបានគេ ខ្ញុំបង្ហាញដុំដៃគឺថាមិនបានដាច់ខាត ។ អ្នកប្រាជ្ញចិនលើកម្រាមដៃ ៥ ថាគ្នាគេមានច្រើនណាស់ ខ្ញុំបង្ហាញម្រាមដៃមួយគឺថាអញតែម្នាក់ឯងទេ តែ

អញអាចវាយអ្នកឯងឥតញញើត ។ សម្តេចចៅហ្វាឮហើយក៏វិលទៅលំនៅឋានវិញ ។ លោកគ្រូសង្ក្រាជនិងសម្តេចចៅហ្វាយកសេចក្តីនេះទៅទូលស្តេច ដើម្បីផ្គាប់ព្រះទ័យ ។ ស្តេចឆ្ងល់ណាស់ ទើបប្រើបម្រើ ឱ្យទៅហៅធនញ្ជ័យ លុះធនញ្ជ័យមកដល់ស្តេចសួរថា សេចក្តីប្រស្នាទាំងនោះយ៉ាងម៉េចខ្លះបានជា ឯងឆ្លើយទូលពុទ្ធដីកាព្រះសង្ឃផ្សេង ប្រាប់សម្តេចចៅហ្វាផ្សេងដូចនេះ ? ធនញ្ជ័យឆ្លើយទៅនឹងស្តេចថា ចិនគេឱបដៃបង្ហាញមកគឺគេសួរថា ក្នុងទ្វីបទាំងនេះតើមានអ្វីខ្លះ ? ទូលបង្គំបត់ដុំដៃបង្ហាញប្រាប់ថា មានភ្នំព្រះសុមេរុនៅកណ្តាល ។ ចិនបង្ហាញម្រាមដៃ ៥ មកទៀតគឺបំណងសួរថា មានព្រះពុទ្ធ ៥ អង្គបានត្រាស់ក្នុងកប្បនេះ ទើបទូលបង្គំបង្ហាញម្រាមដៃ ១ នោះប្រាប់ថាមាន ៥ អង្គមែន ប៉ុន្តែបាន ត្រាស់ ៤ អង្គហើយ នៅមួយអង្គទៀតពុំទាន់បានត្រាស់ ។ ប្រស្នាមានតែប៉ុណ្ណោះទេសូមទ្រង់ជ្រាប ។ ស្តេចសួរបញ្ជាក់ធនញ្ជ័យ ឯងពិតពុទ្ធដីកាលោកផ្សេង ប្រាប់នាម៉ឺនផ្សេង ប្រាប់អញផ្សេងតើអញជឿដូចម្តេច ។ ធនញ្ជ័យទូលថា ឯការពិតដូចខ្ញុំទូលថ្វាយអំបាញ់មិញនេះ ។ ធនញ្ជ័យថ្វាយបង្គំលាស្តេចទៅផ្ទះវិញទៅ ។

ស្តេចព្រមទាំងនាម៉ឺនទាំងអស់នឹកស្ងើចសរសើរប្រាជ្ញាធនញ្ជ័យ ដែលដោះប្រស្នាបានបីយ៉ាងហើយសមផង ។ ធនញ្ជ័យវិលមកដល់ផ្ទះបង្គាប់ឱ្យយកខ្មៅដុស និងក្តារបួនជ្រុង ព្រមទាំងក្តាមបួនក្អមនោះមក ទើបគាត់យកក្តាមដាក់ត្រង់កណ្តាល ហើយយកថាសមានទឹកខ្មៅដាក់គ្រប់ជ្រុងទាំង៤ និងយកក្រដាសក្រាលពីលើក្តារ ។ គាត់ចាប់ក្តាមដាក់ក្នុងថាសទឹកខ្មៅឱ្យវាវារឡើងលើក្រដាសនោះ ។ ទឹកខ្មៅជ្រលក់នឹងជើងក្តាមជិតជាប់លើក្រដាសនោះឯង ទើបគាត់យកទៅហាលថ្ងៃ រួចយកមកចងជាគម្ពីររុំទុក ។ ធនញ្ជ័យប្រមូលកូនក្មេងមកជាច្រើន ហើយឱ្យវាយកក្រដាសនៅសល់ពីធ្វើគម្ពីរម្នាក់មួយសន្លឹកមកអានតែផ្តេសផ្តាសទៅ ក្មេងណាចង់ថាដូចម្តេចក៏ថាទៅ ធ្វើយ៉ាងណាឱ្យឮទ្រហឹងអឺងអាប់ដូចក្មេងរៀនមើលសាស្ត្រា ។ ឯអ្នកប្រាជ្ញចិនព្រឹកឡើងក៏ដើរទៅផ្ទះធនញ្ជ័យ ដើម្បីនឹងចោទប្រស្នា ។ ធនញ្ជ័យទទួលរាក់ទាក់យកកៅអីមកឱ្យអង្គុយ ព្រមទាំងលើកទឹកតែមកឱ្យផឹក ។ ក្មេងៗខំប្រឹងមើលអក្សរតាមពាក្យធនញ្ជ័យប្រាប់ឮកងរំពង រកតែអ្នកប្រាជ្ញចិននិងធនញ្ជ័យចរចាគ្នាស្ទើរមិនកើត ។ អ្នកប្រាជ្ញចិន យកសំបុត្រដែលក្មេងកំពុងរៀនមកមើលមិនស្គាល់តួអក្សរដល់មួយសោះ ។ ធនញ្ជ័យសួរ តើអ្នកស្គាល់អក្សរទាំងនេះទេ? អ្នកប្រាជ្ញចិនឆ្លើយ ទេ ! ខ្ញុំមិនដែលឃើញអក្សរអ្វីបែបនេះទេ ។ ធនញ្ជ័យនិយាយថា បើដូចនោះឯងចាញ់ខ្ញុំត្រឹមអក្សរនេះហើយ ព្រោះបើអ្នកមិនស្គាល់តួអក្សរនេះទេនឹងឆ្លើយប្រស្នាគ្នាមិនបានឡើយ តួអក្សរនេះគេហៅអក្សរមឹងឆ្វេង អក្សរព្រាហ្មណ៍ ។ អ្នកប្រាជ្ញចិនទទួលព្រម

ចុះចាញ់ ធនញ្ជ័យនិយាយបន្តទៅទៀត បើអ្នកចាញ់ខ្ញុំហើយ ខ្ញុំយកតែរបស់ក្នុងសំពៅបួនហ្នឹង ចំណែកសំពៅនិងរូបអ្នក ខ្ញុំឱ្យត្រឡប់ទៅវិញ ។ ឯនគរក៏ខ្ញុំមិនយកដែរ ខ្ញុំឱ្យទៅស្ដេចស្រុកចិន ខ្ញុំគ្រាន់តែផ្ដាំថា កាលណាឃើញឈ្មោះធនញ្ជ័យអ្នកប្រាជ្ញត្រូវតែខ្លាចឱ្យហើយទៅ ។ ភាគីចិនរើអីវ៉ាន់ឱ្យធនញ្ជ័យទាំងអស់ ហើយលាត្រលប់ទៅនគរវិញ ។ ធនញ្ជ័យកាលបើបានទទួលរបស់ពីចិនទាំងអស់ហើយ ក៏ចាត់មនុស្សឱ្យដឹកជញ្ជូនយកទៅទុកក្នុងឃ្លាំងឥតមានយកអ្វីបន្តិចបន្តួចឡើយ ។

ស្ដេចឮថាធនញ្ជ័យឈ្នះព្រមទាំងបានរបស់មកដាក់ឃ្លាំងផង ទ្រង់សប្បាយចិត្តហើយសួរបណ្ឌិតជ័យមានយកទុកខ្លះដែរឬទេ? ធនញ្ជ័យតប ទូលបង្គំឥតមានយកទុកទេ ។[...]

*(ដកស្រង់ពីរឿងធនញ្ជ័យ កម្រងអត្ថបទអក្សរសិល្ប៍ក្រសួងអប់រំ ១៩៨៣)*

## សំណួរ

១. តើការដោះប្រស្នាលើកនេះគេភ្នាល់ដាក់អ្វី ?

២. តើអ្នកប្រាជ្ញចិនសុខចិត្តចុះចាញ់លើប្រធានបទអ្វី ?

៣. តើការទទួលដោះប្រស្នាលើកនេះ ជាការទទួលខុសត្រូវដូចម្ដេចចំពោះវាសនាប្រទេសជាតិ ? ព្រោះអ្វី ?

៤. ចូរបង្ហាញទំនាស់នៅក្នុងអត្ថបទនេះ ។

៥. ចូរបង្ហាញកាលអាកាសនៃរឿងនៅក្នុងអត្ថបទនេះ ។



# គុណនាម

នៅពេលគេចង់បញ្ជាក់សភាពលក្ខណៈរបស់នាម គេប្រើគុណនាម ។ តើគុណនាមជាអ្វី ?

ចូរពិនិត្យឧទាហរណ៍ :

១. សាលារៀនខ្ញុំមានទីធ្លាធំទូលាយ ។

២. តើឪពុករបស់ឯងឈប់ជក់បារីប៉ុន្មានខែហើយ?

៣. ខ្ញុំមិនដឹងថាគាត់ឈប់ជក់បារីពីពេលណាទេ ។

៤. ផ្ទះខ្ញុំនៅខាងមុខគេ ។

៥. ខ្ញុំតែងតែពាក់មួកសុវត្ថិភាពនេះ នៅពេលធ្វើដំណើរតាមម៉ូតូ ។

៦. គាត់សម្រាកថ្ងៃត្រង់យ៉ាងហោចណាស់កន្លះម៉ោង មុននឹងបើកបររថយន្ត ។

ក្នុងល្បះខាងលើពាក្យ "ធំ ប៉ុន្មាន ពេលណា ផ្ទះខ្ញុំ នេះ កន្លះម៉ោង" ជាគុណនាម ។ គុណនាមទាំងនេះមាននាទីផ្សេងគ្នានៅក្នុងល្បះ ។

ពាក្យ "ធំ " ក្នុងល្បះទី ១ ជាគុណនាមប្រក្រតី បញ្ជាក់លក្ខណៈឱ្យ "ទីធ្លា" ។

ពាក្យ"ប៉ុន្មាន" ក្នុងល្បះទី ២ ជាគុណនាមសំណួរ សម្រាប់សួររកពេល"រយៈពេលឈប់ជក់បារី"

ពាក្យ "ពេលណា" ក្នុងល្បះទី ៣ ជាគុណនាមមិនច្បាស់ "ពេលវេលាមិនច្បាស់លាស់ " ។

ពាក្យ "ខ្ញុំ " ក្នុងល្បះទី ៤ ជាគុណនាមកម្មសិទ្ធិ គឺប្រាប់ម្ចាស់កម្មសិទ្ធិ ។

ពាក្យ "នេះ" ក្នុងល្បះទី ៥ ជាគុណនាមចង្អុល "ចង្អុលបង្ហាញវត្ថុនៅជិត" ។

ពាក្យ "កន្លះម៉ោង" ក្នុងល្បះទី ៦ ជាគុណនាមចំនួន "បង្ហាញពីចំនួន" ។

ដូចនេះគុណនាមមាន :

## ១ . គុណនាមប្រក្រតី

- គុណនាមប្រក្រតីសម្រាប់ប្រាប់លក្ខណៈធម្មតា ។ *ឧទាហរណ៍ :*
  - អារម្មណ៍ល្អរៀនសូត្រចេះចាំល្អ ។
  - ទឹកកខ្វក់នាំឱ្យប៉ះពាល់ដល់សុខភាព ។
  - គោខ្មៅធាត់ជាងគោស ។
- គុណនាមប្រក្រតីមាន : ល្អ កខ្វក់ ខ្មៅ ស វែង ខ្លី សម្បូរ ខ្ពស់ តូច ធំ មូល ជ្រុង ស្រួច ទាល ធាត់ ស្គម ខ្លាំង ខ្សោយ ថ្លៃ ថោក សាប ប្រៃ ជូរ ល្វីង ស្រាល ធ្ងន់ ... ។

## ២ . គុណនាមចំនួន

គុណនាមចំនួនជាគុណនាមសម្រាប់រាប់ ។ គុណនាមចំនួនមានពីរយ៉ាង :

- **ចំនួនរាប់ :** សម្រាប់រាប់ឱ្យដឹងចំនួនប៉ុណ្ណេះ ប៉ុណ្ណោះ ។

*ឧទាហរណ៍ :*

- ឪពុកខ្ញុំមានគោប្រាំនឹម ។
- ថ្ងៃនេះសុភាពដកសំណាបបានពីរដំបរ ។

ចំនួនរាប់មានដូចជា ប្រាំនឹម ពីរដំបរ ប្រាំរយ ពីរដណ្ដប់ ប្រាំខាំ ពីរសែន ប្រាំម៉ឺន ប្រាំឡូ ... ។

- **ចំនួនរៀប :** សម្រាប់រាប់ឱ្យដឹង ទី ជាន់ ថ្នាក់ ប៉ុណ្ណេះ ប៉ុណ្ណោះ ។

*ឧទាហរណ៍ :*

- ដាណេរៀនថ្នាក់ទីប្រាំបី ។
- ខ្ញុំរៀនដល់មេរៀនទីបួន ។
- ខ្ញុំភ្ញាក់ពីដំណេកនៅម៉ោងប្រាំ ។

ចំនួនរៀបមាន : ទីប្រាំបី ទីបួន ម៉ោងប្រាំ ជាន់ទីមួយ ថ្នាក់ទីប្រាំបួន ... ។

## ៣ . គុណនាមកម្មសិទ្ធិ

គុណនាមកម្មសិទ្ធិសម្រាប់ប្រាប់ម្ចាស់កម្មសិទ្ធិ ។

*ឧទាហរណ៍ :*

- គោខ្ញុំធាត់ជាងគេ ។
- រាជរដ្ឋាភិបាលជាអ្នកសាងសង់ផ្ទះពួកគាត់ ។

គុណនាមកម្មសិទ្ធិមាន : ខ្ញុំ ឯង វា គាត់ នាង យើង ពួកគាត់ គេទាំងអស់គ្នា ... ។

## ៤ . គុណនាមចង្អុល

គុណនាមចង្អុលសម្រាប់ប្រាប់ទីកន្លែង និងពេលវេលា ។

*ឧទាហរណ៍ :* សាលារៀននេះជាសាលារៀនខ្ញុំ ឯខាងនោះជាសាលាឃុំ ។

គុណនាមចង្អុលមាន :

- ទីជិត : នេះ នោះ ... ។
- ទីឆ្ងាយ : នោះ ណោះ ។

## ៥ . គុណនាមសំណួរ

គុណនាមសំណួរសម្រាប់ចោទសួរ ។

*ឧទាហរណ៍ :*

- តើប្អូនរៀនថ្នាក់ទីប៉ុន្មាន ?
- តើមិត្តទិញសៀវភៅអ្វីខ្លះ ?

គុណនាមសំណួរមាន អ្វីខ្លះ ប៉ុន្មាន អ្វី ស្អី ណាខ្លះ ណាមួយ ... ។

## ៦ . គុណនាមមិនច្បាស់

គុណនាមមិនច្បាស់គឺគុណនាមប្រាប់សេចក្តីមិនជាក់លាក់ មិនប្រាកដ ។

*ឧទាហរណ៍ :*

- ខ្ញុំមិនដឹងថាគាត់ត្រូវការសៀវភៅណាមួយទេ ។
- ខ្ញុំមិនដឹងថាគាត់ទិញអ្វីខ្លះទេ ។

គុណនាមមិនច្បាស់មាន អ្វី ណា អ្វីខ្លះ មួយណា ណាខ្លះ ឯទៀត ដទៃ អ្វីមួយ ... ។

យើងសង្កេតឃើញថាគុណនាមមានច្រើនប្រភេទ ហើយមានលក្ខណៈផ្សេងគ្នា ។

គុណនាមគឺជាពាក្យ សម្តី សម្រាប់សម្តែងសភាពលក្ខណៈរបស់នាម ។ គុណនាមមាន គុណនាមប្រក្រតី គុណនាមចំនួន គុណនាមកម្មសិទ្ធិ គុណនាមចង្អុល គុណនាមសំណួរ និងគុណនាមមិនច្បាស់ ។

## លំហាត់

១. ចូរអ្នកស្រង់គុណនាមក្នុងល្បះខាងក្រោមនិងប្រាប់ពីប្រភេទរបស់វា ។

- ការប្រើប្រាស់ទឹកស្អាតនាំឱ្យមានសុខភាពល្អ ។
- ខ្ញុំមិនដឹងថាគាត់ធ្វើអ្វីខ្លះទេ ។
- តើប្អូនទិញសៀវភៅប៉ុន្មានក្បាល?
- សៀវភៅនេះល្អជាងសៀវភៅនោះ ។
- គាត់ទិញផ្លែក្រូចពីរឡូ ។
- សាលារៀនខ្ញុំទើបនឹងសង់បានបីឆ្នាំប៉ុណ្ណោះ ។
- ដីព្រៃមួយរយហិចតានេះជាតំបន់អភិរក្ស ។

២. ចូរស្រង់គុណនាមពីអត្ថបទខាងក្រោមឱ្យបានប្រាំពាក្យនិងប្រាប់ប្រភេទគុណនាមនីមួយៗ ។

# ជក់បារីនាំឱ្យខូចសុខភាព



## ក. សិក្សាពាក្យគន្លឹះ

- អត្រាមរណៈប្រមាណ (ន) បា. សំ : ចំនួនអ្នកស្លាប់ ។
- អភិវឌ្ឍ (កិ) បា : ចម្រើនលូតលាស់ ចម្រើនក្រៃលែង ។
- វិធានការ (ន) : វិធី របៀប ។
- សាធារណជន (ន) : ជនទូទៅ ។
- ប្ដេជ្ញា (ន) : ការតាំងចិត្តឈប់ប្រព្រឹត្ត ឈប់ធ្វើអ្វីមួយ ។
- ទិវា (ន) : ថ្ងៃប្រារព្ធវិធីមួយ ។ ទិវាប្រឆាំងនឹងការជក់បារីថ្ងៃទី ៣១ ឧសភា ជារៀងរាល់ឆ្នាំ ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទនេះ អ្នកគប្បីអានដោយយកចិត្តទុកដាក់ ដើម្បីឆ្លើយសំណួរទាក់ទងនឹងសេចក្ដីលម្អិតសំខាន់ៗ និងតម្លៃអប់រំរបស់អត្ថបទ ។

## គ. អត្ថបទ

អ្នកជក់បារីហាក់ដូចជាមិនសូវគិតគូរពីសុខភាពឡើយ ។ ពួកគេគិតតែពីអារម្មណ៍របស់គេតែប៉ុណ្ណោះ ។ តាមការស្រាវជ្រាវបញ្ជាក់ថា អត្រាមរណៈនៃអ្នកជក់បារីបានកើនឡើងយ៉ាងខ្ពស់ជាងអត្រាមរណៈប្រមាណនៃអ្នកមិនជក់បារី ។ ក្នុងចំណោមអ្នកជក់បារីទាំងឡាយ អ្នកស្លាប់ដោយសារការជក់បារីមានចំនួនពាក់កណ្ដាល ។ នៅក្នុងទិវាប្រឆាំងនឹងការជក់បារីថ្ងៃទី ៣១ ឧសភា គ.ស. ១៩៩៦ ក្រសួងសុខាភិបាលបានឱ្យដឹងថា អ្នកស្លាប់ដោយសារការជក់បារីនៅចុងសតវត្សទី ២០ នេះមានចំនួនប្រមាណ ៦២លាននាក់ក្នុងប្រទេសកំពុងអភិវឌ្ឍបណ្ដាអ្នកស្លាប់ទាំងនោះបុរសមាន ៥២លាននាក់ ស្ត្រីមាន ១១ លាននាក់ ។ តាមតួលេខថ្មីៗរបស់អង្គការសុខភាពពិភពលោកបានបង្ហាញថា ថ្នាំជក់បានសម្លាប់មនុស្ស ១០០ លាននាក់នៅក្នុងសតវត្សទី ២០នេះ[១] ។ នាពេលបច្ចុប្បន្ននេះថ្នាំជក់សម្លាប់មនុស្ស ៥.៤លាននាក់ក្នុងមួយឆ្នាំ ដោយជំងឺមហារីកបំពង់ក សួត ជំងឺបេះដូង និងជំងឺផ្សេងៗទៀត[២] ។ អង្គការសុខភាពពិភពលោកបានប៉ាន់ប្រមាណថា នៅឆ្នាំ ២០៣០ថ្នាំជក់នឹងសម្លាប់មនុស្ស ៨លាននាក់ក្នុងមួយឆ្នាំ ហើយ ៨០ ភាគរយនៃអ្នកស្លាប់ គឺស្ថិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍដូចជាប្រទេសកម្ពុជាជាដើម[៣] ។

តាមការប្រមើលមើល នៅប្រទេសកម្ពុជាចន្លោះឆ្នាំ ១៩៩៧-២០០៧ មានអ្នកស្លាប់យ៉ាងហោចណាស់ ៧៣ ៥០០នាក់[៤] ដែលបណ្ដាលមកពីការជក់បារី ។ ការជក់បារីបណ្ដាលឱ្យមានការចំណាយមិនផ្ទាល់ប្រហែល ១០៧៩ដុល្លារ[៥] បើប្រៀបធៀបទៅនឹងពន្ធនៃការនាំចូលបារីមានតែ ៦៥៩លានដុល្លារ[៥] ប៉ុណ្ណោះ ។ ដូចនេះការខាតបង់ផ្នែកសេដ្ឋកិច្ចជាតិប្រមាណ ៤២០លានដុល្លារ បើគិតក្នុងមួយឆ្នាំ គឺខាតបង់ ៣៨ លានដុល្លារ[៦] ។ គ្រួសារកម្ពុជាប្រមាណ ៧០ ភាគរយបានប្រើប្រាស់ប្រាក់ ចំណូលរបស់ខ្លួនជាង ១០ ភាគរយទៅលើការទិញបារី[៧] ។

នៅកម្ពុជាក្នុងរយៈពេលខ្លីកន្លងមកនេះ ការហូរចូលនៃបារីគ្រប់ប្រភេទឃើញគួរឱ្យរន្ធត់ពន់ពេក ។ បារីទាំងអស់នេះបានធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធវិទ្យុ និងទូរទស្សន៍យ៉ាងគគ្រឹកគគ្រេង ។ អ្នកជក់បារីនៅប្រទេសកម្ពុជាមានសឹងតែគ្រប់គ្រួសារ ឯកុមារអាយុ ១៥ ឆ្នាំ ក៏មានជក់បារីដែរ ។ គេសង្កេតឃើញថាមានបារីសម្បូរបែប មានអ្នកជក់ច្រើនមិនតិចដែរ ។ ក្នុងពេលជាមួយគ្នានេះដែរ

ក្រុមហ៊ុនបារី បានបញ្ជាឱ្យបោះពុម្ពបម្រាមលើកញ្ចប់បារីរបស់ខ្លួនថា ការជក់បារីនាំឱ្យខូចសុខភាព ដើម្បីឱ្យសាធារណជនដឹង ។ ជំងឺដែលមានប្រភពមកពីការជក់បារីគឺ មហារីកសួត បំពង់ក បេះដូង និងជំងឺផ្សេងៗទៀតមួយចំនួនទៀតទាក់ទងនឹងស្ត្រីមានផ្ទៃពោះ ជក់បារី គឺបណ្តាលឱ្យមានគ្រោះថ្នាក់ខ្លាំងដល់កូនក្នុងផ្ទៃ ។

វិធានការបញ្ឈប់ការជក់បារីមាន ៣ ដែលគួរយកមកអនុវត្ត ៖

- ត្រូវតាំងចិត្តប្តេជ្ញាថាឈប់ជក់បារី ។ វិធានការនេះដូចជាដាច់ខាតពេកហើយ ប្រហែលជាមិនអាចធ្វើទៅរួច ព្រោះបារីជាគ្រឿងញៀនតែជក់ហើយមិនងាយផ្តាច់បានទេ ។
- ពន្យារពេលជក់បារី ។ អ្នកធ្លាប់ជក់បារីពេលក្រោកពីដំណេក ត្រូវពន្យារដល់ពេលស្រស់ស្រូបរួច ។ អ្នកធ្លាប់ជក់រាល់ថ្ងៃត្រូវពន្យារពេលពីរថ្ងៃម្តង ។ ការធ្វើឱ្យមានទម្លាប់ដូចនេះអាចមានរយៈពេលវែង ហើយទីបំផុតជួនកាលអាចឈប់បាន ។
- ការបន្ថយចំនួនបារី អ្នកធ្លាប់ជក់មួយថ្ងៃមួយកញ្ចប់បន្ថយត្រឹម ១៥ ដើមមួយថ្ងៃ ។ រយៈពេលក្រោយៗមក អ្នកអាចបន្ថយនៅត្រឹមមួយដើមក្នុងមួយថ្ងៃ ។ អ្នកមានភាពស៊ាំបែបនេះហើយ អ្នកអាចតាំងចិត្តថា ឈប់ជក់បារីបាន ។

## សំណួរ

១. តើអង្គការសុខភាពពិភពលោកបានបង្ហាញតួលេខថ្មីៗដូចម្តេចខ្លះទាក់ទងនឹងការជក់បារី ?

២. តើពលរដ្ឋកម្ពុជាយើងស្លាប់ដោយសារការជក់បារីមានចំនួនប៉ុន្មាននាក់ ក្នុងចន្លោះឆ្នាំ ១៩៩៧-២០០៧ ?

៣. ចូរបង្ហាញពីតួលេខនៃការខាតបង់សេដ្ឋកិច្ចជាតិដោយសារបារី ។

៤. តើការជក់បារីបង្កឱ្យមានជំងឺអ្វីខ្លះ ?

៥. ចូរបង្ហាញពីវិធានការបញ្ឈប់ការជក់បារី ។

៦. តើអត្ថបទខាងលើមានតម្លៃអប់រំដូចម្តេច ?

---

*(១.២.៣.៤.៥.៦.៧): កម្រងឯកសារថ្នាំជក់ឬសុខភាព រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ដោយសហការជាមួយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដានិងអាដ្រាកម្ពុជា*

# ការប្រគល់ការងារឱ្យទទួលខុសត្រូវ





## ក. សិក្សាពាក្យគន្លឹះ

- សន្និដ្ឋាន (ន) : សេចក្ដីយល់ជាក់ ការយល់ឃើញស៊ប់ ការប្រមូលគំនិតសំខាន់ៗ ។
- ឧបសគ្គ (ន) : ដំណើររារាំង គ្រឿងរារាំងដំណើរ គ្រឿងទើសទាក់ ។
- បុគ្គលិក (ន) : អ្នកធ្វើការឬមន្ត្រីបម្រើការងារនៅស្ថាប័នរដ្ឋឬឯកជន ។
- ថវិកា (ន) : ប្រាក់ លុយ ។
- មូលដ្ឋាន (ន) : ទីដែលជាឫសគល់ ស្ថានដើម គោលការណ៍សំខាន់ ។
- អស្ចារ្យ (គុ) : ដែលគួរឱ្យស្ញើចក្រៃពេក ។
- បដិវត្ត (ន) : ប្រែប្រួល កែប្រែ ផ្លាស់ប្ដូរ ។
- កិត្តិយស (ន) : យសសក្ដិដែលល្បីទូទៅ កេរ្តិ៍ឈ្មោះដ៏រុងរឿង ។
- សោមនស្ស (ន) : សេចក្ដីសប្បាយចិត្ត សេចក្ដីរីករាយ សប្បាយ អំណរ ។
- សារជាតិ (ន) : ជាតិ កំណើតដែលមានតម្លៃ ដែលមានសារៈសំខាន់ មានប្រយោជន៍ ។
- លទ្ធផល (ន) : ផលដែលសម្រេចបាន ។

- ជំនឿចិត្ត (ន) : ការជឿទុកចិត្ត ការជឿជាក់ច្បាស់ក្នុងចិត្ត ។
- ទស្សនៈ (ន) : ការឃើញ ដំណើរយល់ឃើញ ។
- អារម្មណ៍ (ន) : គំនិត ការដឹង ។
- ទេពកោសល្យ (ន) : ភាពប៉ិនប្រសប់ ភាពឈ្លាសវៃ ។
- សមត្ថភាព (ន) : ភាពនៃសេចក្ដីអាចហ៊ាន ។
- ស្មារតី (ន) : សេចក្ដីនឹកឃើញ ការរលឹកបាន ។
- ភារកិច្ច (ន) : រឿងហេតុ ឬការណ៍ដែលកើតមានឡើង ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទខាងក្រោម សូមអ្នកអានដោយយកចិត្តទុកដាក់ដើម្បីឆ្លើយសំណួរមួយចំនួនទាក់ទងគោលបំណងនិងខ្លឹមសារសំខាន់ៗនៃអត្ថបទឱ្យបានត្រឹមត្រូវ ។

## គ. អត្ថបទ

ការដែលដឹងថា ខ្លួននឹងត្រូវរ៉ាប់រងការទទួលខុសត្រូវ ទោះបីការទទួលខុសត្រូវនោះស្មុគស្មាញហើយត្រូវបានអ្នកផ្សេងរំលឹកប្រាប់ក៏ដោយ ដែលតាមការពិតយើងក៏ពិបាកនឹងទទួលយកណាស់ ។ ប៉ុន្តែប្រសិនបើម្យ៉ាងយើងមិនអាចទទួលយកបាន ដោយសារតែមានការលំបាក ហើយម្យ៉ាងទៀតប្រសិនបើដៃគូរបស់យើងជាអ្នកគ្មានការទទួលខុសត្រូវថែមទៀតនោះកិច្ចការអ្វីក៏ដោយគឺងាយនឹងខកចោលពាក់កណ្ដាលផ្លូវ ហើយគ្រប់ការងារទាំងឡាយមិនអាចមានដំណើរការបានងាយស្រួលឡើយ ។ តើធ្វើយ៉ាងណាដើម្បីឱ្យដឹងពីការទទួលខុសត្រូវរបស់ខ្លួនបានត្រឹមត្រូវ ហើយនឹងអាចសម្រេចគ្រប់កិច្ចការទាំងអស់នោះបាន ?

ក្នុងអំឡុងឆ្នាំ ១៩៣០ក្រុមហ៊ុនគ្រឿងអគ្គិសនី ម៉ាត់ស៊ូស៊ីតា (Matsushita) បានបើកសាខាក្រុមហ៊ុនដំបូងគេបង្អស់នៅទីក្រុងកាណាហ្សាវ៉ា ។ ខ្ញុំមិនដែលបានធ្វើដំណើរទៅទីក្រុងកាណាហ្សាវ៉ាសូម្បីតែម្ដងឡើយ ។ ប៉ុន្តែក្រោយពីខ្ញុំគិតសព្វគ្រប់ទៅ ខ្ញុំបានឈានដល់ការសន្និដ្ឋាន ដែលចាំបាច់ត្រូវតែបើកសាខាក្រុមហ៊ុននៅកាណាហ្សាវ៉ាដោយខានមិនបាន ។ នៅពេលនោះ ខ្ញុំមិនដឹងជាឱ្យអ្នកណាទៅទើបល្អទេ ។ អ្នកដែលត្រូវទៅ ហើយអាចធ្វើជាអ្នកទទួលខុសត្រូវនៅសាខាក្រុមហ៊ុនបាន គឺមានច្រើននាក់ ប៉ុន្តែខ្ញុំត្រូវទុកអ្នកដែលមានបទពិសោធខ្ពស់ដូចជាពួកគេទាំងនេះ សម្រាប់ធ្វើការនៅស្នាក់ការធំរបស់ក្រុមហ៊ុន ។ ប្រសិនបើឱ្យពួកគេទាំងនេះចេញទៅនោះបណ្ដាលឱ្យមានឧបសគ្គចំពោះការងារនៅក្នុងក្រុមហ៊ុន ។ ហេតុនេះហើយទើបខ្ញុំមិនបញ្ជូនពួកគេឱ្យទៅធ្វើការនៅកាណាហ្សាវ៉ា ។ តើខ្ញុំត្រូវធ្វើដូចម្ដេចទៅទើបល្អហ្ន៎ ?

នៅពេលនោះ ស្រាប់តែខ្ញុំនឹកឃើញដល់បុគ្គលិកវ័យក្មេងម្នាក់ ។ គេជាបុគ្គលិកទើបតែមានអាយុជាង ២០ឆ្នាំប៉ុណ្ណោះ ។ អូមែនហើយ! គេម្នាក់នោះទោះជាយ៉ាងណា ក៏ប្រហែលជាអាចធ្វើការងារនេះបាន ។ គេនៅក្មេងពិតមែន ប៉ុន្តែមិនមែនមានន័យថាដោយសារតែហេតុផលអាយុ គេមិនអាចធ្វើការងារនោះបានទេ ។ ខ្ញុំមានការយល់ឃើញបែបនេះ ។

ដូច្នេះហើយ ខ្ញុំបានសម្រេចចិត្តបញ្ជូនបុគ្គលិកវ័យក្មេងនោះឱ្យទៅធ្វើជាអ្នកទទួលខុសត្រូវក្នុងការបើកសាខាក្រុមហ៊ុននៅកាណាហ្សាវ៉ា រួចហើយខ្ញុំក៏បានហៅគេមកប្រាប់ "លើកនេះយើងបានសម្រេចថានឹងបើកសាខាក្រុមហ៊ុននៅកាណាហ្សាវ៉ា ខ្ញុំចង់ឱ្យឯងទទួលបន្ទុកនៅទីនោះ ។ ខ្ញុំចង់ឱ្យឯងធ្វើដំណើរទៅកាណាហ្សាវ៉ា រកជួលផ្ទះនិងរៀបចំបើកហាង ។ ខ្ញុំបានត្រៀមថវិកាចំនួន ៣០០យ៉េនរួចហើយ ។ ឯងយកថវិកានេះទៅរៀបចំដំណើរការចុះ ។"

បន្ទាប់ពីស្តាប់បញ្ហានេះរួច បុគ្គលិកវ័យក្មេងនោះមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងព្រមជាមួយនឹងការភ្ញាក់ផ្អើលនោះគេបានសម្លឹងមើលមុខខ្ញុំដោយមិនដាក់ភ្នែក ហើយនិយាយថា "តើខ្ញុំអាចបំពេញភារកិច្ចដ៏សំខាន់នេះកើតឬទេ ? ខ្ញុំទើបតែចូលធ្វើការក្នុងក្រុមហ៊ុនបានប្រហែល ២ឆ្នាំប៉ុណ្ណោះ ហើយជាបុគ្គលិកជើងថ្មីនៅឡើយ ។ ខ្ញុំមានអាយុទើបតែជាង ២០ឆ្នាំ គ្មានបទពិសោធអ្វីទាល់តែសោះ... ។" អ៊ីចឹង! គេមានទឹកមុខខ្វល់ខ្វាយ ពីព្រោះតែខ្លួនត្រូវគេឱ្យទទួលបន្ទុកការងារបើកសាខាក្រុមហ៊ុនជាលើកដំបូងនៅកន្លែងដែលពីមុនមកគ្មានអ្វីទាល់តែសោះ គឺជាការពិបាកនិងជាភារកិច្ចដ៏សំខាន់ ។ បុគ្គលិកនោះ ត្រូវរ៉ាប់រងនូវការទទួលខុសត្រូវធ្ងន់ធ្ងរមួយ ។ ប៉ុន្តែខ្ញុំខ្លួនឯងបានគិតហើយថា ទោះបីជាបុគ្គលិកនោះមានវ័យក្មេងក៏ដោយ ក៏ប្រាកដជាអាចធ្វើកិច្ចការនេះបាន ។ ជាការពិតហើយ បើយើងមិនសាកធ្វើកិច្ចការហ្នឹងមើលទេ នោះយើងក៏មិនដឹងដែរ ប៉ុន្តែជាមូលដ្ឋាន គឺខ្ញុំមានជំនឿចិត្ត ។ ចំពោះការមានជំនឿចិត្តនោះគឺមិនមែនសំដៅតែទៅលើបុគ្គលិកវ័យក្មេងតែម្នាក់ហ្នឹងនោះទេ គឺខ្ញុំមានជំនឿចិត្តលើមនុស្សលោកជាទូទៅតែម្តង ។ ដូច្នេះហើយ ខ្ញុំក៏បានលើកយកបញ្ហានេះមកនិយាយប្រាប់បុគ្គលិកវ័យក្មេងនោះយ៉ាងម៉ឺងម៉ាត់ថា ៖

"គ្មានកិច្ចការអ្វីដែលថាឯងធ្វើមិនកើតនោះទេ ។ ឯងប្រាកដជាធ្វើកិច្ចការនេះកើតជាមិនខាន ។ ចូរឯងសាកគិតមើលទៅ កាលពីសម័យប្រទេសមានសង្គ្រាម បណ្តាលោកមេទ័ពបានបំពេញការងារតាំងពីពួកគាត់មានអាយុមិនដល់ ២០ឆ្នាំផង ពួកគាត់នៅវ័យក្មេងព្រមទាំងមានបន្ទាយខ្លួនឯងហើយធ្វើការគ្រប់គ្រងមនុស្សរបស់គាត់និងប្រជាជន ។ ពួកគាត់បានអនុវត្តការងារគ្រប់គ្រងនោះបានល្អអស្ចារ្យណាស់ ។ អ្នកធ្វើបដិវត្តន៍ (Meiji Ishin) គ្រប់គ្នានោះសុទ្ធតែនៅវ័យក្មេង ប៉ុន្តែក្នុងគ្រាប្រទេសមានអាសន្ន ពួកគេបាននាំគ្នាដោះស្រាយយ៉ាងសមស្រប ហើយបានកសាងនូវប្រទេសជប៉ុនថ្មីមួយ

ឡើង ។ ចុះទម្រាំតែឯងដែលមានអាយុជាង ២០ឆ្នាំទៅហើយនោះ គ្មានរឿងអ្វីដែលថាឯងមិនអាចធ្វើបាននោះទេ ។ មិនជាបញ្ហាអ្វីទេ ឯងប្រាកដជាធ្វើបាន ...” ។

នៅពេលដែលខ្ញុំលើកយករឿងជាច្រើនមកនិយាយដើម្បីលើកទឹកចិត្តគេ មិនយូរប៉ុន្មានបុគ្គលិកវ័យក្មេងនោះបាននិយាយយ៉ាងច្បាស់លាស់ថា “ខ្ញុំយល់ហើយ ខ្ញុំសូមទទួលធ្វើកិច្ចការនេះ ខ្ញុំមានកិត្តិយសណាស់ដែលលោកប្រធានបានតែងតាំងរូបខ្ញុំឱ្យធ្វើកិច្ចការនេះ ។ ខ្ញុំគិតថាខ្ញុំចង់ធ្វើការងារនេះសាកល្បងមើលឱ្យចប់ចុងចប់ដើម” ។ គេមានការផ្លាស់ប្តូរខុសពីពេលមុននេះបន្តិច ហើយមើលទៅគេឃើញថាគេមានការចាប់អារម្មណ៍ខ្លាំងណាស់ ។ ការប្តេជ្ញាចិត្តខ្ពស់បានលេចឡើងយ៉ាងច្បាស់ក្រឡែតនៅលើទឹកមុខរបស់គេ ។ ដូច្នេះហើយ ខ្ញុំក៏មានចិត្តសោមនស្សរីករាយផងដែរ ខ្ញុំបានបញ្ជូនគេឱ្យទៅទីនោះដោយប្រាប់គេថា ៖

“ប្រឹងប្រែងធ្វើការណា៎!” ។ នៅពេលបុគ្គលិករូបនោះបានទៅដល់កាណាហ្សាវ៉ាហើយ គេក៏ចាប់ផ្តើមធ្វើសកម្មភាពការងារភ្លាម ព្រមទាំងបានធ្វើរបាយការណ៍ផ្ញើមកខ្ញុំជាបន្តបន្ទាប់ ។ សំបុត្របានមកដល់ជារៀងរាល់ថ្ងៃ គេបានជូនព័ត៌មានមកខ្ញុំពីវិធីដែលគេចាប់ដំណើរការការងាររបស់គេ ដូចជាការត្រូវរកជួលផ្ទះដែលអាចប្រើប្រាស់ជាហាងបាននិងការរកជួលផ្ទះបានហើយជាដើម មិនយូរប៉ុន្មានដោយហេតុថាគេបានរៀបចំកន្លែងបានរួចស្រេចបាច់ហើយនោះ យើងក៏បានបញ្ជូនបុគ្គលិក២-៣នាក់ពីអូសាកាទៅ រួចបានធ្វើការបើកដំណើរការសាខារបស់ក្រុមហ៊ុនយើង ។

ពិតមែនហើយ ប្រសិនបើយើងចង់ធ្វើហើយគឺយើងប្រាកដជាអាចធ្វើទៅបាន ទោះបីជាអ្នកនោះមានអាយុនៅក្មេងក្តី ទោះបីអ្នកនោះមានបទពិសោធនៅក្មេងខ្ចីក្តី ប៉ុន្តែប្រសិនបើយើងប្រគល់ការងារអ្វីមួយឱ្យគេទទួលខុសត្រូវ ហើយគេមានស្មារតីទទួលខុសត្រូវខ្ពស់លើការងារនោះ នេះហើយគឺជាសារជាតិមនុស្សលោកយើង ។

ប្រសិនបើគេមានស្មារតីទទួលខុសត្រូវហើយ គេនឹងប្រឹងប្រែងធ្វើការងារនោះ ។ នៅពេលដែលគេខិតខំព្យាយាមយ៉ាងដូច្នេះ ការងារប្រាកដជាដំណើរការទៅមុខ ហើយនឹងបានទទួលលទ្ធផលល្អផងដែរ ។ នេះប្រហែលជាលក្ខណៈជាទូទៅរបស់មនុស្សលោកយើង ។

សាខារបស់ក្រុមហ៊ុនអគ្គិសនី (Matsushita) ត្រូវបានបង្កើតឡើងនៅតាមកន្លែងជាច្រើនទូទាំងប្រទេស ហើយភាគច្រើនត្រូវបានបើកដំណើរការតាមទ្រង់ទ្រាយដូចបានពោលខាងដើមនេះ ។ ដូចជាករណីនៅកាណាហ្សាវ៉ា ទាំងអាយុបុគ្គលិកក៏នៅក្មេង ទាំងខ្ញុំខ្លួនឯងក៏គិតនៅក្នុងចិត្តថា បុគ្គលិកម្នាក់នេះរាងក្មេងជ្រុលពេកក៏មិនដឹង ប៉ុន្តែកាលៈទេសៈពេលនោះតម្រូវឱ្យបុគ្គលិកម្នាក់នេះទៅទីនោះតែប៉ុណ្ណោះ ។ លើសពីអ្វីទាំងអស់ ខ្ញុំមានជំនឿចិត្តថា មនុស្សលោកយើងនេះបើតាំងចិត្តធ្វើអ្វីហើយ

នោះប្រាកដជាអាចធ្វើបាន ។ ខ្ញុំមានជំនឿចិត្តលើមនុស្សលោក ។ ការងារបើកសាខាក្រុមហ៊ុននេះគឺជាការងារធ្ងន់ធ្ងរ ប៉ុន្តែប្រសិនបើយើងផ្លាស់ប្តូរទស្សនៈយល់ឃើញនេះចេញ គឺជាការងារគួរឱ្យចាប់អារម្មណ៍ទៅវិញទេ ។ ជាងនេះទៅទៀត ប្រសិនបើខ្លួនយើងត្រូវបានគេប្រគល់ការងារឱ្យទទួលខុសត្រូវ ហើយយើងពេញចិត្តនឹងធ្វើការងារនោះទៅតាមការយល់ឃើញរបស់ខ្លួន នោះអាចនិយាយបានថា គ្មានការងារណាដែលល្អដូចការងារបែបនេះទេ ។

ទោះជាក្នុងករណីណាក៏ដោយ ការមានជំនឿចិត្តលើបុគ្គលិកនិងកូនចៅក្រោមបង្គាប់ ហើយប្រគល់ការងារឱ្យពួកគេទទួលខុសត្រូវពិតជានឹងធ្វើឱ្យអ្នកដែលត្រូវទទួលខុសត្រូវយកអស់នូវស្មារតីទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងបញ្ចេញអស់នូវទេពកោសល្យនិងសមត្ថភាពដែលខ្លួនមាន ដើម្បីបំពេញការងារនោះ ។ ដូច្នេះហើយ ខ្ញុំយល់ថាការសម្តែងចេញនូវការពេញចិត្តពេញថ្លើមក្នុងការបំពេញការងារបែបនេះនឹងនាំមកនូវលទ្ធផលជាផ្លែផ្កា ។

*(ដកស្រង់ពីវិធីសាស្ត្រនៃការគ្រប់គ្រងនិងប្រើប្រាស់មនុស្សឱ្យអស់ពីសមត្ថភាព*

*និពន្ធដោយលោក ម៉ាស៊ឹស៊ីតា កូណុស៊ឹកិ បោះពុម្ពឆ្នាំ ២០០៣)*

## សំណួរ

១. តើអត្ថបទខាងលើនេះនិយាយពីអ្វី ?

២. ចូរបង្ហាញខ្លឹមសារសំខាន់របស់អត្ថបទ ។

៣. តើមនុស្សដែលមានការទទួលខុសត្រូវជាមនុស្សដូចម្តេច ?

៤. តើត្រូវធ្វើដូចម្តេចដើម្បីជំរុញឱ្យមានការទទួលខុសត្រូវចំពោះការងារ ?

៥. ចុះអ្នកវិញ តើអ្នកមានការទទួលខុសត្រូវ ឬទេ ? ជាពិសេសការទទួលខុសត្រូវក្នុងការសិក្សាដើម្បីសម្រេចគោលបំណងរបស់អ្នកទៅអនាគត ?

៦. ចូរបង្ហាញគោលបំណងនៃអត្ថបទខាងលើ ។

៧. តើអត្ថបទនេះមានតម្លៃអប់រំដូចម្តេច ?

# ៧ រឿង ថាដូនិងភ្លើងឆេះស្រូវ



នៅពេលអ្នកស្ដាប់អត្ថបទ អ្នកគប្បីយកចិត្តទុកដាក់ប្រុងប្រៀបស្ដាប់គ្រូរបស់អ្នកអានដោយប្រុងប្រយ័ត្ន ដើម្បីឆ្លើយនឹងសំណួរទាក់ទងនឹងខ្លឹមសារអត្ថបទ ការស្គាល់ហេតុនិងផល និងតម្លៃអប់រំ ។

## សំណួរ

១. តើថាដូនិងជីតារបស់គេរស់នៅឯណា ?

២. តើជីតាប្រើថាដូយកភ្លើងមកធ្វើអ្វី ? ថាដូពេញចិត្តនឹងកិច្ចការនេះឬទេ ? ព្រោះអ្វី ?

៣. តើការសម្រេចចិត្តរបស់លោកតាត្រឹមត្រូវឬទេ ? ហេតុអ្វី ?

៤. តើទង្វើរបស់ជីតាថាដូបង្ហាញពីស្មារតីបែបណា ?

៥. ចូរបង្ហាញពីតម្លៃអប់រំរបស់អត្ថបទនេះ ។



# ឆ្លើយតបទៅនឹងការបញ្ចុះបញ្ចូល

ការបញ្ចុះបញ្ចូលគឺជាការទាក់ទាញចិត្តដោយមធ្យោបាយផ្សេងៗ ដើម្បីឱ្យនរណាម្នាក់ស្របតាមគាំទ្រ ឬធ្វើសកម្មភាពអ្វីមួយ ...។ គេមានវិធីច្រើនយ៉ាងណាស់ ដើម្បីទាក់ទាញនរណាម្នាក់ឱ្យលង់ចិត្តចូលក្នុងអន្ទាក់របស់គេ។ ការបញ្ចុះបញ្ចូលខ្លះមានគោលបំណងទៅរកផ្លូវល្អ មានផលប្រយោជន៍ និងមានកិត្តិយស។ ឯការបញ្ចុះបញ្ចូលខ្លះអូសទាញទៅរកផ្លូវអាក្រក់ គ្មានប្រយោជន៍ និងមានគ្រោះថ្នាក់។ មធ្យោបាយនៃការបញ្ចុះបញ្ចូលមានការលើកសរសើរ ការលួងលោម ការបញ្ឆោរ រហូតការទិញទឹកចិត្តតាមរយៈសម្ភារៈផ្សេងៗ ឬមាសប្រាក់ទៀតផង។

ដូចនេះដើម្បីចៀសវាងការចាញ់បោកគេ ឬធ្វើសកម្មភាពណាមួយដែលមានគ្រោះថ្នាក់នោះយើងគប្បី៖

- ពិចារណារកហេតុផលឱ្យបានច្បាស់លាស់ជាមុនសិន
- រិះគិតមើលថាតើសកម្មភាព ... ត្រឹមត្រូវតាមច្បាប់ឬទេ? ឬខុសច្បាប់?
- ស្វែងយល់ទៅលើបំណងរបស់អ្នកអូសទាញយើង(បំណងល្អឬអាក្រក់) គួរឱ្យជឿទុកចិត្តបានឬទេ?
- ស្វែងយល់ពីមនុស្សទូទៅ តើគេធ្វើដូចយើងដែរឬទេ? មានប្រយោជន៍ឬទេ?
- ពិចារណាថាតើសកម្មភាពនោះមានផលប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ ឬសង្គមឬទេ?
- ពិគ្រោះយោបល់ជាមួយឪពុកម្ដាយ បងប្អូន លោកគ្រូ អ្នកគ្រូ ...។
- ឆ្លើយតប ឬដោះស្រាយទៅតាមស្ថានភាពជាក់ស្ដែងក្នុងករណីដឹងថា សកម្មភាព ឬការអូសទាញនោះបង្កឱ្យមានគ្រោះថ្នាក់។

ក្នុងករណីមាននរណាម្នាក់បញ្ចុះបញ្ចូលអ្នកឱ្យធ្វើអ្វីមួយដោយមិនដឹងពីគោលបំណងច្បាស់លាស់ ឬមានបំណងអាក្រក់ណាមួយ អ្នកគប្បីប្រើប្រាស់បំណិនឆ្លើយតបមួយចំនួនដូចខាងក្រោម៖

## ១. ការពន្យារពេល

- ខ្ញុំសុំពេលសួរយោបល់ឪពុកម្ដាយខ្ញុំសិន។
- ខ្ញុំមិនទាន់ទុកចិត្តទេ ...។
- ខ្ញុំសុំពេលគិតមើលសិន។
- ខ្ញុំនឹងឆ្លើយតបនៅថ្ងៃក្រោយ។
- ចាំបន្តិច ...។

## ២ . បដិសេធ

- សុំទោសខ្ញុំរវល់ណាស់ ...
- ខ្ញុំមិនហ៊ានទេ ខ្លាចមានគ្រោះថ្នាក់ ...
- ខ្ញុំមិនជឿទេ ...
- ខ្ញុំខ្លាចចាញ់បោកគេ ...
- នេះជាអំពើខុសច្បាប់ ខ្ញុំមិនធ្វើទេ ។

## ៣ . អូសទាញគេវិញនិងបញ្ជាក់ហេតុផល

- ធ្វើដូចនេះជាការបំពានលើច្បាប់ មិត្តគួរចៀសវាង ...
- កុំប៉ះពាល់ កុំសាកល្បងវាឱ្យសោះ ពីព្រោះវាអាចឱ្យយើងលង់ខ្លួនក្នុងអបាយមុខ ។
- យើងស្ថិតក្នុងវ័យសិក្សា មិនគួរបោះបង់ពេលវេលារៀនសូត្រឡើយ ។
- នៅផ្ទះធ្វើស្រែចម្ការជាមួយពុកម៉ែយើងវិញ ប្រសើរជាងទៅធ្វើការងារឆ្ងាយគ្មានគោលដៅច្បាស់លាស់ ។
- ក្នុងវ័យនេះ យើងត្រូវខិតខំប្រឹងប្រែងរៀនសូត្រឱ្យមានចំណេះដឹងជ្រៅជ្រះជាមុនសិនសឹម ... ។

## លំហាត់

ចូរអ្នកហាត់និយាយតាមក្រុម ដើម្បីឆ្លើយតបទៅនឹងការបញ្ចុះបញ្ចូលរបស់អ្នកដទៃក្នុងបំណងអូសទាញអ្នកឱ្យ ៖

១. បោះបង់ម៉ោងសិក្សាមុខវិជ្ជាណាមួយដើម្បីទៅដើរលេង ។

២.ផឹកស្រានិងជក់បារី ។

៣. ប្រណាំងម៉ូតូជាមួយមិត្តភក្តិ ។

៤. ចូលរួមជាមួយមិត្តភក្តិដើម្បីទៅវាយធ្វើបាបនរណាម្នាក់ ។

នៅពេលអ្នកនិយាយ អ្នកគប្បីប្រើប្រាស់បំណិនខាងលើ និងបំណិនមួយចំនួនទៀត ដើម្បីទាក់ទាញទឹកចិត្តគេ ។

# អត្ថបទបញ្ចុះបញ្ចូល

អ្នកបានសិក្សារួចហើយពីការឆ្លើយតបទៅនឹងការបញ្ចុះបញ្ចូល ។ ឥឡូវនេះ អ្នកនឹងសិក្សាពីការសរសេរអូសទាញអ្នកដទៃវិញម្ដង ។ ដើម្បីអូសទាញ ឬបញ្ចុះបញ្ចូលឱ្យអ្នកដទៃធ្វើតាមឬជឿជាក់មកលើយើងពិតប្រាកដនោះ យើងគប្បីចេះប្រើសំនួន ឬបំណិនបញ្ចុះបញ្ចូលនិងប្រើមធ្យោបាយផ្សេងៗទៀត ដើម្បីឱ្យគេដើរតាមគោលបំណងរបស់យើង ។ ខាងក្រោមនេះជាសំណេរបញ្ចុះបញ្ចូលមួយដែលបង្ហាញពី "ផលអាក្រក់ច្រើនយ៉ាងកើតពីការផឹកគ្រឿងស្រវឹង" ។

គ្រឿងស្រវឹងមានច្រើនម៉ាកនិងច្រើនប្រភេទដូចជា ស្រាបៀ ស្រាដប និងភេសជ្ជៈផ្សេងៗទៀតដែលគេធ្វើការវេចខ្ចប់ប្រកបដោយភាពទាក់ទាញនិងមានតម្លៃច្រើនកម្រិតតាំងពីតម្លៃថោករហូតដល់ស្រាខ្លះមានតម្លៃខ្ពស់បំផុត ។ ដើម្បីប្រមូលកៀរគរអ្នកគាំទ្រ អ្នកប្រើប្រាស់ផលិតផលទាំងនេះ គេមានសិល្បវិធីដែលផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយមួយចំនួនតាមរយៈបង្ហាញរូបភាពស្រស់សង្ហានៃតារានានាក្នុងការឃោសនា ព្រមទាំងប្រកាសផ្ដល់រង្វាន់លើកទឹកចិត្តជាច្រើន ដើម្បីទាក់ទាញអតិថិជននិងមហាជនទូទៅឱ្យចាប់អារម្មណ៍លើផលិតផលទាំងនោះ ។

រួមផ្សំជាមួយនឹងទម្លាប់របស់ប្រជាជនយើង ដែលរាល់ពេលមានពិធីតូចធំ ការជួបជុំមិត្តភក្តិ ខួបកំណើត បុណ្យទាន ពិធីមង្គលការ ពិធីជប់លៀង ...សុទ្ធតែយកស្រា ស្រាបៀនិងភេសជ្ជៈផ្សេងៗមកទទួលភ្ញៀវ ដើម្បីជាកិត្តិយសនិងធ្វើឱ្យពិធីកាន់តែហ៊ឹកហ៉ាក់ថែមទៀត ។ ក្នុងពិធីជួបជុំគ្នាសប្បាយរីករាយយ៉ាងនេះ គេតែងតែនាំគ្នាផឹកស៊ីនិងញុះញង់គ្នាឱ្យកាន់តែផឹកច្រើនឡើង ដោយភ្លេចគិតដល់សុខភាពខ្លួននិងផលអាក្រក់ច្រើនរាប់មិនអស់ដែលកើតឡើងពីការស្រវឹងនោះឡើយ ។ ការសេពគ្រឿងស្រវឹងលើសលប់នាំឱ្យប៉ះពាល់ដល់សុខភាពជាចម្បងនិងធ្វើឱ្យបាត់បង់ការទទួលខុសត្រូវ ហើយបង្កបញ្ហាច្រើនដូចជា ការទាស់ពាក្យសម្ដីឈានទៅដល់ការប្រព្រឹត្តអំពើឃាតកម្ម ការបង្កគ្រោះថ្នាក់ចរាចរណ៍ អំពើចោរកម្ម ការចម្លងមេរោគអេដស៍ អសន្តិសុខក្នុងសង្គម និងប្រព្រឹត្តអំពើពាលាផ្សេងៗដោយខុសច្បាប់ ។ល ។ លើសពីនេះទៅទៀត ការចំណាយថវិកាដ៏ច្រើនទៅលើគ្រឿងស្រវឹងគឺជាការខាតបង់ច្រើនយ៉ាង គឺសុខភាពមិនមាំមួន ការទាស់ទែងខ្វែងគំនិតនាំទៅដល់ការកាប់សម្លាប់ដែលជាប់ពាក់ព័ន្ធនឹងច្បាប់ ហើយជួនកាលបង្កឱ្យមានការបាត់បង់ជីវិតផងដែរ ។ ដូចនេះ អ្នកដែលញៀននឹងគ្រឿងស្រវឹងត្រូវតែរកវិធីកាត់បន្ថយ ចៀសវាងការផឹកហួសកម្រិត ដែលបង្កឱ្យមានបញ្ហាដូចបានរៀបរាប់ខាងលើ ។ ចំពោះអ្នកដែលមិនទាន់ចេះផឹក ឬមិនទាន់ញៀន សូមកុំសាកល្បងឬបន្ត

ទៅទៀតឱ្យសោះ ។ ប្រសិនបើអ្នកហ៊ានសាកល្បង នោះគ្រោះមហន្តរាយនៅក្បែរខ្លួនអ្នកជានិច្ច ហើយនៅពេលណាគ្រឿងស្រវឹងជ្រាបចូលក្នុងខ្លួនវានឹងហាក់មកប្រញ្ញីជីវិតអ្នកភ្លាម ។

ដូចនេះ យើងទាំងអស់គ្នាមិនត្រូវលង់ខ្លួននឹងការផ្សព្វផ្សាយដែលមានរូបភាពប្រណីតៗអម ដោយវង្វាន់លើកទឹកចិត្តធ្វើឱ្យយើងភ្លេចគិតពីផលវិបាកនៃគ្រឿងស្រវឹង ព្រោះការប្រព្រឹត្តគ្រឿងស្រវឹងហួសកម្រិតនឹងនាំឱ្យយើងធ្លាក់ទៅក្នុងគ្រោះមហន្តរាយ ។ យើងទាំងអស់គ្នាគប្បីគិតដល់សុខភាពខ្លួនឯង គ្រួសារ សុភមង្គលខ្លួនឯង និងសង្គមជាតិរបស់យើង ។

## សំណួរ

១. តើសំណោរនេះនិយាយពីបញ្ហាអ្វី ?

២. ចូរបង្ហាញពីគំនិតសំខាន់ៗនៅក្នុងអត្ថបទសំណោរនេះ ។

៣. ចូរស្រង់សំនួនវោហារអូសទាញពីក្នុងអត្ថបទនេះ ។

៤. តើអត្ថបទនេះបង្ហាញពីផលអាក្រក់ ដែលកើតឡើងពីការស្រវឹងដូចម្ដេចខ្លះ ?

## លំហាត់

ចូរអ្នកសរសេរអត្ថបទបញ្ចុះបញ្ចូលតាមប្រធានបទខាងក្រោម ៖

១. បញ្ចុះបញ្ចូលមិត្តភក្តិរបស់អ្នកឱ្យឈប់ដើរលេងយប់ ។

២. បញ្ចុះបញ្ចូលមិត្តភក្តិឱ្យខិតខំសិក្សាមុខវិជ្ជាណាមួយ ដែលគេមិនបានពិន្ទុខ្ពស់ ។

៣. បញ្ចុះបញ្ចូលមិត្តភក្តិឱ្យបោះបង់ការជក់បារី ។

៤. បញ្ចុះបញ្ចូលមិត្តភក្តិឱ្យគោរពច្បាប់ចរាចរណ៍ ។

មេរៀនទី ៨

# ការជឿជាក់



ការជឿជាក់កើតឡើងពីភាពប្រាកដប្រជាក្នុងចិត្ត ការជឿជាក់ចំពោះខ្លួនឯង និងការទុកចិត្តលើអ្នកដទៃ។ ការមានជំនឿក្នុងចិត្តនិងមានទំនុកចិត្តនឹងជំរុញឱ្យមានសេចក្តីក្លាហាន អំណត់ព្យាយាម ដែលជាកត្តានាំឆ្ពោះទៅរកភាពខ្ពង់ខ្ពស់ ប្រសើរថ្លៃថ្លា និងជ័យជំនះ។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាស្វែងយល់ពីអត្ថបទ ដែលលើកឡើងពីការជឿជាក់ចំពោះខ្លួនឯងនិងអ្នកដែលគួរឱ្យជឿទុកចិត្ត។ ទន្ទឹមនឹងនេះ អ្នកនឹងបានសិក្សាបន្ថែមទៀតអំពី អ្នកនិពន្ធ ទំនាស់ កាលអាកាស ទំហៀបន័យ ជំនួយកិរិយា ការសម្តែងល្ខោនខ្លីៗ ការសរសេរសង្ខេបអត្ថបទល្ខោនជាពាក្យរាយ។

# បម្រើបម្រាស់ភាសាក្នុងអត្ថបទល្ខោនបាសាក់

ប្រវត្តិនិងដើមកំណើតសម្រាប់សម្គាល់ល្ខោនខ្មែរ ត្រូវបានគេស្គាល់ តាមរយៈការចារជាក្បាច់លោតនៅតាមជញ្ជាំងប្រាសាទ ពីព្រោះពួកគេចង់បង្ហាញពីការឆ្លងកាត់នៃជំនាន់មួយទៅជំនាន់មួយ ដោយការចងចាំ និងការនិយាយតៗគ្នាពីមាត់មួយទៅមាត់មួយ ។ ទ្រង់ទ្រាយនៃសិល្បៈត្រូវបានបង្កើតឡើងមុនសម័យអង្គរ ។ ល្ខោនបានចាប់ផ្តើមក្រោយសម័យអង្គរ ដូចជាសម័យលង្វែក សម័យឧដុង្គ និងសម័យចតុមុខ ។ បទភ្លេងល្ខោនដែលល្បីល្បាញបានចងក្រងឡើងដោយខ្សែរឿងជាច្រើន និងទេវកថា ។ ប្រភេទនៃល្ខោនគឺសម្គាល់លក្ខណៈផ្សេងៗគ្នាដោយប្រើប្រាស់ភ្លេង និងអត្ថបទភ្លេងដកចេញពីប្រជុំមាតិការឿងបន្តរតាមដូចជា ល្ខោនមហោរី ល្ខោនគែន ល្ខោនបាសាក់ជាដើម ។ ចំពោះល្ខោនបាសាក់ក៏មានទម្រង់មិនខុសពីល្ខោនដទៃទៀតដែរ ប៉ុន្តែបានយកឈ្មោះរបស់ខ្លួនពីទីកន្លែងកំណើតនៃសិល្បៈនេះដែលបានរីកចម្រើនទៅវិញ ។ ល្ខោនបាសាក់មានកំណើតនៅស្រុកបាសាក់ខេត្តឃ្លាំងទល់មុខខេត្តព្រះត្រពាំងនៃទឹកដីកម្ពុជាក្រោម ។ ម្យ៉ាងទៀត បាសាក់នេះ ជាឈ្មោះទន្លេមួយ ហើយជាខ្នែងមួយនៃទន្លេមេគង្គទាំងបួនដែលប្រសព្វគ្នានៅភ្នំពេញ "ចតុមុខ" ។ ទន្លេនេះបានហូរចាក់ទៅឈូងសមុទ្រចិនគឺនៅទន្លេនេះហើយដែលជាទីតាំងនៃស្រុកបាសាក់ ខេត្តឃ្លាំងទល់មុខនឹងខេត្តព្រះត្រពាំងដែលល្ខោនបាសាក់បានចាប់កំណើតឡើង ។

ចំពោះការប្រើប្រាស់ភាសានៅក្នុងល្ខោនបាសាក់វិញ មានលក្ខណៈចម្រុះទៅដោយការប្រើប្រាស់ជាចម្រៀង ពាក្យជូន ពាក្យកាព្យ ពាក្យរាយ រាជសព្ទ ឬសង្ឃសព្ទជាដើម ។

ចូរអ្នកអានឧទាហរណ៍ខាងក្រោម :

- **ឧកញ៉ាពិភា** : លោកជំទាវ ព្រះបាទករុណា ស្តេចសម្រែជាអម្ចាស់យាងមកដល់ហើយ លោកជំទាវ ។
- **ជំទាវស្រែន** : ព្រះអង្គយាងមកដល់ហើយ ! នែបងប្អូនទាំងអស់គ្នា មើលរៀបចំធ្វើពិធីព្រះរាជបដិសណ្ឋារកិច្ច ដូចដែលខ្ញុំបានរៀបចំចាត់ចែង រួចមកអីចឹងណាអស់លោក ។
- **អ្នកបម្រើ** : បាទ ! លោកជំទាវ ។
- **ជំទាវស្រែន** : អា៎ ! សូមក្រាបថ្វាយបង្គំ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង... ។ អា៎ ! អា៎ !... នែ៎... នែ៎ល្អហើយៗ ។ យី ! ជំទាវស្រែនស្អាតលើសពាក្យដែលគេនិយាយទៅទៀត ។ យី !... អើ... អ៊ី... អ៊ី... លោកជំទាវ.... ។

- ជំទាវស្រែន : ព្រះករុណាជាម្ចាស់ សូមស្ដេចយាងចូលក្រាបទូល ។
- ស្ដេចសំរ៉ែ : អូ ! អូ ! យាងចូល ? យី ! ជំទាវស្រែនស្អាតណាស់ ! អូយាងចូល ! អូស្អាតណាស់ ! ស្អាតលើសស្រីលើផែនដីនេះទៅទៀត ... ។
- ជំទាវស្រែន : សូមព្រះអង្គយាងចូលមក កុំខ្លាចអី ... ។
- ស្ដេចសំរ៉ែ : (ច្រៀង)ឱកែវជីវាមេត្ដាបង បានយល់ភក្ត្រនួនល្អង ព្រឺព្រួចកន្លងក្នុងចិន្ដា លន់តួក្ដីស្នេហា ឱណាកែវមាសបងអើយ (២ដង) ។
- ជំទាវស្រែន : (ច្រៀង)ខ្ញុំម្ចាស់ស្មោះស្ម័គ្រ(២ដង) តែខ្ញុំម្ចាស់លាក់មិនវាចា (២ដង) សូមព្រះអង្គយាង(២ដង)ចូលឆាប់រ៉ា មានព្រះក្រយារៀបចំថ្វាយស្រេច (២ដង) ។
- ជំទាវស្រែន : ឱះ ! សូមព្រះអង្គយាងគង់ លើព្រះទែននេះក្រាបទូល ។ ខ្ញុំម្ចាស់នៅគាល់បម្រើព្រះក្រយាដោយផ្ទាល់ដៃ ណ៎ក្រាបទូល ។
- ស្ដេចសំរ៉ែ : អស្ចារ្យ ! អស្ចារ្យ ! យី ជំទាវស្រែន (ស្ដេចសម្រែរំភើប) ។
- ជំទាវស្រែន : ពួកនាងទាំងអស់គ្នា ! លើកក្រយាមក (ជំទាវបញ្ជាទៅអ្នកបម្រើ) ។
- ស្ដេចសំរ៉ែ : អូ ! អូ ! ក្រយា ! យី ! ជំទាវប៉ិនប្រសប់ តុបតែងទីលំនៅ ស្អាតរុងរឿងប្រៀបបាននឹងវាំងស្ដេច ។ យី ! មើល៍ ...ន៎ែ អើ ! ពីខ្ពល់ខ្មៅយ សុទ្ធតែប៉ាក់ឱន រំលេចទឹកមាស ។
- ជំទាវស្រែន : ពរព្រះអង្គ ! សូមព្រះអង្គប្រទានកិត្តិយស ដល់ខ្ញុំម្ចាស់មួយពែងទៀតក្រាបទូល ។
- ស្ដេចសំរ៉ែ : មិនអីទេ ! មិនអីទេ ! អើៗ អឺៗ...បានស្រែនចាក់ស្រាឱ្យសោយយ៉ាងនេះ ទោះជាត្រូវស្រវឹងដល់ស្លាប់ក៏ដោយក៏មិនខ្លាចដែរស្រែន ...
- ក្រុមច្រៀងបំពេ : ឱព្រះអង្គអើយ ស្ដេចសោយទៅ ក្រយាគ្រប់បែប ថ្វាយព្រះចក្រីអើយ (២ដង) ស្រាក្រហមខៀវ លាយបទតន្ត្រី ទាសាទាសីគាល់ចាំអើយត្រៀបត្រាអើយ... អឺ...អឺ..អឺ..អឺងអើយគាល់ចាំឱត្រៀបត្រា(២ដង) ។ ឱរាត្រីអើយ រាត្រីរនោច លន្លង់លន្លោច ខ្វាយខ្វល់ឱរាអើយ(២ដង) មេឃបាត់ដួងចន្ទ សុទ្ធតែតារា ប្រៀបដូចបុប្ផាត្រូវការហោមន្ដអើយ ...ហា ...អ៊ឹងអើយ ...អ៊ឹងអើយ ...ត្រូវការហោមន្ដ ។

*(ដកស្រង់ដោយកត់ត្រាចេញពីល្ខោនបាសាក់សម្ដែងតាមវិទ្យុ តេដោយ៉ត របស់លោក ទីជីហ្វូត)*

តាមអត្ថបទនេះបានបង្ហាញពីការសន្ទនារវាងតួអង្គដោយការប្រើ ៖

## ក. ពាក្យស្ដេច(រាជសព្ទ)

- ព្រះបាទព្រះករុណា ៖ ស្ដេចព្រះរាជាដ៏ប្រសើរ ។
- អម្ចាស់ ៖ ម្ចាស់ ម្ចាស់ជីវិតលើត្បូង ម្ចាស់ផែនដី ។
- យាង ៖ ទៅ ឬមក ។
- ព្រះរាជបដិសណ្ឋារកិច្ច ៖ ទទួលស្វាគមន៍ដោយយកចិត្តទុកដាក់ ។
- យាងគង់ ៖ អញ្ជើញចូលអង្គុយ ឬសម្រាក ឬទម្រេតខ្លួន ។
- ព្រះនេត្រ ៖ ភ្នែក ។

## ខ. ពាក្យរាយ

- លោកជំទាវ ព្រះករុណា ស្ដេចសម្រេចជាអម្ចាស់យាងមកដល់ហើយ ... ។
- ពួកនាងទាំងអស់គ្នា ! លើកក្រយាមក (ជំទាវបញ្ជាទៅអ្នកបម្រើ) ។
- តាំងពីខ្ពល់ខ្មៅយសុទ្ធតែប៉ាក់ឌិន រំលេចទឹកមាស ... ។

## គ. ពាក្យឧទាន

- យី ! ជំទាវប៉ិនប្រសប់ ... ។
- អ៊ាំ ! អ៊ាំ ! ... ន៏ ... ន៏ល្អហើយ ... ។
- យី ! មើល៍ ... ន៏ ... ។

## ឃ. ពាក្យសមញ្ញ

- ចូលឆាប់
- បងប្អូន ...
- អ៊ីចឹង ...
- មើលរៀបចំ ... ។

## ង. ភាសាបដិរូប(បដិរូបនៃភាសា)

- និមិត្តរូបារម្មណ៍ :
  - រាត្រីរនោច : តំណាងឱ្យភាពអួរអាប់ ។
  - មេឃ : តំណាងឱ្យទឹកចិត្ត ។
  - ដួងចន្ទ : តំណាងឱ្យក្ដីសង្ឃឹម ។
  - តារា : តំណាងឱ្យអ្នកជិតខាង ។
  - បុប្ផា : តំណាងឱ្យនារីរងគ្រោះ ។
  - ហេមន្ត : តំណាងឱ្យក្ដីសង្ឃឹម ។
- ឧបមានរូបារម្មណ៍ :
  - មេឃបាត់ដួងចន្ទ សុទ្ធតែតារា ប្រៀបដូចបុប្ផា ត្រូវការហេមន្តអើយ... ។
- ចួន :
  - ស្មោះស្ម័គ្រ ═══ ខ្ញុំម្ចាស់លាក់
  - ចូលឆាប់រ៉ា ═══ ព្រះក្រយា
- ផ្ទួន :
  - ម្ចាស់ ═══ ម្ចាស់
- រណ្ដំ :
  - ស្មោះ ├──┤ ស្ម័គ្រ

*ភាសាក្នុងល្ខោនបាសាក់មានភាពចម្រុះប្រកបដោយតន្ត្រីភាពនិងមានទម្រង់ជាភាសានិយាយរៀបរាប់យ៉ាងសាមញ្ញនិងបែបធម្មជាតិ ។ ពាក្យពេចន៍ដែលប្រើក្នុងល្ខោនបាសាក់មានច្រើនស្ថានភាពដូចជា រាជសព្ទ(សម្រាប់វណ្ណៈក្សត្រិយ៍) សង្ឃសព្ទ(សម្រាប់ព្រះសង្ឃ) ពាក្យសមញ្ញ(សម្រាប់ប្រជាជនធម្មតា) ពាក្យហៅតាមឋានៈ(មន្ត្រី សេដ្ឋី...) ពាក្យរាយ ពាក្យចួន ពាក្យឧទាន ពាក្យសំណើច ពាក្យយំយែក និងភាសាបដិរូប ... ។*

## លំហាត់

ចូរអ្នកស្រង់ពាក្យដែលមាននៅក្នុងអត្ថបទដកស្រង់ខាងក្រោម ទៅតាមក្រុមដូចតារាងគំរូខាងលើនេះ ។

ស្ដេចសំរែ : អាំ! ជំទាវស្រែន ! ជំទាវស្រែនលែងប្ដី ! យី ! ជំទាវស្រែនស្អាតណាស់ ។ ឱ! យើងចង់បានណាស់ ។ (ច្រៀង) : ឮឈ្មោះនាង ស្រែន ចាប់ផ្ដើមស្នេហា ចង់បានកនិដ្ឋារួមរក្សមេត្រី ។ អស់អញជាស្ដេចត្រូវមានមហេសី (២ដង) រូបស្អាតប្រិមប្រិយដូចទេពកញ្ញា ។ អាំ! បើតាមស្ដាប់តាមការរៀបរាប់របស់ពួកអាមាត្យ ជំទាវស្រែនប្រាកដជាមានទឹកចិត្តមកលើយើងមិនខាន ហាស ! ហាស ! ហាស ! ។

ឧកញ៉ាពិភា : សូមក្រាបថ្វាយបង្គំព្រះករុណា (ឧកញ៉ាពិភាចូលដល់) ។

ស្ដេចសំរែ : អើ !

ឧកញ៉ាពិភា : តើព្រះអង្គទ្រង់ត្រាស់ ហៅទូលបង្គំចូលគាល់នេះ មានកិច្ចការអ្វីទៅក្រាបទូល ?

ស្ដេចសំរែ : អើ ! មានការមួយយ៉ាងសំខាន់ណាស់ លោកឧកញ៉ាពិភា ។

ឧកញ៉ាពិភា : ព្រះករុណាថ្លៃវិសេស ។

ស្ដេចសំរែ : មហាតលិករបស់យើងបានមកទូលថា ជំទាវស្រែនបានឈ្លោះទាស់ទែងនឹងតេជោមាសជាស្វាមីរហូតលះលែងគ្នា ហើយចែកទ្រព្យសម្បត្តិគ្នារៀងខ្លួន ។ ហាស ! ហាស ! ហា !ឥឡូវនេះនារីស្រែនមកបើកផ្ទះលក់ត្រីងៀតនិងផ្ទះលក់គ្រឿងអាវុធ នៅនឹងទីផ្សារកំពង់ហៅមែនទេ ?

ឧកញ៉ាពិភា : ករុណាថ្លៃវិសេស រឿងពិតដូចជាបន្ទូលព្រះអង្គមែនក្រាបទូល ។

ស្ដេចសំរែ : អូមែន ! អេះ ។

ឧកញ៉ាពិភា : ផ្ទះលក់អាវុធនោះ គឺមានសុទ្ធតែកាំបិទផ្គាក់ ហើយនិងដាវល្អៗណាំព្រះអង្គ ។

ស្ដេចសំរែ : អើ ! មិនតែប៉ុណ្ណោះ មហាតលិកវាបានទូលថា ពួកអ្នកបម្រើរបស់ជំទាវស្រែនដែលកាន់កាប់ផ្ទះលក់ត្រីងៀតនិងផ្ទះលក់អាវុធទាំងនោះ បើឃើញពលទាហានរបស់តេជោមាសទៅទិញត្រីងៀត គេលក់ថ្លៃណាស់ ។ ប៉ុន្តែ ...ហោះ

ហោ ! បើពលទាហានយើងទៅទិញ គេលក់ថោកជាទីបំផុត ។ ដូច្នេះជំទាវស្រែនច្បាស់ជានាងកួចចិត្តស្រឡាញ់យើងហើយ ។ លើសពីនេះទៀតឮថានាងស្អាតដូចទេពអប្សរអីចឹង ហ៊ិះ ...ហ៊ឺ ... ។

ឧកញ៉ាពិភា : ព្រះករុណាជាអម្ចាស់ ពិតដូចពាក្យមហាតលិកប្រាកដណាស់ ។

ស្ដេចសំរែ : ប្រាកដមែន ?

ឧកញ៉ាពិភា : ជំទាវស្រែនមានអាយុ ទើបតែ២៨ឆ្នាំប៉ុណ្ណោះ ។

ស្ដេចសំរែ : ២៨ឆ្នាំ ? អូ !

ឧកញ៉ាពិភា : ព្រះករុណាថ្លៃវិសេស ក៏ប៉ុន្តែមិនទាន់មានកូនមួយសោះ ។ ចំណែករូបសោតទៀត នែ៎សាច់ក៏ល្អស្អាតលើសស្រីក្រមុំព្រហ្មចារីយ៍ ដែលទើបចេញពីម្លប់ទៀតណា៎ព្រះអង្គ ។

ស្ដេចសំរែ : យី ! ម្លឹងផង !

ឧកញ៉ាពិភា : ហើយក្នុងឆ្នាំនេះ ព្រះអង្គទើបមានព្រះជន្ម ៤២ ព្រះវស្សា ។

ស្ដេចសំរែ : ទើបតែ ៤២ ព្រះវស្សាទេតើ ! (ស្ដេចសំរែបន្ទរ) ។

ឧកញ៉ាពិភា : ហើយបើបានជំទាវស្រែនមកជាអគ្គមហេសី ឃើញថាសក្តិសមជាទីបំផុតណា៎ក្រាបទូល ។

ស្ដេចសំរែ : ហាស ! ហាស ! ហា ! អើ ! ប្រសើរណាស់ៗ ។ ដូច្នេះហើយ បានជាយើងហៅលោកឧកញ៉ាមកពេលនេះណា៎ ។

ឧកញ៉ាពិភា : ព្រះករុណាថ្លៃវិសេស ។

ស្ដេចសំរែ : ចូរលោកនាំយកទ្រព្យរបស់ល្អៗ ដែលមានតម្លៃរបស់យើងទៅជូនជំទាវស្រែនហើយនិយាយស្ទាបស្ទង់ចិត្តនាងមើល៍ណា៎ ។

ឧកញ៉ាពិភា : ករុណាថ្លៃវិសេស ទូលបង្គំធានាថា និងខិតខំបំពេញកិច្ចការនេះលុះត្រាតែព្រះអង្គ បានសម្រេចដូចព្រះរាជបំណងក្រាបទូល ។

*(ដកស្រង់ដោយកត់ត្រាចេញពីល្ខោនបាសាក់សម្ដែងតាមវិទ្យុ តេជោយ៉ត របស់លោក ទីជីហួត)*

# រឿង តេជោយ័ត



## ក. សិក្សាពាក្យគន្លឹះ

- តេជោ (ន) : អំណាច កម្លាំង អានុភាព ... ។ ឧទាហរណ៍ : តេជោមាស គោរមងារ តំណាងអ្នកមានអំណាច ឬអានុភាពខ្លាំងក្លា ។
- ជំទាវ (ន) : បណ្ដាសក្ដិសម្រាប់ស្ដ្រីជាភរិយាសេនាបតី ដោយព្រះករុណាទ្រង់ប្រោស ព្រះរាជទានតាំង ជំទាវ លោកជំទាវ ។ បណ្ដាសក្ដិនេះទោះបីភរិយារបស់ មន្ត្រីថ្នាក់តូចជាងនេះ គឺក្រៅពីសេនាបតីក៏ទទួលសក្ដិនេះបានដែរ អាស្រ័យដោយព្រះមហាក្សត្រព្រះរាជទានតែងតាំង ។
- ពិទូរ្យ (ន) : ពេជ្រភ្នែកឆ្មា ។
- សូរ្យកាន្ត (ន) : ត្បូង ឬកែវមួយប្រភេទ កាលបើគេយកទៅដាក់ឱ្យចំពន្លឺព្រះអាទិត្យ វា អាចបញ្ចេញកម្ដៅយ៉ាងខ្លាំងបាន ឬក៏បង្កើតជាភ្លើងបាន ។ គេសន្មតថាជា កែវមានគុណភាពពូកែស័ក្ដិសិទ្ធិ ។
- ជន្មា (ន) : អាយុសង្ខារ ជីវិត ... ។
- ពលិកម្ម (ន) : ការលះបង់ ការបូជា ។
- អនិច្ចកម្ម (កិ) : ស្លាប់ ងាប់ ។
- ភក្ត្រា (ន) : មុខ ។
- សហការី (ន) : អ្នកធ្វើការជាមួយគ្នា អ្នកព្រួតជួយគ្នាធ្វើការណាមួយ ។

- សោកា (កិ) : ទួញយំ យំសោក
- វណ្ណៈ (ន) : ថ្នាក់វង្ស ពូជវង្ស ។ តាមលទ្ធិព្រាហ្មណ៍ចែកមនុស្សជា ៤ថ្នាក់ គឺវណ្ណៈព្រាហ្មណ៍ វណ្ណៈក្សត្រ វណ្ណៈវៃស្យៈ និងវណ្ណៈសូទ្រ ។
- សប្បុរសធម៌ (ន) :ការប្រព្រឹត្តល្អ ។
- គុន (ន) : ឈ្មោះសិល្បខាងគ្រឿងអាវុធសម្រាប់ប្រឡូកលោតហក់តយុទ្ធផ្ទាល់ខ្លួន ។
- វិបត្តិ (ន) : សេចក្តីប្រែប្រួល ដំណើរនៃសេចក្តីវិនាស អន្តរាយ ដំណើរគ្រោះថ្នាក់ ការភ្លាត់ខុស ។
- បុណ្យ (ន) : គុណជាគ្រឿងជម្រះសន្តានចិត្ត កុសល អំពើល្អ សេចក្តីសុខ ។
- សក្តិ (ន) : អំណាច ភាពខ្លាំងពូកែ ។
- ចុតហ្វាយ (ន) : សំបុត្រ ។
- ថ្វាយ (កិ) : ឱ្យ (ប្រើសម្រាប់រាស្ត្រធ្វើចំពោះស្តេច ប្រើសម្រាប់ស្តេចធ្វើចំពោះរាស្ត្រវិញ គឺឱ្យស្មើនឹងប្រទាន) ។

## ខ. អភិវឌ្ឍន៍បំណិន

អ្នកគប្បីអានអត្ថបទល្ខោននេះដោយយកចិត្តទុកដាក់ ដើម្បីត្រៀមលក្ខណៈឆ្លើយនឹងសំណួរទាក់ទងនឹង អ្នកនិពន្ធ កាលកំណត់តែង ទំនាស់ កាលអាកាស ទំហៀបន័យ និងខ្លឹមសារអត្ថបទ ។

## គ. អត្ថបទ (ឆាកទី ៨)

[...] **ជំទាវស្រែន :** យី! បង! បង! បងមាសហេតុអី? បងក្អួតឈាមច្រើនម្ល៉េះបង!

**តេជោមាស :** អូនស្រែនៗទប់ស្មារតី កុំតក់ស្លុតឱ្យសោះ គ្មានមនុស្សណាចៀសផុតពីការស្លាប់ គ្រាន់តែមុននិងក្រោយតែប៉ុណ្ណោះ! ។

**ជំទាវស្រែន :** យី! លោកអើយ! ម៉េចអីចឹង ... យ៉ត! យ៉តអឺយយ៉ត! ឆាប់នាំគ្នាមកជួយលោកគ្រូឯងទៅ ។

**យ៉ត :** យី! លោកគ្រូៗ កើតអីហ្នឹងបានជាឈាមទាំងស្រស់អីចឹងលោកគ្រូ!

**ជំទាវស្រែន :** ឈាមច្រើនណាស់ ប្តីសម្លាញ់ៗហេតុអ្វីបងមានរឿងចម្លែកបែបនេះបង ! អូនមិនស្មានៗថាបងយ៉ាងនេះទេ!

**យ៉ត :** លោកគ្រូៗ ម៉េចអីចឹង!

**តេជោមាស :** យ៉ត ឯងមកជិតយើងបន្តិចមក!

**យ៉ត :** ខ្ញុំនៅជិតលោកគ្រូទេ!

**ជំទាវស្រែន :** ម៉េចក៏ឈាមបងធ្លាក់ច្រើនម្ល៉េះ អូនភ័យណាស់!

តេជោមាស : ស្រែនអូនៗ បងមិនរស់ទេ!

ជំទាវស្រែន : (ច្រៀង) លោហិតស្វាមីអើយ ធ្លាក់ស្រោចរាងកាយ ទឹកភ្នែកអូនខ្វាយ ស្រោចស្រពភក្ត្រា (២ដង) មិននឹកស្មានសោះជួបរឿងសោកាឱម្ចាស់ជីវ៉ា តើមូលហេតុអ្វី ?

យ៉ត : លោកគ្រូ ឈាមច្រើនណាស់!

ជំទាវស្រែន : យ៉តអើយ! ឆាប់ទៅរកគ្រូព្យាបាលភ្លាមទៅ ។

តេជោមាស : យ៉ត! កុំទៅណាឆ្ងាយពីគ្រូឱ្យសោះណាឮទេ!

យ៉ត : បាទ!

តេជោមាស : កុំ! កុំអី! ឥតប្រយោជន៍ទេ ឯណា! ឯណា! លោកស្មៀនចូលមក!

លោកស្មៀន : បាទ! លោកម្ចាស់

តេជោមាស : ចូរលោកចាត់ហៅប្រមូលអស់លោក ដែលជាសហការីរបស់ខ្ញុំទាំងអស់ឱ្យមកជួបជុំគ្នាភ្លាមៗឡើង! ។

ជំទាវស្រែន : បង ! សូមបងសម្រាកទៅ កុំប្រឹងនិយាយច្រើនពេកឈាមបងច្រើនណាស់ !

តេជោមាស : ឱ្យបងនិយាយចុះ ឱ្យបងនិយាយចុះ ស្រែនអូននេះជាឆាកជីវិតចុងក្រោយរបស់ប្តីអូន! ឯណាយ៉តចូលមកជិតបន្តិចមក! ។

យ៉ត : បាទ! លោកគ្រូរឿងអីកើតឡើង! រឿងរបៀបណាបានជាត្រូវរងគ្រោះបែបនេះ ?

តេជោមាស : ឯងនឹកមិនឃើញទេឬអី ? កាលដែលគ្រូប្រយុទ្ធនឹងស្តេចសំរែនៅច្រកភ្នំនោះ ហើយផុងក្នុងរណ្តៅភ្លាត់ស្មៀតត្រូវវាដាល់គ្រូមួយដៃចំដើមទ្រូងណា!

យ៉ត : បាទ ! ខ្ញុំនៅចាំទាំងអស់ ។

តេជោមាស : ប៉ុន្តែមានឯងរងទាន់ កុំអីស្តេចសំរែនោះវាកាត់ក្បាលបានបាត់ទៅហើយ ។ ឯងដឹងទេក្បាច់ប្រដាល់ដែលវាដាល់គ្រូនោះ គឺជាក្បាច់យ៉ាងសាហាវបំផុតនៅក្នុងស្មៀតមហាទម្ងន់ណាយ៉ត ! ។

យ៉ត : ហ៎ា ! ក្បាច់មហាទម្ងន់ ! (យ៉តពោលដោយរន្ធត់) ។

តេជោមាស : ត្រូវហើយ ដូចដែលគ្រូធ្លាប់តំណាលអីចឹង ! បើក្រៅពីគ្រូវិញ ត្រូវមួយដៃនោះប្រហែលជានៅមួយកន្លែងទៅហើយណាយ៉ត ! ។

យ៉ត : បើដឹងដូច្នេះ ហេតុអ្វីក៏លោកគ្រូមិនព្យាបាល ?

តេជោមាស : គ្មានវិធីព្យាបាលទេ គ្រឿងក្នុងរបស់លោកគ្រូខ្ទេចខ្ទាំអស់ហើយ វាគ្រាន់តែពន្យារពេលបានយូរខែប៉ុណ្ណោះទេ គ្រូនឹងមុខជាស្រេចទៅហើយ ។ យ៉ត ! គង់តែមានថ្ងៃនេះទេ

យ៉ត : ទេ ! ទេ ! ខ្ញុំត្រូវតែសង្គ្រោះលោកគ្រូឱ្យទាល់តែបានជាដាច់ខាត ។

តេជោមាស : ឥតប្រយោជន៍ទេៗ យ៉តឥឡូវឯងនិយាយមកមើល ! ឯងរស់នៅជាមួយគ្រូជាង ១០ ឆ្នាំនេះ តើឯងយល់ឃើញយ៉ាងណាដែរចំពោះលោកគ្រូ ?។

យ៉ត : លោកគ្រូ ! រាល់ទិវារាត្រី ខ្ញុំនឹកមិនភ្លេចទេចំពោះឧបការគុណរបស់លោកគ្រូដែលមានចំពោះខ្ញុំ ។ យ៉ត ខ្ញុំនេះជាកូនជនជាតិភាគតិចកំព្រាឪពុកម្តាយ ដើរសាត់ត្រាត់សែងត្រែងត្រូវអ្នកផងទាំងពួងគេមើលងាយមើលថោក ហៅថាអាកូនព្នង ។ គេបណ្តេញមិនឱ្យចូលជិតគេ ។ ខ្ញុំឈឺចាប់ណាស់ចំពោះការបែងចែកវណ្ណៈនិងប្រកាន់ពូជសាសន៍នេះ ។ ទើបតែពេលបានជួបលោកគ្រូទេដែលការឈឺចាប់ទាំងប៉ុន្មានបានត្រូវជំនួសវិញដោយក្តីសង្ឃឹមយ៉ាងរីករាយ ។ លោកគ្រូមិនត្រឹមតែបីបាច់ថែរក្សាយ៉ាងសមរម្យប៉ុណ្ណោះទេ ថែមទាំងបង្ហាត់បង្រៀនគុនវិជ្ជានិងអក្សរសាស្ត្រខ្ញុំ រហូតខ្ញុំកសាងខ្លួនបានប៉ុណ្ណេះ គឺលោកគ្រូមានសប្បុរសធម៌មិនប្រកាន់វណ្ណៈ ... ។

តេជោមាស : យ៉ត ! មុននឹងយើងផុតជីវិតទៅ គ្រូនៅមានពាក្យពេចន៍ខ្លះៗចង់ផ្តែផ្តាំដល់ឯងណាយ៉ត !

យ៉ត : ទេ ! លោកគ្រូមិនស្លាប់ទេៗ

ជំទាវស្រែន : ទេ ! បងមិនស្លាប់ទេ !

តេជោមាស : គ្រូមិនរស់ទេ ! ស្រែនអូន !

យ៉ត : ឈាមហូរច្រើនណាស់ !

តេជោមាស : (ច្រៀង)មាសពេជ្រកែវកង ពិទូរ្យសូរ្យកាន្តពុំថ្លៃថ្លើងថ្កានស្មើនឹងវិជ្ជា(២ដង) ទឹកដីមាតុភូមិថ្លៃលើសជន្មា ចងចាំគ្រប់គ្នាកុំបីបែកបាក់ អើយ ។

យ៉ត : (ច្រៀងបន្ត)តែជីវិតខ្ញុំដូចចករសាត់ ជួបតែវិបត្តិបែងចែកវណ្ណៈ បានគុណលោកគ្រូ លើកស្ទួយទុកដាក់ មានងារបុណ្យសក្តិបម្រើនគរ អើយ ... ។

ជំទាវស្រែន : ឱ្យអូនជួយបងម្តេចទៅ? ឱ្យអូនធ្វើម៉េចទៅ ? យ៉តៗអើយ ជួយគ្រូឯងសិនទៅ

តេជោមាស : អឺ ! កុំអីឥតប្រយោជន៍ទេៗ ឯណាៗលោកស្មៀន ?

លោកស្មៀន : បាទ !

តេជោមាស : មកហើយអឺ ! លោកត្រូវធ្វើចុតហ្មាយមួយយកមកឱ្យខ្ញុំចុះហត្ថលេខា ដើម្បីផ្ញើទៅថ្វាយព្រះរាជា គឺមុននឹងខ្ញុំស្លាប់ទៅយើងសូមប្រគល់មុខតំណែងក្នុងដែនដីកំពង់ស្វាយនេះឱ្យទៅយ៉តៗដែលជាសិស្សរបស់យើងនេះ ជាតេជោយ៉តឮទេ ? ស្តាប់បានទេ ?

លោកស្មៀន : បាទ ! ស្តាប់បានហើយលោកម្ចាស់

តេជោមាស : អឺយ៉ត !

យ៉ត : បាទ ! លោកគ្រូ

តេជោមាស : ឯងមាននៅនឹកឃើញពាក្យរបស់គ្រូប្រាប់ឯងទេ! ហាំយ៉ត ! កាលដែលយើងដេញតាមព្រះថៅថៃណាទៅដល់ទល់ដែននោះដែរទេ ?

យ៉ត : ខ្ញុំចាំទាំងអស់លោកគ្រូ ! លោកគ្រូមានប្រសាសន៍ថា សត្រូវណាដែលឆោតល្ងង់បែបព្រះថៅថៃណានោះ យើងត្រូវឱ្យរស់ ។

លោកស្មៀន : លោកម្ចាស់ ! លោកម្ចាស់ ! ចុតហ្មាយដែលលោកម្ចាស់បានបញ្ជានេះខ្ញុំបានធ្វើសព្វគ្រប់អស់ហើយបាទ !

តេជោមាស : បានធ្វើរួចហើយអឺ !(លោកស្មៀនយកលិខិតជូនលោកតេជោមាស)

លោកស្មៀន : សូមលោកម្ចាស់ចុះហត្ថលេខាទាន !

តេជោមាស : មិនអីទេ ! យកមកនេះ (តេជោមាសពិនិត្យ ហើយចុះហត្ថលេខារួចហុចទៅលោកស្មៀន) រួចហើយយកទៅចុះ ។ ល្អត្រឹមត្រូវហើយ ។ លោកឧកញ៉ាព្រហ្មស្រីទ្វារប្រាសាទដប់ សូមលោកនាំយកចុតហ្មាយនេះទៅថ្វាយព្រះជ័យចេស្តាជាបន្ទាន់ណា ! ។

ឧកញ៉ាព្រហ្មស្រី : បាទ ! សូមទទួលបញ្ជាលោកម្ចាស់ !

យ៉ត : លោកគ្រូ ! ខំប្រឹងនិយាយអ្វីខ្លាំងម្ល៉េះ !

តេជោមាស : យ៉តឯងចងចាំពាក្យយើងល្អណាស់ ចូរឯងអនុវត្តចុះឥតខុសទេ ឮទេយ៉ត !

ជំទាវស្រែន : បង ! ហេតុអីក៏ភ្នែកបងរិលត្រឡប់ដូច្នេះ ?

តេជោមាស : ស្រែនអូន ! ធ្វើម៉េចយើងជួបគ្នាបានតែត្រឹមនេះ ... យ៉ត ! យ៉ត ! (តេជោមាសស្រែករកយ៉តទាំងសំឡេងស្អកស្អា) ។

យ៉ត : បាទ ! ខ្ញុំនៅជិតលោកគ្រូទេ លោកគ្រូមើលខ្ញុំស្គាល់ទេ ?

តេជោមាស : ចាំទុកណា យើងត្រូវធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីប្រទេសជាតិ មិនមែនបម្រើបុគ្គលណាម្នាក់ទេ ទោះជាស្តេចផែនដីក៏ដោយ បើប្រព្រឹត្តអំពើអ្វីដែលផ្តល់គ្រោះមហន្តរាយដល់មាតុភូមិយើង ក៏តោងហ៊ានប្រឆាំងដែរ (និយាយចប់ក៏ដាច់ខ្យល់ស្លាប់ទៅ) ។

យ៉ត : លោកគ្រូ ! លោកគ្រូ ! លោកគ្រូអនិច្ចកម្មចោលខ្ញុំហើយ !

ជំទាវស្រែន : បង ! បងមាស ! បងស្លាប់អីក៏ទាន់ហាន់ម្ល៉េះប្តីសម្លាញ់អូន មុននឹងបងស្លាប់បងផ្តែផ្តាំរៀបរាប់សព្វគ្រប់ធ្វើឱ្យអូនៗអាល័យបងណាស់ !

យ៉ត : លោកគ្រូខ្ញុំមិនចង់រស់នៅទេ !

ជំទាវស្រែន : (ច្រៀង) វាលវដ្តសង្សារ អើយ ... ធំឥតកោះត្រើយ អើយ ... ទុក្ខខ្ញុំឥតស្បើយ ស្មើរបែកឱរា អើយ ... ឱប្ដីសម្លាញ់ អើយ ... គួរអី អើយ ... បងមរណាចោលអូនឯកាកំព្រារីងរៃ ... ។ បងមាសៗ ...

ឧកញ៉ាព្រហ្មស្រី : លោកតេជោមាស លោកជាមហាបុរសខ្មែរមួយរូប ធ្លាប់មានគុណលើប្រទេសជាតិ ដោយបានស្រោចស្រង់មាតុភូមិពីគ្រោះមហន្តរាយជាច្រើនលើកច្រើនគ្រា មិនគួរស្លាប់ពេលនេះសោះ ។ យើងទាំងអស់គ្នាសោកស្ដាយចំពោះរូបលោកណាស់ ថ្វីបើលោកផុតជីវិតទៅមែនក៏ប៉ុន្តែកេរ្តិ៍ឈ្មោះរបស់លោក នៅតែជាប់ក្នុងដួងចិត្តកុលបុត្រកម្ពុជារាប់ម៉ឺនឆ្នាំ តទៅមុខទៀតឥតមានសាបសូន្យឡើយ ។ ...............................................

តេជោយ៉ត : តាំងពីលោកគ្រូអនិច្ចកម្មទៅ កិច្ចការគ្រប់ជំពូកក្នុងដែនកំពង់ស្វាយនេះ ត្រូវធ្លាក់មកលើរូបខ្ញុំទាំងអស់ ប៉ុន្តែដើម្បីប្រទេសជាតិ ដើម្បីប្រជាជន ទោះបីការលំបាកស្មុគស្មាញយ៉ាងណា ក៏ខ្ញុំខំពុះពារជានិច្ច ។ (ច្រៀង) កើតមកមួយជាតិធាតុតែមួយចាន មុនពេលក្ស័យប្រាណ អីយត្រូវតែស្មោះស្ម័គ្រ (២ដង) បម្រើនគរមិនឱ្យជាតិធ្លាក់ ផ្ដល់ម្លប់ត្រជាក់ជូនប្រជាជន ។
(និយាយ) គ្មានអាវុធអ្វីដែលមុតជាងឆន្ទៈមោះមុតនោះទេ ។ ពាក្យសម្ដីអប់រំប្រៀនប្រដៅ ប្រកបដោយមនសិការស្នេហាជាតិ របស់លោកគ្រូមាស ជាប់ជានិច្ចក្នុងអារម្មណ៍របស់ខ្ញុំ ។ (តេជោយ៉តកំពុងគិតទៅដល់ពាក្យទូន្មានរបស់តេជោមាសជាគ្រូ ហើយនាងម៉ែក៏ចូលមកដល់) [...] ។

*(ដកស្រង់ចេញពីល្ខោនបាសាក់រឿង តេជោយ៉ត អ្នកនិពន្ធ ទី ជីហួត ២៨-១២-១៩៨៣)*

## សំណួរ

១. តើអត្ថបទនេះដកស្រង់ពីរឿងអ្វី ? អ្នកនិពន្ធឈ្មោះអ្វី ? និពន្ធឡើងនៅថ្ងៃ ខែ ឆ្នាំណា ?
២. ហេតុអ្វីបានជាតេជោមាសមានរបួសធ្ងន់ធ្ងរយ៉ាងនេះ ?
៣. តើតេជោមាសហៅស្មៀនមកធ្វើអ្វីនៅពេលដឹងថាខ្លួនត្រូវស្លាប់ ? ហេតុអ្វី ?
៤. តើតេជោយ៉តប្ដេជ្ញាចិត្តដូចម្ដេចខ្លះចំពោះភារកិច្ចរបស់ខ្លួន ?
៥. តាមសំដីឧកញ៉ាព្រហ្មស្រី តើតេជោមាសជាតួអង្គដូចម្ដេច ?
៦. ចូរបង្ហាញពីទំហៀបន័យ ឬឧបមាននៅក្នុងអត្ថបទ ។

# ជំនួយកិរិយា ឬកិរិយាសព្ទជំនួយ

ភាសាខ្មែរយើងមានល្បះខ្លះ ប្រើកិរិយាសព្ទបង្គោលតែមួយមិនទាន់មានន័យគ្រប់គ្រាន់នៅឡើយ ។ ដូចនេះ ដើម្បីធ្វើឱ្យល្បះនោះមានន័យគ្រប់គ្រាន់ល្អត្រឹមត្រូវ លុះត្រាតែប្រើកិរិយាសព្ទជំនួយ ឬជំនួយកិរិយាថែមទៀត ។ ដូចម្ដេចហៅថាជំនួយកិរិយា ? តើជំនួយកិរិយាមានអ្វីខ្លះ ?

## ក. កិរិយាបំពេញ

កិរិយាបំពេញសម្រាប់ប្រើជាមួយកិរិយាសព្ទបង្គោល ដើម្បីប្រាប់លទ្ធផលនៃអំពើ ឬលទ្ធភាពសម្រេចនៃអំពើនោះ ។

*ឧទាហរណ៍ :*

១. គាត់មើលឃើញពួកយើង ។ "ឃើញ" ជំនួយកិរិយាគឺជាកិរិយាបំពេញ ។

២. គាត់មើលពុំឃើញពួកយើងទេ ។ "ពុំឃើញ" កិរិយាបំពេញ ។

៣. ក្មេងនេះដេកលក់ស្រួលណាស់ ។ "លក់" ជំនួយកិរិយា ។

៤. ក្មេងនេះដេកពុំលក់ ។ "ពុំលក់" ជំនួយកិរិយា ។

៥. ខ្ញុំលើករនាស់នេះរួច តែលើកបាវអង្ករនេះពុំរួចទេ ។ "រួច" និង "ពុំរួច" ជាជំនួយកិរិយា ។

## ខ. កិរិយាទិសដៅ

កិរិយាទិសដៅសម្រាប់ប្រើជាមួយកិរិយាសព្ទបង្គោល ដើម្បីប្រាប់ទិសដៅ ឬទិសដៅនៃអំពើកិរិយាបង្គោលនោះ ។ ចូរពិនិត្យឧទាហរណ៍ ៖

១. វាដើរចូលក្នុងថ្នាក់ ។ "ចូល" ជំនួយទិសដៅ ប្រាប់ទិសដៅនៃអំពើឆ្ពោះទៅខាងក្នុង ។

២. សុភាពចុះមកទីនេះមួយភ្លែត ។ "មក" ជំនួយទិសដៅនៃអំពើឆ្ពោះមកជិតអ្នកនិយាយ ។

៣. កូនៗប្រមូលអីវ៉ាន់ឡើងគោក ។ "ឡើង" ជំនួយទិសដៅនៃអំពើឆ្ពោះទៅលើ ។

៤. វែកកណ្ដាប់នេះទៅស្រែផង ។ "ទៅ" ជំនួយទិសដៅនៃអំពើឆ្ពោះទៅឆ្ងាយពីអ្នកនិយាយ ។

## ឃ. ពាក្យដើមកិរិយា

ពាក្យដើមកិរិយាប្រើជាមួយកិរិយាបង្គោល សម្រាប់សម្ដែងគុណលក្ខណៈរបស់កិរិយាបង្គោលនោះ ។ វាមានលក្ខណៈប្រហាក់ប្រហែលនឹងកិរិយាខាងដើមដែរ ។ ចូរពិនិត្យឧទាហរណ៍ ៖

១. ល្ខោនជិតលេងហើយ ។ "ជិត" ជំនួយប្រាប់ពេលហៀបនឹង ជិត .... ។

២. ការសិក្សាខ្ញុំសព្វថ្ងៃកាន់តែរីកចម្រើនឡើង ។ "កាន់តែ" ជំនួយប្រាប់សភាពលក្ខណៈ ។

៣. ឯងត្រូវតែទៅរៀនវិញ ។ "ត្រូវតែ" ជំនួយប្រាប់ភាពចាំបាច់បំផុត ។

៤. វាទើបនឹងមកពីសាលារៀន ។ "ទើបនឹង" ជំនួយប្រាប់ពេល ។

តាមឧទាហរណ៍ទាំងអស់ខាងលើបញ្ជាក់ថា ជំនួយកិរិយាទាំងអស់សុទ្ធតែជួយកិរិយាបង្គោលនៅក្នុងល្បះ ។

*ជំនួយកិរិយា គឺជាពាក្យសម្រាប់បង្គ្រប់ន័យសេចក្តីរបស់កិរិយាសព្ទបង្គោលណាមួយនៅក្នុងល្បះ ។*

*ជំនួយកិរិយាមានកិរិយាបំពេញ កិរិយាទិសដៅ កិរិយាខាងដើម និងពាក្យដើមកិរិយា ។*

## លំហាត់

១. ចូរបង្ហាញពាក្យដែលជាជំនួយកិរិយានៅក្នុងល្បះខាងក្រោមៈ

- វាអានសៀវភៅនេះចប់ហើយ ។
- គាត់រកឃើញគោហើយ ។
- ដាណាបើកទ្វារជូនលោកតា ។
- គាត់ចុះទៅកំពង់ទឹកអំបាញ់មិញ ។
- តាសំចូលចិត្តនិទានរឿងណាស់ ។
- សម្លាញ់គួរតែខំរៀនឡើង ។
- បងខ្ញុំទើបតែមកពីស្រែ ។
- បូផាកំពុងតែសរសេរសំបុត្រ ។

២. ចូរតែងល្បះឱ្យបាន ៦ ល្បះដោយប្រើជំនួយកិរិយា ។

# ការធ្វើដំណើរទៅបប៉ៃលិន



## ក. សិក្សាពាក្យគន្លឹះ

- វ៉ាលិស (ន) : ហិបតូចស្រាលធ្វើពីផ្ដៅស្បែក ឬសំពត់សាច់ក្រាស់សម្រាប់ដាក់អីវ៉ាន់ស្រាលៗដូចជាសម្លៀកបំពាក់ ។
- អនេក (គុ) : ដែលច្រើនរាប់ពុំបាន រាប់ពុំអស់ ។
- សត្វចតុប្បាទ (ន) : សត្វជើងបួន ។
- សង្វេគ (ន) : សេចក្ដីអាណិតដល់អ្នកដែលរងទុក្ខ ។
- យីហោ (ន) : គ្រឿងសំគាល់ នាមដែលតាំងសំគាល់របស់ឈ្មួញ ។
- អធ្យាស្រ័យ (ន) : សេចក្ដីសន្ដោស ការមិនប្រកាន់ទោស ។
- សប្បុរស (ន) : អ្នកប្រព្រឹត្តល្អ បុរសអ្នកស្ងប់ ។
- សន្និវាស (ន) : ការនៅអាស្រ័យ ការជ្រកអាស្រ័យ ការស្នាក់នៅ ។
- កិរិយា (ន) : អំពើ ឫកពា ។
- ល្ហាសល្ហន់ (ន) : ដំណើរទន់ភ្លន់ល្ហាសល្ហន់ រាងល្វត ដំណើរល្វត ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ អ្នកគប្បីអានដោយយកចិត្តទុកដាក់ [illegible] មឆ្លើយនឹងសំណួរទាក់ទងនឹងទំហៀបន័យ ឬឧបមាន តួអង្គ កាលអាកាស និងខ្លឹមសារអ[illegible]

## គ. អត្ថបទ

[...] លុះ **ថៅ ចិត្រ** បានទទួលសំបុត្រគ្រូពេទ្យហើយ ក៏ចាត់ចែងសំពត់អាវដាក់វ៉ាលិសផ្ដៅនិងអីវ៉ាន់សម្រាប់ធ្វើដំណើរទៅរួចស្រេចហើយ ក៏ប្រះដេកសប្រាកដោយសេចក្ដីត្រេកអរដ៏លើសលប់ ក្នុងយប់នោះស្ទើរតែដេកមិនលក់ទាល់ភ្លឺ។ ដល់ម៉ោង ៥ ជិតភ្លឺ នាឡិកាឯផ្សារវាយឮសូរម៉ឺងៗយ៉ាងច្បាស់ លាស់រហូតដល់ផ្ទះ **ថៅ ចិត្រ**ៗ ក្រោកឡើងលុបលាងមុខមាត់រួច ក៏ស្ទៀកពាក់យួរវ៉ាលិសចុះពីផ្ទះដើរសំដៅទៅផ្សារវិលបម្រុងទៅឡើងរថយន្ត ដែលដើរទៅផ្លូវបាត់ដំបង-បប៉ៃលិន។ **ថៅ ចិត្រ** ទិញសំបុត្រកន្លែងរួចស្រេចហើយក៏អង្គុយចាំដរាបដល់ពេលរថយន្តចេញពីទីផ្សារក្រុងបាត់ដំបងទៅ។ វេលាម៉ោង ៦ និង ១៥នាទី រថយន្តក៏បើកចេញសំដៅទៅទិសខាងត្បូងដល់ទៅផ្សារភាស៊ីស្រា ក៏បត់ត្រង់ទៅឯលិច តាមផ្លូវបប៉ៃលិន។ **ថៅ ចិត្រ** អង្គុយមើលភូមិប្រទេសសងខាងមាគ៌ានោះ មុខគួរឱ្យស្រងេះស្រងោច អណ្ដែតអណ្ដូង ក្នុងចិត្តជាចំឡែកណាស់នឹកដល់ឪពុកដែលទើបនឹងអនិច្ចកម្មទៅថ្មីៗ កាលណា ទឹកភ្នែកក៏ជោរជន់ចេញមក តែខំទប់ទល់មិនឱ្យទឹកភ្នែកស្រក់ចុះទាល់តែបាន ដើម្បីការពារកុំឱ្យអ្នកជិះរថយន្តជាមួយគ្នាមានសេចក្ដីសង្ស័យមន្ទិលមកលើខ្លួន ហើយបន្លំនិយាយសើចលេងកំសាន្តជាមួយនឹងអ្នកជិះទាំងអស់គ្នារៀងៗទៅ។

ឯផ្លូវដែលឡើងទៅស្រុកបប៉ៃលិន មិនសូវឆ្ងាយប៉ុន្មានពីក្រុងបាត់ដំបងក៏ពិតមែន តែជាផ្លូវលំបាកបន្តិច ត្បិតត្រូវបររថយន្តឡើងកាត់ភ្នំនិងសសៀរតាមជើងភ្នំខ្ពស់ឡើងៗ ហើយកោងបរបត់បែនដរាបដល់ស្រុកបប៉ៃលិន ទុកជាបង្ខំយ៉ាងណាក៏គង់តែរថយន្តរត់មិនលឿនរហ័សដូចផ្លូវរាបទេ។ **ថៅ ចិត្រ**ក្រឡេកមើលទេសភាពតាមសងខាងផ្លូវ សឹងដេរដាសទៅដោយស្រែចម្ការច្បារដំណាំនិងភូមិស្រុកដោយអន្លើៗឃ្លាតឆ្ងាយដាច់ៗពីគ្នា លុះជិតដល់បប៉ៃលិនក៏ឃើញតែព្រៃព្រឹក្សា លតាវល្លិ និងភ្នំតូចធំជាច្រើនអនេក ព្រមទាំងសត្វបក្សាបក្សីនិងសត្វចតុប្បាទ ក៏មានកុះករច្រើននៅតាមដងព្រៃព្រឹក្សាអស់នោះ។ **ថៅ ចិត្រ** បានឃើញសព្វសត្វអស់នោះ ក៏កើតមានចិត្តសង្វេគនឹករលឹកដល់ឪពុកកាន់តែខ្លាំងឡើងៗ ស្ទើរតែទប់ទឹកភ្នែកពុំបាន។

លុះដល់រថយន្តបរបើកកាត់ព្រៃភ្នំក្រំថ្មជាច្រើនអន្លើ វេលាម៉ោង ១១ ថ្ងៃត្រង់រថយន្តក៏បានទៅដល់ទីផ្សារបប៉ៃលិនដោយស្រួល។ **ថៅ ចិត្រ** ចុះពីរថយន្តដើរទៅស៊ើបសួររកផ្ទះ **ហ្លួងរតនសម្បត្តិ**។ មានភូមាម្នាក់នៅទីផ្សារនោះចង្អុលប្រាប់ថា ផ្ទះ **ហ្លួងរតនសម្បត្តិ** នៅឯណោះចម្ងាយពីទីផ្សារនេះទៅ

ប្រហែល ៥០០ ម៉ែត្រ ក្បែរមាត់ផ្លូវខាងជើង នៅខ្លោងទ្វារផ្ទះនោះមានសរសេរយីហោ "**គ្រឹះស្ថានរតនសម្បត្តិ**" អញ្ជើញទៅចុះគង់នឹងឃើញមិនខាន ។ **ថៅ ចិត្រ**ក៏ចេញដើរទៅតាមពាក្យភូមានោះ ហើយទៅឈរវេរានៅមុខផ្ទះដូចមានយីហោខាងលើនេះ មួយស្របក់មានកម្មករម្នាក់ចេញពីក្នុងភូមិនោះមកសួរថា "អញ្ជើញមករកអ្នកណា?"

**ថៅ ចិត្រ** ភ្ញាក់ព្រើត ព្រោះពេលនោះកំពុងឈរមើលភូមិប្រទេសយ៉ាងភ្លើតភ្លើន ស្រាប់តែក្រឡេកឃើញបុរសខ្មៅម្នាក់ឈរសួរក្បែរខ្លួនទើបប្រាប់ថា " ខ្ញុំមករកលោក**ហ្លួងរតនសម្បត្តិ**វេលានេះលោកនៅឬទេ ? " ។

បុរសនោះឆ្លើយតប " លោកនៅខាងលើផ្ទះ បើចង់ជួបនឹងលោក អញ្ជើញមកតាមខ្ញុំ " ហើយបុរសនោះក៏ដើរនាំមុខ **ថៅ ចិត្រ** ឡើងទៅលើផ្ទះ ។

គេប្រាប់ឱ្យ **ថៅ ចិត្រ**អង្គុយលើកៅអីមួយនៅក្នុងបន្ទប់ទទួលភ្ញៀវ ហើយដើរចូលទៅក្នុងមួយស្របក់ ក៏លេចមនុស្សចាស់សក់ស្កូវម្នាក់ដើរចេញមកដោយឫកពាអង់អាច ស្លៀកសារុងស្លូត្រពាក់អាវទ្រនាប់ តាមទំនៀមអ្នកនៅផ្ទះ ពាក្យដំបូងដែលនិយាយនឹង **ថៅ ចិត្រ** នោះដូច្នេះថា "ក្មួយមកពីណា ? ត្រូវ ការជួបនឹងខ្ញុំមានការអ្វី ?" ។

**ថៅ ចិត្រ** សង្កេតដឹងច្បាស់ថា លោកនេះហើយដែលហៅថា"**ហ្លួងរតនសម្បត្តិ** " ដែលខ្លួនត្រូវការជួប ទើបរំកិលខ្លួនចុះពីកៅអីបន្ទន់ខ្លួនសំពះដោយសេចក្តីគោរពគួរសម ។

ឯ **ហ្លួងរតនសម្បត្តិ** ជាអ្នកជំនួញលក់ត្បូងដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងស្រុកប៉ៃលិន ក៏អង្គុយ លើកៅអីមួយ **ថៅ ចិត្រ** សង្កេតតាមឫកពារបស់លោកនេះ យល់ថាជាអ្នកមានអធ្យាស្រ័យល្អ ចិត្តសប្បុរស គួរជាទីគោរពរាប់អានមែន ។

"ទានប្រោសមាន!" **ថៅ ចិត្រ** ឆ្លើយដោយឱនលំទោនហើយថា "លោកគ្រូពេទ្យ **ស្អាត** បានផ្ញើសំបុត្រ ១ ច្បាប់មកជួបព្រះតេជព្រះគុណ" ។

"អើ! ពេទ្យ **ស្អាត** ក្មួយខ្ញុំនោះឬ!" លោកនិយាយទាំងញញឹមតាមដោយលោកជាអ្នកមានអធ្យាស្រ័យ រីករាយជានិច្ច ហើយសួរថា "សំបុត្រនោះនៅឯណា ?"

**ថៅ ចិត្រ** លូកដៃទៅក្នុងហោប៉ៅយកសំបុត្រនោះជូនទៅ លោក **ហ្លួង** ទទួលយកទៅអានដោយសេចក្តីត្រេកអរ លុះមើលចប់ហើយក៏បែរមកពិចារណាមើល លក្ខណៈ **ថៅ ចិត្រ** ម្តងទៀត ។

**ហ្លួង** "ក្មួយឯងមែនទេឬអីឈ្មោះ **ថៅ ចិត្រ** ដែលគ្រូពេទ្យ **ស្អាត** បាន បញ្ជូនខ្លួនមកឱ្យខ្ញុំ ?" ។

ចិត្រ "ទានប្រោសខ្ញុំបាទនេះហើយ!" **ហ្លួង** "ចុះក្មួយធ្វើការយ៉ាងនេះបានដែរឬ ? ការរបស់ខ្ញុំនេះវាធ្ងន់ណាស់ តោងទ្រាំជីកដីក្នុង ១ ថ្ងៃ ៥-៦ ម៉ោងទើបស្ទុះរួច រូបរាងស្អាតបាតដូចជាក្មួយនេះ ខ្ញុំយល់ថាទ្រាំទ្រការងារមិនបានយូរប៉ុន្មានទេ មុខជារត់ទៅផ្ទះវិញហើយ!"។

**ថៅចិត្រ** "មនុស្សដទៃទៀតគេទ្រាំធ្វើបានយ៉ាងណា ឯខ្ញុំបាទគង់តែធ្វើបានដូចជាគេដែរ សូមព្រះតេជព្រះគុណកុំព្រួយឱ្យសោះ!" **ថៅ ចិត្រ** ពោលរាប់រងយ៉ាងម៉ឹងម៉ាត់។ ពាក្យនេះហើយដែលធ្វើឱ្យ **ហ្លួងរតនសម្បត្តិ** មានសេចក្តីពេញចិត្តណាស់ ហើយ **ថៅ ចិត្រ** និយាយតទៀតថា "ទានប្រោស! មនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ មិនប្រកាន់ការស្រាលៗស្រួលៗទេ ខ្ញុំបាទមិនដែលគិតដូច្នេះទេ កាល បើខ្ញុំបាទមានកម្លាំងពលំដរាបណា ខ្ញុំបាទនឹងខិតខំធ្វើការដរាបនោះ ទោះបីធ្ងន់ក្តីស្រាលក្តី"។

"អ្នកឯងនិយាយនេះត្រូវណាស់" លោក **ហ្លួង** និយាយសរសើរហើយថា "ល្អើយចុះ ឯខ្ញុំតែងមានការសម្រាប់មនុស្សដែលចង់ធ្វើជានិច្ច វេលានេះអណ្តូងត្បូងទិសខាងកើត ខ្ញុំកំពុងឱ្យចាប់ផ្តើមជីកត្បូងមានតម្លៃមួយអន្លើ ព្រឹកស្អែកនេះខ្ញុំនឹងបញ្ជូនអ្នកឯងឱ្យទៅធ្វើការនៅទីនោះ ធ្វើការក្នុងគ្រាដំបូងនេះខ្ញុំនឹងតាំងប្រាក់ខែឱ្យអ្នកឯងត្រឹមតែ ៣០ រៀលសិន ប៉ុន្តែអ្នកឯងអាចបានប្រាក់ខែច្រើនជាងនេះទៅទៀត បើខំយកចិត្តទុកដាក់ធ្វើការដោយម៉ឹងម៉ាត់ហើយហ្មត់ចត់ផង"។

**ថៅ ចិត្រ** ឱនក្បាល ទទួលយល់ព្រមដោយសេចក្តីគោរពម្តងទៀត។ ក្នុងខណៈនោះមានសូរស្បែកជើងលាន់ឮពីខាងក្រោម ឡើងមកលើផ្ទះ ព្រមទាំងមានសំឡេងយ៉ាងឆ្មារតូចលាន់រំពងមកពីខាងក្រោយ **ថៅ ចិត្រ**ៗ ក៏ចោល ភ្នែកក្រឡេកមើលទៅ ប្រទះនឹងភ្នែកទាំងគូកំពុងតែសម្លឹងចំត្រង់មក ជាដួងភ្នែកប្រកបដោយទឹកដម គួរជាទីចាប់ចិត្តស្នេហា តែមានឫកពាឆ្មើងឆ្មៃបន្តិច មានកិរិយាក្និកក្នក់ញ៉ៀងញ៉ូង ល្វាសល្វន់ល្អណាស់ សម្បុរស្បែកសស្អាត មុខមូលក្រឡង់ដូចវង់ព្រះចន្ទ្រ សូរសំឡេងស្រួយស្រស់ដូចសូររគាំងប្រាក់ ដំណើរល្វាសល្វន់ដូចផ្កាកុលាបដែលត្រូវខ្យល់បក់លិចៗនៅកណ្តាលសួនច្បារដូច្នោះ ឱល្អអីល្អម្ល៉េះ! នេះប្រហែលជាអញយល់សប្តិឃើញទេដឹង ?។

**ថៅ ចិត្រ** ភ្ញាក់ស្មារតីលែងសម្លឹងស្រឡាំងកាំង ក្នុងពេលដែលលោក **ហ្លួង** ស្រែកហៅកូនស្រីនោះឱ្យឡើងមកខាងលើផ្ទះ"មកឯណេះ **នារី**! ថ្ងៃនេះប៉ាបានមនុស្សចូលមកធ្វើការថ្មីម្នាក់ទៀតហើយ"។

នាងក្រមុំ **នារី** ឈានជើងឡើងជណ្តើរមួយៗ ភ្នែកសម្លឹងមើល **ថៅ ចិត្រ** ដោយកិរិយាឆ្មើងឆ្មៃបន្តិចដែលជាទំនៀមរបស់ស្ត្រីក្រមុំរូបស្រស់ ហើយសួរទៅឪពុកថា "ប៉ា! នេះឬអ្នកចូលមកធ្វើការថ្មីរបស់យើង" ?

លោក **ហ្លួង** ញាក់មុខទទួលហើយងាកទៅនិយាយនឹងថៅ **ចិត្រ** ថា "**ថៅ ចិត្រ** នេះនារី កូនស្រីតែមួយរបស់ខ្ញុំ" ។

**ថៅ ចិត្រ** លើកដៃសំពះសួរនាង **នារី** ងក់ក្បាលទទួលគំនាប់ ដោយកិរិយាឆ្មើងៗតាមនិស្ស័យរបស់នាង ។

នាង **នារី** សម្លឹងមើលកម្មករថ្មីរបស់ឪពុកតាំងអំពីក្បាលរហូតដល់ចុងជើង មើលហើយមើលទៀត នៅទីបំផុតក៏លាន់មាត់ថា "កម្មករនេះស្គមដូចអ្នកញៀនអាភៀននឹងមានកម្លាំងជីកដីបានឬប៉ា ?" ។

**ថៅ ចិត្រ** កាលត្រូវស្រីក្រមុំស្តីដាក់មុខដូច្នេះក៏នឹកអៀនខ្មាសណាស់ ក្រឡេកចោលកន្ទុយភ្នែកទៅនាងមួយភ្លែត ហើយតបទៅថា "មនុស្សត្រង់គេមិនដែលសម្គាល់ថា ជាមនុស្សល្ងង់ទេ ឯមនុស្សស្គមក៏គេមិនសម្គាល់ថា ជាមនុស្សខ្សោយដែរ ស្គមយ៉ាងខ្ញុំបាទនេះមានកម្លាំងខ្លាំងដូចមនុស្សធាត់មាំដែរ គ្រាន់តែមិនសូវមានសាច់ឈាមធាត់បរិបូណ៌ប៉ុណ្ណោះទេតើ!" ។

នាង **នារី** ធ្វើមុខក្រញូវទំនងខឹងបន្តិចៗផង ដោយនាងមិននឹកនាថា **ថៅ ចិត្រ**ហ៊ានឆ្លើយដូច្នេះសោះ ព្រោះមិនធ្លាប់មានមនុស្សណាមួយក្នុងផ្ទះហ៊ាននិយាយ លេងសម្តីរោហារនឹងនាងឡើយ ។

លោក ហ្លួង ឃើញកូនខឹងដូច្នោះក៏បញ្ឈប់ថា "**ថៅ ចិត្រ**! ណ្ហើយឈប់ស្លេះប៉ុណ្ណឹងសិនចុះ ឯងកំពុងនឿយហត់អស់កម្លាំង ទៅរកសម្រាកខ្លួនឱ្យបាត់នឿយហត់សិនទៅ" ។

[...] តាំងពីថ្ងៃនោះមក ថៅចិត្រក៏បានធ្វើជាកម្មករជីករកត្បូងនៅគេហដ្ឋានរបស់លោកហ្លួងរតនសម្បត្តិ ទោះបីការនោះជាការធ្ងន់ក៏ដោយ ថៅចិត្រក៏ឥតមានការធុញទ្រាន់ តែងតែខំធ្វើការនោះដោយខ្មីឃ្មាតអស់ពីចិត្តពីថ្លើម មិនមាននឹកនាដល់សេចក្តីនឿយហត់ឡើយ ។ ភាសិត១បទថា "ខ្លួនទីពឹងខ្លួន" ដែលជាពាក្យបណ្តាំរបស់បិតាចុងក្រោយបង្អស់នោះ នៅឮសូរកងរំពងក្នុងត្រចៀករបស់ថៅចិត្រ ហាក់ដូចជាមានទេវតាមកចាំខ្សឹបប្រាប់នឹងត្រចៀកជានិច្ច ។ ការខំប្រឹងធ្វើការយ៉ាងម៉ឺងម៉ាត់ ឥតមានទម្រន់និងអធ្យាស្រ័យល្អរបស់ថៅចិត្រនោះ ជាហេតុធ្វើឱ្យពួកកម្មករធ្វើការផងគ្នាស្រឡាញ់រាប់អានជាច្រើន រហូតដល់ហ្លួងរតនសម្បត្តិ ក៏មានចិត្តមេត្តាក្មេងនោះជាច្រើនដែរ ។

ថៅចិត្រចូលមកធ្វើការនៅផ្ទះលោកហ្លួងរតនសម្បត្តិ អស់វេលា៦ខែកន្លងមកហើយនោះ តែងមានជួបប្រទះនឹងធម្មជាតិថ្មីៗ ដូចជាព្រៃភ្នំក្រំថ្ម ព្រឹក្សាលតាវល្លិ និងអាកាសស្រស់បរិសុទ្ធ ដែលជារបស់ចម្លែកក្នុងជីវិតថៅចិត្រ តែដែលចម្លែកយ៉ាងពន្លឹកជាងនេះទៅទៀតនោះ គឺយុននារីថៅហ្វាយក្រមុំរបស់ថៅចិត្រ ដែលជាស្ត្រីប្រកាន់ខ្លួន មានឫកពាឆ្មើងឆ្មៃ ហើយជានារីមានរូបឆោមយ៉ាងល្អឯក

ក្នុងស្រុកប៉ៃលិន ហាក់ដូចផ្កាកុលាបកំពុងរីកផ្សាយក្លិនក្រអូបឈ្ងុយឈ្ងប់ក្នុងវស្សានរដូវ ។ វេលាដែលចៅចិត្រអង្គុយក្នុងផ្ទះស្នាក់តែម្នាក់ឯង ច្រើនប្រមូលយករឿងអស់នេះមកគិតនឹកជានិច្ច ហើយនឹកឆ្ងល់តែម្នាក់ឯងថា ចុះហេតុដូចម្ដេចបានជាអញចេះតែរំពឹងនឹកដល់នាងក្រមុំនេះអីម្ល៉េះ ! ចុះអញជាប់ចិត្តប្រតិព័ទ្ធនាងក្រមុំនេះឬអី ? អា៎ ! មិនបានទេ នាងនេះរូបឆោមល្អមែនហើយ ប៉ុន្តែឫកពាឆ្មើងឆ្មៃប្រកាន់ខ្លួនហួសពេក ថែមទាំងមានសម្បត្តិស្ដុកស្ដម្ភណាស់ ហួសវិស័យនឹងឈោងតោងបេះប្រលេះយកឱ្យបាន ចុះអ្នកមានប្រយោជន៍អ្វី ដែលអ្នកនៅខំនឹកដល់គេទុកជាខំទប់ចិត្តមិនឱ្យគិតដូចម្ដេចៗ ក៏នៅតែមានចិត្តរិះរេទៅរកគូអារម្មណ៍នោះ ទាល់តែបាន !។ នៅទីបំផុតចៅចិត្រភាវនា"ខ្លួនទាបកុំតោង ដៃខ្លីកុំឈោង ស្រវាឱបភ្នំ" ។

ចំណែកនាងនារីក៏ធ្លាប់គិតថា កម្មករថ្មីរបស់នាងនេះជាមនុស្សចម្លែកជាងគេ មិនចេះប្រចុបប្រចែងចៅហ្វាយនាយ និយាយត្រង់ទៅត្រង់មក ឥតចេះក្រែងចិត្តគេសោះ ថែមទាំងចេះនិយាយសម្ដីទាន់សម័យទៀតផង បានជានាងនឹកជឿថា កម្មករកម្លោះនោះបានរៀនសូត្រចេះដឹងច្រើនគួរសមដែរ ។ ជួនកាលនាងបានឮសូរបុរសកំលោះនោះស្រែកច្រៀងរាយទំនុកតាមការកម្សាន្តរបស់ខ្លួនក៏មានច្រៀងទំនុកយុវាភិរម្យជាពាក្យរំលឹកយុវជនក៏មាន ទើបនាងយល់ថាកម្មករកំលោះនោះ ច្បាស់ជាចេញមកពីសាលាមធ្យមសិក្សាណាមួយជាប្រាកដ ។ [...]

*(ដកស្រង់ពីរឿង កុលាបប៉ៃលិន អ្នកនិពន្ធ ញ៉ុក ថែម គ.ស.១៩៦០)*

## សំណួរ

១. ហេតុអ្វីបានជាចៅចិត្រធ្វើដំណើរទៅប៉ៃលិន ?

២. នៅពេលឃើញនិងដឹងពីបំណងរបស់ចៅចិត្រ តើហ្លួងរតនសម្បត្តិពោលដូចម្ដេចខ្លះ ?

៣. តើចំណុចត្រង់ណាខ្លះដែលបញ្ជាក់ថាចៅចិត្រមានការជឿជាក់លើសមត្ថភាពខ្លួនឯង ?

៤. ចូរបង្ហាញពីទំហៀបន័យឬឧបមានក្នុងអត្ថបទនេះ ។

៥. ចូរបង្ហាញពីកាលអាកាសរបស់អត្ថបទដកស្រង់នេះ ។



# ជំនឿជាក់លើខ្លួនឯង



## ក. សិក្សាពាក្យគន្លឹះ

- ជំនឿជាក់ (ន) : ការជឿច្បាស់ក្នុងចិត្ត ភាពច្បាស់ក្នុងចិត្ត ។
- មហាសាល (គុ) : ដែលមហាធំធេង ធំសម្បើម អស្ចារ្យ ។
- សមត្ថភាព (ន) : ភាពនៃសេចក្ដីអាចហ៊ាន សេចក្ដីមោះមុត ។
- ទាសករ (ន) : ខ្ញុំបម្រើ ។
- វិជ្ជមាន (គុ) : ដែលកំពុងមាននៅឡើយ ។
- អាណាព្យាបាល (ន) : អ្នកគ្រប់គ្រង បីបាច់ថែរក្សា ។
- ស័ក្ដិសិទ្ធិ (ន) : សេចក្ដីសម្រេច វិសេសវិសាល ពូកែឆុតឆាប់ ។
- អភិវឌ្ឍន៍ (ន) : សេចក្ដីរីកចម្រើន លូតលាស់ ។
- ឧបត្ថម្ភ (ន) : ការទំនុកបម្រុង ការផ្គត់ផ្គង់ ការផ្ដល់ឱ្យ ។
- សេពគប់ (ន) : ការរាប់រកយកជាគ្នា ការរាប់រកគ្នា ។
- មោទនភាព (ន) : ភាពអំនួត ។

- ឧបសគ្គ (ន) : ដំណើររារាំង គ្រឿងរារាំងដំណើរ ។
- គុណធម៌ (ន) : ធម៌ដែលមានដំណើរចម្រើន សេចក្តីល្អ ល្អបរិសុទ្ធ ។
- អធ្យាស្រ័យ (ន) : បំណង ចំណង់ចិត្ត អារម្មណ៍ ។
- សតិ (ន) : ស្មារតី សេចក្តីនឹកឃើញ ការរឭកបាន ការចាំបាន ការប្រុងប្រយ័ត្ន មិនឱ្យភ្លេច ការរឭកឃើញមិនភ្លេច ។
- បញ្ញា (ន) : សេចក្តីដឹងទូទៅ សេចក្តីដឹងកើតអំពីការរៀន ស្តាប់ គិត សួរ ការដឹងច្បាស់នូវសេចក្តីពិត ។
- វិនិច្ឆ័យ (ន) : ការជម្រះក្តី ការកាត់ក្តី
- សុចរិត (ន) : សេចក្តីល្អ បរិសុទ្ធត្រឹមត្រូវ
- កិត្តិយស (ន) : កេរ្តិ៍ឈ្មោះដ៏រុងរឿង យសសក្តិដែលល្បីទូទៅ ។
- កិត្តិនាម (ន) : កេរ្តិ៍ឈ្មោះ នាមដ៏ល្បីល្បាញ ។
- លោភៈ (ន) : សេចក្តីលោភលន់ ការលោភលន់ ។
- មោហៈ (ន) : សេចក្តីវង្វេង សេចក្តីល្ងង់ អវិជ្ជា មិនស្គាល់ខុសត្រូវ ។
- ទោសៈ (ន) : កំហឹង កំហុស ការស្អប់ ការប្រទូស្ត ។
- អាត្មា (ន) : ខ្លួន ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទខាងក្រោមនេះ សូមអ្នកអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរមួយចំនួនទាក់ទងនឹង សេចក្តីលម្អិត គំនិតសំខាន់ តម្លៃអប់រំ និងសង្ខេបអត្ថបទ ។

## គ. អត្ថបទ

អ្នកមានជំនឿជាក់លើខ្លួនឯង គឺជាអ្នកដែលចេះប្រើកម្លាំងមហាសាល ដែលបង្កប់នៅក្នុងខ្លួនគេផ្ទាល់ឱ្យក្លាយជាប្រយោជន៍ ។

ជំនឿជាក់លើខ្លួនឯងគឺជាគុណសម្បត្តិដ៏ធំធេងរបស់បុគ្គលសំខាន់ៗទាំងឡាយ ។ មនុស្សដែលនឹងឈានទៅកាន់តំណែងធំៗទាំងឡាយ មិនមាននរណាម្នាក់ឡើយ ដែលប្រាសចាកជំនឿជាក់លើខ្លួនឯង ព្រោះថាបើអ្នកណាគ្មានជំនឿជាក់លើខ្លួនឯងទេ នោះពិតជាមិនអាចនឹងឈានឡើងតំណែងខ្ពស់បានឡើយ ។

ការមានចំណេះដឹងច្រើនតែម្យ៉ាងនៅមិនទាន់គ្រប់គ្រាន់ទេក្នុងការកសាងជីវភាព ។ អ្នកដែលមានជំនឿជាក់លើខ្លួនឯងរមែងមានរបៀបជាងអ្នកដែលមានចំណេះដឹងច្រើនតែគ្មានជំនឿជាក់លើខ្លួនឯង ។ អ្នកខ្លះរៀនមិនសូវពូកែ តែពេលទៅធ្វើការបែរជារីកចម្រើនបានល្អជាងអ្នកដែលរៀនពូកែក៏មានដែរ ដោយសារតែគេមានជំនឿជាក់លើខ្លួនឯង ។

វិធីហ្វឹកហាត់ឱ្យខ្លួនឯងមានជំនឿជាក់លើខ្លួនឯង មានដូចតទៅ ៖

- ត្រូវដឹងថាខ្លួនយើងទីពឹងខ្លួនយើង(ខ្លួនទីពឹងខ្លួន) ហើយព្យាយាមជួយខ្លួនឯងឱ្យបានច្រើនជាទីបំផុត ។ អ្នកដែលចូលចិត្តសុំអង្វរឱ្យអ្នកដទៃជួយខ្លួន តែមិនព្រមជួយខ្លួនឯង រមែងបំផ្លាញអនាគតរបស់ខ្លួន ឬការរីកចម្រើនរបស់ខ្លួននៅទីបំផុត ។
- ត្រូវចេះរាប់អានខ្លួនឯង ជឿលើសមត្ថភាពរបស់ខ្លួនឯង និងមិនមើលងាយខ្លួនឯង ។
- កុំគិតថាខ្លួនធ្វើមិនបាន ចូរគិតជានិច្ចថាយើងអាចធ្វើបាន គិតតែក្នុងផ្លូវវិជ្ជមាន កុំគិតក្នុងផ្លូវអវិជ្ជមាន ពោលគឺមិនត្រូវគិតថាយ៉ាប់ណាស់ ធ្វើមិនកើតទេ មិនអាចតស៊ូបានទេ ។ល ។

មនុស្សដែលនឹងមានជំនឿជាក់លើខ្លួនឯង ភាគច្រើនកើតពីការហ្វឹកហាត់អប់រំនៅវ័យក្មេងរបស់អាណាព្យាលឬឪពុកម្ដាយ ។ ក្មេងណាដែលអាណាព្យាបាលព្យាយាមបណ្ដោយឱ្យជួយខ្លួនឯងតាំងពីនៅក្មេង លុះធំឡើងច្រើនតែមានជំនឿជាក់លើខ្លួន ។ ផ្ទុយទៅវិញក្មេងណាដែលអាណាព្យាបាលច្រើនតែចាំជួយគ្រប់ពេលវេលា លុះគេធំឡើងក៏ច្រើនតែទន់ខ្សោយហើយរមែងរង់ចាំជំនួយពីអ្នកដទៃជារឿយៗ ។

ទម្លាប់ជួយខ្លួនឯងមានសារៈសំខាន់ណាស់សម្រាប់អ្នកដែលប្រាថ្នាចង់បានភាពរីកចម្រើន ឬចង់ក្លាយខ្លួនជាបុគ្គលសំខាន់ ។ មិនមានបុគ្គលសំខាន់ណាម្នាក់ខ្វះគុណសម្បត្តិប្រការនេះឡើយ ព្រោះវាជាគុណសម្បត្តិមូលដ្ឋាន ដែលចាំបាច់ត្រូវមាន សូម្បីតែពុទ្ធភាសិតក៏បានពោលថា ខ្លួនទីពឹងខ្លួន ។

ក្នុងករណីដែលមិនទាន់អាចជួយខ្លួនឯងបាន ក៏មានក្ដីសង្ឃឹមថានឹងបានទទួលជំនួយពីអ្នកដទៃដើម្បីនឹងធ្វើឱ្យយើងអាចជួយខ្លួនឯងបាននៅទីបំផុត មិនមែនរង់ចាំតែទទួលការជួយឧបត្ថម្ភជារៀងរហូតនោះទេ ។

យើងមានគោលការណ៍ដែលនឹងធ្វើឱ្យអ្នកដទៃជឿជាក់មានទំនុកចិត្តដូចតទៅនេះ

- ត្រូវមានភាពស្មោះត្រង់និងសុចរិត មិនធ្វើការអ្វីដោយលោភៈ ទោសៈ មោហៈ ឬដោយការយល់ដឹងមិនដល់ហេតុការណ៍ពិត តែត្រូវមានការត្រិះរិះ មានហេតុផល និងមានការវិនិច្ឆ័យដែលត្រឹមត្រូវ ។

- ត្រូវចេះការពារខ្លួនឯងភ្លាមៗនៅពេលដែលកើតហេតុការណ៍ណាមួយ មិនបណ្តែតបណ្តោយឱ្យរឿងហេតុនោះរីករាលដាលឡើងរហូតដល់មិនអាចដោះស្រាយបាន មិនបណ្តោយឱ្យគេចោទប្រកាន់ឬនិន្ទារហូតដល់ខូចកេរ្តិ៍ឈ្មោះ ប៉ះពាល់កិត្តិយសទេត្រូវរកវិធីរំងាប់ហេតុការណ៍អាក្រក់តាំងពីដំបូងទី ។
- ធ្វើការដោយភាពល្អិតល្អ ហើយហ៊ានទទួលខុសត្រូវគ្រប់បែបយ៉ាងលើការងារដែលបានធ្វើនោះ បើមានទង្វើណាមួយខុសឆ្គងក៏មិនគួរនឹងដោះស្រាយយករួចខ្លួន ត្រូវហ៊ានទទួលកំហុស ហើយចាត់ទុកថា វាជាមេរៀនដ៏ល្អដែលនឹងមិនធ្វើឱ្យយើងមានកំហុសបែបនេះជាថ្មីទៀត ។
- ត្រូវជឿជាក់និងមានទំនុកចិត្តលើខ្លួនឯង ដើម្បីធ្វើយ៉ាងណាឱ្យអ្នកដទៃទុកចិត្តយើង ហើយវានឹងធ្វើឱ្យយើងធ្វើការងារអ្វីមួយយ៉ាងជាក់លាក់រួចរាល់និងមិនខុសឆ្គង ។
- ត្រូវមានគុណធម៌ជាគ្រឿងគ្រប់គ្រងចិត្ត ដើម្បីជាការស្រឡាញ់និងជឿជាក់ពីអ្នកដទៃ ។
- ត្រូវបំបាត់ភាពអាត្មានិយម និងមានការលះបង់ មិនផ្លាស់រំលងតួនាទី ។ ចៀសវាងការប្រើអំណាចផ្តាច់ការ ដែលនាំដល់ភាពស្អប់ខ្ពើមនិងភាពជឿជាក់ ។
- ត្រូវធ្វើខ្លួនឱ្យបានសមរម្យ មានភាពយុត្តិធម៌ មិនលំអៀង ធ្វើឱ្យអ្នកដទៃមានការជឿជាក់គោរព ស្រឡាញ់ យល់អធ្យាស្រ័យគ្នាហើយមិនចេះកេងប្រវ័ញ្ចពីអ្នកដទៃ និងមានការតាំងចិត្តខ្ពស់ដើម្បីឱ្យបានផលល្អ ហើយបង្កើតនូវស្នាដៃឬលទ្ធផលអ្វីមួយ បានដល់ជាគ្រឿងធានារ៉ាប់រងក្នុងជំនឿជាក់ពីមនុស្សគ្រប់មជ្ឈដ្ឋាន និងទទួលបានកិត្តិយសខ្ពង់ខ្ពស់គួរជាទីពេញចិត្ត ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅ អភិវឌ្ឍខ្លួនឯងរបស់លោក ច័ន្ទ បូទ្ធី*
*ថ្ងៃ៣២ ខែ តុលា ឆ្នាំ២០០២ ទំព័រទី ៦៥-៦៦ ៨៩-៩២ និង ១១១-១១២)*

## សំណួរ

១. តើដូចម្តេចហៅថា ការជឿជាក់ ?

២. តើមនុស្សដែលមានភាពជឿជាក់លើខ្លួនឯងជាមនុស្សមានលក្ខណៈដូចម្តេច ?

៣. តើយើងត្រូវធ្វើដូចម្តេចខ្លះដើម្បីបណ្តុះស្មារតីនិងទម្លាប់ឱ្យមានជំនឿជាក់និងភាពទុកចិត្តបាន ?

៤. តើការមានជំនឿជាក់លើខ្លួនឯងផ្តល់ប្រយោជន៍អ្វីខ្លះដល់ខ្លួនឯង គ្រួសារ និងសង្គម ?

៥. តើអត្ថបទខាងលើនេះមានតម្លៃអប់រំដូចម្តេច ?

៦. ចូរអ្នកសង្ខេបអត្ថបទខាងលើឡើងវិញ ។



# សំដែងតួតាមអត្ថបទល្ខោន

អ្នកបានអានរួចហើយពីវគ្គដកស្រង់ពីល្ខោនបាសាក់រឿង " តេជោយ៉ត " ។ ឥឡូវនេះ ចូរអ្នករៀបចំ សម្តែងតួទៅតាមអត្ថបទអំណាននេះ ។ ការសម្តែងនេះត្រូវចាប់ផ្តើមត្រង់ "តេជោមាស" ហៅលោកស្មៀនឱ្យធ្វើចុតហ្មាយដើម្បីផ្ញើទៅព្រះរាជា ជាហូរហែរហូតដល់ឧកញ៉ាព្រហ្មស្រី ពោលពាក្យកោតសរសើរ តេជោមាស ថាជាវីរបុរសខ្មែរមួយរូបមានគុណបំណាច់លើប្រទេសជាតិ ហើយ ឧកញ៉ាព្រហ្មស្រី មានការសោកស្តាយចំពោះមរណភាព "តេជោមាស" ។

## ១ . ការត្រៀមរៀបចំសម្តែង

- អានអត្ថបទដកស្រង់រឿង "តេជោយ៉ត" ក្នុងអំណានទី ១ ។

តេជោមាស : ចូរលោកចាត់ហៅប្រមូលអស់លោក ដែលជាសហការីរបស់ខ្ញុំទាំងអស់ឱ្យមកជួបជុំគ្នាភ្លាមៗឡើង !

ជំទាវស្រែន : បង ! សូមបងសម្រាកទៅ កុំប្រឹងនិយាយច្រើនពេកឈាមបងច្រើនណាស់ !

តេជោមាស : ឱ្យបងនិយាយចុះ ឱ្យបងនិយាយចុះ ស្រែនអូននេះជាឆាកជីវិតចុងក្រោយរបស់ប្តីអូន ! ឯណាយ៉តចូលមកជិតបន្តិចមក !

យ៉ត : បាទ ! លោកគ្រូរឿងអីកើតឡើង ! រឿងរបៀបណាបានជាត្រូវរងគ្រោះបែបនេះ ?

តេជោមាស : ឯងនឹកឃើញទេឬអី ? កាលដែលគ្រូប្រយុទ្ធនឹងស្តេចសម្រែនៅច្រកភ្នំនោះហើយផុងក្នុងរណ្តៅភ្លាត់ស្មៀតត្រូវវាដាល់គ្រូមួយដៃចំដើមទ្រូងណា !

យ៉ត : បាទ ! ខ្ញុំនៅចាំទាំងអស់ ។

តេជោមាស : ប៉ុន្តែ មានឯងរងទាន់ កុំអីស្តេចសំរែនោះវាកាត់ក្បាលបានបាត់ទៅហើយ ។ ឯងដឹងទេក្បាច់ប្រដាល់ដែលវាដាល់គ្រូនោះ គឺជាក្បាច់យ៉ាងសាហាវបំផុតនៅក្នុងស្មៀតមហាទម្ងន់ណាយ៉ត ! ។

យ៉ត : ហាំ ! ក្បាច់មហាទម្ងន់ ! (យ៉តពោលដោយរន្ធត់) ។

តេជោមាស : ត្រូវហើយ ដូចដែលគ្រូធ្លាប់តំណាលអីចឹង ! បើក្រៅពីគ្រូវិញ ត្រូវមួយដៃនោះប្រហែលជានៅមួយកន្លែងទៅហើយណាយ៉ត !

យ៉ត : បើដឹងដូច្នេះ ហេតុអ្វីក៏លោកគ្រូមិនព្យាបាល ?

តេជោមាស : គ្មានវិធីព្យាបាលទេ គ្រឿងក្នុងរបស់លោកគ្រូខ្ទេចខ្ទាំអស់ហើយ វាគ្រាន់តែពន្យារពេលបានយូរខែប៉ុណ្ណោះទេ គ្រូនឹងមុខជាស្រេចទៅហើយ ។ យ៉ត ! គង់តែមានថ្ងៃនេះទេ

យ៉ត : ទេ ! ទេ ! ខ្ញុំត្រូវតែសង្គ្រោះលោកគ្រូឱ្យទាល់តែបានជាដាច់ខាត ។

តេជោមាស : ឥតប្រយោជន៍ទេៗ យ៉តឥឡូវឯងនិយាយមកមើល ! ឯងរស់នៅជាមួយគ្រូជាង ១០ ឆ្នាំនេះ តើឯងយល់ឃើញយ៉ាងណាដែរចំពោះលោកគ្រូ ?

យ៉ត : លោកគ្រូ ! រាល់ទិវារាត្រី ខ្ញុំនឹកមិនភ្លេចទេចំពោះឧបការគុណរបស់លោកគ្រូដែលមានចំពោះខ្ញុំ ។ យ៉ត ខ្ញុំនេះជាកូនជនជាតិភាគតិចកំព្រាឪពុកម្ដាយ ដើរសាត់ត្រាត់សែងព្រែងត្រូវអ្នកផងទាំងពួងគេមើលងាយមើលថោក ហៅថាអាកូនព្នង ។ គេបណ្ដេញមិនឱ្យចូលជិតគេ ។ ខ្ញុំឈឺចាប់ ណាស់ចំពោះការបែងចែកវណ្ណៈនិងប្រកាន់ពូជសាសន៍នេះ ។ ទើបតែពេលបានជួបលោកគ្រូទេដែល ការឈឺចាប់ទាំងប៉ុន្មានបានត្រូវជំនួសវិញដោយក្ដីសង្ឃឹមយ៉ាងរីករាយ ។ លោកគ្រូមិនត្រឹមតែបីបាច់ថែ រក្សាយ៉ាងសមរម្យប៉ុណ្ណោះទេ ថែមទាំងបង្ហាត់បង្រៀនគុនវិជ្ជានិងអក្សរសាស្ត្រខ្ញុំ រហូតខ្ញុំកសាងខ្លួនបានប៉ុណ្ណេះ គឺលោកគ្រូមានសប្បុរសធម៌ មិនប្រកាន់វណ្ណៈ ... ។

តេជោមាស : យ៉ត ! មុននឹងយើងផុតជីវិតទៅ គ្រូនៅមានពាក្យពេចន៍ខ្លះៗចង់ផ្ដែផ្ដាំដល់ឯងណាយ៉ត !

យ៉ត : ទេ ! លោកគ្រូមិនស្លាប់ទេៗ ។

ជំទាវស្រែន : ទេ ! បងមិនស្លាប់ទេ !

តេជោមាស : គ្រូមិនរស់ទេ ! ស្រែនអូន !

យ៉ត : ឈាមហូរច្រើនណាស់ !

តេជោមាស : (ច្រៀង)មាសពេជ្រកែវកង ពិទូរ្យសូរ្យកាន្ត ពុំថ្លៃថ្កើងថ្កានស្មើនឹងវិជ្ជា(២ដង)
ទឹកដីមាតុភូមិថ្លៃលើសជន្មា ចងចាំគ្រប់គ្នាកុំបីបែកបាក់ អើយ ។

យ៉ត : (ច្រៀងបន្ត)តែជីវិតខ្ញុំដូចចកសោត ជួបតែវិបត្តិបែងចែកវណ្ណៈ បានគុណលោកគ្រូលើកស្ទួយទុកដាក់ មានងារបុណ្យសក្តិបម្រើនគរ អើយ ... ។

ជំទាវស្រែន : ឱ្យអូនជួយបងម្ដេចទៅ ? ឱ្យអូនធ្វើម៉េចទៅ ? យ៉តៗអើយ ជួយគ្រូឯងសិនទៅ ។

តេជោមាស : អឺ ! កុំអឺឥតប្រយោជន៍ទេៗ ឯណាៗលោកស្មៀន ?

លោកស្មៀន : បាទ !

តេជោមាស : មកហើយអឺ ! លោកត្រូវធ្វើចុតហ្មាយមួយយកមកឱ្យខ្ញុំចុះហត្ថលេខា ដើម្បីផ្ញើទៅថ្វាយព្រះរាជា គឺមុននឹងខ្ញុំស្លាប់ទៅយើងសូមប្រគល់មុខតំណែងក្នុងផែនដីកំពង់ស្វាយនេះឱ្យទៅយ៉តៗដែលជាសិស្សរបស់យើងនេះ ជាតេជោយ៉តឮទេ ? ស្តាប់បានទេ ? ។

លោកស្មៀន : បាទ ! ស្តាប់បានហើយលោកម្ចាស់ ។

តេជោមាស : អឺយ៉ត !

យ៉ត : បាទ ! លោកគ្រូ ។

តេជោមាស : ឯងមាននៅនឹកឃើញពាក្យរបស់គ្រូប្រាប់ឯងទេ ! ហា៎យ៉ត ! កាលដែលយើងដេញតាមព្រះចៅថៃណាទៅដល់ទល់ដែននោះដែរទេ ? ។

យ៉ត : ខ្ញុំចាំទាំងអស់លោកគ្រូ ! លោកគ្រូមានប្រសាសន៍ថា សត្រូវណាដែលឆោតល្ងង់បែបព្រះចៅថៃណានោះ យើងត្រូវទុកឱ្យរស់ ។

លោកស្មៀន : លោកម្ចាស់ ! លោកម្ចាស់ ! ចុតហ្មាយដែលលោកម្ចាស់បានបញ្ជានេះខ្ញុំបានធ្វើសព្វគ្រប់អស់ហើយបាទ ! ។ [...]

- ជ្រើសរើសតួសម្រាប់សំដែង ៖
  - តេជោមាស
  - ជំទាវស្រែន
  - តេជោយ៉ត
  - លោកស្មៀន
  - ឧកញ៉ាព្រហ្មស្រី

- តួនីមួយៗហាត់អានតាមសម្តីតួអង្គនៅក្នុងរឿង
- តួនីមួយៗកត់ត្រាសម្តីតួអង្គដែលខ្លួនដើរតួ ។

## ២ . ការសំដែង

- សម្តែងសាកល្បងដោយយកឯកសារកត់ត្រាសម្តី តួនាទីរបស់ខ្លួននីមួយៗមកអាន ។
- សម្តែងតួដោយប្រើសម្តីផ្ទាល់ខ្លួនទៅតាមដំណើររឿងដោយមិនប្រើឯកសារកត់ត្រាឡើយ ។

នៅពេលសម្តែង អ្នកគប្បី ៖

- ចងចាំបទសន្ទនាឬសម្តីតួអង្គដែលអ្នកដើរតួ
- ដាក់អារម្មណ៍ទៅតាមស្ថានភាពតួអង្គនៅក្នុងរឿង (*ឧទាហរណ៍ :* កម្សត់ យំសោក ...)
- ប្រើពាក្យពេចន៍ កាយវិការ ចរិតលក្ខណៈឱ្យសមទៅតាមតួអង្គនីមួយៗក្នុងដំណើររឿង
- ប្រមាណពេលវេលាសម្តែងរបស់អ្នកឱ្យបានសមស្រប
- មិនគួរបញ្ចេញបញ្ចូលពាក្យពេចន៍ ឱ្យឃ្លាតឆ្ងាយពីសាច់រឿងទេ ឬប្រើពាក្យពេចន៍មិនសមរម្យ អសីលធម៌ឡើយ ។

# សំណេរសង្ខេបអត្ថបទល្ខោនជាពាក្យរាយ

អ្នកបានសិក្សាពីអត្ថបទដកស្រង់រឿង តេជោយ៉ត រួចហើយ ។ ឥឡូវនេះចូរអ្នកសរសេរសង្ខេបអត្ថបទនេះឡើងវិញជាពាក្យរាយ ។ នៅពេលសង្ខេបអត្ថបទអ្នកគប្បី ៖

- មិនត្រូវសរសេរពង្រីកគំនិតសំខាន់ៗនោះទេ
- រៀបចំគំនិតសំខាន់ៗឱ្យទៅជាអត្ថបទសង្ខេបត្រឹមត្រូវមួយ
- មិនត្រូវលើកយកសេចក្ដីលម្អិតមកធ្វើសេចក្ដីសង្ខេបទេ
- សរសេរសង្ខេបឱ្យចំខ្លឹមសារសំខាន់ៗនៃអត្ថបទ
- ប្រើប្រាស់ពាក្យពេចន៍ ឃ្លាល្បះឱ្យបានសមរម្យនិងត្រឹមត្រូវ ។

**មេរៀនទី**

**៩**

# សេចក្ដីថ្លៃថ្នូរ



សេចក្ដីថ្លៃថ្នូរ គឺជាភាពចាំបាច់របស់មនុស្ស ដែលបានស្ដែងចេញតាមរយៈអំពើរបស់ខ្លួន ។ អំពើល្អទាំងនោះត្រូវបានផ្សារភ្ជាប់ជាមួយនឹងសកម្មភាពវិជ្ជមាន ដោយការប្រកាន់មុខរបរសុចរិត ការគោរពសិទ្ធិ ឬក៏ការគោរពច្បាប់ជាដើម ។ មិនតែប៉ុណ្ណោះសេចក្ដីថ្លៃថ្នូរក៏បានកំណត់តម្លៃបុគ្គល ឬតម្លៃជាតិ ឱ្យមានភាពវិសេសវិសាលថែមទៀត នៅចំពោះមុខសង្គមមនុស្ស ឬពិភពលោកទាំងមូល ។

ដូច្នេះក្នុងមេរៀននេះ អ្នកនឹងទទួលបានពុទ្ធិថ្មីៗទៀតក្នុងការលើកតម្លៃអ្នកឱ្យមានសេចក្ដីថ្លៃថ្នូរតាមរយៈការប្រកបការងារសុចរិត ការប្រកាន់ឥរិយាបថប្រកបទៅដោយសីលធម៌ ព្រមទាំងការគោរពសិទ្ធិគ្នាជាដើម ។ អ្នកនឹងបានសិក្សាផងដែរអំពី បំរៀបន័យ ឬមេតាផរ នាមនិងប្រភេទរបស់នាម ខ្លឹមសារអត្ថបទ គំនិតបង្កប់ក្នុងអត្ថបទកំណាព្យ តម្លៃអប់រំ ការសូត្រកំណាព្យ ការតែងកំណាព្យ ។

# បំរៀបន័យ ឬមេតាផរ

ក្នុងភាសាខ្មែរមានសំនួនពាក្យជាច្រើន ដែលមានន័យប្រៀបធៀបពីអង្គមួយទៅអង្គមួយទៀត ពីវត្ថុមួយទៅវត្ថុមួយទៀត ។ ជាមួយនេះ ចូរអ្នកអានឧទាហរណ៍ខាងក្រោម ៖

- ចកជីវិត ៖ ជីវិតរសាត់អណ្តែតគ្មានទិសដៅ ។
- ភ្នំថ្មឹង ៖ ថ្មឹងជាច្រើនគរជាគំនរខ្ពស់ដូចជាភ្នំ ។
- ជើងភ្នំ ៖ ជាផ្នែកខាងក្រោមនៃភ្នំ ដូចអវយវៈខាងក្រោមរបស់មនុស្ស ដែលហៅថា ជើង ។
- សមុទ្រទឹកភ្នែក ៖ ជាទុក្ខដ៏សែនធ្ងន់ធ្ងរដែលស្តែងចេញតាមរយៈការយំបញ្ចេញទឹកភ្នែកប្រៀបបាននឹងទឹកសមុទ្រ ។
- មេឃស្រកានាគ ៖ ជាមេឃដែលមានដុំពពករូបរាងដូចស្រកាធំៗ ដែលប្រៀបបាននឹងស្រកានាគ ។

ឧទាហរណ៍ខាងលើបញ្ជាក់ថា សំនួនពាក្យទាំងនេះកើតចេញពីទំហៀបមួយ ដែលមិនប្រើសំនួនប្រៀបធៀប "ដូច ដូចជា ហាក់ដូចជា ឬឧបមា ..." នៅចន្លោះនៃអង្គទាំងពីរនោះទេ ។

*បំរៀបន័យ ឬមេតាផរ គឺជាទំហៀបន័យដោយគ្មានចំណងធៀបឡើយ ។*

## លំហាត់

ក. ចូរអ្នកអានអត្ថបទដកស្រង់ខាងក្រោមនេះ ដើម្បីស្វែងរកសំនួនពាក្យដែលជា "មេតាផរ" ៖

[...] រទេះភ្លើងបោលលឿនដូចព្យុះ កាត់ព្រៃខ្លងនិងព្រេច រត់ឆ្លងអូរ ហើយពុះជ្រែកជើងភ្នំដោយបញ្ចេញសន្ទឹកខ្ទរលំពង ធ្វើឱ្យរញ្ជួយផែនពសុធា ។

បើគេសម្លឹងមើលតាមបង្អួចនៃទូរថភ្លើងណាមួយគេនឹងបានឃើញកម្រាលព្រំបៃតងលាតសន្ធឹងដាច់កន្ទុយភ្នែកនារដូវវស្សា ។ [...]

បុប្ផាទាំងនេះហាក់ដូចជាឧបត្ថិកឡើងសម្រាប់ជាគ្រឿងលម្អនៃសំពត់ព្រំពណ៌បៃតង ដែលលាតសន្ធឹងក្រោមមេឃស្រកានាគនិងក្រោមរស្មីថ្លាត្រចះនៃព្រះសុរិយា ។

ខ. ចូរអ្នកជ្រើសរើសសំនួនពាក្យខាងក្រោម ដែលបញ្ជាក់ថា ជា "មេតាផរ"៖

| | | |
|---|---|---|
| - ជើងជណ្តើរ | - ក្បាលព្រែក | - ភ្នែកភ្នាល់ចាបពួក |
| - ក្បាលជ្រោយ | - អន្លង់ស្នេហ៍ | - ត្រកួនភ្លេចបឹង |
| - ខ្លាក្រដាស | - ជើងល្អ | - ម្រាមដៃដូចបន្លាក្រូច |
| - ខ្លួនបងដូចជាដំរី | - វិថីជីវិត | - មេឃប្រែពណ៌ |
| - ដួងចន្ទ្រា | - សមុទ្រទឹកសាប | - លឿងដូចមាសឆ្អិន |

# ភាពថ្លៃថ្នូរនៃបុគ្គល



## ក. សិក្សាពាក្យគន្លឹះ

- យស (ន) : អានុភាព ឥស្សរភាព ទ្រព្យធន បរិវារ កេរ្តិ៍ឈ្មោះល្អ ។
- សក្តិ (ន) : អំណាច សេចក្តីអង់អាច ។
- កុង្សីយ៍ (ន) : ក្រុមឬពួកអ្នកទូន្មាន ។
- សច្ចំ (កិ វិ) : ទៀង ពិត ប្រាកដ មែន មែនហើយ ។
- កតញ្ញូ (ន) : អ្នកដឹងឧបការគុណដែលអ្នកឯទៀតបានធ្វើចំពោះខ្លួន ។
- ខន្តី (ន) : សេចក្តីអំណត់អត់ធន់ អំណត់អត់ឱន ។
- ឧបេក្ខា (ន) : ការតាំងចិត្តជាកណ្តាល ដំណើរមិនលំអៀងទៅខាងណា ។
- ពាក្យសត្យ (ន) : ពាក្យពិត ទៀងទាត់ ពាក្យទៀងត្រង់ ។
- អវចី (ន) : កន្លែងដែលអាក្រក់ ឋានអាក្រក់ប្រៀបដូចឋាននរកអវិចី ។
- ទសពិធ (ន) : រាជធម៌១០យ៉ាងគឺធម៌១០ប្រការសម្រាប់ព្រះរាជាទ្រង់ប្រព្រឹត្តព្រមទាំងណែនាំពួកសេនាបតី មន្ត្រីតូចធំនិងរាស្ត្រឱ្យប្រព្រឹត្តផងដែរ ។

- សច្ចា (កិ) : ប្រកាសពាក្យសច្ចៈ ពាក្យពិត សំបូងសង្រួង ។
- បរលោក (ន) : លោកឯមុខ លោកឯនាយ ។
- រែកពុន (កិ) : ទទួលរ៉ាប់រងការងារ ឬទទួលបន្ទុកការងារណាមួយដ៏ធ្ងន់ធ្ងរ ។
- ឆ្លូកឆ្លាក់ (កិ) : ខ្មីឃ្មាត ប្រឹងប្រែងបំពេញកិច្ចការណាមួយ ។
- បារាំងសេស (ន) : មនុស្សជាតិបារាំង ។
- ហ្លួង (ន) : ព្រះរាជា ។
- ចូកចាំង (កិ) : ពង្រាប ឬចូកឆាយ ឈូសឆាយឱ្យស្មើ ។
- ឥន្ទ្រិយ (គុ) : ញាណទាំង ៦ របស់មនុស្ស ដែលមាននាទីសំខាន់ៗរៀងៗខ្លួនដូចជា ចក្ខុឥន្ទ្រិយ(ភ្នែក) សោតិន្ទ្រិយ(ត្រចៀក) ឃានិន្ទ្រិយ(ច្រមុះ) ជីវ្ហិន្ទ្រិយ(អណ្តាត) កាយិន្ទ្រិយ(កាយ ខ្លួន) មនិន្ទ្រិយ(ចិត្ត មនោ) ។
- ភ័ព្វ (ន) : ដែលមានសំណាងល្អ ដែលមានសេចក្តីសុខ ។
- វិញ្ញាណ (ន) : ធម្មជាតិដែលដឹងច្បាស់ពីអារម្មណ៍ឬចិត្ត ។
- បទ (ន) : ទំនង ដំណើរទំនង ដើមទង ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទកាព្យដកស្រង់ពីច្បាប់ក្រមង៉ុយ សូមអ្នកអានដោយយកចិត្តទុកដាក់ ហើយកត់ចំណាំចំណុចសំខាន់ៗដែលមានក្នុងកំណាព្យដូចជា ស្គាល់ពីអត្ថបទសេចក្តីលម្អិតនិងខ្លឹមសារសំខាន់ៗក្នុងអត្ថបទកាព្យឱ្យបានច្បាស់លាស់ ដើម្បីត្រៀមឆ្លើយនឹងសំណួរមួយចំនួនខាង ក្រោម ៖

## គ. អត្ថបទ

១. បើអ្នកមានយស មានសក្តិខ្ពង់ខ្ពស់ គាប់នឹងរាជការ
ធ្វើធំធ្វើថី មន្ត្រីមានត្រា ព្រះហ្លួងឧកញ៉ា
សាលាកុង្សីយ៍ ។

២. ចេះច្បាប់បារាំង កុំភ្លេចសច្ចំ កតញ្ញូខន្តី
កុំឆ្មើងហួសមាឌ ភ្លេចញាតិប្រុសស្រី ជំនុំកាត់ក្តី
យកឧបេក្ខា ។

៣. កុំកាន់សីហលោ កុំកាន់លោភោ ទោសោមោហា
កុំជក់អាភៀន កុំឃ្លានផឹកស្រា កុំស្អប់ខាងណា
សច្ចាយកត្រង់ ។

៤. ល្បួងលោមពិសោធ កុំឆបញ្ឆោត បញ្ចូលឱ្យបង់
ឱ្យបែកឱ្យបាក់ ពាក្យសត្យពាក្យសង្ឃ កូនអើយផ្ចិតផ្ចង់
តម្រង់ស្មារតី ។

៥. កុំភ្លើនឃើញប្រាក់ កុំភ្លើនភ្លាត់សក្តិ ធ្លាក់ទៅអវិថី
កាន់ធម៌ទសពិធ រឹតឡើងរាសី គាប់ពីលោកិយ
ដល់បរលោកនាយ ។

៦. អ្នកក្តីជាភ្លើង កុំកាត់កាន់ជើង អ្នកម្ខាងមើលងាយ
ថៅក្រមជាទឹក រំឭករំលាយ កុំជេរកុំវាយ
បង្ខំនាំខុស ។ [...]

៧. បើទៅជារាស្ត្រ ប្រាជ្ញាវៃឈ្លាស គួសវាសឆ្លកឆ្លាក់
ឱ្យឆ្លៀតរែកពុន បើធ្ងន់សុំដាក់ ខំរកមាសប្រាក់
ឱ្យគ្រាន់ទាន់ចាយ ។

៨. រាជ្យបារាំងសេស កូនកុំប្រហែស កុំថ្នមរូបកាយ
ដើរគិតដេកគិត ជួញជិតជួញឆ្ងាយ បើចង់សប្បាយ
ស្រេចនៅមានទ្រព្យ ។

៩. រាជ្យហ្លួងពីមុន រកស៊ីរែកពុន មានក្រតាមភ័ព្វ
រាជ្យលោកឥឡូវ ត្រូវខំឱ្យញាប់ តែខ្ជិលច្រើនជាប់
ខ្នោះជើងខ្នោះដៃ ។

១០. តាំងពីឆ្នាំច ចាំជាតំណ ទំនិញឡើងថ្លៃ
ចងក្បិនឱ្យតឹង ប្រឹងកុំសំចៃ សញ្ជឹងយប់ថ្ងៃ
កុំឱ្យក្រខ្សត់ ។

១១. បើចង់ស្រួលខ្លួន រៀនសូត្រឱ្យម្ជួន ឱ្យមាំឱ្យស្ទាត់
កុំចេះស្ទាក់ស្ទើរ ល្ងីល្ងើឥតបទ បើចេះប្រាកដ
ប្រាក់រត់តាមហៅ ។

១២. កុំថ្នមកម្លាំង កាប់ជីកចូកចាំង កុំថារងាក្តៅ
រៀនអ្វីឱ្យឆ្អិន កុំឱ្យខ្លោចឆៅ កុំដេកតែខ្លៅ
ក្រក្រៅសណ្តាប់ ។

១៣. បើល្ងង់ឱ្យចេះ　រករៀនតម្រិះ　រិះរកតម្រាប់
ឥន្ទ្រិយឆ្វេងស្ដាំ　កុំចាំគេប្រាប់　រៀនស្ដីរៀនស្ដាប់
រៀនមើលឱ្យស្ដែង ។

១៤-កើតមកជាមនុស្ស　ទាំងស្រីទាំងប្រុស　មិនមែនចេះឯង
បើក្រឱ្យមាន　វិញ្ញាណចេះក្រែង　គិតគ្រប់កន្លែង
កុំដេកតែក្រ ។

*(ដកស្រង់ពី ច្បាប់ល្បើកថ្មីនៃច្បាប់ក្រមង៉ុយ)*

## សំណួរ

១. តើអត្ថបទកាព្យខាងលើនេះ តាក់តែងឡើងដោយកវីណា ? តើលោករស់នៅក្នុងសម័យកាលណា ?
២. តើកំណាព្យនេះ ជាបទអ្វី ? គេប្រើបទនេះនៅពេលណា ?
៣. តើអត្ថបទកាព្យ មានន័យដូចម្ដេច ? ចូរបកស្រាយ ។
៤. តើឃ្លាថា "បើក្រឱ្យមាន"តើមានអ្វី ? "កុំដេកតែក្រ" មានន័យដូចម្ដេច ?
៥. តើអត្ថបទកាព្យនេះ ក្នុងមួយល្បះមានប៉ុន្មានឃ្លា ? មួយឃ្លាមានប៉ុន្មានព្យាង្គ ? ចូរគូសគំនូសតាងចំណាប់ចួន ។
៦. តើខ្លឹមសារនៃអត្ថបទកាព្យនេះ បានផ្ដល់តម្លៃអប់រំយ៉ាងណាខ្លះ ?
៧. ចូរអ្នកបង្ហាញពីបំរៀបន័យនៅក្នុងអត្ថបទកាព្យខាងលើ ។

# នាមនិងប្រភេទនាម

ក្នុងមេរៀននេះ ប្អូននឹងសិក្សាអំពីនាមនិងប្រភេទនាម ។

ដូចម្ដេចហៅថានាម ? តើនាមមានអ្វីខ្លះ ?

ចូរពិនិត្យឧទាហរណ៍ :

១. ពូដឹកគោទៅឱ្យស៊ីស្មៅតាមភ្លឺស្រែ ។

២. តាសុកនាំអាពាលទៅរកសត្វ ឯព្រៃភ្នំខ្សាច់ស ។

៣. ការរស់នៅរបស់ប្រជាជនកម្ពុជាពឹងផ្អែកមួយផ្នែកលើការបង្កបង្កើនផល ។

៤. អ្នកភ្ជួរ អ្នករាស់ អ្នករែកកណ្ដាប់ អ្នកស្ទូង បំពេញភារកិច្ចរៀងៗខ្លួនយ៉ាងសកម្ម ។

ក្នុងឧទាហរណ៍នេះបានឱ្យឃើញថា :

ល្បះទី ១ : ពាក្យ "ពូ គោ ស្មៅ ភ្លឺស្រែ" ជាសាធារណនាមដែលសម្គាល់ចំពោះ មនុស្ស សត្វ រុក្ខជាតិ ទីកន្លែង ជាដើម ។

ល្បះទី ២ : ពាក្យ "សុក ពាល ខ្សាច់ស" ជាអសាធារណនាមដែលសម្គាល់ចំពោះ មនុស្សម្នាក់ សត្វមួយ ទីកន្លែងមួយ ។

ល្បះទី ៣ : ពាក្យ "ការរស់នៅ ការបង្កបង្កើនផល"ជាករណនាមដែលសម្ដែងសភាពឬសកម្មភាព ។

ល្បះទី ៤ : ពាក្យ "អ្នកភ្ជួរ អ្នករាស់ អ្នករែក អ្នកស្ទូង" ជាការកនាមដែលប្រាប់អ្នកធ្វើអំពើ ។

*នាម គឺថ្នាក់ពាក្យមួយប្រភេទសម្រាប់សម្គាល់មនុស្ស សត្វ វត្ថុ ទីកន្លែង សកម្មភាព និង បញ្ជាក់ពីឈ្មោះមនុស្ស សត្វ ទីកន្លែងណាមួយ ... ។*

- *សាធារណនាម ឬនាមសាធារណ៍ គឺជានាមសម្ដែងមិនចំពោះ ទូទៅ ។*
- *អសាធារណនាម ឬនាមអសាធារណ៍ គឺជានាមសម្ដែងឈ្មោះប្រាកដ ចំពោះ មិនទូទៅ ។*
- *នាមករណ៍ ឬករណនាម គឺជានាមសម្ដែងសភាព ឬសកម្មភាព ។*
- *នាមការក៍ ឬការកនាម គឺជានាមសម្ដែងអ្នកធ្វើអំពើ ឬអ្នកមានសភាពលក្ខណៈបែបណាមួយ ។*

- នាមករណ៍ ឬករណនាមចេញមកពី :

- កិរិយាសព្ទ

| កិរិយា | ករណនាម | កិរិយា | ករណនាម |
|---|---|---|---|
| ធ្វើ | ទង្វើ | ប្រព្រឹត្ត | ការប្រព្រឹត្ត ឬប្រព្រឹត្តិ |
| សង្កេត | ការសង្កេត | អនុវត្ត | ការអនុវត្ត ឬអនុវត្តន៍ |
| អធិប្បាយ | ការអធិប្បាយ | | |
| ជោរ | ជំនោរ | | |

- គុណនាម

| គុណនាម | ករណនាម | គុណនាម | ករណនាម |
|---|---|---|---|
| សុខ | សេចក្តីសុខ | កាច | កំណាច |
| ចម្រើន | សេចក្តីចម្រើន | ខ្ពស់ | កម្ពស់ |
| ថ្លៃថ្នូរ | សេចក្តីថ្លៃថ្នូរ | វែង | ប្រវែង |
| លំបាក | សេចក្តីលំបាក | ក្រាស់ | កម្រាស់ |

- នាមការក៍ ឬការកនាមចេញមកអំពី :

- កិរិយាសព្ទ

| កិរិយា | ការកនាម | កិរិយា | ការកនាម |
|---|---|---|---|
| យាម | អ្នកយាម | ចាំ | ឆ្មាំ |
| ពោល | អ្នកពោល | ដើរ | ថ្មើរ |
| នាំ | អ្នកនាំ | កាន់ | ខ្មាន់ |
| ស៊ី | អ្នកស៊ី | កើត | ខ្មើត |

- គុណនាម

| គុណនាម | ការកនាម | គុណនាម | ការកនាម |
|---|---|---|---|
| ល្អ | អ្នកល្អ | ក្រ | អ្នកក្រ |
| អាក្រក់ | អ្នកអាក្រក់ | ក្លាហាន | អ្នកក្លាហាន |
| កណ្ដាល | អ្នកកណ្ដាល | ខ្សត់ | អ្នកខ្សត់ |
| តូច | អ្នកតូច | ខ្សោយ | អ្នកខ្សោយ |

- នាម

| នាម | ការកនាម | នាម | ការកនាម |
|---|---|---|---|
| ក្រុង | អ្នកក្រុង | ស្រុក | អ្នកស្រុក |
| ភូមិ | អ្នកភូមិ | ស្រែ | អ្នកស្រែ |
| ចម្ការ | អ្នកចម្ការ | ព្រៃ | អ្នកព្រៃ |

## លំហាត់

១. ចូរតែងល្បះឱ្យបាន ៤ល្បះដោយប្រើ :

- សាធារណនាម ចំនួន ១ល្បះ
- អសាធារណនាម ចំនួន ១ល្បះ
- នាមករណ៍ ឬករណនាម ចំនួន ១ល្បះ
- នាមការក៍ ឬការកនាម ចំនួន ១ល្បះ ។

២. ចូរអ្នកជ្រើសរើសនាមខាងក្រោមនេះ ទៅតាមប្រភេទនីមួយៗ : ពូម៉ន ភ្នំពេញ ក្របី ស្វា អ្នកក្រុង វាលស្រែ ស្រូវ ម្រេច សុភាព អ្នកក្រ កម្មករ និយោជិត ថៅកែ ។

៣. ចូរអ្នកជ្រើសរើសពាក្យ ជាកិរិយា ជាគុណនាម និងជានាម ដើម្បីបង្កើតឱ្យទៅជាករណនាម ការកនាម ចំនួន ៥ពាក្យ ក្នុងនាមនីមួយៗ ។

# ឧត្តមភាពបុគ្គល



## ក. សិក្សាពាក្យគន្លឹះ

- ស្លែង (គុ) : ដែលឱ្យទោស ដែលនាំឱ្យទាស់ ។
- ក្រោធ (ន) : កំហឹង ខឹងខ្លាំង ។
- ដោះសា (កិ) : រ៉ាយរ៉ាប់ រៀបរាប់ បូបាច់ សាទុក្ខ សាទោស ។
- ឆ្លា (កិ.វិ) : ដែលចេញអាការប្រញាប់ប្រញាល់ តែវឹមវាម ទទឹសទទាស ។
- សង្ឃ្យក (កិ) : ស្រែកគំរាម ស្រែកសន្ធាប់ឱ្យស្លុត ។
- ពលរេហ៍ (ន) : សេនា ទាហាន កងទ័ព ។
- បៀតបៀន (កិ) : ជ្រៀតបៀត យាយី ធ្វើទុក្ខអ្នកដទៃឱ្យបានក្ដីក្ដៅក្រហាយ ។
- សិរសា (ន) : ក្បាល ។
- ពារ (កិ) : ប៉ះលើ ឬប៉ះត្រូវទាំងស្រុង ប្រទះលើគ្រោះកាច ... ។
- បារម្ភ (ន) : ដំណើរនឹកថប់ ឬនឹកព្រួយជាមុន ។
- ឧត្តម (គុ) : ខ្ពង់ខ្ពស់ ប្រសើរ ថ្លៃថ្លា ។
- សង្ខាត (កិ) : ខំប្រឹងប្រែង ស្រវាស្រទេញ ខ្មីឃ្មាត ។

- ទេសនា (ន) : ការសម្ដែងធម៌ ។
- វៀរ (កិ) : លើកលែង តម ឈប់ខាន ។
- ក្រឹត្យក្រម (ន) : ដំណើរ បែប លំនាំ ឬក្បួនច្បាប់ ។
- ធម្មា (ន) : ធម៌ សភាវៈទ្រទ្រង់សត្វលោក គឺបុណ្យ បាប សុចរិត ទុច្ចរិត ... ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទកាព្យដកស្រង់ពី "ច្បាប់ទូន្មានខ្លួន"ខាងក្រោមនេះ អ្នកត្រូវអានដោយយកចិត្តទុកដាក់ ហើយត្រៀមឆ្លើយសំណួរមួយចំនួន ដែលទាក់ទងសេចក្ដីលម្អិតក្នុងអត្ថបទកាព្យ ខ្លឹមសារអត្ថបទ រកគំនិតសំខាន់បង្កប់ក្នុងអត្ថបទកាព្យនិងបង្ហាញពីកាព្យមាត្រ ។

## គ. អត្ថបទ

### បទព្រហ្មគីតិ

[...] ១. ពាក្យក្រកុំអាលប្រាប់ ពាក្យឥតសព្ទកុំអាលថ្លែង
ពាក្យពិតកុំឱ្យចែង ពាក្យពិតស្លែងពុំគួរលាក់ ។

២. គេប្រាប់កុំអាលក្រោធ គេបញ្ឆោតកុំអាលភ្ញាក់
សឹកដេកកុំអាលបាក់ គ្នាជំពាក់ប្រើដោះសា ។

៣. គេរត់កុំអាលដេញ គេលើកចេញកុំអាលថា
សឹកដល់កុំអាលឆ្លា ពួវាចាកុំអាលយក ។

៤. គេប្រើកុំអាលទៅ គេឱ្យហៅកុំអាលមក
គេឱ្យកុំអាលយក គេសង្ឃកកុំអាលថយ ។

៥. ខ្លួនតូចកុំខំពារ ខ្លួនអ្នកជាកុំគិតធ្លោយ
ឱ្យគិតក្រែងក្រក្រោយ ខ្លួនខ្សត់ខ្សោយឱ្យបារម្ភ ។

៦. ទំនៀមទំនឹមព្រេង ច្បាប់ថ្លាថ្លែងដោយក្រឹត្យក្រម
ពាក្យនេះជាឧត្ដម ចូរបាខំៗត្រងត្រាប់ ។

៧. សង្ខាតរកស៊ីចុក ជួលលក់ទិញតាមច្បាប់
ខ្សត់គ្មានឃ្លានស្ទូស្លាប់ កុំខុសច្បាប់ព្រះធម្មា ។

៨. មានទ្រព្យត្បិតសំណាង ជាតិមុនសាងទានសីលា
បើកើតជាតិនេះណា មានទ្រព្យធនត្បិតទានគេ ។

៩. បើខ្លួនមានស័ក្តិបុណ្យ បានទ្រព្យធនខ្ញុំពលរេហ៍
ធ្វើចិត្តឱ្យត្រង់ត្រៃ ជាតិទៅមុខនឹងបានទៀត ។

១០. ស៊ីបានៗនឹងខំ លោកវាយដំគេបៀនបៀត
បំបាត់ទ្រព្យគេឆ្លៀត ខុសច្បាប់ផងមិនទេឡើយ ។

១១. ល្អតែនៅលោកិយ លុះដល់ក្ស័យជីវិតហើយ
ទល់ទុក្ខពុំដែលស្បើយ រូបវែងរងកម្មវេទនា ។

១២. ព្រះទ្រង់ទេសនាមក គួរតែយកទុកសិរសា
មនុស្សសត្វផងក្តីណា ពុំដែលវៀរពីក្តីស្លាប់ ។

១៣. គួរតែសាងសីលទាន នោះនឹងបានបុណ្យលាងបាប
រក្សាសីលដរាប នោះប្រសើរពេកកូនអើយ ។ [...]

*(ដកស្រង់ចេញពី "ច្បាប់ទូន្មានខ្លួន" របស់ពុទ្ធសាសនបណ្ឌិត្យ ព.ស ២៥៣៥ គ.ស. ១៩៩៥)*

## សំណួរ

១. តើអត្ថបទកាព្យខាងលើនេះ តែងជាបទអ្វី? ដកស្រង់ចេញពីសៀវភៅណា ?

២. តើអត្ថបទនេះមានចំណុចណាខ្លះ ដែលនិយាយទាក់ទងទៅនឹងសេចក្តីថ្លៃថ្នូរ ?

៣. ចូរបង្ហាញពីតម្លៃអប់រំក្នុងអត្ថបទនេះ ។

៤. តើល្បះនេះ "ព្រះទ្រង់ទេសនាមក គួរតែយកទុកសិរសា មនុស្សសត្វផងក្តីណា ពុំដែលវៀរពីក្តីស្លាប់" មានន័យដូចម្តេច ?

៥. ចូរប្រាប់រង្វាស់កាព្យ ចំណាប់ចួន ផ្ទួន រណ្តំ ចង្វាក់ និងបរិយាកាសនៃកំណាព្យនេះ ។

៦. ចូរពន្យល់ន័យនៃឃ្លានីមួយៗនៃវគ្គ :

ពាក្យក្រកុំអាលប្រាប់ ពាក្យឥតសព្ទកុំអាលថ្លែង
ពាក្យពិតកុំអាលថែង ពាក្យពិតស្លែងពុំគួរលាក់ ។



# តម្លៃនៃការសេពគប់



ចូរអ្នកស្ដាប់អត្ថបទកាព្យ "តម្លៃនៃការសេពគប់" ហើយត្រៀមខ្លួនឆ្លើយនឹងសំណួរខាងក្រោមនេះ ដែលបង្ហាញឱ្យអ្នកឃើញពីការចេះប្រកាន់យកសេចក្ដីថ្លៃថ្នូរ ដែលបានមកពីការសេពគប់ ។

## សំណួរ

១. តើអត្ថបទកំណាព្យនេះសសេរជាបទអ្វី ? មានប៉ុន្មានព្យាង្គក្នុងមួយឃ្លា ? ហើយមានប៉ុន្មានឃ្លាក្នុងមួយល្បះ ?

២. តើពាក្យ "គប់" មានន័យប៉ុន្មានយ៉ាង? អ្វីខ្លះ ? តើ "គប់" នៅទីនេះគឺសំដៅទៅលើអ្វី ? ចូរបញ្ជាក់ដោយរកឧទាហរណ៍ក្នុងអត្ថបទនេះ ។

៣. ហេតុដូចម្ដេច បានជាកវីលើកយកការសេពគប់មកធ្វើការអប់រំដល់អ្នកសិក្សា ?

៤. តើឱវាទរបស់កវីក្នុងអត្ថបទកាព្យខាងលើនេះ បានផ្ដល់តម្លៃអប់រំយ៉ាងណាខ្លះ ?

៥. តើការសេពគប់មិត្តល្អបានផ្ដល់តម្លៃដល់អ្នកយ៉ាងណាខ្លះ ?

# សូត្រកំណាព្យបទពាក្យ៨និងបទពាក្យ៩

ការសូត្រកំណាព្យមានបែបបទផ្សេងៗ អាស្រ័យលើប្រភេទបទក្នុងការលើកដាក់សំឡេង ឱ្យទៅចង្វាក់នៃបទកំណាព្យនោះ។ តទៅនេះ យើងសាកល្បងសូត្រកំណាព្យបទខាងក្រោម ដើម្បីស្វែងយល់ពីការលើកដាក់សំឡេង ព្រមទាំងស្វែងយល់ពីខ្លឹមសារដែលទាក់ទងទៅនឹងភាពថ្លៃថ្នូររបស់បុគ្គល និងជាតិខ្លួន។

**ចូរអ្នកសូត្រកំណាព្យខាងក្រោមនេះ :**

## បទពាក្យ ៨

- រង្វាស់កាព្យ : ១វគ្គមាន៤ឃ្លា មួយឃ្លាៗ មាន៨ព្យាង្គ។
- របៀបសូត្រ : គេសូត្រទម្លាក់សំឡេងលើព្យាង្គទី៣ និងទី៥ នៃឃ្លានីមួយៗ។

ក. អនិច្ចាតោថ្មលោកកសាង មើលថាថាងយ៉ាងរស់ស្មុះប្រែប្រាយ
ឥឡូវមកធ្លាយធ្លាក់បាក់ខ្ចាត់ខ្ចាយ ស្តាយអើយស្តាយមិនគួរមកពិការ។
មានអ្នកព្រៃចង្រៃឥតគំនិត ទៅសំលៀងកាំបិតគ្រឿងប្រហារ
ឱ្យខូចខាតសាច់បង់អាសា មិនស្តាយការស្នាដៃបុរាណសោះ។
ឱតោអើយតោឈរមិនមើលមៀង មកឱ្យគេសំលៀងខ្នងតោចុះ
ម្តេចមិនខឹងខាំវាសំលៀងនោះ ឱ្យវាលុះក្តីមរណ៍យក៏វាទៅ។
អាណាអើយបំផ្លាញរូបតោលោក គ្មានប្រយោគឱ្យយល់ការរាក់ជ្រៅ
គួរឬលោកខំសាងតាំងទុកនៅ មកសត្រូវបំផ្លាញរបស់លោក។
*(ដកស្រង់ចេញពី សុត្តន្តប្រីជាឥន្ទ)*

ខ. គន់ៗស្ពានស្ពានថ្មគួរប្រជិត ជាក្តារថ្មជាសជិតប្រកិតគោក
ទោះដំរីបរជាន់ក៏គ្មានយោគ ឥឡូវជ្រោកស្រុតខ្លះតែដើរបាន។
ប្រកាន់ដៃច្នៃរូបវាសុក្រឹ ដប់សិរសីដូចស្និទ្ធជិតជុំប្រាណ
លើកពពារឡើងពភ្លាក់ហាក់ហៅឋាន សម្តែងប្រាណព្រួញរូបជាមួយគ្នា។
មើលនាគរាជរបង់អាចអំណាចស្វែង ខ្លួនកវែងក្បាលក៏ដល់តាមទ្វារា
លូនលើស្ពានមានជើងគល់គង្គា កន្ទុយបែកខ្វែកគ្នាតាមផ្លូវ។
ឱ! រូបវាសុក្រឹឥតក្រែងគ្រុឌ តាំងសម្តែងឫទ្ធិរុទ្ធិតសត្រូវ
ប្រសិនបើគ្រុឌមកយល់យ៉ាងពុំនៅ គង់ស្មុះទៅជ្រកក្នុងសិន្ធុនេះ។

នាគអើយនាគបាសាណបុរាណសាង ពីដើមយ៉ាងល្អដូចម្ដេចអេះ
ឥឡូវនាគងាកធ្លាក់បាក់របេះ ឃើញតែរាងយ៉ាងនេះអស់លម្អ ។

*(សុត្តន្តប្រីជាឥន្ទ កំណាព្យខ្មែរភាគ ១ ឆ្នាំ ១៩៨៤)*

## បទពាក្យ ៩

- រង្វាស់កាព្យ : ១វគ្គមាន៤ឃ្លា មួយឃ្លាៗ មាន៩ព្យាង្គ ។
- របៀបស្ទួន : គេស្ទួនទម្លាក់សំឡេងលើព្យាង្គទី៣ និងទី៦ គ្រប់ៗឃ្លា ។

ក. [...] ខ្ញុំស្រឡាញ់ដួងចន្ទ្រាជាល្បែងក្មេង ម្ដាយពោលលេងឱ្យកូនតូចពនសុំបាយ
សុំសម្ល ទឹកបំពង់ ចេក ដូង ស្វាយ កូនសប្បាយញ៉ាំចិបៗ សើចក្អឹកៗ ។
ខ្ញុំស្រឡាញ់ដួងចន្ទ្រាមានពោធិធំ ជីដូនខ្ញុំប្រាប់ដូច្នេះមកជាញឹក
មើលទៅឃើញមានឫសគល់ដើមមែកស្លឹក ក្រោមពោធិព្រឹក្សដូនចាស់រវៃអំបោះ ។
ខ្ញុំស្រឡាញ់ដួងចន្ទ្រាហៅសសាង្ក ព្រះឥន្ទ្រស្អាងរូបទន្សាយទុកនៅនោះ
រំលឹកកាលពោធិសត្វគិតសង្គ្រោះ ព្រាហ្មណ៍ដោយស្មុះលោតចូលភ្លើងជាអាហារ ។
ខ្ញុំស្រឡាញ់ដួងចន្ទ្រាហៅលោកខែ នៅស្រុកខ្មែររាជពិធីដ៏ថ្លៃថ្លា
អកអំបុកងើយមើលដួងចន្ទ្រា បន់ទេពតាសូមខេមរាបានចម្រើនថ្កាន ។ [...]

*(ដកស្រង់ចេញពី បុប្ផាខ្មៅ របស់លោកគយសារុន)*

ខ. ឱអង្គរ ឈររឹងមាំ ទ្រាំរយឆ្នាំ
ចារចងចាំ ផ្ដាំទុកកេរ ស្ថេរស្ថិតនៅ
កេរកម្មករ ល្អប្រណីត ក្រឹត្យត្រឹមត្រូវ
ដល់ឥឡូវ នៅកោតស្ញែង ខែងរឹងណាស់ ។
កោតសាមគ្គី ស៊ីសង្វាក់ ដាក់ផែនការ
រួចរចនា ចារសាងសង់ ខ្ជង់ជាក់ច្បាស់
រួមកសិករ បវរខ្នាញ់ បញ្ញាវន្តឈ្នះ
ជ័យត្រចះ ដាស់ស្មារតី ប្រិយអធន ។
កោតគំនិត ពិតជឿនលឿន ខឿនវិជ្ជា
ពិតពុះពារ ធានាច្បាស់ ម្ចាស់ជីពជន្ម
ចិត្តខ្ពង់ខ្ពស់ រស់រវើក លើករូបមន្ត
ឥតទម្រន់ ធ្ងន់កាយចិត្ត ប្រិតមធ្យ័ត ។

កោតខន្តី ឱ្យព្យាយាម ទាមទារខំ
ប្រឹងលត់ដំ សមស័ក្តិសិទ្ធិ រឹងម៉ឺងម៉ាត់
ថ្មលើថ្ម ដ៏ធ្ងន់ក្រៃ ដៃអារកាត់
លើកឆ្លៀលឆ្វាត់ ចាត់ចែងគ្រប់ ផ្គុំគល់ផ្តុំ ។
កោតសំណង់ សង់ត្រឹមត្រូវ នូវក្បួនច្បាប់
ប្រើប្រដាប់ ប្រាប់ប្រឌិត សិទ្ធិធេងធំ
ប្រើបញ្ញា ខ្លាំងក្លាក្រៃ ច្នៃបរម
សាងសំណុំ ក្រុមប្រាសាទ ស្អាតវិចិត្រ ។
កោតក្បូរក្បាច់ ដាច់ល្អឆើត កើតស្នាដៃ
ស្រស់ប៉ប្រៃ ថ្លៃថ្នូរពិត រឹតប្រណីត
ទេពកោសល្យ ដល់កម្រិត ល្អិតល្អន់ជិត
ចូលសណ្ឋិត ចិត្តសន្ធំ ងំឱរា ។

*(លោក ស.កាពុន ៣០-០៥-១៩៨៤ កំណាព្យខ្មែរភាគ ១ ក្រសួងអប់រំ ឆ្នាំ ១៩៨៤)*

## លំហាត់

ចូរអ្នកហាត់សូត្រកំណាព្យខាងក្រោមនេះ ដោយលើកដាក់សំឡេងទៅតាមបទនីមួយៗ :

ក. ខ្ញុំដើរដល់យប់ថ្នល់លោកសំអាត ឃើញពួកជាតិខ្មែរយើងជាគូលី
នឹកអាណិតជាតិខ្មែរក្រដល់ទី ទទួលការគូលីស៊ីឈ្នួលគេ ។
គន់រូបរាងទុព៌លពោះកំប៉េះ សក់ក្រញាញ់ខ្មៅក្រញេះឆ្អេះដូចភេ
ទាំងស្លៀកពាក់សំពត់ក៏ខុសគេ ឱខ្មែរទេម្តេចក៏ខុសនឹងយើងម្ល៉េះ ។

*(ដកស្រង់ចេញពី សុត្តន្តប្រីជាឥន្ទ)*

ខ. ១. 

| | | |
|---|---|---|
| ស្មាក្រាស់ក្រិន | ក្លិនគគ្រុក | មុខគគ្រិច |
| កខ្វក់ក្រៃ | ថៃមិនតិច | ញូចមិនអស់ |
| អត់អ៊ីកក់ | សក់ខ្លះកោរ | ត្រងោលចោះ |
| ទ្រាំចិត្តស្មៀម | ត្រៀមសោះក្រោះ | អស់រឿងស្អាត ។ |

២.

| | | |
|---|---|---|
| ចិត្តជរា | គ្រាទ្រុឌទ្រោម | លោមចិត្តឈឺ |
| ភ្លើងកំសួល | ឆួលបំភ្លឺ | គឺសង្វាត |
| ទ្រាំខាំធ្មេញ | ញេញញក្នុងខួរ | មួរនាំខាត |
| ខឹងនាំខូច | ដូច្នេះឆ្លាត | ប៉ាតមុខទៅ ។ |

៣.

| | | |
|---|---|---|
| បង្គឺធូន់ | ទន់ដងរែក | ស្អែកគ្មានចប់ |
| ធ្ងន់ក្ដីទុក្ខ | គុកគ្មានស្ងប់ | កបសល់នៅ |
| ដង្ហើមស្លាប់ | ស្លាប់មុនស្លាប់ | ស្លាប់ជាផ្លូវ |
| ដើរឆ្លងជ្រោះ | ខ្ពស់សែនជ្រៅ | ត្រូវប្រយ័ត្ន ។ |

៤.

| | | |
|---|---|---|
| ច្បាប់ត្បូងចប | របបក្បត់ | កត់ឱ្យច្បាស់ |
| ត្រូវចងចាំ | ផ្ដាំក្មេងចាស់ | ដាស់កុំស្ងាត់ |
| ខ្មែរអន្តរាយ | ចាយជីវិត | គិតម៉ឺងម៉ាត់ |
| ស្មៀតក្អែកខ្មៅ | ខ្លោមិនបាត់ | ប្រយ័ត្នអើយ ។ |

*(ដកស្រង់ចេញពីសំឡេងសាដៀវ របស់លោកម៉ៅ អាយុទ្ធ)*

# តែងកំណាព្យបទពាក្យ៨ ពាក្យ ៩

អ្នកបានសូត្រកំណាព្យបទពាក្យ៨និងបទពាក្យ៩រួចមកហើយ ។ ពេលនេះ អ្នកត្រូវចេះវិធីតែងកំណាព្យប្រភេទបទខាងលើនេះ ដើម្បីឱ្យអ្នកស្គាល់ពីតម្លៃនៃកំណាព្យខ្មែរកាន់តែច្បាស់ថែមទៀត ។

## ក. បទពាក្យ៨

- **រង្វាស់កាព្យ** : ១វគ្គមាន៤ឃ្លា ១ឃ្លាៗ មាន៨ព្យាង្គ ។
- **ចំណាប់ចួន**



- **ចួនក្នុងវគ្គ**
  - ព្យាង្គទី ៨ នៃឃ្លាទី ១ ចួននឹងព្យាង្គទី ៣ឬទី ៥ នៃឃ្លាទី ២ ។
  - ព្យាង្គទី ៨ នៃឃ្លាទី ២ ចួននឹងព្យាង្គទី ៨ នៃឃ្លាទី ៣ ។
  - ព្យាង្គទី ៨ នៃឃ្លាទី ៣ ចួននឹងព្យាង្គទី ៣ឬទី ៥ នៃឃ្លាទី ៤ ។
- **ចួនឆ្លងវគ្គ**
  - ព្យាង្គទី៨ នៃឃ្លាទី ៤ វគ្គទី ១ ចួននឹងព្យាង្គទី ៨ នៃឃ្លាទី ២ វគ្គទី ២ ។

*ឧទាហរណ៍ :*

គេពាក់វ៉ែនតាមើលឃើញជាក់ច្បាស់ ផ្ទុយស្រឡះឯងងងឹតសូន្យសុង
ពាក់វ៉ែនតាហើយងងឹតជិតស្លុង ភាពងងឹតមាននៅក្នុងងងឹតពេកក្រៃ ។
ងងឹតនេះចំតួងងឹតអវិជ្ជា វេទនាមិនភ្លឺងងងឹតទាំងថ្ងៃ
ងងឹតមិនចេះអក្សរងងឹតចង្រៃ រោគឧត្បាតព្រៃផ្សៃកើតព្រោះងងឹត ។

*(ដកស្រង់ចេញពីកំណាព្យខ្មែរភាគ ១ របស់លោក លី សុមុនីទំព័រទី ៧០ ឆ្នាំ ១៩៨៤)*

## ខ. បទពាក្យ៩

- វង្វាស់កាព្យ : ១វគ្គមាន៤ឃ្លា មួយឃ្លាៗ មាន៩ព្យាង្គ ។
- ចំណាប់ចួន



- ចួនក្នុងវគ្គ
  - ព្យាង្គទី៩ នៃឃ្លាទី ១ ចួននឹងព្យាង្គទី ៣ ឬព្យាង្គទី ៦ នៃឃ្លាទី ២ ។
  - ព្យាង្គទី៩ នៃឃ្លាទី ២ ចួននឹងព្យាង្គទី ៩ នៃឃ្លាទី ៣ ។
  - ព្យាង្គទី៩ នៃឃ្លាទី ៣ ចួននឹងព្យាង្គទី ៣ ឬព្យាង្គទី ៦ នៃឃ្លាទី ៤ ។
- ចួនឆ្លងវគ្គ
  - ព្យាង្គទី៩ នៃឃ្លាទី ៤ វគ្គទី ១ ចួននឹងព្យាង្គទី ៩ នៃឃ្លាទី ២ វគ្គទី ២ ។

*ឧទាហរណ៍ :*

១. ចូរកូនយល់ថាជាតិស្ត្រីមិនថយថោក ព្រោះទ្វីបលោកមានទំនោរជាប់ជំពាក់
លើឥត្ថីភាពជាងអ្វីប្រាកដជាក់ អ្វីក៏ធ្លាក់វិលក្រឡឹងជុំវិញស្ត្រី ។
២. ស្ត្រីភេទខ្សោយតែឫទ្ធិខ្លាំងដណ្តប់ពេក រឿងទុក្ខសោកសុខចម្រើនលើផែនដី
រឿងទុក្ខសោកសុខចម្រើនរបស់ប្តី ក៏គង់ស្ត្រីកាន់ស្តាប់ក្នុងកណ្តាប់ដៃ ។

*(ស្នាព្រះហស្តព្រះអង្គឌួង សម្រង់ចាកពីកំណាព្យ "កើតជាមនុស្សចេះ" លោក គយ សារុន)*

## លំហាត់

ដោយផ្អែកតាមកាព្យមាត្រនៃបទពាក្យ ៨ និងបទពាក្យ ៩ ដែលអ្នកសិក្សារួចមកខាងលើនេះ ចូរអ្នកល្បងតែងកំណាព្យ ៖

ក. បទពាក្យ ៨ចំនួន ៥ល្បះ ដែលនិយាយទាក់ទងនឹងភាពថ្លៃថ្នូររបស់សិស្សក្នុងការសិក្សា ។

ខ. បទពាក្យ ៩ចំនួន ៤ល្បះ ដែលនិយាយពីភាពថ្លៃថ្នូរនៃការគប់មិត្ត ។

## សេចក្ដីណែនាំ

ដើម្បីជុំរុញឱ្យការតាក់តែងកំណាព្យរបស់អ្នក ប្រព្រឹត្តទៅប្រកបដោយខ្លឹមសារនិងត្រូវទៅតាមកាព្យមាត្ររបស់កំណាព្យនីមួយៗ អ្នកគប្បី ៖

១. កំណត់និងជ្រើសរើសប្រធានបទឱ្យបានច្បាស់លាស់ ។

២. កំណត់ក្នុងការជ្រើសរើសបទ ។

៣. រៀបចំខ្លឹមសារឱ្យមានទំនាក់ទំនងគ្នា ពីមួយទៅមួយឱ្យបានត្រឹមត្រូវ ។

៤. ពិនិត្យចំណាប់ចួន (ក្នុងវគ្គនិងឆ្លងវគ្គ) កុំឱ្យឆ្គង ។

៥. ពិនិត្យចៀសវាងកំហុសអក្ខរាវិរុទ្ធនិងសញ្ញាសម្គាល់ផ្សេងៗ ។

# ឧត្តមភាព



មនុស្សគ្រប់ៗគ្នាតែងប្រាថ្នាចង់បានភាពខ្ពង់ខ្ពស់ ប្រសើរថ្លៃថ្លា និងកិត្តិយសខ្ពស់មុខមាត់នៅក្នុងសង្គម ។ កិត្តិយសនិងភាពខ្ពង់ខ្ពស់ប្រសើរថ្លៃថ្លាអាចកើតមានបានឬមិនបានអាស្រ័យលើឧត្តមគតិ សកម្មភាព និងការសេពគប់របស់បុគ្គលម្នាក់ៗ ។ ការតស៊ូ អំណត់ព្យាយាមប្រព្រឹត្តតែអំពើល្អត្រឹមត្រូវតាមច្បាប់ និងវៀរចាកអំពើអន្ធពាលនាំឱ្យយើងទទួលបាននូវឧត្តមភាព ។

ក្នុងមេរៀននេះ អ្នកនឹងសិក្សាស្វែងយល់ពីឧត្តមភាពមួយចំនួន ដែលជាបទពិសោធក្នុងការរៀបចំខ្លួនឱ្យមានឧត្តមប្រយោជន៍ចំពោះខ្លួនឯង គ្រួសារ និងសង្គមជាតិ ។ អ្នកនឹងបានសិក្សាបន្ថែមទៀតទៅលើ រឿងរូបភាព ទំនាស់នៅក្នុងរឿង ការផ្តើមរឿង ដំណើររឿង និងបញ្ចប់រឿង កាលអាកាសរបស់រឿង តម្លៃអប់រំ ផ្ទាក់និងឈ្នាប់ តែងរឿងរូបភាពខ្លី ។

# និទានកថា

អ្នកបានសិក្សារួចហើយពីទេវកថានិងព្រេងកថា ។ នៅពេលនេះ អ្នកនឹងសិក្សាពីនិទានកថា ។

ចូរអ្នកកត់ចំណាំនូវលក្ខណៈខុសប្លែកគ្នារវាងព្រេងកថានិងទេវកថា ។

**ទេវកថា** គឺជារឿងប្រឌិតដែលឆ្លុះបញ្ចាំងពីការយល់ដឹងដំបូងរបស់មនុស្ស ពីប្រភពកំណើតនៃអាទិទេព ទេវៈ អ្នកតា មនុស្ស សត្វ រុក្ខជាតិ បាតុភូតធម្មជាតិ និងប្រភពពិធីបុណ្យគោរពបូជាផ្សេងៗ ។

សម័យបុរាណកាលមនុស្សរស់នៅរណបនឹងធម្មជាតិ ដូចនេះគេបកស្រាយបញ្ហាផ្សេងៗទៅតាមការយល់ឃើញរបស់គេ ។ រឿងទេវកថាមានជាអាទិ៍ រឿងកំណើតរន្ទះ អ្នកតាទឹក អ្នកតាភ្នំ រឿងដើមកំណើតសត្វផ្សោត ... ។

- ដំណើររឿងទាក់ទងនឹងអភិធម្មជាតិដែលមនុស្សធម្មតាមិនអាចដោះស្រាយបាន ។
- តួអង្គជាអមនុស្សតំណាងឱ្យអនុភាពដ៏អស្ចារ្យប្រយុទ្ធប្រឆាំងនឹងធម្មជាតិ ... ។

**ព្រេងកថា** គឺជារឿងប្រឌិតដែលដំណើររឿងទាក់ទងនឹងទំនៀមទម្លាប់ ប្រពៃណី ជំនឿ ប្រវត្តិភូមិស្រុក ទីកន្លែង ឬប្រវត្តិសាស្ត្ររបស់ប្រទេស ។ ព្រេងកថាមានលក្ខណៈសម្គាល់ ៖

- ដំណើររឿងទាក់ទងនឹង ឈ្មោះភូមិស្រុក ទីកន្លែង ប្រវត្តិសាស្ត្ររបស់ប្រទេស ជំនឿ ប្រពៃណី ទំនៀមទម្លាប់របស់ប្រជាជន ហើយរហូតមកដល់បច្ចុប្បន្នក៏នៅតែបញ្ជាក់បាន ។
- តួអង្គជាមនុស្សធម្មតា ឬបុគ្គលអស្ចារ្យនៅក្នុងប្រវត្តិសាស្ត្រ ។

រឿងព្រេងកថាមានជាអាទិ៍ រឿងអ្នកតាឃ្លាំងមឿង រឿងប្រាសាទអង្គរវត្ត រឿងតាដុងយាយជ័យ រឿងទាក់ទងនឹងពិធីលើករាសី ពិធីធ្វើធ្មេញ ទំនៀមទម្លាប់ពូនភ្នំស្រូវ ... ។

តើដំណើររឿងនៅក្នុងនិទានកថា មានលក្ខណៈសម្គាល់ដូចម្ដេច ? តួអង្គជានរណាខ្លះ ?

ចូរអានរឿងនិទានកថាខាងក្រោម ៖

## ១. រឿងបុរសជីកក្អម

មាននិទានមួយថា មានយុវជនម្នាក់រស់នៅក្រលំបាកវេទនាណាស់ ក្រោយពីឪពុកម្ដាយរបស់គេស្លាប់អស់ទៅ ។ មិនយូរប៉ុន្មាន ខ្មោចឪពុកបានមកពន្យល់សប្តិថា កូនឯងក្រលំបាកណាស់ យើងជាឪពុកគ្មានរបស់អ្វីនឹងឱ្យកូនទេ ដូចនេះ ចូរកូនទៅជីកក្អមនៅក្រោមខ្ទមអ្នកតា នាទិសឦសានផ្ទះយើង ដើម្បីយកទៅលក់គ្រាន់ចិញ្ចឹមជីវិតរាល់ថ្ងៃកុំបីខាន ។ បុរសនោះក៏ទៅជីកក្អមតាមការពន្យល់សប្តិរបស់ឪពុក ។ គាត់ជីកបានក្អមយកទៅលក់បានប្រាក់រាល់ថ្ងៃ ។

នៅស្រុកនោះមានមហាសេដ្ឋីម្នាក់មានកូនស្រីច្រើន ។ កូនស្រីបងៗទាំងប៉ុន្មានសេដ្ឋីបានរៀបចំឱ្យមានប្តីអស់ នៅសល់តែកូនស្រីពៅម្នាក់ឈ្មោះនាងពៅ ។ នាងប្រកែកមិនព្រមយកប្តីឡើយ ។

នៅថ្ងៃមួយ វេលាដែលបុរសយកក្តាមទៅលក់ នាងពៅក៏ទិញក្តាមពីបុរសនោះ ហើយប្រាប់ថាបើបានក្តាមត្រូវយកមកលក់ឱ្យខ្លួនតែរាល់ ថ្ងៃកុំលក់ឱ្យអ្នកផ្សេង ។ តាមពិតនាងពៅលួចស្រឡាញ់បុរសនោះ តែយុវជននោះមិនដឹងខ្លួនឡើយ ។ យុវជនបានក្តាមយកមកលក់ឱ្យនាងពៅរាល់ថ្ងៃ ។ នាងពៅកាន់តែស្រឡាញ់បុរសនោះខ្លាំងឡើង ឯបុរសនោះក៏ដឹងខ្លួនដែរ តែមិនហ៊ាននិយាយដូចម្តេចឡើយ ព្រោះជាអ្នកក្រទុរគត ។ រឿងហេតុនេះមិនកំបាំងភ្នែកបងស្រីរបស់នាងពៅឡើយ ។ បងស្រីនាងក៏នាំដំណឹងនេះទៅប្រាប់ឪពុក ព្រមទាំងញុះញង់ឱ្យឪពុកបណ្តេញនាងពៅចេញពីផ្ទះទៀតផង ។ សេដ្ឋីខឹងនឹងនាងពៅខ្លាំងណាស់ក៏បណ្តេញនាងពៅឱ្យទៅរស់នៅជាមួយបុរសកម្សត់ ។ នាងពៅក៏ចុះចេញពីផ្ទះមហាសេដ្ឋីទៅរស់នៅជាមួយបុរសកម្សត់នោះទៅ ។ ប្តីប្រពន្ធទាំងពីរនាក់នេះប្រកបរបរជីកក្តាមលក់ដដែល ហើយបានប្រាក់ជាហូរហែ ។ មិនយូរប៉ុន្មាន គ្រួសារនេះមានប្រាក់កាសច្រើនគ្រាន់បើ ។ នាងជាប្រពន្ធមិនចង់ឱ្យប្តីប្រកបរបរជីកក្តាមលក់ទៀតទេ តែប្តីមិនព្រម ។ ថ្ងៃមួយ នាងប្រពន្ធលបទៅជីកគាស់រំលើងដីកន្លែងជីកក្តាមនោះចោលអស់ ។ ស្អែកឡើងប្តីក៏ទៅជីកក្តាមតាមធម្មតាដូចសព្វដង តែពេលទៅដល់ ក៏ឃើញកន្លែងជីកក្តាមនោះរលើងខ្ទេចខ្ទីអស់ ហើយបានឃើញសម្បកក្តាមស្ងួតមួយធំចម្លែកក៏កាន់យកទៅទុកក្រោមផ្ទះដោយមិនបានប្រាប់ប្រពន្ធឡើយ ។ នៅវេលាយប់ នាងពៅកាន់ប្រាក់របូតពីដៃមួយណែនធ្លាក់ចំសម្បកក្តាមនោះ នាងមិនបានប្រាប់ប្តីទេ ព្រោះនឹកថាចាំព្រឹកសឹមរើសយកមកទុក ។ លុះព្រឹកឡើង នាងទៅរើសស្រាប់តែឃើញប្រាក់ពេញសម្បកក្តាម ។ នាងក៏ប្រាប់ដំណឹងនេះដល់ប្តី ។ រាល់វេលាយប់ នាងពៅតែងទម្លាក់ប្រាក់ឱ្យចំសំបកក្តាម ។ លុះព្រឹកឡើង នាងចុះមករើសឃើញប្រាក់ពេញសម្បកក្តាម ។ បើទម្លាក់ប្រាក់ណែនសម្បកក្តាមពេញដោយប្រាក់ណែន បើទម្លាក់មាសប្រាក់ សម្បកក្តាមពេញដោយមាសប្រាក់ដែរ ។ មិនយូរប៉ុន្មាន គ្រួសារនាងពៅក្លាយជាអ្នកមានស្តុកស្តម្ភ ហើយយកមាសប្រាក់ទៅកប់ទុកច្រើនអន្លើ ។

ថ្ងៃមួយ ប្តីប្រពន្ធមានការនឹករលឹកដល់សេដ្ឋីជាមាតាបិតា ពួកគេក៏នាំគ្នាទៅសួរសុខទុក្ខគាត់ តែនៅពេលទៅដល់ផ្ទះត្រូវបងស្រីៗជេរប្រទេចមើលងាយមើលថោកតិះដៀលថាមនុស្សរហាមឪពុកម្តាយកាត់កាល់ចោលហើយ ហេតុអ្វីក៏មករាប់រកទៀត ។ នាងពៅឆ្លើយតបទៅវិញថាប្រាក់បងៗប៉ុណ្ណឹងខ្ញុំមិនកោតទេ ប្រាក់របស់ខ្ញុំច្រើនរាប់រយដងឯណោះ! ពេលនោះក៏កើតមានការភ្នាល់គ្នាដោយនាងពៅឱ្យបងស្រីៗទៅរាប់ប្រាក់របស់ខ្លួន បើរាប់អស់ក្នុងមួយថ្ងៃ នាងចែកឱ្យបងៗពាក់កណ្តាល តែបើរាប់មិនអស់ទេនាងមិនចែកឱ្យទេ ។ បងស្រីៗទៅរាប់ប្រាក់នាងពៅមិនអស់ឡើយ ។ ដំណឹងនេះដឹង

ដល់សេដ្ឋីជាមាតាបិតា ។ សេដ្ឋីក៏ចាត់អ្នកបម្រើឱ្យទៅពិនិត្យមើល ទើបដឹងថាគ្រួសារនាងពៅមានប្រាក់ច្រើនមែន ហើយក៏អនុញ្ញាតឱ្យគ្រួសារនាងពៅមករស់នៅជាមួយខ្លួនវិញ ។ ចំណែកឯបងស្រីៗក៏គោរពកោតខ្លាចនាងពៅ និងប្ដីនាងនោះខ្លាំងណាស់ ។ ក្រោយមក សេដ្ឋីក៏ធ្វើមរណកាលទៅ បុរសជីកក្ដាមនិងនាងពៅបានក្លាយជាសេដ្ឋីជំនួសបិតាមាតាតរៀងមក ។

*(ដកស្រង់ និងកែសម្រួលពីប្រជុំរឿងព្រេងខ្មែរភាគ ១ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ)*

## ២. រឿងអណ្ដើកនិងស្វា

មាននិទានមួយថា អណ្ដើកនិងស្វាសុំធ្វើជន្លងនឹងគ្នា ប៉ុន្តែគ្មានកូនចៅទៅចងសម្ព័ន្ធអ្វីទេគឺគ្រាន់តែនិយាយនឹងមាត់ប៉ុណ្ណោះ ។ អ្នកទាំងពីររាប់អានគ្នាដូចជន្លងគេដទៃដែរ ។ លុះចំណេរយូរទៅ ជន្លងខាងស្វាមានកូនត្រូវរៀបការ ខាងស្វាហៅភ្ញៀវសព្វគ្រប់ហើយ ក៏នឹកឃើញអណ្ដើកជាជន្លង ។ ប្ដីប្រពន្ធស្វាក៏ឱ្យអ្នកបម្រើទៅអញ្ជើញអណ្ដើកជាជន្លង ។ ថ្ងៃរៀបការ អណ្ដើកក៏ទៅដល់ដូចភ្ញៀវឯទៀតដែរ តែឡើងទៅស៊ីផឹកនឹងគេមិនបានឡើយ ។ ពួកស្វាបានឃើញអណ្ដើក ក៏នាំដំណឹងទៅប្រាប់ស្វាជាជន្លង ។ ជន្លងស្វាក៏ចុះមកអញ្ជើញអណ្ដើកដល់គល់ឈើ ។ ជន្លងស្វាក៏រកមធ្យោបាយឱ្យអណ្ដើកខាំវល្លិរួចយោងអណ្ដើកទៅលើដើមឈើ ប៉ុន្តែមុននឹងយោងទៅ ស្វាបានផ្ដាំថា បើឃើញអ្វីឬអ្នកណាសួរអ្វីសុំកុំមាត់ឱ្យសោះ ប្រយ័ត្នធ្លាក់ស្លាប់ ។ នៅពេលស្វាយោងជិតទៅដល់កន្លែងសុវត្ថិភាពទៅហើយ គាប់ជួនជន្លងស្រីស្វាឃើញអណ្ដើលភ្លាមក៏ស្រែកសួរពីខាងលើ ៖ "ជន្លង ! សុខសប្បាយទេឬ ?" ។ អណ្ដើកភ្លេចបណ្ដាំ ហាមាត់ឆ្លើយទៅនឹងជន្លងស្វា ក៏របូតមាត់ធ្លាក់ខ្លួនដល់ដីបែកស្នូកស្លាប់នាវេលានោះទៅ ។

*(ដកស្រង់ពីប្រជុំរឿងព្រេងខ្មែរភាគ ១ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ)*

ក្រោយពីបានអានឧទាហរណ៍ខាងលើអ្នកបានឃើញ ៖

១. រឿងបុរសជីកក្ដាម : បង្ហាញពីជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជននាសម័យកាលមួយដែល

- មានការប្រកាន់វណ្ណៈរវាងអ្នកមាន(សេដ្ឋី) និងអ្នកក្រ(កសិករ)
- មានជីវភាពរស់នៅ(កសិករ)លំបាកតោកយ៉ាក(ជីកក្ដាមលក់ ...)
- ឱ្យតម្លៃទៅលើទ្រព្យសម្បត្តិជាធំ(សេដ្ឋីទទួលស្គាល់នាងពៅនៅពេលដែលគ្រួសារនាងក្លាយជាអ្នកមាន)
- តួអង្គនៅក្នុងរឿងនេះជាមនុស្ស ។ រឿងនេះមិនបានបង្ហាញឈ្មោះអ្នកនិពន្ធទេ ។

២. រឿងអណ្ដើកនិងស្វា : បង្ហាញពីជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជននាសម័យកាលមួយដែល

- មានសាមគ្គីភាពទូលំទូលាយរវាងប្រជាជននិងប្រជាជន
- ប្រកាន់ខ្ជាប់នូវប្រពៃណីទំនៀមទម្លាប់ប្រពៃណី(អញ្ជើញភ្ញៀវចូលរួមមង្គលការ ...)

- ឱ្យតម្លៃទៅលើពាក្យសំដី (អណ្ដាតជាអាទិ៍កន្លង បានសុខទុក្ខផងពីព្រោះអណ្ដាត ...)
- តួអង្គនៅក្នុងរឿងនេះជាសត្វ ។ រឿងនេះមិនបានបង្ហាញឈ្មោះអ្នកនិពន្ធទេ ។

តាមឧទាហរណ៍ទាំងពីរខាងលើបង្ហាញថា រឿងទាំងពីរនេះសុទ្ធតែបង្ហាញពីជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងសង្គមបរិយាកាសមួយដែលមានការបែងចែកវណ្ណៈ ការលោភលន់ ប្រពៃណីទំនៀមទម្លាប់ល្អ សុជីវធម៌ ការរាប់អាន ការចងមិត្តភាព ... ។ រឿងទាំងពីរនេះមិនមានឈ្មោះអ្នកនិពន្ធទេ ។

*និទានកថា គឺជារឿងប្រឌិតដែលគេនិយាយតគ្នាពីមាត់មួយទៅមាត់មួយ រហូតមិនស្គាល់ឈ្មោះអ្នកនិពន្ធដើម ។ ប្រធានបទដែលលើកឡើងក្នុងនិទានកថាច្រើនផ្ដោតទៅលើបញ្ហាក្នុងសង្គមដូចជា ជីវភាពរស់នៅរបស់ប្រជាជនគ្រប់លំដាប់ថ្នាក់ មុខរបរ ជម្លោះឬទំនាស់ផ្សេងៗ ប្រពៃណីទំនៀមទម្លាប់ សុជីវធម៌ សាមគ្គីភាព ការគ្រប់គ្រង ។ល។ តួអង្គក្នុងនិទានកថាអាចជាមនុស្ស សត្វ រុក្ខជាតិ ជាដើម ។*

## លំហាត់

ក. ចូរអានរឿងបីខាងក្រោម ហើយប្រាប់ពីប្រភេទរឿងនីមួយៗ ។

### ១. រឿង ភ្នំសែនហាន (នៅខេត្តកំពត)

សម័យពីព្រេងនាយក្នុងគ្រាមួយដែលអ្នកស្រុកអំណត់ណាស់ មានមនុស្សច្រើននាក់នាំគ្នាទៅរកស៊ីធ្វើការនៅជើងភ្នំនោះ ដែលជាភ្នំពុំទាន់មានឈ្មោះថាអីនៅឡើយ ហើយពុំទាន់មានដើមឈើច្រើនដែរ ។ គេបាននាំគ្នាដាំដំណាំផ្សេងៗជាច្រើន មានចេក ពោត ត្រាវ ដំឡូង ដូង ស្លាជាដើម ។ ក្នុងគ្រានោះមានតាម្នាក់ឈ្មោះ "សែន" បានធ្វើចម្ការក្នុងទីនោះដែរ ។ ពេលដែលដំណាំកំពុងតែលូតលាស់ល្អល្មមប្រើការបាន ស្រាប់តែមានដំរីស្តមួយចូលមកកាច់ចេក ដកដំណាំនោះស៊ីជារឿយៗ ។ តាសែនគិតថា "បើអញមិនរកមធ្យោបាយដើម្បីកំចាត់ដំរីនេះចេញទេ មុខតែថ្ងៃណាមួយវានឹងស៊ីដំណាំនេះអស់ជាមិនខាន" ទើបគាត់ចាប់លំពែងនិងកាំបិតព្រាដេញចាក់កាប់ដំរីស្តនោះដរាបដល់ស្លាប់ ។ ឯជនឯទៀតៗមិនហ៊ានដេញចាក់កាប់ដំរីនោះសោះឡើយ ។ កាលបើតាសែនសម្លាប់ដំរីនោះបានហើយ អ្នកស្រុកភូមិទាំងអស់នាំគ្នាហៅឈ្មោះគាត់ថា "តាសែនក្លាហានៗ" ។

លុះចំណេរតៗមក ទោះបីតាសែនបានធ្វើមរណកាលទៅហើយក្ដី ក៏មនុស្សអ្នកស្រុកភូមិនាំគ្នាហៅភ្នំដែលជាលំនៅតាសែននោះថា "ភ្នំតាសែនក្លាហាន" ។ លុះយូរៗមកទៀតក៏ហៅខ្លីត្រឹមតែ "ភ្នំសែនហានៗ" រហូតមកដល់សព្វថ្ងៃនេះ ។

*(ដកស្រង់ពីប្រជុំរឿងព្រេងខ្មែរភាគ ៦)*

# ២. រឿងពស់ថ្លាន់ក្អែពិស

កាលពីព្រេងនាយ មានគូស្រករពីរនាក់ប្ដីប្រពន្ធទើបនឹងរៀបការហើយ ក៏នាំគ្នាទៅលេងផ្ទះឪពុកម្ដាយរបស់ខ្លួន ។ ពេលនោះ មានពស់ថ្លាន់មួយលូនចេញពីព្រៃមកលិទ្ធដានជើងប្ដីប្រពន្ធទាំងពីរនាក់នោះធ្វើឱ្យអ្នកទាំងពីរស្លាប់ដោយសារអំណាចពិសពស់ថ្លាន់នៅពេលពួកគេទៅដល់ផ្ទះឪពុកម្ដាយ ។ ឪពុកម្ដាយបងប្អូនញាតិសន្ដានក៏ធ្វើបុណ្យព្រមទាំងយំសោកទ្រហឹងពេញភូមិ ។ សំឡេងនេះធ្វើឱ្យឮដល់ពស់ថ្លាន់ ពស់ថ្លាន់ក៏សួរទៅក្អែក ៖ "បងក្អែក! ខ្ញុំឮសូរមាត់មនុស្សធ្វើអ្វីអ៊ូអរម្ល៉េះក្នុងភូមិនោះ ?" ។ ក្អែកឆ្លើយថា "គេសើចសប្បាយព្រោះគេធ្លាប់ដឹងថាបងថ្លាន់ឯងនេះពូកែណាស់គ្រាន់តែលិទ្ធស្នាមជើងក៏ធ្វើឱ្យគេស្លាប់បានដែរ ប៉ុន្តែឥឡូវនេះលិទ្ធដានជើងរបស់គេទៅបែរជាមិនស្លាប់ទៅវិញទើបសើចសប្បាយរីករាយទាំងអស់គ្នា" ។ ពស់ថ្លាន់ឮដូចនេះមានការអាក់អន់ចិត្តយ៉ាងខ្លាំងហើយនិយាយម្នាក់ឯង "ពិសរបស់អញធ្លាប់តែខ្លាំងណាស់ គ្រាន់តែលិទ្ធដានជើងគេក៏ស្លាប់ដែរ ឥឡូវបែរជាមិនពូកែដូចមុនសោះទុកវាធ្វើអ្វីត្រូវតែក្អែចោលឱ្យអស់ " ។ ពោលហើយថ្លាន់ក៏ក្អែពិសរបស់ខ្លួនចេញមកក្រៅអស់រលីងគ្មានសល់ ។

ពពួកសត្វទាំងឡាយមានពស់ផ្សេងៗ ត្រី ក្អែប ខ្ទួយ ...និងសត្វដទៃទៀតដឹងដំណឹងនេះក៏នាំគ្នាមកដណ្ដើមគ្នាយកពិសពស់ថ្លាន់ សត្វខ្លះបានច្រើនបានតិចទៅតាមសមត្ថភាពរៀងៗខ្លួន ។ ហេតុនេះហើយបានជាមានពស់មួយចំនួនមានពិសខ្លាំងណាស់ដូចជាពស់វែកដំបូក វែកស្រវ៉ែ វែករនាម ពស់ពញ្លាក់ជាដើម កាលណាចឹកមនុស្ស ឬសត្វហើយពិបាកព្យាបាលណាស់ ។

ចាប់តាំងពីពេលនោះមកពស់ថ្លាន់ក៏អស់ឫទ្ធិអំណាច លែងមានពិសដែលអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់មនុស្សសត្វរហូតដល់សព្វថ្ងៃនេះ ។

*(ដកស្រង់ និងកែសម្រួលពីប្រជុំរឿងព្រេងខ្មែរភាគ ៧)*

# ៣. រឿងមនុស្សលោភ

កាលពីព្រេងនាយមានកុមារីម្នាក់អាយុ ១៤ឆ្នាំម្ដាយប្រើឱ្យទៅជីកដំឡូង ។ ក្មេងនោះរៀបចបរួចស្រេចចេញដើរទៅរកដំឡូង ។ ទៅដល់ព្រៃធំមានដំបូកមួយមានរូងជ្រៅ ។ កុមារីនោះទៅជីកដំឡូងនៅជើងដំបូកនោះរបូតផ្លែចបជ្រុះធ្លាក់ទៅក្នុងរូងនោះ ។ នាងនោះមិនដឹងធ្វើដូចម្ដេចក៏ស្រែកប្រកាសថា ៖ "លោកណាជួយយកផ្លែចបឱ្យខ្ញុំបាន ខ្ញុំនឹងសងគុណលោក" ។ ស្រែកតែប៉ុណ្ណោះមានខ្លាចាស់មួយដំបៅក្បាលរុយបែងដង្កូវចុះគគ្រិច ចេញមកពីក្នុងព្រៃប្រាប់ទៅនាងនោះថា ៖ "នាង! តាយកឱ្យបានផ្លែចបនោះ តែបើតាយកបាននាងឯងគ្រាន់តែរកចៃឱ្យបានហើយ តាមិនចាំបាច់យកគុណពីចៅទេ" ។ នាងឮខ្លាថាដូច្នោះ ក៏និយាយថា ៖ "ឱលោកតាអើយ! ឱ្យតែលោកតាជួយយកឱ្យបានចុះ" ។ ខ្លានោះយកផ្លែចបបានពីក្នុងរូងឱ្យទៅនាង ហើយឱ្យនាងនោះរកចៃឱ្យ ។ នាងនោះយកបន្លាមកឆ្កឹះដង្កូវនៅដំបៅក្បាលខ្លានោះ ។ ខ្លានោះចេះតែសួរនាងថា ៖ "នាង! ដំបៅតាស្អុយឬក្រអូប ?" ។ តាមពិតដំបៅនោះស្អុយណាស់ ប៉ុន្តែនាងឆ្លើយថា ៖ "ក្រអូបណាស់លោកតា ។ ខ្លានោះចេះតែសួរ នាងចេះតែថាក្រអូប ។ លុះឆ្កឹះដង្កូវនោះអស់ទៅ ខ្លានោះបាត់ឈឹបាត់រមាស់ ហើយនិយាយប្រាប់នាងនោះថា នាង! នាងយកជាលមួយមកតានឹងដាក់ដំឡូងឱ្យ" ។ នាងនោះយកជាលមួយមកឱ្យខ្លាៗដាក់សុទ្ធតែមាសប្រាក់ពេញជាល ហើយចងមាត់ជាលជាប់ឱ្យទៅនាងនោះ រួចប្រាប់នាងថា ៖ "នាង! នាងយកជាលនេះទៅផ្ទះហៅបងប្អូនមកជុំ បិទទ្វារឱ្យជិតសឹមបើក ។ នាងនោះលាខ្លាដើរទៅដល់ផ្ទះ ហៅបងប្អូនមកជុំរួចក៏បើកជាលនោះ ។ ដល់បើកទៅបានសុទ្ធតែមាសនិងប្រាក់ចែកគ្នា ។ លុះយូរបន្តិចដឹងទៅដល់ស្រីឯទៀត ដែលមានកូនក្រមុំ ស្រីនោះបញ្ឆោះកូនក្រមុំថា ៖ "ឯងមើលកូនគេៗទៅជីកដំឡូងបានមាសប្រាក់យកមកចែកបងប្អូនគេ ឯងឯងវិញទៅជីកដំឡូងបានតែដំឡូងគ្មានបានខ្មោចអ្វីទេ" ។ ថ្ងៃក្រោយស្រីនោះឱ្យកូនទៅជីកដំឡូងដូចនាងនោះ លុះទៅបានជួបប្រទះនឹងខ្លាមុននោះ ក៏ធ្វើជាជ្រុះចបដូចនាងមុនហើយថា ៖ "លោកណាយកចបឱ្យខ្ញុំ ខ្ញុំនឹងសងគុណលោក " ។ ខ្លានោះឮហើយក៏មកយកឱ្យ រួចឱ្យនាងនោះចាប់ដង្កូវឱ្យ ។ ខ្លាសួរដូចមុនថា ៖ "នាង ! ដំបៅតាស្អុយឬក្រអូប?" ។ នាងនោះឆ្លើយថា ៖ "ស្អុយណាស់" ។ ខ្លាឮដូច្នោះ ក៏ប្រាប់ថានាងយកជាលមួយមកតានឹងដាក់មាសប្រាក់ឱ្យ ។ "នាងយកជាលមួយឱ្យខ្លាៗ ចាប់សុទ្ធតែពស់វែកដាក់ពេញជាលហើយឱ្យទៅនាងនោះប្រាប់ថា ៖ "នាងយកទៅផ្ទះហៅបងប្អូនមកជុំ បិទទ្វារឱ្យជិតសឹមបើក" ។ "នាងនោះទៅដល់ផ្ទះហើយប្រាប់ម្ដាយ ម្ដាយអរណាស់ឱ្យបងប្អូនមកជុំបិទទ្វារបើកជាលមើល ពស់វែកចេញមកចឹកមនុស្សទាំងនោះស្លាប់អស់ទៅ ។

*(ដកស្រង់ពីប្រជុំរឿងព្រេងខ្មែរភាគ ២)*

# រឿងអាខ្វាក់អាខ្វិន



## ក. សិក្សាពាក្យគន្លឹះ

- ឃ្លេ (ន) : ឈ្មោះសត្វក្នុងដំណើររឿងរបស់អ្នកនិពន្ធតាមពិតគ្មានសត្វឃ្លេទេ ។
- អានប់កូនក្រោល (ន) : ឈ្មោះសន្មតដែលគេនិយាយសម្ដៅកូនគោដែលល្អជាគោជំរើសរបស់ម្ចាស់ក្នុងចំណោមមេគោដែលខ្លួនចិញ្ចឹម ។
- តក្កមា (កិ) : តក់ស្លុត ស្លន់ញ័ររន្ធត់ ស្មើរភ័ន្តភាំងស្មារតី ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ អ្នកគប្បីអានដោយយកចិត្តទុកដាក់ដើម្បីត្រៀមលក្ខណៈឆ្លើយទៅនឹងសំណួរទាក់ទងនឹង សង្គមបរិយាកាស តួអង្គ វិធីតែងនិពន្ធ (ការផ្ដើមរឿង ដំណើររឿង បញ្ចប់រឿង) និងតម្លៃអប់រំរបស់អត្ថបទ ។

## គ. អត្ថបទ

កាលពីព្រេងនាយមានមនុស្សពីរនាក់ ។ ម្នាក់ខ្វាក់ម្នាក់ខ្វិននៅបម្រើគេទាំងពីរនាក់ ប៉ុន្តែម្ចាស់ដោយខ្លួន ។ អស់អ្នកស្រុកហៅថា អាខ្វាក់អាខ្វិន ។ ទាំងពីរនាក់យកគ្នាជាសម្លាញ់ ។ នាយខ្វាក់ ខ្វាក់ភ្នែកទាំងពីរមើលមិនឃើញ នាយខ្វិន ខ្វិនជើងទាំងពីរដើរមិនរួច បើនឹងទៅណាបានតែកិលនឹងគូទ ។ អាខ្វាក់អាខ្វិនត្រូវថៅហ្វាយនាយប្រើនឿយលំបាកណាស់ ។ សម្លាញ់ទាំងពីរប្រាណគិតពិគ្រោះគ្នា ៖

"យើងនឿយហត់ណាស់ គេប្រើទាំងយប់ទាំងថ្ងៃគ្មានពេលសម្រាកសោះនឹងទ្រាំនៅជាមួយគេនេះទៀតមិនបានទេ មានតែយើងរត់ចេញពីនេះ ។"

អាខ្វាក់សួរអាខ្វិន ៖

- ដូចនេះ យើងគិតធ្វើដូចម្ដេច?

- អញឃើញទូកគេនៅកំពង់នោះមាន យើងត្រូវជិះទូករត់ទើបបាន ។ អាខ្វិនតបអាខ្វាក់ ។

អាខ្វាក់អាខ្វិនគិតគូរព្រមគ្នាហើយ ដល់យប់ក៏បបួលគ្នាចុះទៅកំពង់ ហើយអុំទូកចេញដំណើរទៅ ។ ប៉ុន្តែអាខ្វាក់អាខ្វិនជាមនុស្សមិនចេះអុំទូក ។ តាមពិតទូកចេះតែវិលនៅត្រង់កំពង់នោះឯង ។

ព្រះអាទិត្យចោលពន្លឺពីបូព៌ា ម្ចាស់អាខ្វាក់អាខ្វិនចុះមកដងទឹកឃើញវាទាំងពីរនាក់អង្គុយឈមមុខទល់គ្នាចែវទូក ។ គេក៏ហៅឱ្យអុំទូកចូលមកច្រាំង ។ ម្ចាស់វាដឹងថា អាខ្វាក់អាខ្វិនលួចរត់ ប៉ុន្តែគេគិតថា វានឹងរត់ទៅណា បើសុទ្ធតែខ្វាក់ខ្វិនដូចនេះ ។ គេហៅឱ្យឡើងទៅផ្ទះវិញ ឱ្យធ្វើការដូចធម្មតា ។

នៅយូរបន្តិចទៅ អាខ្វាក់អាខ្វិនបបួលគ្នារត់ទៀត ។ អាខ្វិននិយាយនឹងអាខ្វាក់ ៖

យើងរត់ម្ដងនេះតាមជើងគោកវិញ ដើម្បីកុំឱ្យម្ចាស់យើងតាមទាន់ដូចជើងទឹកទៀត ។

អាខ្វាក់ឆ្លើយ ៖

- ទៅដូចម្ដេចបានជើងគោកនោះបើអញខ្វាក់ឯងខ្វិននិងរត់ទៅមិនរួចទេ ។

- ឯងកុំព្រួយ ឯងឱ្យអញជិះលើឯង ហើយអញបង្ហាញផ្លូវ ។ អាខ្វិនបញ្ជាក់ទៅអាខ្វាក់ ។

អាខ្វាក់អាខ្វិនគិតស្រុះស្រួលគ្នាហើយ ដល់យប់គេដេកស្ងាត់អស់ អាខ្វាក់លើកអាខ្វិនឱ្យជិះលើស្មា ។ អាខ្វិនបង្ហាញអាខ្វាក់ធ្វើដំណើរចេញទៅ ឯម្ចាស់ផ្ទះលុះព្រឹកឡើងមិនឃើញអាខ្វាក់អាខ្វិន ដឹងថាពីរនាក់នេះលួចរត់ទៀតហើយ ប៉ុន្តែគិតថាមនុស្សខ្វាក់ខ្វិនវានឹងរត់ទៅណារួច ក៏មិនទៅតាមរក ។ អាខ្វាក់អាខ្វិនខំដើរអស់ពេលពីរបីថ្ងៃ ទើបបានដល់ស្រុកមួយ ។ ស្រុកនោះមានខ្លាសាហាវណាស់ អ្នកស្រុកហាមប្រាមកូនចៅមិនឱ្យដើរលេងផ្ដេសផ្ដាសព្រលប់យប់ងងឹតកុំឱ្យលេងនៅជីខ្លាចខ្លា ។ អាខ្វាក់អាខ្វិនទៅដល់ស្រុកនោះជួនពេលព្រលប់ធំ ។ អាខ្វាក់និយាយទៅកាន់អាខ្វិន ៖

- យើងមកដល់ស្រុកគេហើយ ដើម្បីមានអ្វីចិញ្ចឹមជីវិតនឹងគេ យើងគិតធ្វើស្រែ ។ តើយើងបាន នង្គ័ល រនាស់ គោក្របីឯណានឹងប្រកបការងារស្រែនឹងគេ ។
- ឯងកុំខ្វល់ មាមីងយើងសម្បូរគោណាស់ឱ្យតែយើងមានកំលាំងធ្វើ ។ យើងទៅធ្វើស្រែគេ គេ មកជួយធ្វើស្រែយើងវិញ ។ អាខ្វិនតបទៅអាខ្វាក់ ។

អាខ្វាក់អាខ្វិនដើរទៅទាក់ទងផ្ទះអ្នកស្រុកនៅ ។ គេស្រែកហៅវាទាំងពីរនាក់ ឱ្យឡើងលើផ្ទះជាប្រញាប់ខ្លាចខ្លាខាំ ។ អាខ្វាក់និយាយដោយសំឡេងខ្លាំងៗ ៖

ឃ្លេមិនខ្លាច ទៅខ្លាចអីខ្លា ។

ពេលនោះ សត្វខ្លាដែលសម្ងំនៅជើងរបងឮសម្ដីអាខ្វាក់ក៏គិត ៖

ពីដើមគេខ្លាចតែអញ ឥឡូវគេបែរជាទៅខ្លាចឃ្លេទៅវិញ ។ ឃ្លេនោះយ៉ាងម៉េច អញមិនដែលឃើញសោះ ។ អញចាំលបមើលឱ្យឃើញសិន ។

អាខ្វិនប្រគោងជណ្ដើរឡើងទៅលើផ្ទះ ។ អាខ្វាក់ដើរចេញមកក្រៅរបងដើម្បីបន្ទោបង់ ។ វាស្ទាបៗទៅប៉ះលើខ្លា វាស្មានថាគោ ។ វាស្ទាបរកស្នែងមិនប៉ះសោះក៏លាន់មាត់ ៖

អានេះធាត់ណាស់ អញទុកជាអានប់កូនក្រោល ។

អាខ្វិនបាត់អាខ្វាក់យូរពេក លាអ្នកផ្ទះចុះមកដឹកិលតាមរកអាខ្វាក់ ។ ឃើញអាខ្វាក់កំពុងស្ទាបខ្លាក៏ស្រែក ៖

អាខ្វាក់ខ្លា! ខ្លាធំណាស់!

អាខ្វាក់គំហកទៅអាខ្វិន ៖

ឃ្លេមិនខ្លាច ទៅខ្លាចអីខ្លា ខ្វះគោទឹមផងចាប់យកទៅទឹម ហុចកន្ទុះឱ្យអញ ។

អាខ្វិនបោះកន្ទុះឱ្យអាខ្វាក់ ។ វាតាំងយកចុងខ្សែចាក់ច្រមុះខ្លា ។ ខ្លាកាលបានត្រូវអាខ្វាក់ ហ៊ានស្ទាបអង្អែលវាយ៉ាងស្និទ្ធ ក៏នឹកស្មានថាអាខ្វាក់ជាសត្វឃ្លេ ។ ខ្លាភិតភ័យតក្កមា ។ លុះត្រូវអាខ្វាក់ចាក់ច្រមុះទៀត វាឈឺយ៉ាងខ្លាំងក៏តាំងច្រលោតរត់យ៉ាងលឿនបញ្ចេញសម្រែករំពងភូមិ ។ អាខ្វាក់ស្រែក ៖

ដេញ ! ដេញ ! អាខ្វិនជួយព័ទ្ធអញ អញចាប់ឱ្យបាន ។

អាខ្វិនអង្គុយញ័រទទ្រើកខ្លាចខ្លា ។ អាខ្វាក់ចេះតែស្រែក ៖

ចាប់ ! ចាប់ឱ្យបាន ។

ខ្លារត់ចូលព្រៃបាត់ ។ អាខ្វាក់អាខ្វិននាំគ្នាចេញពីភូមិនោះ ។

ទៅដល់ឆ្ងាយបន្តិច បានឃើញខ្ទមស្រែគេមួយ មានខ្សែពួរ និងអណ្ដើកមួយ។ អាខ្វិនឃើញហើយនិយាយប្រាប់អាខ្វាក់ ៖

- វ៉ឺយអាខ្វាក់ មានខ្ទមគេមានខ្សែពួរ និងអណ្ដើកមួយផង ។

- យកទាំងអស់មក ។ អាខ្វាក់ប្រាប់ទៅអាខ្វិន ។

អាខ្វិនប្រកែក ៖

យកធ្វើអីធួន់ឥតអំពើ ។

អាខ្វាក់តបទៅវិញ ៖

- ធួន់អីឯង ធួន់តែអញទេ ចេះតែយកទៅ ។

អាខ្វិនកាន់យករបស់រួចហើយ ក៏ឡើងជិះលើអាខ្វាក់ ។ អាខ្វាក់ជាមនុស្សមានកម្លាំងខ្លាំងអាចទ្រាំទ្របានទាំងអស់ ។

វាទាំងពីរនាក់ ដើរលេចវាលចូលព្រៃ លេចព្រៃចូលវាល ចេះតែត្រេចរង្គាត់ទៅឆ្ងាយណាស់ ក៏បានដល់សាលាមួយ ។ សាលានេះ ជាកន្លែងដែលយក្សតែងតែមកស៊ីមនុស្សរាល់ៗថ្ងៃ ។ ថ្ងៃដែលអាខ្វាក់អាខ្វិនទៅដល់ ជួនពេលដែលស្ដេចឱ្យបុត្រីតែមួយឈ្មោះ នាងពៅ ទៅយក្សស៊ី បើពុំនោះទេវានឹងស៊ីមនុស្សក្នុងនគរទាំងនាម៉ឺន ទាំងស្ដេច ។ នាងពៅអាណិតរាស្ត្រ នាម៉ឺន និងស្ដេចក៏សុខចិត្តឱ្យយក្សស៊ី ។

អាខ្វាក់អាខ្វិននាំគ្នាចូលសំណាក់ក្នុងសាលានោះ ។ នាងពៅបានប្រាប់ទៅជនពិការទាំងពីរឱ្យចេញទៅវិញជាប្រញាប់ ។ បើខំតែនៅ មុខជាយក្សស៊ីទាំងអស់គ្នាមិនខាន ។ ឯអាខ្វាក់ហេតុតែនិស្ស័យជាមនុស្សមិនចេះខ្លាច និងមានកម្លាំងខ្លាំងក្លា កាលបើឮនាងពៅប្រាប់ដូចនោះក៏ឆ្លើយ ៖

- ខ្លាចអីយក្សនោះ បើវាមកយើងមិនចេះកាប់វាឱ្យស្លាប់ ។ នាងនៅឱ្យស្ងៀម បើមានដាវមុតល្អយកមកឱ្យយើងមួយមក ។

នាងពៅតបទៅអាខ្វាក់វិញ ៖

- បើអ្នកសម្លាប់យក្សនេះបាន អ្នកអាចយករបស់ទ្រព្យទាំងប៉ុន្មានដែលគេយកមកឱ្យយក្ស ។ សូមអ្នកយកទាំងអស់ចុះ ។

- នាងកុំភ័យ មានបាយចំណីចំណុកយកមកឱ្យយើងស៊ីមានកម្លាំងនឹងកាប់យក្សនោះឱ្យងាប់ ។

អាខ្វិនវិញភ័យស្ទើរស្លាប់ រកកន្លែងពួនគ្មាន ។ អាខ្វាក់ស៊ីបាយឆ្អែតហើយបិទទ្វារសាលាទាំងអស់ ។ ដល់ព្រលប់ងងឹតបន្តិច យក្សហោះ ឮសន្ធឹកដូចព្យុះ លាន់ខ្ទរទាំងដី ។ អាខ្វិនភ័យណាស់ស្ទើរនឹងលេចអាចម៍លេចនោម ។ ឯនាងពៅសន្លប់នៅក្នុងស្គរ ។

អាខ្វាក់ឮសន្ធឹកយក្សមកមិនខ្លាចសោះ អង្គុយចាំនៅប្របមាត់ទ្វារ ។ យក្សមកដល់ឃើញទ្វារសាលាបិទ ក៏ស្រែកសន្ធាប់ឮដូចផ្គរ ៖

- នរណាបិទទ្វារសាលាអញ?

អាខ្វាក់ស្រែកពីខាងក្នុងមក ដោយគ្មានញញើតបន្តិចសោះ ៖

- អញបិទទ្វារសាលា ឯងមកមានការអី ?

យក្សឆ្លើយ ៖

- ឯងមកពីណាចិត្តធំម្ល៉េះ មាឌឯងប៉ុនណាមកហ៊ានប្រឆាំងនឹងអញ ។

អាខ្វាក់បោះសត្វអណ្ដើកទៅ ហើយប្រាប់យក្ស ៖

- នេះជាចៃរបស់អញ ។

យក្សឃើញ ហើយគិតស្មាន ៖

- ចៃវាប៉ុននោះ ម្ល៉េះសមខ្លួនវាធំមែន ។

- ហ៎ នេះរោមជើងអញ ។ អាខ្វាក់បោះខ្សែពួរដែលគេប្រើសម្រាប់ទាក់ក្របីទៅឱ្យយក្ស ។

យក្សមើលឃើញ ភ្លាត់មាត់ឧទាន ៖

- រោមជើងប៉ុននោះ ធំជាងរោមជើងអញឆ្ងាយណាស់ ។

យក្សបុកពោះភឹប ប្រានទ្វារអើតក្បាលមើលក្នុងសាលា ។ អាខ្វាក់ឮស្នូរទ្វារ វាវាត់មួយដាវយ៉ាងរហ័ស ដាច់កយក្សធ្លាក់ពីលើស្មា ស្លាប់នៅទីនោះ ។ ក្រោយពីសម្លាប់យក្សហើយ អាខ្វាក់អាខ្វិនក៏នាំគ្នាចេញដំណើរទៅដោយយកទ្រព្យរបស់នៅក្នុងសាលានោះទៅជាមួយផង ។ លុះភ្លឺច្បាស់ឡើងនាងពៅភ្ញាក់ពីសន្លប់នាងត្រេកអរណាស់ ។ ឯពួកមនុស្សម្នាមកមើលឃើញនាងពៅនៅរស់ក៏ក្រាបទូលស្ដេចតាមដំណើរ ។ ស្ដេចបានចាត់មន្ត្រីឱ្យរកអាខ្វាក់អាខ្វិនដើម្បីរៀបអភិសេកឱ្យសោយរាជ្យ ។

ពេលដែលអាខ្វាក់អាខ្វិនប្រមូលបានរបស់ទាំងនោះហើយក៏ចែកគ្នា ស្រាប់តែផ្លែក្រសាំងមួយធ្លាក់ត្រូវខ្នងវា ។ អាខ្វិននឹកស្មានតែអាខ្វាក់ដាល់វា វាក៏ដាក់ភ្នែកអាខ្វាក់ប៉ាច់ ។ មួយរំពេចនោះភ្នែកអាខ្វាក់ម្ខាងភ្លឺឡើង ។ អាខ្វាក់ធាក់អាខ្វិនត្រូវជើងម្ខាង ។ ជើងម្ខាងរបស់អាខ្វិនលើកបត់បាន ។ អាខ្វិនដាល់អាខ្វាក់ភ្លឺភ្នែកម្ខាងទៀត ។ ភ្នែកអាខ្វាក់ទាំងសងខាងភ្លឺស្រលះ ។ អាខ្វាក់ធាក់អាខ្វិនត្រូវជើងម្ខាង

ទៀត ។ ជើងអាខ្វិនទាំងពីរទៅជាមាំដូចជើងគេឯង ។ បន្ទាប់មក ពួកគេក៏ចែកទ្រព្យរបស់នោះដោយត្រឹមត្រូវ ។ ពួកគេក៏បានជួបនឹងមន្ត្រីស្ដេច ហើយក៏បានចូលទៅគាល់ស្ដេចតាមព្រះរាជបញ្ជា ។ ស្ដេចសាកសួរដឹងសព្វហេតុការណ៍ ក៏បានឱ្យអាខ្វាក់សោយរាជ្យនិងលើកនាងពៅឱ្យជាជាយា ។ ឯអាខ្វិនបានងារជាឧបរាជ ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅប្រជុំរឿងព្រេងខ្មែរភាគ ២)*

## សំណួរ

១. ហេតុអ្វីបានជានាយខ្វាក់នាយខ្វិនបបួលគ្នារត់ ?

២. តើការធ្វើដំណើររបស់នាយខ្វាក់និងនាយខ្វិនជួបហេតុការណ៍អ្វីខ្លះ ?

៣. តើភាពជោគជ័យរបស់នាយខ្វាក់នាយខ្វិនកើតឡើងដោយកត្តាអ្វីខ្លះ ?

៤. ហេតុអ្វីបានជាស្ដេច សម្រេចព្រះទ័យឱ្យនាយខ្វាក់សោយរាជ្យនិងលើកនាងពៅឱ្យទៅជាជាយា ?

៥. ចូរបង្ហាញពីទំហៀបន័យ ឬឧបមានដែលអ្នកនិពន្ធប្រើក្នុងអត្ថបទនេះ ។

៦. រឿងនេះតើអ្នកនិពន្ធផ្ដើមរឿង បង្ហាញដំណើររឿងនិងបញ្ចប់រឿងដូចម្ដេចខ្លះ ?

៧. តើរឿងនេះជារឿងប្រឌិតប្រភេទណា ?

៨. តើរឿងនេះមានតម្លៃអប់រំដូចម្ដេច ?

# ភ្នំប្រុស ភ្នំស្រី

កាលពីព្រេងនាយ មានស្តេចស្រីមួយអង្គព្រះនាម "ស្រីអយុធ្យា" សោយរាជ្យនៅនគរខ្មែរ ។ ដោយព្រះនាងជាស្តេចសោយរាជ្យ គ្មានបុរសណាមួយហ៊ានដណ្តឹងយកជាភរិយាឡើយ ម្ល៉ោះហើយ ព្រះនាងរកដណ្តឹងបុរសដ៏មានរូបជាទីគាប់ព្រះទ័យមកធ្វើជាស្វាមី ។ ការធ្វើដូចនោះ ស្រីៗដែលនៅក្រោមព្រះរាជាវាទព្រះនាងក៏ដណ្តឹងប្រុសៗធ្វើជាប្តីតាមដែរ ។ ក្នុងរជ្ជកាលនោះគួរឱ្យវេទនាសម្រាប់ស្ត្រីខ្លះ ដែលមានរូបអន់ៗទៅរកដណ្តឹងប្រុសៗ គេនាំគ្នាប្រកែកមិនយក ។ គេរើសតែស្រីស្អាតៗ ទើបយកធ្វើជាភរិយា ។ ការធ្វើដូចនេះ អស់មួយរាជ្យស្តេចស្រីនោះ ។




លុះមកដល់រាជ្យស្តេចក្រោយៗទៀត
ឥឡូវនេះ ដូចជាមិនសមសោះខ្លួនយើងជាស្រី ហើយដើរដណ្តឹងប្រុសៗធ្វើជាប្តី!
យើងមានការលំបាកណាស់ពេលទៅដណ្តឹងគេម្តងៗ!


យើងគួរតែរកវិធី ដើម្បីឱ្យប្រុសមកដណ្តឹងយើងវិញ
យើងគិតទៅជួបគ្នា ដើម្បីរកវិធីដោះស្រាយ


បើដូចនេះ យើងនឹងនាំគ្នាលើកដីចាក់ពូនជាភ្នំ ភ្នាល់ជាមួយនឹងពួកប្រុសៗ បើប្រុសៗចាញ់ យើងត្រូវឱ្យប្រុសៗដណ្ដឹងយើងជាស្រីៗវិញ
មែនហើយ ...! វិធីនេះល្អណាស់ ...!
លុះគិតដូចនោះហើយពួកស្រីៗ ក៏នាំគ្នាទៅបបួលប្រុសៗភ្នាល់


ឥឡូវនេះពួកស្រីៗភ្នាល់លើកដីពូនភ្នំ! បើពួកយើងចាញ់ត្រូវដណ្ដឹងស្រីៗធ្វើជាប្រពន្ធវិញម្ដង
ភ្នាល់ក៏ភ្នាល់! យើងមិនខ្លាចទេ

ពួកគេបានចាត់មេកំណែន កេណ្ឌមនុស្សឱ្យបានច្រើន។ ខាងស្រីមានមេកំណែនខាងស្រីដើរកេណ្ឌ។ ខាងប្រុសមានមេកំណែនខាងប្រុសដើរកេណ្ឌ។




លុះកេណ្ឌបានគ្នាគ្រប់ចំនួនទាំងខាងប្រុស ខាងស្រីនិងយល់ព្រមលើលក្ខខណ្ឌទាំងអស់គ្នារួចហើយ ពួកគេក៏នាំគ្នាជញ្ជូនដី រែកទូលតាមថាមពលរៀងៗខ្លួនទៅ។




ពេលនោះ ជាពេលរាត្រី ពួកស្រីៗមានប្រាជ្ញា ជញ្ជូនដីអស់វេលា ៣-៤ ម៉ោង ក៏នាំគ្នាបង្ហូតគោមតូចមួយយ៉ាងខ្ពស់ នៅជ្រុងឦសានភ្នំ។
ផ្កាយព្រឹករះហើយ! ពួកយើងនាំគ្នាសម្រាក!
បានសម្រាកហើយយើង!
ពួកប្រុសៗក្រឡេកមើលទៅលើ ឃើញគោមដែលស្រីៗបង្ហូតនឹងឫស្សីមួយដើមនោះ ស្មានថាផ្កាយព្រឹករះ ក៏បបួលគ្នាឈប់ធ្វើការ នាំគ្នានិទ្រាលក់អស់ទៅ។

ពួកស្រីៗក៏នាំគ្នាជញ្ជូនដីដរាបដល់ផ្កាយព្រឹកមែនទែនរះទើបឈប់ ។ ដល់មាន់រងាវកឺត ប្រុសៗ ភ្ញាក់ឡើង ឃើញផ្កាយព្រឹករះ ក៏លាន់មាត់ មែនហើយ! យើងចាញ់កលស្រីៗហើយ ...!




តាំងពីពេលនោះមក ប្រុសៗក៏ដណ្ដឹងស្រីៗធ្វើជាភរិយាដរាបមកដល់សព្វថ្ងៃនេះ ។

## សំណួរ

១. ហេតុអ្វីបានជាសម័យនោះស្រីៗទៅដណ្ដឹងប្រុសៗធ្វើជាប្ដី ?

២. តើគេប្រើវិធីបែបណាដើម្បីផ្លាស់ប្ដូរប្រពៃណីស្រីដណ្ដឹងប្រុសនេះ ?

៣. តាមដំណើររឿងតើអ្នកឃើញគេចែករូបភាពជាប៉ុន្មានប្លង់ ?

៤. តើរូបភាពតាមប្លង់នីមួយៗមានបង្ហាញអ្វីខ្លះ ?

៥. ចូរបង្ហាញកាលអាកាសរបស់រឿងនេះ ។

៦. ចូរបង្ហាញពីទំនាស់ក្នុងខ្លួននិងក្រៅខ្លួនរបស់តួអង្គនៅក្នុងរឿងនេះ ។

៧. ចូរបង្ហាញពីឧត្ដមភាពរបស់ក្រុមស្រីៗតាមរយៈដំណើររឿងនេះ ។



# រឿងខ្សែកដែលបាត់ទៅ



## ក. សិក្សាពាក្យគន្លឹះ

- ស្ដុកស្ដម្ភ (គុ) : ច្រើនឥតគណនា ហូរហៀរ ច្រើនលើសលប់ ។
- គតិបណ្ឌិត (ន) : គំនិតវាងវៃប្រកបដោយប្រាជ្ញាញាណ គំនិតខ្ពង់ខ្ពស់ ... ។
- សុចរិត (ន) : សេចក្ដីស្មោះត្រង់ សេចក្ដីទៀងត្រង់ ភាពត្រឹមត្រូវ ... ។
- ទុច្ចរិត (ន) : ការប្រព្រឹត្តអាក្រក់ទាំងកាយវាចាចិត្ត អំពើអាក្រក់ ។
- ចៅក្រម (ន) : អ្នកកាត់ក្ដី ។
- រង្កៀសចិត្ត (ន) : ការអាក់អន់ចិត្ត ការទាស់ចិត្ត ... ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលដែលអ្នកអានអត្ថបទ អ្នកគប្បីអានដោយយកចិត្តទុកដាក់ដើម្បីត្រៀមលក្ខណៈឆ្លើយនឹងសំណួរទាក់ទងនឹងកាលអាកាស ទំនាស់ និងតម្លៃអប់រំរបស់អត្ថបទ ។

## គ. អត្ថបទ

កាលពីដើម មានសេដ្ឋីម្នាក់ជាកំពូលអ្នកមានស្ដុកស្ដម្ភនៅក្នុងស្រុកមួយ ។ ថ្ងៃមួយ សេដ្ឋីនោះបានចេញដំណើរទៅក្រៅ រួចក៏ជ្រុះបាត់ថង់មួយ ។ ក្នុងថង់នោះមានកាសមាសមួយពាន់កាស និងខ្សែកដ៏មានតម្លៃមួយខ្សែធ្វើពីមាសសុទ្ធលំអដោយត្បូងមរកតធំៗប្រាំមួយគ្រាប់ ។ គាត់មានការសោកស្ដាយយ៉ាងខ្លាំង ហើយខិតខំដើររកស្វះស្វែងគ្រប់ទីកន្លែង ប៉ុន្តែនៅតែរកពុំឃើញ ។ សេដ្ឋីបានឱ្យគេប្រកាសប្រាប់ប្រជារាស្ត្រក្នុងស្រុកទាំងមូលឱ្យដឹងថា គាត់នឹងជូនរង្វាន់មួយរយកាសមាសដល់នរណាដែលរើសបានថង់នោះ ហើយយកមកប្រគល់ឱ្យម្ចាស់គេវិញ ។

ជាភ័ព្វព្រេងសំណាង មានបុរសសុចរិតកម្សត់ម្នាក់រើសបាន ។ គេជាអ្នកលក់នំបុ័ង ក្រតោកយ៉ាកណាស់ រកបានព្រឹកខ្វះល្ងាច តែគេជាមនុស្សតស៊ូអំណត់ព្យាយាម មានភក្តីភាព និងស្មោះត្រង់ជាទីបំផុត ។ ពេលរើសបានភ្លាម គេបានពិនិត្យមើលហើយឃើញមានទ្រព្យរបស់មានតម្លៃជាច្រើន ។ ដូចនេះ គេមានចិត្តអាណិតអាសូរដល់ម្ចាស់របស់នោះខ្លាំងណាស់ ព្រោះគេនឹកឃើញថា សូម្បីតែខ្លួនឯងដែលបាត់របស់អ្វីមួយតែបន្តិចបន្តួចប៉ុណ្ណោះ គង់មានការសោកស្ដាយទៅហើយ ចុះទំរាំរបស់ដ៏សន្ធឹកយ៉ាងនេះ មិនដឹងជាម្ចាស់គេស្ដាយប៉ុនណាទៅ ។ គិតរួចគេបម្រុងនឹងយកថង់នោះទៅប្រគល់ជូនសេដ្ឋីនោះវិញ តែប្រពន្ធគេបានឃាត់ ៖

- កុំយកទៅឱ្យគេវិញអីបង! ទ្រព្យសម្បត្តិនេះច្រើនណាស់ វាអាចល្មមជួយឱ្យយើងក្លាយជាអ្នកមាននឹងគេម្ដងហើយ!

បុរសកម្សត់ក៏តបទៅប្រពន្ធវិញ ៖

- សម្បត្តិនេះមិនមែនជារបស់យើង មិនដឹងជាម្ចាស់គេមានការសោកស្ដាយប៉ុនណាទេ ដូចនេះកុំបន្លំយករបស់គេ មិនល្អទេ ។ រង្វាន់មួយរយកាសមាសគ្រប់គ្រាន់ណាស់ហើយសម្រាប់យើង ព្រោះយើងរកបានដោយសុចរិត ។ ដោយមិនអាចឃាត់ប្ដីបាន ប្រពន្ធក៏យល់ស្របតាមប្ដី ។

បុរសកាន់ថង់មាសទៅផ្ទះសេដ្ឋី រួចប្រគល់ទៅឱ្យសេដ្ឋីវិញ ។ សេដ្ឋីស្គាល់ច្បាស់ជាថង់របស់ខ្លួនហើយ មានចិត្តត្រេកអរណាស់ គាត់បើកថង់មើលរាប់កាសមាស មើលខ្សែក ឃើញថារបស់ទាំងនេះនៅគ្រប់ចំនួនល្អត្រឹមត្រូវ ប៉ុន្តែដោយទឹកចិត្តលោភលន់និងចង់ឱ្យបុរសកំសត់នោះរករបស់មកសងគាត់ថែមពីលើរបស់ដែលបាត់នេះទៀត គាត់ក៏ធ្វើជាភ្ញាក់លាន់មាត់ ៖

- យី! ម៉េចអីចឹង! នៅក្នុងថង់ខ្ញុំដែលជ្រុះបាត់នេះ មានខ្សែកពីរខ្សែដូចគ្នា ឥលូវហេតុអ្វីឃើញតែមួយខ្សែយ៉ាងនេះ ?

ឮដូច្នេះបុរសកំសត់ក៏តបទៅវិញ ៖

- លោកពូ! ម៉េចក៏លោកពូមានប្រសាសន៍អីចឹង ? ខ្សែកមានតែមួយខ្សែទេ ។ ខ្ញុំឥតបានប៉ះពាល់យកអ្វីទាល់តែសោះ ។ ខ្ញុំរើសបានថង់ភ្លាម ខ្ញុំកាន់មកទីនេះភ្លាម ។
- ឯងកុហក! ឯងលួចយកខ្សែកបាត់ហើយនៅប្រកែកទៀត!

ជម្លោះប្រកែកកាន់តែខ្លាំងក្លាឡើង ។ ពួកអ្នកមានៗជាច្រើនបានចូលមកធ្វើជាសាក្សីក្នុងរឿងនេះ ។ គេនាំគ្នាកាន់ជើងសេដ្ឋី ហើយចោទបុរសកម្សត់ថាជាចោរ ។ គេនាំគ្នាយករឿងនេះទៅប្ដឹងចៅក្រម ។ ចៅក្រមជាមនុស្សម្នាក់ប្រកបដោយគតិបណ្ឌិត និងធ្លាប់មានកេរ្តិ៍ឈ្មោះល្បីល្បាញថាសុចរិតយុត្តិធម៌ និងប៉ិនប្រសប់វែកមុខជនទុច្ចរិត ។

ចៅក្រមសួរទៅបុរសកម្សត់ ៖

- មើលក្មួយ! ក្មួយនិយាយតាមត្រង់មកមើល៍ តើក្មួយយករបស់គេមែនឬ ?
- លោកអើ! បើក្មួយចង់បានរបស់គេ ចាំបាច់ក្មួយខំកាន់ថង់នោះ យកមកឱ្យគេវិញ! ក្មួយទុកថង់មាសនេះនៅផ្ទះក្មួយតែម្តងជាការស្រេចទៅហើយ វាគ្មានរឿងវែងឆ្ងាយអីផង ។

ចៅក្រមសួរទៅសេដ្ឋី ៖

- ថង់លោកពិតជាមានខ្សែកពីរខ្សែមែនឬ ?
- បាទ! ពិតជាមានពីរខ្សែមែន ខ្ញុំសូមស្បថជូន ។

ចៅក្រមងាកទៅអង្គប្រជុំទាំងមូលរួចនិយាយ ៖

សេដ្ឋីជាអ្នកមានស្តុកស្តម្ភ ពោរពេញដោយកិត្តិយសមិនលោភលន់ ទាមទារ ចង់បានអ្វី ដែលមិនមែនជារបស់ខ្លួនទេ ។ ឯក្មួយខាងនេះជាមនុស្សសុចរិត ស្មោះត្រង់គួរឱ្យគោរព ។ សេដ្ឋីទាមទារថង់មាសដែលមានខ្សែកពីរខ្សែ ។ ក្មួយប្រុសខាងនេះរើសបានថង់មាសដែលមានខ្សែកតែមួយខ្សែ ។ ដូចនេះថង់នេះមិនមែនជារបស់សេដ្ឋីឡើយ ។ សូមលោកទៅប្រកាសដំណឹងម្តងទៀតចុះ ក្រែងអាចរកថង់លោកឃើញ ។ ខ្ញុំនឹងតម្កល់ថង់នេះនៅទីនេះ ទំរាំរកម្ចាស់ពិតប្រាកដឃើញ ឬទំរាំដល់ហួសកំណត់តំកល់ ។ ចំណែកក្មួយដែលរើសបានថង់មាសនិងខ្សែកដ៏មានតម្លៃនេះ ខ្ញុំសូមជូនរង្វាន់ពីររយកាសមាស ជារង្វាន់ចំពោះទឹកចិត្តស្មោះត្រង់និងសុចរិតគួរឱ្យសរសើររបស់ក្មួយ ។ ខ្ញុំជឿថាម្ចាស់ថង់មាសពិតជាមិនរង្កៀសចិត្តអ្វីទេចំពោះរង្វាន់ដ៏ស្តួចស្តើងនេះ ។ សូមក្មួយអញ្ជើញយកចុះ! បុរសកម្សត់ទទួលយកពីររយកាសមាស ដោយក្តីរីករាយហួសប្រមាណ ។ គេថ្លែងអំណរគុណចំពោះចៅក្រម រួចត្រឡប់ទៅផ្ទះវិញ ។ មួយឆ្នាំកន្លងទៅ កំណត់ពេលតម្កល់ហួសទៅហើយ ។ គ្មាននរណាមកបង្ហាញខ្លួនថា ជាម្ចាស់ថង់មាសនេះសោះ ។ គេបានចំណាយធនធានទាំងនេះ ឧបត្ថម្ភជនអភ័ព្វទាំងឡាយក្នុងទីក្រុង ។ សេដ្ឋីកំហូចស្តាយទ្រព្យរបស់ខ្លួន ដេកមិនលក់បក់មិនល្ហើយ ... តែដឹងធ្វើម៉េច! ឥឡូវចំណេះវាជិះកឯងទៅហើយ ។

*(ដកស្រង់ពីសៀវភៅរឿងនិទានក្រសួងអប់រំ ១៩៩៤)*

## សំណួរ

១. ហេតុអ្វីបានជាបុរសកម្សត់យកថង់មាសប្រគល់ឱ្យសេដ្ឋីវិញ ?

២. តើសេដ្ឋីសុខចិត្តទទួលយកថង់ប្រាក់ដោយសុទ្ធចិត្តដែរឬទេ ? ព្រោះអ្វី ?

៣. តើចៅក្រមកាត់ក្តីយ៉ាងដូចម្តេច ? ព្រោះអ្វី ?

៤. តើទង្វើរបស់តួអង្គបុរសកម្សត់បានបង្ហាញអំពីឧត្តមភាពអ្វីខ្លះ ?

៥. ចូរបង្ហាញកាលអាកាសរបស់រឿងនេះ ។

៦. ចូរបង្ហាញទំនាស់នៅក្នុងរឿងនេះ ។

៧. ចូរបង្ហាញតម្លៃអប់រំរបស់រឿង ។



# សង្ខេបរឿង

ការសង្ខេបគឺការនិយាយឬសរសេរបំព្រួញខ្លឹមសារឱ្យបានខ្លីដោយប្រើសម្ដីផ្ទាល់ខ្លួន ហើយលើកយកតែចំណុចសំខាន់ៗ គំនិតសំខាន់ៗ ឬព្រឹត្តិការណ៍សំខាន់ៗមកបង្ហាញ ។

គេអាចសង្ខេបគំនិតសំខាន់ៗចេញពីរូបភាព រឿង កំណាព្យ សម្ដីអ្នកដទៃ សុន្ទរកថា ។ល ។

អ្នកបានសិក្សារួចហើយអំពីរឿងរូបភាព រឿងភ្នំប្រុសភ្នំស្រី ។ ឥឡូវនេះ ចូរអ្នកសង្ខេបរឿងនេះឡើងវិញឱ្យបានជាអត្ថបទសង្ខេបមួយមានន័យគ្រប់គ្រាន់ទៅតាមដំណើររឿងតាំងពីដើមដល់ចប់ ។

## លំហាត់

ចូរអ្នកជ្រើសរើសរឿងរូបភាពណាមួយឬរូបភាពបង្ហាញពីសកម្មភាពអ្វីមួយមកនិយាយសង្ខេបឱ្យបានត្រឹមត្រូវប្រាប់មិត្តភក្តិនៅក្នុងក្រុមរបស់អ្នក ។ នៅពេលអ្នកសង្ខេបអ្នកត្រូវយកចិត្តទុកដាក់លើ :

- **មុនពេលនិយាយ**
  - កំណត់ព្រឹត្តិការណ៍សំខាន់ៗនៃរឿង ។
  - កំណត់គោលគំនិតសកម្មភាពឱ្យបានច្បាស់លាស់ ។
  - រកគតិអប់រំឬតម្លៃអប់រំនៃរឿងឱ្យបានជាក់លាក់ ។
- **ពេលនិយាយ**
  - និយាយសង្ខេបគំនិតសំខាន់ៗ ព្រឹត្តិការណ៍ឱ្យបានគ្រប់គ្រាន់តាមដំណើររឿង ។
  - ប្រើពាក្យពេចន៍សំដីឱ្យបានច្បាស់លាស់សមរម្យនៅក្នុងការនិយាយ ចៀសវាងប្រើពាក្យលេងសើចផ្ដេសផ្ដាស ។
- **ក្រោយពេលនិយាយ**
  - ស្ដាប់មតិ ឬយោបល់អ្នកដទៃ ។
  - ចូលរួមកែលម្អ ផ្ដល់យោបល់ បង្ហាញមតិ របស់ខ្លួនដោយប្រកាន់ឥរិយាបថ និងពាក្យសម្ដីសមរម្យ ។

# រឿងរូបភាព

អ្នកបានសិក្សារួចហើយអំពីរឿងភ្នំប្រុសភ្នំស្រីជារូបភាព ។ ឥឡូវនេះ ចូរអ្នកអានរឿងខាងក្រោមរួចតាក់តែងរឿងនេះឡើងវិញជារឿងបែបរូបភាព ។

នៅពេលអ្នកតាក់តែងអ្នកត្រូវគិតថា :

- តើរឿងនេះមានព្រឹត្តិការណ៍សំខាន់ៗអ្វីខ្លះ ?
- តើមានកាលអាកាសអ្វីខ្លះ នៅក្នុងដំណើររឿង ដោយរៀបចំចែកជាប្លង់ឱ្យសមស្រប ។
- មានតួអង្គណាខ្លះ ។
- តើតួអង្គនីមួយៗមានសកម្មភាពអ្វីខ្លះ ?
- តើរឿងនេះចែកជាប៉ុន្មានប្លង់រូបភាព ?
- តើរូបភាពនីមួយៗត្រូវមានតួអង្គនិងសកម្មភាពអ្វីខ្លះ?
- តើត្រូវបង្ហាញសម្ដីដូចម្ដេចខ្លះរបស់តួអង្គនីមួយៗដើម្បីឱ្យអ្នកអានយល់ដំណើររឿង ?
- តើត្រូវរៀបរាប់ដូចម្ដេចខ្លះដើម្បីឱ្យអ្នកអានមើលយល់ពីលំដាប់លំដោយនៃដំណើររឿង ?
- គូរព្រាងរូបភាពតួអង្គនីមួយៗតាមលក្ខណៈនិងការពណ៌នាតាមប្លង់នៃដំណើររឿងឱ្យបានសបស្រម ។

## រឿងចចក

កាលពីព្រេងនាយ មានចចកត្រោសធំមួយ ដល់ខែរំហើយ វាដើររកត្រពាំងបឹងបួដែលរីងទឹកដើម្បីចាប់ត្រីស៊ីជាអាហារ ។ លុះទៅដល់ត្រពាំងមួយរីងទឹកអស់នៅតែប្រលង់ឃើញសុទ្ធតែភក់ខ្មៅលាយឡំនិងស្លឹកឈើស្អុយរលួយមាន ត្រី កំពឹស បង្កង ក្ដាមជាច្រើន វាលាន់មាត់ ៖ "ថ្ងៃនេះអញមានលាភធំណាស់ ជាលាភចម្លែកជាងសព្វថ្ងៃ" ។ ឯកំពឹសមានប្រាជ្ញា ឮដូចនោះ ក៏និយាយលួងលោមចចក ៖ "យើងទាំងអស់គ្នា សុទ្ធតែជាចំណីបងឯងហើយ ។ ប៉ុន្តែខ្លួនឯងប្រឡាក់សុទ្ធតែភក់ បើបងស៊ីទាំងភក់យ៉ាងនេះមិនឆ្ងាញ់ពិសាទេ !" ។ ចចកសួរ ៖ "ធ្វើដូចម្ដេចនឹងឆ្ងាញ់ពិសា ?" ។ កំពឹសឆ្លើយ ៖ "បងឯងត្រូវយកពួកយើងទៅលាងទឹកឱ្យជ្រះស្អាត ហើយសឹមស៊ីទើបឆ្ងាញ់ពិសា" ។ ចចកសួរទៅកំពឹសទៀត "ធ្វើដូចម្ដេចនឹងយកទៅលាងទឹកបាន បើមានគ្នាច្រើនដល់ម្លេះ ?" ។ កំពឹសឆ្លើយ ៖ "ខ្ញុំធានាគិតឱ្យបងធ្វើបានស្រួល ប៉ុន្តែត្រូវធ្វើតាមខ្ញុំ" ។ ចចកក៏យល់ព្រមធ្វើតាមកំពឹស ។ កំពឹស ៖ "ចូរបងចុះមកដេកននៀលក្នុងភក់នេះ យើងទាំងអស់គ្នានឹងខាំតោងរោមបង ហើយបងនាំយើងទៅរកស្ទឹងបឹងបួងណាមានទឹកថ្លាច្រើន បងលាងយើងឱ្យស្អាត ហើយសឹមស៊ីឱ្យឆ្ងាញ់ពិសាតាមចិត្តចុះ" ។ លុះទៅដល់បឹងធំមួយ មានទឹកថ្លាឆ្វេងត្រជាក់ស្រឹប ចចកក៏ដើរចុះទៅក្នុងទឹក អស់ត្រី កំពឹសក៏លោត

ចូលទៅក្នុងទឹកបឹង ហើយប្រាប់ចចក ៖ "បងទៅជញ្ជូនពួកខ្ញុំឱ្យអស់សិន ចាំមកស៊ីឱ្យឆ្ងាញ់ ពួកខ្ញុំរង់ចាំបងនៅទីនេះ" ។ ចចកក៏ទៅជញ្ជូនត្រី និងកំពឹសលុះត្រាតែអស់ពីត្រពាំងនោះ ។ ឯពួកត្រី កំពឹស ក្ដាម ខ្យងដឹងថាចចកជញ្ជូនមកអស់ហើយ ក៏នាំគ្នាមុជទៅក្នុងទឹកជ្រៅបាត់អស់ ។ ចចកដឹងថាកំពឹសបញ្ឆោតដូចនោះ ខឹងខ្លាំងណាស់ក៏ដើរទៅបបួលអស់សត្វតូចធំ ដំរី រមាស ខ្លា ពស់ធំ ពស់តូច ពស់ថ្លាន់ ទាំងសត្វហើរគ្មានសល់ឡើយមកបាចទឹកបឹងនោះឱ្យរីងនិងបានចាប់មច្ឆជាតិទាំងនោះស៊ីឱ្យអស់ ។ គេឱ្យពស់ថ្លាន់ធ្វើទំនប់ សត្វឯទៀតនាំគ្នាបាច ។ សត្វក្នុងទឹកបឹងដឹងដំណឹងនេះភ័យណាស់ក៏នាំគ្នាគិត ៖ "យើងធ្វើដូចម្ដេច ដើម្បីឱ្យសត្វទាំងនោះលែងបាចទឹកតទៅទៀត" ។ ត្រីក្រាញ់ក៏ឆ្លើយ ៖ "ខ្ញុំឮគេថាបងសុភាទន្សាយជាអ្នកមានប្រាជ្ញា ចេះដោះស្រាយទុក្ខមនុស្សសត្វផងទាំងឡាយ ។ ដូចនេះ ខ្ញុំទៅពឹងបងសុភាទន្សាយឱ្យមកជួយដោះស្រាយទុក្ខពួកយើង" ។ ពួកសត្វក៏យល់ព្រម ហើយត្រីក្រាញ់ក៏ប្រឹងនន្ទៀលទៅប្រឡាក់ដីស្រមក ទៅរកទន្សាយ លុះត្រូវថ្ងៃក៏ក្រៀមស្រកាក្រញ្ញង់ស្អិតជាប់នឹងស្បែក ។ ពេលយប់ សុភាទន្សាយចេញមករកស៊ីឃើញត្រីក្រាញ់កំពុងនន្ទៀលដូចនេះក៏សួរ ៖ "បងត្រីក្រាញ់ឯងទៅណា ?" ។ ត្រីក្រាញ់ឆ្លើយដោយត្រេកអរ ៖ "បងសុភាទន្សាយអាណិតខ្ញុំ ត្រីទាំងអស់នៅក្នុងបឹងគេប្រើខ្ញុំមកអញ្ជើញបងទៅ ត្បិតឮអស់ទាំងមនុស្សនិយាយថា បងជាអ្នកមានប្រាជ្ញា ចេះកាត់សេចក្ដីដោះទុក្ខអ្នកដទៃ ។ ឥឡូវនេះមានហ្វូងសត្វដំរី គោ ក្របី រមាស រមាំង ជ្រូក ពស់ធំ ពស់តូច ទាំងសត្វហើរ កុក ក្រៀល ចង្កៀលខ្យង ទុង ទោម ក្អែកទឹក ប្រវឹក ស្មោញទាំងប៉ុន្មាន បានបបួលគ្នាមកបាចទឹកបឹងឱ្យរីង និងបានចាប់អស់ត្រី អណ្ដើក កន្ធាយ ស៊ីជាចំណីអាហារអស់ពីក្នុងបឹងនេះ ។ គេឱ្យពស់ថ្លាន់ ពស់ធំ ពស់តូច ធ្វើជាទំនប់ទប់បឹងនេះឯង ។ សូមបងមេត្តាជួយអស់បងប្អូនខ្ញុំ ឱ្យរួចផុតពីភ័យនេះម្ដង និងបានល្បីកេរ្តិ៍ឈ្មោះតទៅ ។ ពួកយើងនឹងតបស្នងសងគុណ ហើយមិនភ្លេចគុណបងអស់មួយជីវិត" ។ ទន្សាយឮត្រីក្រាញ់និយាយអង្វរដូចនោះក៏ឆ្លើយ ៖ "បងទៅមុនចុះ ហើយប្រាប់បងប្អូនកុំឱ្យភិតភ័យ ចាំខ្ញុំជួយដោះស្រាយឱ្យ កុំបារម្ភ" ។ លុះព្រឹកព្រហាមឡើង ទន្សាយក៏ទៅមាត់បឹងឃើញសត្វទាំងនោះកំពុងតែបាចទឹក ក៏យកស្លឹកឈើដែលដង្កូវស៊ីធ្លុះៗមកធ្វើជាសំបុត្រហើយស្រែកហៅសត្វទាំងនោះ ឱ្យស្ដាប់ខ្លួន ៖ "នែ! បងប្អូនទាំងអស់គ្នា ព្រះឥន្ទ្រលោកនឹងមកកាច់ ជើងត្រុំ ប្រមុំជើងអក កាច់ក្បាលចចក ដកភ្លុកដំរីស" ។ ពួកសត្វឮថា សំបុត្រព្រះឥន្ទ្រដូចនោះ ភិតភ័យណាស់ផ្អើលបោលជាន់គ្នា ដំរី ក្របី រមាស រមាំង ស្ទុះបោលទៅជាន់លើពស់ថ្លាន់ដែលធ្វើជាទំនប់ដាច់ខ្លួនជាពីរបីកំណាត់ ធ្លាយទំនប់លិចទឹកស្លាប់អស់ ។

តាំងពីថ្ងៃនោះមក អស់សត្វទាំងពួងនឹកកោតខ្លាចប្រាជ្ញាទន្សាយ ហើយចាត់ទុកសុភាទន្សាយជាគ្រូបាអាចារ្យទាំងអស់គ្នា ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅប្រជុំរឿងព្រេងខ្មែរភាគ ១)*

**យើងបម្រើសេវាកម្ម :**

- អភិវឌ្ឍសៀវភៅនិងសម្ភារឧបទេស
- បោះពុម្ព
- ចែកផ្សាយដល់សាលារៀន

**WE SERVE :**

- Book and teaching-aid development
- Printing
- Distribution to schools


គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ (គ.ប.ច)

PUBLISHING AND DISTRIBUTION HOUSE ( PDH )

**បណ្ណាគារ គ.ប.ច**

**PDH BOOKSHOP**

១៤៨ មហាវិថីព្រះនរោត្តម ភ្នំពេញ ទូរស័ព្ទ: ០២៣ ៦៣ ៦៣ ០៣៣ 148, Norodom Boulevard, Phnom Penh, Tel: 023 63 63 033

មានលក់សៀវភៅសិក្សាគោលសម្រាប់សិស្សនិងសម្រាប់គ្រូ សៀវភៅហ្វឹកហាត់ សៀវភៅអំណានបន្ថែម សម្ភារឧបទេស ព្រមទាំងសម្ភារការិយាល័យគ្រប់មុខ !

Selling textbooks, teacher´s manuals, workbooks, supplementary readers, teaching-aids and stationary !

IBC INTERNATIONAL BOOK CENTER

$ 2.85


9789995001216